**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# កាលានុវត្តភាពនៃក្របខណ្ឌគតិយុត្តិក្នុង ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១ ដល់ថ្ងៃទី១៤ ខែ សីហាឆ្នាំ២០២១

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា អ៊ាក ផលច័ន្ទម៉ាលីការ៍
កញ្ញា វណ្ណដា ហង្សបញ្ចមា

សាស្ត្រាចារ្យណែនាំ
លោក **កាន់ សុទ្ធប៉ូលីន**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៨
ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **អ៊ាក ផលច័ន្ទម៉ាលីកា** និង **វណ្ណដា ហង្សបញ្ញមា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី២១ ក្រុម L4B2 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**

លោកឪពុក អ្នកម្តាយ អ្នកមានគុណ ដែលបានផ្តល់កំណើត បីបាច់ថែរក្សា ទំនុកបម្រុង ទាំងផ្នែកស្មារតី និងសម្ភារៈ រួមទាំងដំបូន្មានល្អៗ ដល់កូនគ្រប់ពេលវេលា ហើយតែងតែ លើកទឹកចិត្ត និងជាស្រ័យរាល់កំហុសខុសឆ្គងរបស់កូន។ ពិសេសជាងនេះទៅទៀតនោះ លោកបានខិតខំប្រឹងប្រែងអស់ពីក្នុងទ្រូងដើម្បីឱ្យ កូន នឹងមានអនាគតល្អ មានចំណេះចេះដឹងក្នុងសង្គម កូននឹងខិតខំប្រឹងប្រែង និងបណ្តុះបណ្តាលចំណេះវិជ្ជា ជាការតបស្នងសងគុណ។

ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស សាស្ត្រាចារ្យ និងបុគ្គលិក ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានដឹកនាំពង្រឹងវិស័យនិងពិតខំប្រឹងប្រែងអស់កម្លាំងកាយចិត្តក្នុងការបង្ហាត់បង្រៀនដល់រូបនាងខ្ញុំផ្ទាល់ និង ឯកសារពាក់ព័ន្ធនៅក្នុងបណ្ណាល័យ ដើម្បីជាជំនួយក្នុងការស្រាវជ្រាវរបស់យើងខ្ញុំ។

លោកសាស្ត្រាចារ្យ **កាន់ សុទ្ធប៉ូលីន** ជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀន និងចំណាយពេលដ៏មានតម្លៃរបស់លោកធ្វើការពន្យល់ណែនាំផ្តល់ចំណេះដឹងនិងបទពិសោធន៍ល្អៗ ក្នុងការស្រាវជ្រាវ ដើម្បីតាក់តែងសារណានេះ ហើយរូបនាងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការខិតខំប្រឹងប្រែងរបស់សាស្ត្រាចារ្យ។

ជាទីបញ្ចប់ នាងខ្ញុំសូមប្រសិទ្ធិពរជ័យសិរីមង្គលដល់លោកអ្នក ដែលមានគុណទាំងអស់ខាងលើឱ្យបានទទួលនូវពុទ្ធពរ ទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ព្រមទាំងសម្រេចនូវគោលបំណង និងទទួលបាននូវសេចក្តីចម្រើន និងជោគជ័យគ្រប់ភារកិច្ចទាំងអស់។

# អារម្ភកថា

ជាបឋម យើងខ្ញុំសូមគោរពដល់សាស្ត្រាចារ្យ និង មិត្តអ្នកអានទាំងអស់ជាទីគោរព និង ជាទីរាប់អាន។ យើងខ្ញុំជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រឆ្នាំទី៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលមានសេចក្ដីសោមនស្សរីករាយជាក្រៃលែង ក្នុងការមានឱកាសទទួលបានការតាក់តែងនូវសារណាក្រោមប្រធានបទ " **កាលានុវត្តភាពនៃក្របខណ្ឌគតិយុត្តិក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** " ឱ្យលេចជារូបរាងឡើង ដើម្បីបញ្ចប់អំពីការស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។ ជាពិសេសដើម្បីទុកជាឯកសារ ជំនួយផ្នែកច្បាប់ និងផ្នែកស្មារតី សម្រាប់និស្សិតច្បាប់ទាំងឡាយ ដែលមានគោលបំណង សិក្សាស្រាវជ្រាវ និងស្វែងយល់បន្ថែម ចង់ដឹងអំពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ដោយយើងខ្ញុំយល់ថាប្រធានបទខាងលើនេះ គឺពិតជាមានសារៈសំខាន់ណាស់ ឬអាចហៅបានថាជាប្រធានបទក្ដៅ សម្រាប់សង្គមបច្ចុប្បន្ន។ ពិសេសជាងនេះទៅទៀតនោះ គឺក្នុងបរិបទនៃការរីករាលដាលនៃជំងឺកូវីដ១៩។ ជំងឺកូវីដ១៩ ហាក់បីដូចជាកតាលីករជំរុញកំណើននៃវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកទ្វេមួយកំរិតទៀត និងជួយសម្រួលដល់ការរស់នៅប្រជាជនឱ្យមានភាពងាយស្រួលជាងមុន រួមទាំងកាត់បន្ថយហានិភ័យ និងសម្ពាធសេដ្ឋកិច្ចក្នុង និងក្រៅប្រទេសផងដែរ ។ ថ្វីត្បិតតែមានការអភិវឌ្ឍខ្លាំង ហើយប្រទេសជាច្រើនលើពិភពលោកបានកំពុងតែប្រើប្រាស់ និងទាញយកផលប្រយោជន៍ ពីបច្ចេកវិទ្យាដ៏ទំនើបនេះ ប៉ុន្តែសម្រាប់ប្រទេសកម្ពុជាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក គឺជាគំនិតថ្មីមួយដែលទើបតែមានសន្ទុះកើនឡើងខ្លាំងនៅប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលជាហេតុនាំឱ្យប្រទេសកម្ពុជា មិនទាន់មានច្បាប់គ្រប់គ្រងសកម្មភាពនេះ ពេញលេញបរិបូណ៌នោះទេ ដូច្នេះយើងខ្ញុំសង្ឃឹមថាការសិក្សាស្រាវជ្រាវនេះ អាចចូលរួមចំណែករំលែកចំណេះដឹង និងការផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយ អំពីការយល់ដឹងបន្ថែមទៅលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិវត្រូនិច។

ក្នុងការស្រាវជ្រាវនេះ យើងខ្ញុំមានការព្យាយាមខិតខំប្រឹងប្រែងយ៉ាងយកចិត្តទុកដាក់បំផុតក្នុងការប្រមូលចំណេះដឹង ដែលបានសិក្សាអស់រយៈពេល៤ឆ្នាំ កន្លងមកនេះ ហើយរួមផ្សំជាមួយការស្រាវជ្រាវឯកសារជាច្រើន ពាក់ព័ន្ធវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មេរៀន បទពិសោធន៍ និងការអនុវត្តនៅក្នុងវិស័យនេះ ទាំងក្នុងនិងក្រៅប្រទេស ដើម្បីធ្វើជាស្ពានឱ្យសារណារបស់យើងខ្ញុំទទួលបានសមិទ្ធិផលយ៉ាងល្អប្រសើរ។

ដោយសារណានេះ គឺជាស្នាដៃដំបូង យើងខ្ញុំជឿជាក់ថានឹងមានការខ្វះខាតដោយប្រការណាមួយ ដូចជា ការបកស្រាយ ការប្រើប្រាស់ពាក្យពេចន៍ ឃ្លាឃ្លោង និងអក្ខរាវិរុទ្ធជាដើម អាស្រ័យហេតុនេះ យើងខ្ញុំ

សូមអភ័យទោសទុកជាមុនរាល់កំហុសឆ្គងទាំងឡាយ ដែលកើតមានឡើងឥតព្រាងទុក។ ជាចុងក្រោយ យើងខ្ញុំ មានសេចក្តីសោមនស្សរីករាយជាទីបំផុតក្នុងការទទួលរងចាំនូវរាល់មតិរិះគុណកំហុសឆ្គង ដើម្បីស្ថាបនាពីសំណាក់សាស្ត្រាចារ្យ និស្សិត បញ្ញាវ័ន្ត និងមិត្តអ្នកអានទាំងអស់ក្នុងគោលបំណងស្ថាបនា និងកែរលំអរឱ្យមានភាពល្អប្រសើរជាងនេះថែមទៀត ។

ថ្ងៃសុក្រ ៤រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១
អ៊ាក ផលច័ន្ទម៉ាលីការ៍ វណ្ណដា ហង្សបញ្ចមា

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**
**សញ្ញាណទូទៅនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

ផ្នែកទី១៖ សញ្ញាណនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ........ ៤

កថាខណ្ឌទី១៖ ប្រវត្តិនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ........ ៤

ក. ការចាប់កំណើតនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ........ ៤

ខ. ការវិវឌ្ឍមកដល់នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា ........ ៥

កថាខណ្ឌទី២៖ និយមន័យនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ........ ៧

ក. ការបកស្រាយតាមនិយមន័យទូទៅ និង ការបកស្រាយតាមអង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍ (UNCTAD) ........ ៧

ខ. គោលការណ៍នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ........ ៨

កថាខណ្ឌទី៣៖ ទម្រង់នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ........ ១១

ក. ទម្រង់ពាណិជ្ជកម្មរវាងឯកជន និង ឯកជន ........ ១១

ខ. ទម្រង់ពាណិជ្ជកម្មរវាងរដ្ឋ និងឯកជន ........ ១២

ផ្នែកទី២៖ លក្ខណៈនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ........ ១៣

កថាខណ្ឌទី១៖ ទំនាក់ទំនងប្រតិបត្តិការនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ........ ១៣

ក. ទំនាក់ទំនងពេលវេលា និងទីកន្លែងបញ្ជូនចេញនៃសារទិន្នន័យ ........ ១៣

ខ. ទំនាក់ទំនងពេលវេលា និងទីកន្លែងទទួលនៃសារអេឡិចត្រូនិក ........ ១៤

កថាខណ្ឌទី២៖ ការទូរទាត់ និងការផ្ទេរប្រាក់ក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ........ ១៥

ក. ការចូលរួមរបស់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ........ ១៦

ខ. ប្រភេទប្រតិបត្តិការទូទាត់ប្រាក់ ........ ១៧

កថាខណ្ឌទី៣៖ ការផុតរលត់នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ........ ១៩

ក. ការទូទាត់ប្រាក់ ........ ១៩

ខ. ការបញ្ជូនចេញ និងការបានទទួល ........ ១៩

## ជំពូកទី២

## ក្របខណ្ឌគតិយុត្តិនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា


ផ្នែកទី១៖ ដំណើការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ....................២១

កថាខណ្ឌទី១៖ លក្ខខណ្ឌ និង ការផ្ដល់លិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណ.................... ២២

ក. លក្ខខណ្ឌក្នុងការបង្កើតពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក.................... ២២

ខ. ការផ្ដល់លិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណ ....................២៥

កថាខណ្ឌទី២៖ កិច្ចសន្យាទិញលក់តាមប្រព័ន្ធអេឡិចត្រូនិក ....................២៦

ក. ការអនុវត្តកិច្ចសន្យាអេឡិចត្រូនិក....................២៦

ខ. ការបង្ហាញឆន្ទៈរបស់ភាគី.................... ២៧

កថាខណ្ឌទី៣៖ ការបង្កើតពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក៖....................២៨

ក. ការបង្កើតកិច្ចសន្យានាំឱ្យមានសុពលភាព....................២៨

ខ. កំហុសឆ្គងនៃការបញ្ចូលព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិក ....................៣០

កថាខណ្ឌទី៤៖ ហត្ថលេខាអេឡិចត្រូនិក....................៣១

ក. ប្រតិបត្តិការហត្ថលេខាអេឡិចត្រូនិក....................៣១

ខ. អានុភាពគតិយុត្តិនៃហត្ថលេខាអេឡិចត្រូនិក....................៣៤

ផ្នែកទី២៖ ការអនុវត្តនីតិវិធីក្នុងការប្រមូលពន្ធលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក....................៣៥

កថាខណ្ឌទី១៖ កាតព្វកិច្ចសារពើពន្ធក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក....................៣៦

កថាខណ្ឌទី២៖ ការអនុវត្តកាតព្វកិច្ចសារពើពន្ធនៅកម្ពុជា .................... ៣៧

ផ្នែកទី៣៖ កិច្ចការពារអ្នកប្រើប្រាស់នៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក....................៣៩

កថាខណ្ឌទី១៖ ច្បាប់ពាក់ព័ន្ធនឹងមាតិកាអ៊ីនធើណេតនៅកម្ពុជា.................... ៤០

កថាខណ្ឌទី២៖ បទល្មើសក្លែងបន្លំនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក....................៤២

កថាខណ្ឌទី៣៖ ការការពារទិន្នន័យឯកជនតាមច្បាប់ព្រះរាជាណាចក្រកម្ពុជា.................... ៤៥

ក. គោលការណ៍រដ្ឋធម្មនុញ្ញ .................... ៤៦

ខ. ច្បាប់ស្ដីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក.................... ៤៦

៣.៣ គោលការណ៍ក្រមរដ្ឋប្បវេណី.....៤៨
កថាខណ្ឌទី៤៖ កិច្ចអភិវឌ្ឍក្របខណ្ឌកិច្ចការពារអ្នកប្រើប្រាស់នៅកម្ពុជា.....៤៩
ក. ក្របខ័ណ្ឌគតិយុត្តិ និងស្ថាប័នសម្របសម្រួល.....៥០
ខ. ប្រព័ន្ធសន្តិសុខទូរគមនាគមន៍ បច្ចេកវិទ្យា និងព័ត៌មានវិទ្យា.....៥១

## ជំពូកទី៣
## ឧបសគ្គនៃការរីកចម្រើនវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ផ្នែកទី១៖ បញ្ហាប្រឈមនៃវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា.....៥៣
កថាខណ្ឌទី១៖ ចរាចរណ៍ប្រព័ន្ធអ៊ីនធើណេត និង សេដ្ឋកិច្ចអាជីវកម្មនៅកម្ពុជា.....៥៤
ក. សេដ្ឋកិច្ចអាជីវកម្មនៅកម្ពុជា.....៥៤
ខ. ហេដ្ឋារចនាសម្ព័ន្ធអ៊ីនធើណេត.....៥៥
គ. សន្តិសុខចរាចរណ៍ប្រព័ន្ធអ៊ីនធើណេតតែមួយ.....៥៧
កថាខណ្ឌទី២៖ ការប្រើប្រាស់សេវាធនាគារនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា.....៥៩
ក. ការវាយតម្លៃលើប្រតិបត្តិការធនាគារទូទៅ.....៥៩
ខ. ការលើកកម្ពស់បច្ចេកវិទ្យាហិរញ្ញវត្ថុ (Fintech) នៅកម្ពុជា.....៦៣
កថាខណ្ឌទី៣៖ ហេដ្ឋារចនាសម្ព័ន្ធភស្តុភារពាណិជ្ជកម្មក្នុងស្រុក.....៦៤
ក. ការរៀបចំរដ្ឋបាលភូមិសាស្ត្រ.....៦៥
ខ. ការផ្តួចផ្តើមចេញនូវរចនាសម្ព័ន្ធភូមិសាស្ត្រថ្មី.....៦៦
កថាខណ្ឌទី៤៖ ការរួមបញ្ចូលនូវប្រព័ន្ធឌីជីថលអេកូឡូជី.....៦៩
ក. និយមន័យប្រព័ន្ធឌីជីថលអេកូឡូជី.....៦៩
ខ. កិច្ចសហប្រតិបត្តិការនៅក្នុងតំបន់អាស៊ាន.....៧០
ផ្នែកទី២៖ ផលប៉ះពាល់នៃជំងឺកូវីត-១៩ លើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក.....៧២
កថាខណ្ឌទី១៖ ផលប៉ះពាល់វិជ្ជមាននៃជំងឺកូវីត-១៩ លើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក.....៧៣
ក. ផលប៉ះពាល់វិជ្ជមាន ចំពោះរដ្ឋាភិបាល.....៧៣
ខ. ផលប៉ះពាល់វិជ្ជមាន ចំពោះប្រជាពលរដ្ឋ.....៧៤
កថាខណ្ឌទី២៖ ផលប៉ះពាល់អវិជ្ជមាននៃជំងឺកូវីត-១៩ លើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក.....៧៥
ក. ផលប៉ះពាល់អវិជ្ជមាន ចំពោះរដ្ឋាភិបាល.....៧៦

ខ. ផលប៉ះពាល់អវិជ្ជមាន ចំពោះប្រជាពលរដ្ឋ ........................................................................ ៧៧
ផ្នែកទី៣៖ ឥទ្ធិពលនៃវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ........................................................ ៧៩
កថាខណ្ឌទី១៖ សក្តានុពល និង ផលប៉ះពាល់នៃពាណិជ្ជកម្មអេឡិចត្រូនិក ........................................ ៧៩
ក. សក្តានុពលនៃពាណិជ្ជកម្មអេឡិចត្រូនិកទៅលើសេដ្ឋកិច្ច និងសង្គម........................................ ៧៩
ខ. ផលប៉ះពាល់នៃពាណិជ្ជកម្មអេឡិចត្រូនិកទៅលើសេដ្ឋកិច្ច និងសង្គម ........................................ ៨១
កថាខណ្ឌទី២៖ ការគ្រប់គ្រងហានិភ័យ............................................................................................ ៨៣
ក. ហានិភ័យក្នុងប្រទេស............................................................................................................ ៨៣
ខ. ហានិភ័យក្រៅប្រទេស ........................................................................................................... ៨៥
**សេចក្តីសន្និដ្ឋាន**............................................................................................................................ ៨៧
**អានុសាសន៍**..................................................................................................................................... ៩០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជាបានលេចរូបរាងឡើង ស្ថិតក្រោមជម្រកដ៏ត្រចះត្រចង់នៃរបបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ ដែលប្រកាន់យកប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី។ ជាក់ស្តែងសេដ្ឋកិច្ចកម្ពុជាមានសន្ទុះយ៉ាងកត់សម្គាល់ចាត់តាំងពីឆ្នាំ២០១១ ប្រភពនៃកំនើនសេដ្ឋកិច្ចនៅកម្ពុជាពឹងផ្អែកទៅលើកសិកម្ម ឧស្សាហកម្ម និង ពាណិជ្ជកម្មដែលជាផ្នែកចម្បងដែលជម្រុញឱ្យមានចរន្តខ្វាត់ខ្វែងក្នុងប្រទេស។ ជាពិសេសផងនោះអ្វីដែលយើងសង្កេតថាវិស័យពាណិជ្ជកម្មគឺជាចរន្តឈាមនៃសេដ្ឋកិច្ចជាតិ ដែលធ្វើឱ្យរបត់នៃដំណើរការផលិតកម្ម និង ប្រើប្រាស់មានសភាពថេរល្អ និង គ្មានអតិផរណាជាប្រចាំ។ ការរីកដុះដាលទៅមុខជាលំដាប់នេះ បានមកការការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការដាក់ចេញនូវយន្តការថ្មីៗ និងការកែប្រែគោលនយោបាយចាស់ៗឱ្យមានប្រសិទ្ធភាពឆាប់រហ័ស[1] ដូចជាការពង្រឹងប្រព័ន្ធពាណិជ្ជកម្មបើកចំហរ តាមរូបភាពការធ្វើសេរីភាវូបនីយកម្ម និងការបង្កើតឡើងនូវគោលនយោបាយពាណិជ្ជកម្ម ក្នុងក្របខ័ណ្ឌនៃថ្នាលដុះដាលក្នុងថ្នាក់តំបន់ និង ពិភពលោក ដោយការផ្តោតយកចិត្តទុកដាក់លើទិដ្ឋភាពនៃការពង្រឹងវិស័យច្បាប់ ក្រោមការផ្តល់នូវសច្ចាប័នចំពោះអនុសញ្ញាអន្តរជាតិធំៗនៃអង្គការពាណិជ្ជកម្មពិភពលោកហៅកាត់ថា WTO ដូចជា កិច្ចព្រមព្រៀងពាណិជ្ជកម្មនិង វិនិយោគ ការអនុវត្តវិធានការសម្រួលពាណិជ្ជកម្ម សេចក្តីសម្រេច អនុស្សារណៈ និង ការអនុម័ត ការព្រៀង និងការកែទម្រង់ ច្បាប់ និង លិខិតបទដ្ឋានគតិយុត្តិនានាដើម្បីឱ្យស្របតាមសមាហរណកម្មណាណិជ្ជកម្មអន្តរជាតិ។[2] ក្រសួងពាណិជ្ជកម្ម គឺជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រង និង ដឹកនាំវិស័យពាណិជ្ជកម្មនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ កម្ពុជាមានក្រសួងពាណិជ្ជកម្មនេះជាស្ថាប័នគ្រប់គ្រងការធ្វើពាណិជ្ជកម្ម ដែលបានលេចរូបរាងឡើងស្ទើរគ្រប់សម័យកាលរបស់កម្ពុជា ដែលមាននាយកដ្ឋាននីតិកម្មតែងតែស្វះស្វែងបង្កើតនូវច្បាប់សម្រាប់គ្រប់គ្រងលើការវិវត្តវិស័យនេះតាមសម័យកាល និងភាពផ្លាស់ប្តូរនៃបរិបទពាណិជ្ជកម្មក្នុងតំបន់។

ពាណិជ្ជកម្មគឺជាកត្តាចម្បងសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិឱ្យបានរីកចម្រើនទៅមុខ ស្របទៅនឹងសម័យកាលជឿនលឿននៃបច្ចេកវិទ្យាទំនើបដែលផ្តល់ឱ្យការរស់នៅរបស់មនុស្សជាតិមានភាពងាយស្រួល។ ការជះឥទ្ធិពលគ្របដណ្តប់សេដ្ឋកិច្ចក្នុងតំបន់យ៉ាងសកម្មនៃវិស័យពាណិជ្ជកម្មនាពេលបច្ចុប្បន្ន

[1] រាជរដ្ឋាភិបាលកម្ពុជាក្រសួងផែនការ.(២០១៨, ខែឧសភា). សេចក្តីណែនាំសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣(ផ.យ.អ.ជ. ២០១៩-២០២៣)។

[2] សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ក្រសួងពាណិជ្ជកម្ម និង MPDF. ប្រទេសកម្ពុជា និង អង្គការពាណិយជ្ជកម្មពិភពលោក: *សៀវភៅមគ្គុទេសក៏សំរាប់អាជីវកម្ម។*

នេះគឺជាទស្សនៈវិស័យដែលបង្ហាញបានយ៉ាងពិតប្រាកដថា ការលូតលាស់នៃវិស័យនេះគឺត្រូវមានលក្ខណៈសមស្របទៅនឹងតម្រូវការ និង ទំនើបកម្មនៃការរស់នៅរបស់មនុស្សជាតិទូទាំងពិភពលោក។ តាមរយៈការអភិវឌ្ឍន៍ឥតឈប់ឈរនៃបច្ចេកវិទ្យាក្នុងទស្សវត្សចុងក្រោយនេះ បានផ្តល់នូវការផ្លាស់ប្រែយ៉ាងពេញចិត្តទៅកាន់បណ្តារប្រទេសនានានៅលើពិភពលោក។ ឥទ្ធិពលនៃសកលភាវូបនីយកម្ម និងវឌ្ឍនភាពនៃបច្ចេកវិទ្យាបានធ្វើអោយផលិតកម្មទំនិញ និងសេវាកាន់តែមានសន្ទុះ និងផ្តល់នូវភាពពេញចិត្តកាន់តែខ្លាំងដល់អតិថិជន។ ក្នុងនោះដែរ បណ្តូរកម្មទំនិញឆ្លងប្រទេសកាន់តែមានភាពងាយស្រួលឡើងពីមួយថ្ងៃទៅមួយថ្ងៃ។ ដោយសារ ការរីកចំរើននៃបច្ចេកវិទ្យា មធ្យោបាយដោះដូរទំនិញជាច្រើនត្រូវបានប្រើប្រាស់តាមរយៈប្រព័ន្ធអេឡិចត្រូនិក ដែលជាមធ្យោបាយថ្មីមួយដែលទាក់ទាញចំណាប់ អារម្មណ៏របស់អតិថិជននាពេលបច្ចុប្បន្ន ។ ដូចគ្នាផងដែរបទពិសោធន៏ដ៏ថ្មីស្រឡាងនៃប្រតិបត្តិការពាណិជ្ជកម្មនេះគឺលេចចេញនូវរូបរាងដ៏ទាក់ទាញដែលធ្វើឱ្យប្រជាជនកម្ពុជានិយមនិងឆ្ពោះទៅកាន់វិថីថ្មីនៃការរស់នៅរបស់ពួកគេនោះគឺ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ជាក់ស្តែងយើងអាចឃើញបានតាមរយៈបណ្តារប្រទេសអភិវឌ្ឍន៏ធំៗនៅក្នុងសាកលលោក ពាណិជ្ជកម្មតាមអេឡិចត្រូនិកជាសកម្មភាពប្រចាំថ្ងៃសម្រាប់ការទិញលក់ផលិតផលនានា ដូចជាប្រតិបត្តិការទិញលក់ទំនិញនៅក្នុងវេបសាយ AMAZON ដែលបង្កើតឡើងនៅសហរដ្ឋអាមេរិច ALIBABA ដែលបង្កើតឡើងនៅប្រទេសចិន។

ជាមួយនឹងការរីកចម្រើននៃបច្ចេកវិទ្យាក្នុងតំបន់ និងសាកលលោក កម្ពុជាក៏បានបង្កើតជាសកម្មភាពធុរកិច្ចថ្មីៗជាច្រើនតាមប្រព័ន្ធអេឡិចត្រូនិក។ នៅឆ្នាំ២០១៧ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកសរុបនៅកម្ពុជាដោយប្រើប្រាស់មធ្យោបាយទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក ត្រូវប៉ាន់ស្មានមានទំហំប្រមាណ ១១២ លានដុល្លាអាមេរិក ដែលស្មើនឹង០,៥១% នៃផ.ស.ស។ ក្នុងនោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងស្រុកមានទំហំប្រមាណ ៦,៤ លានដុល្លាអាមេរិក ខណៈដែលទំហំពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្លងកាត់ព្រំដែនមានទំហំប្រមាណ ១០៥ លានដុល្លាអាមេរិក ដែលមានកំណើនក្នុងរង្វង់៣០%ក្នុងរយៈពេលបីឆ្នាំកន្លងមក។ ដោយឡែកការអភិវឌ្ឍន៏នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះតម្រូវឱ្យមានដំណើរការត្រឹមត្រូវដោយមាននូវច្បាប់សម្រាប់ធ្វើការគ្រប់គ្រងនូវរបបគតិយុត្តិថ្មីក្រោមបដិវត្តន៏បច្ចេកវិទ្យានៃទស្សវត្សថ្មីនេះ ព្រមទាំងតម្រូវការយ៉ាងចាមបាច់ល្អិតល្អន់សម្រាប់មូលដ្ឋានបច្ចេកវិទ្យាមួយចំនួនដែលមានតួនាទីយ៉ាងមហិមាក្នុងការគ្រប់គ្រងវិស័យនេះ។ ក្នុងដំណើរការវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនាពេលបច្ចុប្បន្ននៅកម្ពុជា យើងសង្កេតឃើញបាននឹងកំពុងតែដើរទៅមុខឱ្យតាមទាន់របបគតិយុត្តិមួយដែលមានភាពពេញលេញសម្រាប់វិសោធនកម្មនៃបរិបទថពាណិជ្ជកម្មថ្មីនេះ។ យ៉ាងណា

មិញចំនុចជាច្រើនត្រូវលើកយកមកធ្វើការសិក្សា និង ពិភាក្សាទៅលើពាណិជ្ជកម្មប្រភេទនេះឱ្យមានកាលានុវត្តភាពនាពេលបច្ចុប្បន្ន និង អនាគត។

ដោយផ្អែកលើមូលដ្ឋានច្បាប់ជាតិ និង អន្តរជាតិ រួមទាំងការអនុវត្តន៍ជាក់ស្តែងនៅកម្ពុជាកន្លងមក មានចំណោទបញ្ហាចំនួនបីដែលគួរគប្បីលើកឡើងមកសិក្សាឱ្យមានប្រសិទ្ធភាពជុំវិញប្រធានបទ “**សាកលភាវូបនីយកម្មនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅព្រះរាជាណាចក្រកម្ពុជា**” រួមមានដូចខាងក្រោម៖

១. តើសារធាតុនៃពាណិជ្ជកម្មតាមអេឡិចត្រូនិកមានលក្ខណៈដូចម្តេច?

២. តើរបបគតិយុត្តិនៅកម្ពុជាទាក់ទងនឹងវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅ កម្ពុជាមានភាពពេញលេញនិងសមស្របទៅនឹងដំណើរការល្អប្រសើរនៃវិស័យនេះហើយ ឬនៅ?

៣. តើអ្វីជាកត្តាដែលចោទជាបញ្ហាប្រឈមដែលផ្តល់ជាឧសគ្គរាំងស្ទះការអភិវឌ្ឍពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា?

ដោយហេតុតែសមាជិកភាពនៅក្នុង WTO និង ការធ្វើកំណែទម្រង់រដ្ឋាភិបាល មិនទាន់គ្រប់គ្រាន់ទេសម្រាប់ការទទួលផលប្រយោជន៍ពីណាណិជ្ជកម្ម។ ប្រទេសកម្ពុជានឹងទទួលបានផលប្រយោជន៍ច្រើនពីការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម ប្រសិនបើក្រុមហ៊ុនអាជីវកម្ម និង ប្រជាជនទាំងឡាយយល់ដឹងពីវិធាន និងបទប្បញ្ញត្តិនៃទិដ្ឋភាពពាណិជ្ជកម្មថ្មី ដើម្បីអនុវត្ត និង សិក្សាឱ្យបានស៊ីជម្រៅជាមួយនឹងបរិបទពាណិជ្ជកម្មក្នុងទស្សវត្សថ្មីនេះ៕ ដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហាដែលបានលើកឡើងខាងលើ និង ផ្តល់ជាការពិភាក្សាឱ្យបានក្បោះក្បាយជុំវិញប្រធានបទនេះ យើងខ្ញុំសូមធ្វើការសិក្សាដោយបែងចែកចេញជាបីជំពូកដូចខាងក្រោម៖

- ជំពូកទី ១ សញ្ញាណទូទៅនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- ជំពូកទី ២ របបគតិយុត្តិនៃពាណិជ្ជកម្មតាមប្រព័ន្ធិ អេឡិចត្រូនិកនៅកម្ពុជា
- ជំពូកទី ៣ បញ្ហាប្រឈម និង ឧបសគ្គរាំងដំណើរការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា

# ជំពូកទី១

# សញ្ញាណទូទៅនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

# ជំពូកទី១
# សញ្ញាណទូទៅនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

នៅក្នុងជំពូកដំបូង ក្នុងការសិក្សាស្រាវជ្រាវដែលចងក្រងទៅជាសារណានេះ ដើម្បីបញ្ចប់ការសិក្សានេះ យើងនឹងសិក្សា ទៅលើដំណាក់កាលដំបូងនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយស្វែងយល់អំពី សញ្ញាណ ដំណើរការ រួមទាំងគោលការណ៍ លក្ខខណ្ឌសំខាន់ៗ និង តួនាទីរបស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិច ត្រូនិកទៅក្នុងសង្គមសព្វថ្ងៃ ទាំងអស់នេះជាគ្រឹះ ដើម្បីងាយស្រួលក្នុងការសិក្សាស្វែងយល់ទៅឡើងមួយកម្រិត ទៀត។ ដូចនេះក្នុងជំពូកទី ១ នេះយើងនឹងសិក្សាទៅលើ ផ្នែកសំខាន់ៗ ដោយផ្នែកទី១ យើងសិក្សាទៅលើ សញ្ញាណទូទៅនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក រីឯផ្នែកទី២ គឺសិក្សាទៅលើសមភាពនៃពាណិជ្ជកម្មតាម ប្រព័ន្ធអេឡិចត្រនិច ។

## ផ្នែកទី១៖ សញ្ញាណនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

នៅក្នុងជំពូកទី១ ផ្នែកទី១ នេះផងដែរ គឺកថាខណ្ឌទី១ យើងសិក្សាទៅលើ ប្រវត្តិនៃពាណិជ្ជកម្មតាម ប្រព័ន្ធអេឡិចត្រូនិក ដែលពន្យល់អំពីការកកើតឡើង រីឯកថាខណ្ឌទី២ គឺ និយមន័យនៃពាណិជ្ជកម្មតាមប្រព័ន្ធ អេឡិចត្រូនិក ដែលនាំឲយល់កាន់តែច្បាស់អ្វីទៅជា និយមន័យនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចំណែក ឯកថាខណ្ឌទី៣ ជាទម្រង់នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលបង្ហាញអំពីទម្រង់បែបបទនៃពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក និងកថាខណ្ឌទី៤ គឺគោលការណ៍នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

### កថាខណ្ឌទី១៖ ប្រវត្តិនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

#### ក. ការចាប់កំណើតនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ទម្រង់នៃការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនមែនទើបតែចាប់កំណើតកើតមានឡើងនៅ ពេលដែលមានលេចឡើងនោះឡើងទេ ក៏ប៉ុន្តែកើតមានឡើងតាំងពី ក្នុងសម័យទសវត្សរ៍ទី ៧០ មកម្ល៉េះ គេ ឃើញមាននូវការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកចាប់ផ្តើមកើតមានឡើង ព្រោះថាការកើតមានឡើងនៅ ក្នុងសម័យនោះបដិវត្តន៍ឧស្សាហកម្មដំណាក់កាលទី ៣ ដែលជាសម័យបដិវត្តន៍ដែលមានការរីកចម្រើននៅ ដំណាក់កាលដំបូងនៅពេលនោះគេឃើញមានការប្រើប្រាស់នៅប្រព័ន្ធបច្ចេកវិទ្យាដូចជា Electronic Data Internet និង Electronic Funds Transfer និងមានការអនុញ្ញាតឲ្យមានការធ្វើជំនួញដោយការផ្ញើសារឯកសារ ដែលទាក់ទងទៅនឹងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដូចជាការបញ្ជាទិញតាមអេឡិចត្រូនិក និងការ ទូទាត់អេឡិចត្រូនិក ដូចជាការទូទាត់វិក្កយបត្រជាដើម។

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងទសវត្សរ៍ទី ៨០ វិញម្តងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលវិវត្តន៍ខ្លួនឡើងបន្ថែមទៀត ដោយមានការរីកចម្រើនឡើងនូវប្រព័ន្ធបច្ចេកវិទ្យា ដែលធ្វើឲ្យការធ្វើពាណិជ្ជកម្មក្រោមទម្រង់អេឡិចត្រូនិកនេះកាន់តែរីកចម្រើនឡើងដូចជា តាមរយៈការរីកចម្រើនឡើងនិងការទទួលស្គាល់រាជការនិងការទទួលទូទាត់ប្រាក់ការបើកប្រាក់តាមរយៈម៉ាស៊ីនអេធីអឹម ជាដើម។

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មកដល់ទសវត្សរ៍ទី៩០ វិញម្តងពេលគឺនៅចុងសតវត្សទី ២០ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឈានដល់ការរីកចម្រើនមួយកម្រិតទៀតនោះគឺនៅក្នុងទសវត្សរ៍ទី៩០ នេះ ពាណិជ្ជករនិងអ្នកប្រើប្រាស់ ដើម្បីប្រើប្រាស់នៅប្រព័ន្ធអ៊ីនធើណេតហើយរួមបញ្ចូលគ្នាធ្វើសហប្រតិបត្តិការដោយចាប់ផ្តើមប្រើប្រាស់អ៊ីនធើណេតនៅពេលនោះ ក៏មានការចាប់ផ្តើមកម្មវិធីឬការអនុវត្តក្រោមគំនិត ប្រកបដោយភាពច្នៃប្រឌិតចាប់ផ្តើមមានលក់តាមរយៈប្រព័ន្ធអេឡិចត្រូនិកដោយផ្ទាល់តែម្តងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងដើមសតវត្សទី ២១។

## ខ. ការវិវឌ្ឍមកដល់នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា

នៅដើមឆ្នាំ ២០០០ ការធ្វើជំនួញក្នុងក្រុមហ៊ុននៅសហភាពអឺរ៉ុបនៅសហរដ្ឋអាមេរិកបានចាប់ផ្តើមផ្គត់ផ្គង់នូវសេវារបស់ខ្លួនតាមរយៈបណ្តាញទូទៅក្នុងពិភពលោកដែលគេហៅថា World Wide Web ហើយចាប់ពីពេលនោះហើយបានជាមនុស្សចាប់ផ្តើមមូលមាត់គ្នា សហការគ្នាក្នុងការប្រើប្រាស់នូវពាក្យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឬអ៊ីខមមើសដែលកាន់តែពេញនិយមពេលដែលកកើតឡើងនូវបដិវត្តន៍ឧស្សាហកម្មជំណាក់កាលទី ៤ ដែលយើងនឹងសិក្សានៅផ្នែកខាងក្រោមបន្ទាប់ដែររីកចម្រើននៃបដិវត្តន៍ឧស្សាហកម្មដែលបានធ្វើតាមពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកាន់តែទូលំទូលាយទទួលបានការចាប់អារម្មណ៍កាន់តែខ្លាំងឡើងសម្រាប់មជ្ឈដ្ឋានទូទៅជាពិសេសពីសំណាក់ពាណិជ្ជករដែលធ្វើជំនួញឬពាណិជ្ជកម្មជាដើម។

នៅថ្ងៃទី ១៨ ដល់ថ្ងៃទី ២៩ កញ្ញាឆ្នាំ ២០០០ ក្រុងការងារនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករបស់គណៈកម្មាធិការច្បាប់ពាណិជ្ជកម្មអន្តរជាតិរបស់អង្គការសហប្រជាជាតិ បានឯកភាពលើច្បាប់គំរូពីហត្ថលេខាតាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងកិច្ចប្រជុំលើកទី ៣៧ របស់ខ្លួននៅក្នុងទីក្រុងសេណែវ។ ច្បាប់គំនូរស្តីពីហត្ថលេខាតាមប្រព័ន្ធអេឡិចត្រូនិកចូលជាធរមាននៅក្នុងឆ្នាំ ២០០១ ។ បន្ថែមពីនេះនៅថ្ងៃទី ២៣ ខែវិច្ឆិកាឆ្នាំ ២០០៦ សន្និបាតរបស់អង្គការសហប្រជាជាតិបានអនុម័តនូវសន្ធិសញ្ញាស្តីពីការប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកនៅក្នុងកិច្ចសន្យាអន្តរជាតិ ផ្សំឡើងដោយគណៈកម្មាធិការច្បាប់ពាណិជ្ជកម្មអន្តរជាតិរបស់អង្គការសហប្រជាជាតិ ក្នុងគោលបំណង ជួយសម្រួលដល់ការប្រើប្រាស់ ទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងពាណិជ្ជកម្មអន្តរជាតិ។

ទន្ទឹមនឹងនេះដែលច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៨ ខែតុលាឆ្នាំ ២០១៩ មានសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១៨ ខែតុលាឆ្នាំ ២០១៩ ។ គោលបំណងនៃច្បាប់នេះ គឺគ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងព្រះរាជាណាចក្រកម្ពុជាជាមួយនិងអន្តរជាតិ ហើយបង្កើតភាពប្រាកដប្រជាផ្នែកគតិយុត្តិ ក្នុងប្រតិបត្តិការការពារពាណិជ្ជកម្ម និងរដ្ឋប្បវេណីតាមប្រព័ន្ធអេឡិចត្រូនិក រួមទាំងផ្តល់ទំនុកចិត្តដល់សាធារណជនក្នុងការប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកផងដែរ។

ការចង់សិក្សា ទៅលើការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឬ E-Commerce ពិតជាមិនអាចកាត់ផ្តាច់បានឡើយ ពីការសិក្សាពីលើកឡើងអំពីបដិវត្តន៍ឧស្សាហកម្មទី ៤ ដែលជាសញ្ញាណកាន់តែរីកចម្រើនមួយនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចមួយតាមបែបសេដ្ឋកិច្ចឌីជីថល ការដែលរីកសាយភាយនៃបដិវត្តន៍ឧស្សាហកម្មទី ៤ នេះវាមិនមែនជារឿងមួយដែលថ្មីស្រឡាងនោះទេ។ បដិវត្តន៍ឧស្សាហកម្មលើកទី ៤ នេះបាននិងកំពុងតែអភិវឌ្ឍខ្លួនឡើងតាំងពីដើមសតវត្សទី ២១ មកម្ល៉េះហើយដំណើរការនៃការអភិវឌ្ឍន៍នេះ គឺពឹងផ្អែកទៅលើមូលដ្ឋានគ្រឹះរបស់បច្ចេកវិទ្យាឌីជីថល ក្នុងបដិវត្តន៍ឧស្សាហកម្មទី ៣។ ការរីកសាយភាយនៃបដិវត្តន៍ឧស្សាហកម្មទី ៤។[3] របបគំហើយវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាថ្មីៗមួយចំនួនដែលបានចូលរួមចំណែកដល់ការកកើតឡើងនៃបដិវត្តន៍ឧស្សាហកម្មទី ៤ ដែលបានរៀបរាប់បញ្ចូលជាក្រុមទៅតាមប្រភេទរូបសាស្ត្រ ដូចជាការបោះពុម្ពឈ្មោះ បច្ចេកវិទ្យារបស់ទំនើប និងរថយន្តដំណើរការដោយស្វ័យប្រវត្តិ រួមទាំងប្រភេទឌីជីថលដែលជាឧបករណ៍តភ្ជាប់ទៅប្រព័ន្ធអ៊ីនធើណេតឬហៅថា Internet Of Things ឬ LOT និងប្រភេទជីវសាស្ត្រជាដើម។[4] លើសពីនេះទៅទៀត តាមរយៈការរីកចម្រើននៃបដិវត្តន៍ឧស្សាហកម្មទី ៤ នេះបានធ្វើឲ្យការធ្វើពាណិជ្ជកម្មកាន់តែប្រសើរជាងមុនដូចជា ដែលប្រើប្រាស់នៅប្រទេសវិទ្យានិងប្រព័ន្ធអ៊ីនធើណេតប្រើប្រាស់ក្នុងវិស័យពាណិជ្ជកម្មហើយកាន់តែមានភាពរហ័ស។ ជាពិសេស វាបានធ្វើឲ្យទីក្រុងកាន់តែឆ្លាតវៃតាមរយៈប្រព័ន្ធកម្ពុជាមានសុវត្ថិភាព ឧត្តមភាព នូវសន្តិសុខដូចជាតាមរយៈទីក្រុងវៃឆ្លាតត្រូវបានបំពាក់ដោយ ប្រព័ន្ធកាំមេរ៉ាសុវត្ថិភាព។ តាមរយៈបដិវត្តន៍ឧស្សាហកម្មទី ៤ នេះនាពេលថ្មីៗនេះ នាយករដ្ឋមន្ត្រីកម្ពុជាបានប្រើអនុសាសន៍ដល់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុឲ្យបង្កើតក្របខ័ណ្ឌសេដ្ឋកិច្ចឌីជីថល លើកកម្ពស់សេដ្ឋកិច្ច និងសង្គមតាមរយៈលើកកម្ពស់សេដ្ឋកិច្ចនេះហើយ ដែលធ្វើឲ្យកម្ពុជាមានទស្សនវិស័យវែងឆ្ងាយក្នុងការបង្កើតឲ្យមាននូវការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះឡើង ដើម្បីកំណើនសេដ្ឋកិច្ចជាតិតាមរយៈសេដ្ឋ

[3] មុន្នីវិសាល ត.(២០១៩ ថ្ងៃ០៤ ខែមិថុនា).*អត្ថបទជំនួយស្មារតីស្តីអំពីបដិវត្តន៍ឧស្សាហកម្មទី៤(ឧស្សាហកម្ម៤.០)១(*៣)។

4 ឆែម រិទ្ធី អ៊ួច ច័ន្ទតារ៉ានី. ឧស្សាហកម្ម ៤.០៖ ការប្រមើលឃើញ និងបញ្ហាប្រឈមទៅអនាគតនៃវិស័យកម្មន្តសាលនៅកម្ពុជា។

កិច្ចបែបឌីជីថលការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដូចជាទិញទំនិញតាមអនឡាញ ការដឹកជញ្ជូនប្រកបដោយសុវត្ថិភាពប្រសិទ្ធភាពខ្ពស់និងការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកជាដើម។ ដូច្នេះ បដិវត្តន៍ឧស្សាហ៍កម្មទី ៤ នេះមានឥទ្ធិពលខ្លាំងក្លា ទៅដល់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ទាំងការបង្កើតការរួមផ្សំនឹងការដំណើរការប្រកបដោយប្រសិទ្ធភាពខ្ពស់ សុវត្ថិភាពទាំងព័ត៌មាន និងកំណត់ត្រា និងអត្ថន័យខែដែរសុទ្ធតែពឹងផ្អែកទៅលើប្រព័ន្ធបច្ចេកវិទ្យាទាំងអស់។ តាមរយៈរាជរដ្ឋាភិបាលកម្ពុជា ដើម្បីឱ្យទាន់ទៅនៅបដិវត្តឧស្សាហ៍កម្មទី ៤ នេះយ៉ាងហោចណាស់ ក៏ប្រើប្រាស់រយៈពេលទៅមុខទៀត ដែលដើម្បីធ្វើការអភិវឌ្ឍន៍ខ្លួនឲឱ្យទាន់សភាពការណ៍ហើយការបម្រែបម្រួលសម័យឌីជីថលបច្ចេកវិជ្ជាអ៊ីនធើណេតទាំងអស់នោះ។

លើសពីនេះយើងត្រូវយល់ឲ្យច្បាស់នូវនិយមន័យនៃពាក្យគន្លឹះដែលជាផ្នែកមួយ នៅក្នុងការសិក្សាអំពីអត្ថន័យនៃរបស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលនឹងកំណត់សំគាល់អត្ថន័យនៃពាណិជ្ជកម្មនៃអេឡិចត្រូនិកទៅតាមវចនានុក្រមបទដ្ឋានគតិយុត្តិនិងអន្តរជាតិ។

## កថាខណ្ឌទី២៖ និយមន័យនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

### ក. ការបកស្រាយតាមនិយមន័យទូទៅ និង ការបកស្រាយតាមអង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍ (UNCTAD)

ដោយយោងតាមវចនានុក្រមភាសាអង់គ្លេសអន្តរជាតិពាក្យពាណិជ្ជកម្មថ្នាក់ពាក្យជានាម គឺជាការទិញនិងលក់នូវទំនិញ និងសេវា ចំណែកអេឡិចត្រូនិកអ្នកពាក្យគុណនាម ជាឧបករណ៍អេឡិចត្រូនិក ដែលប្រើបន្ទះឈីបដែលអាចឆ្លងចរន្តអគ្គិសនីបាន។ ស្រដៀងគ្នានេះផងដែរបនានុក្រមធុរកិច្ចជាភាសាអង់គ្លេសក៏បានពន្យល់ពីអត្ថន័យ នៃពាក្យពាណិជ្ជកម្មថាជាការផ្លាស់ប្តូររវាងទំនិញឬសេវាជាមួយនឹងប្រាក់ឬវត្ថុផ្សេងៗ ដែលជាទូទៅធ្វើឡើងលើចម្ងាយដែលឆ្ងាយល្មម ដែលចាំបាច់ត្រូវមានការដឹកជញ្ជូនពីកន្លែងមួយទៅកន្លែងមួយ ឬឆ្លងទីក្រុងរដ្ឋឬព្រំប្រទល់ជាតិណាមួយពាក្យអេឡិចត្រូនិកត្រូវបានផ្តល់អត្ថន័យថា ជាឧបករណ៍ឬប្រព័ន្ធតិចណូឡូជីដែលនឹងចូលគ្នារវាងវិលទាប និងបន្ទះរឹង ដែលមានផ្គុំនិងសមាសភាពតូចជាច្រើន ដែលធម្មតាប្រើក្នុងការបញ្ជូនឬដំណើរការការទិន្នន័យឌីជីថល។ លើសពីនេះទៅទៀតពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវបានគេឲ្យនិយមន័យយ៉ាងទូលាយផ្សេងៗគ្នាជាច្រើន ទៅតាមច្បាប់អន្តរជាតិដែលខាងក្រោមនេះ នឹងយកច្បាប់អន្តរជាតិសំខាន់ៗដែលទាក់ទងទៅនិងការកំណត់និយមន័យនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមើលសិក្សាបន្ថែម។

យោងតាមអង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍ ១៩៩៧ បានកំណត់និយមន័យនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ជាគ្រប់ទម្រង់នៃប្រតិបត្តិការពាណិជ្ជកម្មទាំងអស់ ដែលជាប់ទាក់ទងទៅនឹងសកម្មភាពជំនួញដោយផ្អែកទៅលើដំណើរការ និងការបញ្ជូនទិន្នន័យឌីជីថល ដែលមានទាំងឯកសារសំឡេង

និងរូបភាព ដែលរាប់បញ្ចូលទាំងនីតិបុគ្គល និងរូបវន្តបុគ្គល ដែលផ្អែកទៅលើដំណើរការអេឡិចត្រូនិកនិងការបញ្ជូនទិន្នន័យរួមទាំងការបញ្ចូលឯកសារសំឡេងមករូបភាពយោង[5] ទៅតាមអង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍ ដែលបានកំណត់និយមន័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកតែជាការផលិតកាន់តែចាយការធ្វើទីផ្សារការលក់ការប្រគល់ទំនិញនិងការផ្គត់ផ្គង់សេវាកម្មតាមមធ្យោបាយអេឡិចត្រូនិក។

យោងទៅតាមកំណើតរបស់ក្របខ័ណ្ឌអាស៊ានបានកំណត់ថា ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក សំដៅលើប្រតិបត្តិការអេឡិចត្រូនិកនៅតាមបណ្តាញអ៊ីនធើណេតវាមិនដែលបើកទូលាយផ្សេងទៀតពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលត្រូវបានប្រើប្រាស់នៅក្នុងក្របខណ្ឌអ៊ីអាស៊ាន គឺចង់សំដៅទៅលើប្រតិបត្តិការអេឡិចត្រូនិក នៅលើប្រព័ន្ធបណ្តាញអ៊ីនធើណេតឬនៅលើបណ្តាញបើកទូលាយផ្សេងទៀត។

ម្យ៉ាងវិញទៀត យោងទៅតាមឧបសម្ព័ន្ធនិយមន័យនៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក គឺសំដៅដល់សកម្មភាពទិញលក់ ជួសជុល ផ្លាស់ប្តូរទំនិញឬ សេវាកម្ម ដោយរាប់បញ្ចូលទាំងសកម្មភាពពាណិជ្ជកម្ម និង រដ្ឋប្បវេណីព្រមទាំងសកម្មភាព និងប្រតិបត្តិការរបស់រដ្ឋ តាមប្រព័ន្ធអេឡិចត្រូនិក[6]។

ពោលគឺ និយមន័យជារួម មិនបានចាកឆ្ងាយពីគ្នាដាច់ស្រឡះឡើយពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវបានផ្តល់ជានិយមន័យទូទៅ ថាជាការផលិតជាការចែកចាយ ជាការលក់ទំនិញឬសេវាកម្មត្រូវតាមមធ្យោបាយអេឡិចត្រូនិកពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ជាសកម្មភាពនៃការទិញ ឬលក់ផលិតផលទៅលើសេវាកម្មអនឡាញឬអ៊ីនធើណេត។

### ខ. គោលការណ៍នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវបានស្ថិតនៅក្នុងច្បាប់ជាអន្តរជាតិជាឯកសណ្ឋានមួយស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលមានឈ្មោះ UNCITRAL Model Law on Electronic Commerce 1996 (MLEC)។ ច្បាប់នេះត្រូវបានបង្កើតដោយអង្គការសហប្រជាជាតិ និងចូលរួមអនុម័តដោយ ៧០ បណ្តាប្រទេសក្នុងពិភពលោក ដោយមានគោល បំណងធ្វើឱ្យការធ្វើទំនាក់ទំនងពាណិជ្ជកម្មមានលក្ខណៈជឿនលឿន ងាយស្រួលដល់ មនុស្សជាតិ និង រារាំងដល់ការកើតមានវិវាទនៃច្បាប់ពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក តាមយុត្តធិការនិមួយៗ។ គោលការណ៍សំខាន់ៗនៅក្នុងច្បាប់នេះមាន៣ គឺៈ

---

[5] OECD. (១៩៩៧). A framework for biotechnology statistics [ក្របខ័ណ្ឌសម្រាប់ស្ថិតិបច្ចេកវិទ្យាជីវសាស្ត្រ]។

[6] ឧបសម្ព័ន្ធនិយមន័យនៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

**គោលការណ៍នៃការមិនរើសអើង**

ជាមូលដ្ឋានគ្រឹះរបស់ច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិកដោយ ធានាថាសកម្មភាព ប្រតិបត្តិការតាមទម្រង់អេឡិចត្រូនិកនឹងមិនត្រូវបានបដិសេធចំពោះអនុភាពគតិយុត្តិ សុពលភាពឬការអនុវត្តដោយផ្អែកលើមូលដ្ឋានដែលវាជាទម្រង់អេឡិច ត្រូនិកឡើយ។ ទោះបីទម្រង់នៃប្រតិបត្តិការទាំងពីរមានភាពខុសគ្នាដោយការទិញលក់ផ្ទាល់មានកិច្ចសន្យាលាយលក្ខណ៍អក្សរ មានវិក័យប័ត្រ និង ផលិតផលដែលអាចមើលឃើញ មុនសម្រេច ចិត្តទិញក៏ដោយ ក៏មិនអាចលើកយកជាហេតុផលដែលបំបាត់សុពលភាពរបស់ប្រតិបត្តិ ការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានដែរ ព្រោះសុពលភាព នៃប្រតិបត្តិការ ត្រូវបានទទួលស្គាល់ថាមានសុពលភាពដូចគ្នា។ ដូចនេះប្រតិបត្តិការតាមទម្រង់ អេឡិច ត្រូនិច មិនត្រូវបានលើកជាហេតុផលដើម្បីធ្វើឱ្យកិច្ចសន្យា ទិញលក់អសុពលភាពឡើយ។[7]

**គោលការណ៍នៃអព្យាក្រឹតភាព**

តម្រូវឱ្យមានការអនុម័តបទប្បញ្ញត្តិដែលមានអព្យាក្រឹតភាពទៅនឹងបច្ចេកវិទ្យាដែលកំពុងប្រើប្រាស់ និង បច្ចេកវិទ្យាដែលអាចមាននៅពេលអនាគត។ ដោយមើលឃើញអំពីការរីក ចម្រើនខាងបច្ចេកវិទ្យាយ៉ាងឆាប់រហ័សវិធានអព្យាក្រឹតមានគោលបំណងសម្របសម្រួលការអភិវឌ្ឍនាពេលអនាគតដោយមិនចាំបាច់មានការបង្កើតច្បាប់ទៀតដែលអាចប៉ះពាល់ដល់តម្លៃនៃបច្ចេកវិទ្យានាពេលបច្ចុប្បន្ន។ នៅក្នុងន័យនេះគឺគេសំដៅដល់ការដែលមានបច្ចេកវិទ្យាជឿនលឿននាពេលអនាគត ដែលមានសន្ទុះខ្លាំងក្លាអាចធ្វើឱ្យបច្ចេកវិទ្យាចាស់បានត្រូវមើលរំលងអំពីរបបគតិយុត្តិរបស់វា ហើយក្លាយជាការប៉ះពាល់សិទ្ធដល់អ្នកប្រើប្រាស់។[8]

**គោលការណ៍សមភាពមុខងារ**

បង្ហាញពីលក្ខណៈវិនិច្ឆ័យដែលសកម្មភាពប្រតិបត្តិការពាណិជ្ជកម្មតាមអេឡិចត្រូនិកត្រូវបានចាត់ទុកថាមានភាពស្មើគ្នានឹងប្រតិបត្តិពាណិជ្ជកម្មដោយផ្ទាល់។ ប្រតិបត្តិការពាណិជ្ជកម្ម តាមអេឡិចត្រូនិកបានកំណត់នូវតម្រូវការចាំបាច់នានាដើម្បីឱ្យមានលក្ខណៈសមស្របទៅនឹងមុខងារប្រតិបត្តិពាណិជ្ជកម្មដោយផ្ទាល់ ដូចជា ការលាយលក្ខណ៍អក្សរ ការចុះហត្ថលេខា និង កំណត់ត្រា។ នៅក្នុងន័យនេះច្បាប់ដែលចែងអំពីរពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិកត្រូវតែរួមបញ្ចូលនូវមុខងារដែលអាចផ្តល់អនុភាពគតិយុត្តិ

[7] បកប្រែពី Luca Castellani.(n.d). UNICITRAL Legal Instrument for E-commerce and paperless trade [គណៈកម្មការអង្គការសហប្រជាជាតិស្តីពីវិធានពាណិជ្ជកម្មអន្តរជាតិ លិខិតតុបករណ៍ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងពាណិជ្ជកម្មដោយគ្មានលាយល័ក្ខណ៍អក្សរ]។

ដល់ប្រតិបត្តិការប្រភេទនេះ។ វាមិនចាំបាច់ទាល់តែមានលក្ខណៈដូចគ្នាបេះដាក់ទៅនឹង មុខងារប្រតិបត្តិពាណិជ្ជកម្មដោយផ្ទាល់នោះទេ ប៉ុន្តែវាមានលក្ខណៈត្រឹមត្រូវច្បាស់លាស់ ទៅតាមការអនុវត្តជាក់ស្តែង។

ក្រៅពីនេះ មានគោលការណ៍ទូទៅមួយចំនួនក្រោមបរិបទពាណិជ្ជកម្មអន្តរជាតិដែល ទាក់ទងនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដូចជា៖

**គោលការណ៍សមធម៌ (Pacta Sunt Servanda)**

តម្រូវឱ្យភាគីនៃប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវអនុវត្តឱ្យបានសុចរិតត្រឹមត្រូវទៅតាមលក្ខណ្ឌដែលបានចែងនៅក្នុងប្រតិបត្តិការនោះ។នៅក្នុងគោលការណ៍នេះមុនពេលដែលអតិថិជនយល់ព្រមធ្វើប្រតិបត្តិការពាណិជ្ជកម្មពួកគេត្រូវអាន និង យល់ជា មុនអំពីលក្ខខណ្ឌតម្រូវការដើម្បីបំពេញប្រតិបត្តិការពាណិជ្ជកម្មនេះដោយសុចរិត។ ដូចគ្នានេះ បន្ទាប់ពីអតិថិជនបានបំពេញលក្ខណ្ឌក្នុងការទិញទំនិញ ពាណិជ្ជករត្រូវ តែអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងការប្រគល់ទំនិញឱ្យបានស្របតាមល័ក្ខខ័ណ្ឌដែលអតិថិជនបានព្រៀងទុក ដោយគ្មានការក្លែងបន្លំ ឬ ផ្តល់ព័ត៌មានមិនពិតដល់អតិថិជន។ការបំពេញកាតព្វកិច្ចទៅតាមតម្រូវការ និង ព្រមព្រៀងរបស់ភាគីនេះហើយ ត្រូវបានចាត់ទុកថាបាន បំពេញនូវគោលការណ៍ សមធម៌ និង សុចរិត។[9]

**គោលការណ៍ស្វ័យភាពបុគ្គល**

ភាគីជាប់កិច្ចសន្យាមានសេរីភាពក្នុងការជ្រើសរើសលក្ខខណ្ឌណាមួយ ដែលសមស្របសម្រាប់ប្រតិបត្តិការ លើកលែងតែការផ្តល់កិច្ចសន្យា ឬកិច្ចព្រមព្រៀងនោះធ្វើឡើង មិនស្រប ច្បាប់។ ភាគីគឺជាម្ចាស់នៃកិច្ចសន្យា ដូចនេះវាក៏អាចហៅម្យ៉ាងទៀតបានថាគោលការណ៍សេរីភាពនៃកិច្ចសន្យា ដែលគូរភាគីមានសិទ្ធផ្តល់សំណើរ ហើយភាគីម្ខាងទៀតមានសិទ្ធ ទទួលយកតាមការជ្រើសរើសរបស់ពួកគេ។ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកជាប្រភេទប្រតិបត្តិការដែលមានការចូលរួមរវាងគូរភាគី ដូចនេះហើយគោលការណ៍នេះត្រូវបានយក មកអនុវត្តន៏ផងដែរ។

**គោលការណ៍អន្តរប្រតិបត្តិការ**

ការបង្កើតឱ្យមានលក្ខណៈឯកសណ្ឋានស្របច្បាប់ និង មានការទទួលស្គាល់គ្នាទៅវិញ រវាងបណ្តារប្រទេស ដើម្បីជួយសម្រួលដល់ប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ប្រកបដោយភាពស្រប

---

[9] បកប្រែពី Luca Castellani.(n.d). UNICITRAL Legal Instrument for E-commerce and paperless trade [គណៈកម្មការអង្គការសហប្រជាតិស្តីពីវិធានពាណិជ្ជកម្មអន្តរជាតិ លិខិតគុបករណ៍ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងពាណិជ្ជកម្មដោយគ្មានលាយល័ក្ខណ៏អក្សរ]។

ច្បាប់។គោលការណ៍បានកំណត់ជាសំណុំពិធីការ ឬ កិច្ចព្រមព្រៀងរួមមួយ ដែលធានាបាននូវការផ្តល់ជូនសេវាកម្មយ៉ាងមានប្រសិទ្ធភាព តាមរយៈពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។[10]

**កថាខណ្ឌទី៣៖ ទម្រង់នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

ជាទូទៅ ពេលដែលនិយាយអំពីរពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក យើងតែងតែគិតដល់ប្រតិបត្តិការពាណិជ្ជកម្មរវាងអ្នកលក់ និងអ្នកទិញ។ យ៉ាងណាមិញ ប្រភេទនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវបានចែកចេញជាទម្រង់ច្បាស់លាស់ទៅតាមលក្ខណៈរបស់វាមាន ដូចខាងក្រោម ៖

**ក. ទម្រង់ពាណិជ្ជកម្មរវាងឯកជន និង ឯកជន**

**ពាណិជ្ជកម្ម នឹង ពាណិជ្ជកម្ម (B2B)**

ជាប្រភេទប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករវាងក្រុមហ៊ុននឹង ក្រុមហ៊ុន។ក្រុមហ៊ុនផលិត អ្នកលក់បោះដុំ ឬអ្នកផ្គត់ផ្គង់។តំណាងចែកចាយដុំជ្រើសរើស ធ្វើប្រតិបត្តិការពាណិជ្ជកម្ម អេឡិចត្រូនិកប្រភេទនេះ។ជាធម្មតា ប្រតិបត្តិការប្រភេទនេះ សំដៅទៅលើពាណិជ្ជកម្ម អេឡិចត្រូនិកដែលកើតឡើងរវាងក្រុមហ៊ុន ជាជាងក្រុមហ៊ុន និងអតិថិជន។ ការអនុវត្តប្រតិបត្តិការបែបនេះតាមអ៊ិនធឺណេតផ្តល់ ជូននូវអត្ថប្រយោជន៍ នៃការប្រកួតប្រជែងដ៏អស្ចារ្យលើសពីវិធីសាស្ត្រសាមញ្ញ។ឧទាហរណ៍ រោងចក្រផលិត ឬសហគ្រាសដំឡើងគ្រឿងចក្រ បានលក់ផលិតផលសម្រេចរបស់ខ្លួនទៅកាន់ ក្រុមហ៊ុនលក់គ្រឿងចក្រ រួចក្រុមហ៊ុនក៏បាន លក់បន្តរទៅឱ្យអ្នកទិញចុងក្រោយ។[11]

**ពាណិជ្ជកម្ម នឹង អ្នកប្រើប្រាស់(B2C)**

ជាប្រភេទប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករវាងក្រុមហ៊ុននឹង អ្នកប្រើប្រាស់ ចុងក្រោយ។ ប្រតិបត្តិការប្រភេទនេះមានភាពល្បីល្បាញទូទាំងពិភពលោក និង នៅប្រទេសកម្ពុជា ដែលមនុស្សទូទៅ ពេញនិយមប្រើប្រាស់ព្រោះវាផ្តល់ទំនាក់ទំនងយ៉ាង ជិតស្និតរវាងអ្នកលក់ និង អ្នកទិញ ដូចទៅនឹងប្រតិបត្តិការពាណិជ្ជកម្មផ្ទាល់ផងដែរ។ អ្នកប្រើប្រាស់អាចស្វែងរកទំនិញគ្រប់ប្រភេទ និងពត៌មាន របស់ទំនិញដោយខ្លួនឯង ផ្ទាល់ ដោយកាត់បន្ថយការប៉ះពាល់ចំពោះសេវាកម្មបម្រើអតិថិជន និង ចំនេញពេលវេលា។ ទំនិញទាំងនោះរួមមាន សម្លៀកបំពាក់ ឧបករណ៍ប្រាស់ប្រាស់ ម្ហូបអាហារ ។ល។

[10] បកប្រែពី Luca Castellani.(n.d). UNICITRAL Legal Instrument for E-commerce and paperless trade [គណៈកម្មការអង្គការសហប្រជាតិស្តីពីវិធានពាណិជ្ជកម្មអន្តរជាតិ លិខិតតុបករណ៍ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងពាណិជ្ជកម្មដោយគ្មានលាយល័ក្ខណ៍អក្សរ]។

[11] បកប្រែពី Hashim Shaker et al.,(២០១៣). Review on Electronic Commerce[ការពិនិត្យមើលទៅលើពាណិជ្ជកម្មអេឡិចត្រូនិក,១៣៥៩។

**អ្នកប្រើប្រាស់ នឹង អ្នកប្រើប្រាស់ (C2C)**

ជាប្រភេទប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលប្រតិបត្តិការត្រូវបានធ្វើឡើងតាមរយៈអន្តរការីដែលផ្តល់នូវវេទិកាតាមអ៊ិនធឺណេត (online platform) សម្រាប់ ប្រតិបត្តិការទិញលក់នេះ។ នៅក្នុងប្រភេទប្រតិបត្តិការពាណិជ្ជកម្មនេះ អន្តរការីដើរ តួរជាអ្នកផ្តល់វេទិការសម្រាប់ឱ្យអ្នកលក់ដាក់តាំងទំនិញរបស់ខ្លួន និង ទាក់ទាញអ្នកទិញបានច្រើន ព្រោះអ្នកលក់ និង អ្នកទិញឈរនៅវេទិការតែមួយ។អ្នកលក់នៅទីនេះក៏ដើរតួរជាអតិថិជនដែរព្រោះពួកគេទទួលយកសេវាពីអន្តរការីដើម្បីសម្រួលដល់ប្រតិបត្តិការលក់ឱ្យមានទីផ្សារ និង ស្រូបយកអតិថិជនបានច្រើន។ឧទាហរណ៍ ក្រុមហ៊ុន Food Panda ជាអន្តរការីមួយដែលផ្តល់វេទិកាទៅឱ្យអ្នកលក់ម្ហូបអាហារ បានដាក់លក់ម្ហូបរបស់ខ្លួន ចំនែកឯអ្នកទិញអាចចូល ទិញម្ហូបដែលគេចង់បាននៅក្នុងវេទិកានេះផងដែរ។[12]

**អ្នកប្រើប្រាស់ នឹង ពាណិជ្ជកម្ម (C2B)**

ជាប្រភេទប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករវាងបុគ្គលឯកជនដែលផ្តល់សំណើរនូវស្នាដៃរបស់ខ្លួនទៅកាន់ពាណិជ្ជករ។ ប្រតិបត្តិការប្រភេទនេះត្រូវបានគេពេញ និយមប្រើប្រាស់នៅក្នុងសង្គមដែលមានការអភិវឌ្ឍន៏ធនធានមនុស្សខ្ពស់។ វាមាន លក្ខណៈស្រដៀងនឹងការធ្វើលទ្ធកម្មដែរ។ ឧទាហរណ៍ កូនសិស្សផ្នែកស្ថាបត្យកម្ម មួយចំនួនបានរចនាស្លាកសញ្ញារៀងៗខ្លួនសម្រាប់ក្រុមហ៊ុនមួយរួចដាក់លក់នៅក្នុង អ៊ិនធឺណេត ដើម្បីឱ្យក្រុមហ៊ុនទិញយកស្លាកសញ្ញាមួយក្នុងចំណោមស្លាកសញ្ញា ទាំងអស់ដែលបានដាក់បង្ហាញ។ ទំនិញទាំងនោះរួមមាន សួយសារ រូបថត គំនូរ រូបភាព ប្លង់រចនា ។ល។

**ខ. ទម្រង់ពាណិជ្ជកម្មរវាងរដ្ឋ និងឯកជន**

**ពាណិជ្ជកម្ម នឹង ស្ថាប័នសាធារណៈ (B2A)**

ជាប្រភេទប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករវាងក្រុមហ៊ុនឯកជន និង ស្ថាប័នសាធារណៈ ជាពិសេសការវិនិយោគជាមួយរាជរដ្ឋាភិបាល។ ប្រតិបត្តិការនេះ ទាក់ទងទៅនឹងតម្រូវការសាច់ប្រាក់ច្រើនរួមមាន វិស័យសារពើពន្ធ, សន្តិសុខសង្គម, ការងារ, ឯកសារច្បាប់និងការចុះឈ្មោះជាដើម។ ឧទាហរណ៍ នៅប្រទេសកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ ក្រោមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានបង្កើត application មួយដែលអនុញ្ញាត្តិឱ្យក្រុមហ៊ុនចុះបញ្ជីអាចបង់ពន្ធប៉ាតង់ប្រចាំឆ្នាំ ឬតម្កល់ប្រទិវេទបានតាមរយៈប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ។

---

[12] បកប្រែពី Hashim Shaker et al.,(២០១៣). Review on Electronic Commerce[ការពិនិត្យមើលទៅលើពាណិជ្ជកម្មអេឡិចត្រូនិក,១៣៥៩។

**អ្នកប្រើប្រាស់ នឹង ស្ថាប័នសាធារណៈ (C2A)**

ជាប្រភេទប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករវាង អ្នកប្រើប្រាស់ ឬ បុគ្គល ឯកជន ជាមួយនឹង ស្ថាប័នសាធារណៈ ដូចជា៖

- វិស័យអប់រំ ដែលចែកចាយកម្មវិធីសិក្សាពីចម្ងាយ
- និរភ័យសង្គម ដែលចែកនូវពត៌មាន និង ការបង់ភាគទាន
- ពន្ធដារ ដែលទាក់ទងនឹងការបង់ពន្ធប្រចាំខែ
- វិស័យសុខាភិបាល ដែលទាក់ទងនឹងការណាត់ជួប ផ្តល់ពត៌មានអំពីជំងឺ និង ការបង់ថ្លៃសេវាសុខាភិបាល។

ប្រភេទប្រតិបត្តិការនេះកំពុងត្រូវបានរាជរដ្ឋាភិបាលកម្ពុជាព្យាយាមសិក្សានិង បង្កើតឱ្យ មានភាពសមស្របទៅនឹងការអភិវឌ្ឍវិស័យរដ្ឋបាលនៅកម្ពុជា។ ដោយមានការគាំទ្រពីកំណើនបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍។ទម្រង់ប្រតិបត្តិការពាណិជ្ជកម្មB2A និង C2A ដែលពាក់ព័ន្ធនឹងរដ្ឋបាលសាធារណៈត្រូវបានផ្សារភ្ជាប់យ៉ាងខ្លាំង ទៅនឹងការច្នៃប្រឌិតថ្មីឱ្យមានភាពងាយស្រួលក្នុងការផ្តល់ សេវាកម្មសាធារណៈ យ៉ាងមាន ប្រសិទ្ធភាពចំពោះប្រជាពលរដ្ឋ។

## ផ្នែកទី២៖ លក្ខណៈនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

### កថាខណ្ឌទី១៖ ទំនាក់ទំនងប្រតិបត្តិការនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ការបកស្រាយអំពី ទំនាក់ទំនងប្រតិបត្តិការនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ គឺមានសារៈសំខាន់ ដោយហេតុតែវាជាមូលហេតុមួយដ៏ចម្បងមួយសម្រាប់ធ្វើការថ្លឹងថ្លែងពី កាតព្វកិច្ច និង ការទទួលខុសត្រូវរបស់ភាគីនៅក្នុងប្រតិបត្តិការនៃពាណិជ្ជកម្មតាមប្រព័ន្ធ អេឡិចត្រូនិក។ ការយល់ដឹងអំពីទំនាក់ទំនងនេះគឺមានភាពស៊ីជម្រៅចំពោះដំណើរការ លម្អិតនៃប្រតិបត្តិការដ៏ពេញនិយមមួយនេះ។

#### ក. ទំនាក់ទំនងពេលវេលា និងទីកន្លែងបញ្ជូនចេញនៃសារទិន្នន័យ

នៅក្នុងប្រតិបត្តិការពាណិជ្ជកម្មទូទៅ អ្នកប្រើប្រាស់អាចបានដឹងនូវព័ត៌មានដូចជាតម្លៃ គុណភាព និងលក្ខណៈនៃទំនិញ ជាមុននឹងធ្វើការសម្រេចចិត្តជាវទំនិញ។ ចំនែកឯនៅក្នុងប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក គឺត្រូវមានការបញ្ជូនចេញ (Dispatch) នូវព័ត៌មានទៅកាន់អតិថិជនដើម្បីជ្រើសរើសទិញទំនិញ។ បញ្ជូនព័ត៌មាននេះហើយដែលជាចំណុច ចាប់ផ្តើមឱ្យកើតមានឡើងនូវដំណើរការអេឡិចត្រូនិក។ ព័ត៌មានដែលត្រូវបានបញ្ជូនចេញតាមរយៈអេឡិចត្រូនិកនេះ យើងអាចហៅម៉្យាងទៀត ថាសារអេឡិចត្រូនិក (Electronic Message)។

សារអេឡិចត្រូនិក ត្រូវបានចាត់ទុកថាបានចាកចេញនៅពេលដែលអ្នក កាន់កាប់ឬអ្នកគ្រប់គ្រងព័ត៌មាននោះបានចុចបញ្ជូនចេញនូវព័ត៌មាន ស្របពេលដែលអ្នកទទួលបានទទួលនូវ ព័ត៌មានដែលបានបញ្ជូនមកនេះ។ លើសពីនេះផងដែរ មាត្រា១៥ នៃ UNCITRAL Model Law បានបញ្ជាក់ន័យនៃវាក្យសព្ទការបញ្ជូនចេញ ដោយមានន័យថា ព័ត៌មានមួយត្រូវបានបញ្ជូនចេញគឺ នៅពេលដែលព័ត៌មាននោះលែងស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នក ផ្ញើរចេញតទៅទៀត។[13]

ចំពោះទីតាំងនៃការបញ្ជូន គឺមានលក្ខណៈខុសគ្នាទៅនឹង ប្រតិបត្តិការពាណិជ្ជកម្មផ្ទាល់ ក៏ព្រោះតែពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមិនតម្រូវឱ្យ មានជាទីតាំងលក់ ឬផ្គត់ផ្គង់ទំនិញផ្ទាល់នោះទេ គឺគេអាចធ្វើឡើងបានតាមរយៈម៉ូបាល់អេប (Mobile App) ឬ វេបសាយ (Website) នៃការផ្គត់ផ្គង់នោះជាដើម។ ទីតាំងនៃការបញ្ជូនាសារអេឡិចត្រូនិកត្រូវបានកំណត់ដោយផ្អែកលើទីតាំងអាជីវកម្មរបស់អ្នកផ្ញើរនូវព័ត៌នោះ ដោយមិនកំណត់យកទីតាំងដែលព័ត៌មាននោះបានផ្ញើរចេញមកនោះទេ។ នៅត្រង់ចំនុចនេះ បើទោះបីអាជីវករតាមរយៈពាណិជ្ជតាមប្រព័ន្ធអេឡិចត្រូនិក គ្មានទីតាំងច្បាស់លាស់មួយសម្រាប់អាជីវកម្មខ្លួនប្រាកដក្តី ក៏ប្រតិបត្តិប្រភេទនេះតម្រូវឱ្យមានការចាត់តាំងនូវទីតាំងមួយដែលអាចចាត់ទុកថាជាទីតាំងអាជីវកម្មសម្រាប់ការបញ្ជូនចេញនូវព័ត៌មាននៃការលក់របស់ខ្លួន។ ឧទាហរណ៍ អាជីវករលក់សម្លៀកបំពាក់តាមរយៈវេបសាយ ដែលការលក់នេះគឺធ្វើនៅគេហដ្ឋានផ្ទាល់ ក៏ប៉ុន្តែអាជីវករម្នាក់នោះក៏អាចធ្វើការលក់ទំនិញរបស់គាត់ពេលចេញទៅក្រៅ ឬគ្រប់ទីកន្លែងយ៉ាងងាយស្រួល ក៏ប៉ុន្តែសារអេឡិចត្រូនិកដែលគាត់បានបញ្ជូនទៅកាន់អតិថិជន ត្រូវបានចាត់ទុកថាបញ្ជូនចេញពីផ្ទះរបស់គាត់តែមួយគត់។ ការកំណត់បែបនេះគឺមានគោលដៅដើម្បីធ្វើឱ្យការទិញទំនិញក្រោមពាណិជ្ជកម្មតាមអេឡិចត្រូនិក មានលក្ខណៈដូចទៅនឹងការទិញលក់ទំនិញដោយផ្ទាល់ដែរ។ អាជីវករលក់ទំនិញតារយៈថ្នាលអនឡាញ មិនអាចលើកហេតុផលគេចវេសថាការផ្តល់ព័ត៌មានរបស់ខ្លួនមិនមានសុពលភាពដោយហេតុមិនបានប្រព្រឹត្តិនៅទីតាំងអាជីវកម្មរបស់ខ្លួនបានឡើយ។

### ខ. ទំនាក់ទំនងពេលវេលា និងទីកន្លែងទទួលនៃសារអេឡិចត្រូនិក

ការទទួលបានសារអេឡិចត្រូនិក (Receipt) គឺត្រូវបានកំណត់ថាពិតជាបានកើតមានការទទួលនៅពេលដែលអ្នកទទួលអាចទាញយក (Retrieve) និង អាចដំណើរការប្រើប្រាស់នូវព័ត៌មាន នោះបាន។ សារទិន្នន័យមិនត្រូវបានចាត់ទុកថាបានទទួលនោះទេ ប្រសិនបើអ្នកទទួលមិនអាចប្រើប្រាស់ព័ត៌មាននោះបានបើទោះបីជាវាបានមកដល់ប្រព័ន្ធអ្នកទទួលក៏ដោយក្តី។ ជាសមញ្ញកាលដែលអ្នកទទួលបានមានលទ្ធ

[13] សេចក្តីពន្យល់មាត្រា១៥ នៃ UNCITRAL Model Law របស់សភាអង្គការសហប្រជាជាតិ, ផ្សព្វផ្សាយដោយគេហទំព័រច្បាប់ lexmercatoria។អាចរកមើលនៅ https://www.jus.uio.no/lm/un.electronic.commerce.model.law.1996/art.15.html

ភាពអាចដឹងពីព័ត៌មានដែលបានបញ្ជូនមកខ្លួនហើយ ត្រង់ចំនុចនេះគឺបញ្ជាក់ថាគេពិតជាបានទទួលពិតប្រាកដ។ បើនៅក្នុងករណីដែលការបញ្ជូនមកដល់នោះមានភាពមិនប្រក្រតី ឬមិនអាចដំណើរការដែលផ្តល់ការលំបាកដល់អ្នកទទួលក្នុងការបានដឹង និង អាចប្រើប្រាស់ព័ត៌មាននោះ គឺមិនអាចចាត់ទុកថាបានទទួលយ៉ាងពេញលេញបានឡើយ។[14]

ចំពោះទីកន្លែងវិញ សារអេឡិចត្រូនិកត្រូវបានចាត់ទុកថាទទួលបាននូវត្រង់ កន្លែង ឬទីតាំងដែលអ្នកបញ្ជូនបានកំណត់អាស័យដ្ឋានច្បាស់លាស់មួយសម្រាប់ធ្វើការបញ្ជូនចេញជាឯកតោភាគី។ទីតាំង និងអាស័យដ្ឋាននៅត្រង់ចំនុចនេះ សំដៅដល់ប្រព័ន្ធព័ត៌មានជាក់លាក់មួយដែលបានកំណត់ (Designed Information System) ដោយអ្នកបញ្ជូន។

ក្នុងករណី ដែលគ្មានការបញ្ជាក់អំពីទីតាំងនៃអាស័យដ្ឋានដែលទទួលនោះទេ ទីតាំងអាជីវកម្ម (Place of Business)របស់អ្នកទទួល ត្រូវបានសន្មតថា ជាទីតាំងដែលបានទទួលសារទិន្នន័យ។ ការបញ្ជាក់ទីតាំងនៅលើក្បាលលិខិត សំបុត្រ ឬ អ៊ីម៉ែលមិនអាចបញ្ជាក់ថាជាការកំណត់នូវទីតាំងដែលត្រូវបានទទួលនោះឡើយ។[15] ចំពោះទីតាំងអាជីវកម្មគឺអាចបែងចែកជាច្រើនសណ្ឋានទៀតដូចជា៖

- ប្រសិនបើមានទីតាំងអាជីវកម្មច្រើនកន្លែង ត្រូវកំណត់យកទីតាំងអាជីវកម្មដែលមានទំនាក់ទំនងទៅនឹងកិច្ចសន្យាដែលពាក់ព័ន្ធ
- ប្រសិនបើរូបវន្តបុគ្គលពុំមានទីតាំងអាជីវកម្មទេ នោះទីតាំងអាជីវកម្មសំដៅដល់ទីលំនៅ អចិន្ត្រៃយ៍របស់រូបវន្តបុគ្គលនោះ

**កថាខណ្ឌទី២៖ ការទូរទាត់ និងការផ្ទេរប្រាក់ក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

ប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានភាពខុសប្លែកពីប្រតិបត្តិការដោយផ្ទាល់ ដោយប្រតិបត្តិការនេះធ្វើឡើងតាមរយៈថ្នាលបច្ចេកវិទ្យា និងត្រូវមានការចូលរួមយ៉ាងចាំបាច់ពី គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ បណ្តាសេវាទូទាត់ប្រាក់ ឧបករណ៍ទូទាត់ប្រាក់អេឡិចត្រូនិក ឬ មធ្យោបាយទូទាត់តាមប្រព័ន្ធអេឡិចត្រូនិកនានា។ ការទូទាត់ប្រាក់តាមរយៈ ប្រព័ន្ធអេឡិចត្រូនិកនេះផ្តល់នូវមធ្យោបាយយ៉ាងងាយស្រួលដល់អ្នកលក់និងអ្នកទិញដោយធនាគារ និង ក្រុមហ៊ុនទូទាត់ទាំងនេះជាដើមកំពុងព្យាយាមវិវត្តប្រព័ន្ធទូទាត់ឌីជីថលដោយណែនាំបច្ចេកវិទ្យាថ្មីៗ ដើម្បីស្រូបទាញអតិថិជន។

[14] សេចក្តីពន្យល់មាត្រា១៥ នៃ UNCITRAL Model Law របស់សភាអង្គការសហប្រជាជាតិ, ផ្សព្វផ្សាយដោយគេហទំព័រច្បាប់ lexmercatoria។អាចរកមើលនៅ https://www.jus.uio.no/lm/un.electronic.commerce.model.law.1996/art.15.html

[15] សេចក្តីពន្យល់មាត្រា១៥ នៃ UNCITRAL Model Law របស់សភាអង្គការសហប្រជាជាតិ, ផ្សព្វផ្សាយដោយគេហទំព័រច្បាប់ lexmercatoria។អាចរកមើលនៅ https://www.jus.uio.no/lm/un.electronic.commerce.model.law.1996/art.15.html

### ក. ការចូលរួមរបស់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ

គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុដើរតួរយ៉ាងសំខាន់ក្នុងដំណើរការ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដោយហេតុអ្នកប្រើប្រាស់នឹងត្រូវការថ្នាលបច្ចេកវិទ្យាមួយសម្រាប់ការទូទាត់ប្រាក់។ការសិក្សាមួយដែលធ្វើឡើងដោយធនាគារអភិវឌ្ឍន៍អាស៊ីបានបង្ហាញថា ការធ្វើឱ្យប្រសើរឡើងនូវសមាហរណកម្មហិរញ្ញវត្ថុរបស់ព្រះរាជាណាចក្រកម្ពុជាអាចជំរុញកំណើនសេដ្ឋកិច្ចបាន ៦% (ប្រាំមួយភាគរយ) ប្រសិនបើផលិតផលនិងសេវាកម្មហិរញ្ញវត្ថុផ្លូវការត្រូវបានចែកចាយដល់គ្រប់ផ្នែកនៃប្រជាជន។[16] សេវាកម្មហិរញ្ញវត្ថុក្នុងន័យនេះ គឺសំដៅលើការប្រើប្រាស់សេវារបស់ធនាគារ និង ហិរញ្ញវត្ថុដែលផ្តល់ឥណទានតាមប្រព័ន្ធឌីជីថលពេញលេញ នៅក្នុងប្រតិបត្តិការលក្ខណៈបុគ្គល ក្រុមគ្រួសារ សហគម ម្ចាស់អាជីវកម្មខ្នាតតូចបំផុត អាជីវកម្មខ្នាតតូច ឬខ្នាតមធ្យម ឬប្រតិបត្តិការទូទៅដែលមានលក្ខណៈជាប្រចាំសម្រាប់តម្រូវការជីវភាពរស់នៅ។

មុនពេលដែលមានប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ការចូលរួមរបស់ ធនាគារនៅក្នុងប្រព័ន្ធអ៊ីនធើណែតគឺនៅមានកម្រិត ព្រោះទំនាក់ទំនងអ្នកប្រើប្រាស់មិនមាន លក្ខណៈជាប្រចាំ។[17] នៅក្នុងន័យនេះធនាគារត្រូវ បង្កើតគេហទំព័ររបស់ខ្លួនដើម្បីផ្តល់ ព័ត៌មានអំពីសេវារបស់ខ្លួនទៅកាន់អ្នកប្រើប្រាស់ ឬអតិថិជនថ្មីៗ។ ដូចគ្នានេះផងដែរ អ្នកប្រើប្រាស់មួយចំនួនមិនមានលទ្ធភាព ឬចំណេះដឹងគ្រប់គ្រាន់សម្រាប់ការចូល ទៅក្នុងគេហទំព័រនោះទេ។ ជាការអនុវត្តតាមប្រពៃណី អតិថិជនធ្វើប្រតិបត្តិការហិរញ្ញវត្ថុដោយ ធ្វើដំណើរទៅកាន់ធនាគារដោយផ្ទាល់ ឬដកប្រាក់តាមរយៈទូរដកប្រាក់ (ATM) ទាក់ទងតាមរយៈអ៊ីម៉ែល ឬ តេទូរស័ព្ទដៃ ដែលប្រតិបត្តិការនេះប្រើប្រាស់រយៈពេលយូ និង គ្មានភាពងាយស្រួល។ ទន្ទឹមនឹងបរិបទនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ធនាគារក៏អាចណែនាំនូវផលិតផលថ្មី របស់ខ្លួនតាមរយៈ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីទាក់ទាញនូវអតិថិជន និង ដៃគូរសហការដែលជាអ្នកលក់ផងដែរ។ មួយវិញផងដែរធនាគារ និងមីក្រូហិរញ្ញវត្ថុដើរ តួរជាអ្នកសម្របសម្រួលផ្តាច់មុខ ក្នុងប្រតិបត្តិការ ទូទាត់ប្រាក់យ៉ាងឆាប់រហ័សស្របទៅតាម ទំនើបកម្មនៃដំណើរការ ពាណិជ្ជកម្មមួយនេះ។
វិស័យទាំងពីរនេះបានផ្សារភ្ជាប់គ្នាយ៉ាងស្អិតរមួតដែលមិនអាចខ្វះគ្នាបាននោះទេ។ វិស័យទាំងពីរបានចូលរួមយ៉ាងសកម្ម និង ឆ្លើយឆ្លងគ្នាទៅវិញទៅមកដើម្បីធ្វើឱ្យពាណិជ្ជកម្មតាប្រព័ន្ធអេឡិចត្រូនិកដំណើរការទៅ

[16] Husain Haider. (២០២១, ថ្ងៃទី៣ ខែកុម្ភៈ). Fintech បង្ហាញពីវិធីសាស្ត្រឆ្ពោះទៅកាន់បរិយាប័ន្នហិរញ្ញវត្ថុពេញលេញសម្រាប់ប្រជាជនកម្ពុជា. *ខ្មែរថែមស៍*។

[17] បកប្រែពី John Wenninger. (២០០០, ខែមិនា). The Emerging Role of Banks in E-Commerce [ការលេចចេញនូវតួរនាទីរបស់ធនាគារនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក]. *Current Issues in economics and finance, ៦*(៣),២-៣ ។

មុខបានយ៉ាងមានតម្លាភាព និង ប្រសិទ្ធភាព។ ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក និងជម្រើសហិរញ្ញវត្ថុផ្សេងៗទៀតអាចដើរតួរជាជំនួយអន្តរការី ឬ ជាតួរអង្គឯករាជ្យសម្រាប់រចនាសម្ព័ន្ធដើមធនាគាររបស់ខ្លួនដោយមានការបង្កើតនូវគំរូពាណិជ្ជកម្មថ្មីឱ្យស្របតាមទំនើបកម្មនៃពាណិជ្ជកម្មជំនាន់ថ្មី។[18] ដោយសម្លឹងមើលជុំវិញការអភិវឌ្ឍតតឈប់ឈរនៃការជឿនលឿននេះ ឱកាសនៃការបង្កើតថ្មីនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ នឹងដើរទន្ទឹមគ្នាជាមួយនឹងបញ្ហាប្រឈម ព្រោះបច្ចេកវិទ្យាមានទំនោរផ្លាស់ប្តូរយ៉ាងឆាប់រហ័សទៅតាមទីផ្សារ និងតម្រូវការរបស់ប្រជាជន។ ការផ្តល់នូវសេវាកម្មទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក(E-payment)[19] ដែលមានសុវត្ថិភាពនឹង បង្កើននូវបរិយាប័ណ្ណហិរញ្ញវត្ថុ (Financial Inclusion) និង ការប្រើប្រាស់ប្រព័ន្ធឌីជីថលឱ្យកាន់តែច្រើនសម្រាប់ប្រជាពលរដ្ឋគ្រប់ជាន់ថ្នាក់។

### ខ. ប្រភេទប្រតិបត្តិការទូទាត់ប្រាក់

នៅកម្ពុជា បញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិកមានប្រតិបត្តិការចំនួនបីប្រភេទ ៖

• ការផ្ទេរឥណទាន (Credit Remittance) ៖ ការផ្ទេរឥណទានត្រូវបានប្រើសម្រាប់ការទូទាត់ សងប្រាក់ដែលផ្តើមឡើងដោយអ្នកសងប្រាក់(Payer) ទៅអ្នកទទួលផល ។ ធនាគារពាណិជ្ជផ្តល់ សេវាផ្ទេរឥណទានតាមរយៈ សាខា ម៉ាស៊ីនទូទាត់ដោយស្វ័យប្រវត្តិ (ATM) អ៊ីនធើណែត កុំព្យូទ័រ និងទូរស័ព្ទចល័ត ។

• ឥណទានផ្ទាល់ (Direct Credit) ៖ ការទូទាត់សងប្រាក់តាមរយៈឥណទានផ្ទាល់ផ្តើមឡើងដោយអ្នកសងប្រាក់តែម្នាក់ទៅអ្នកទទួលផលមួយឬច្រើននាក់តាមចំនួនប្រាក់និងពេលវេលាដែលបានកំណត់។ ឥណទានផ្ទាល់ត្រូវបានប្រើជាទូទៅសម្រាប់ការបើកប្រាក់បៀវត្សរ៍។

• ឥណពន្ធផ្ទាល់ (Direct Debit) ៖ ឥណពន្ធផ្ទាល់មានពីរទម្រង់គឺប្រភេទឥណពន្ធផ្ទាល់ដោយបង្ខំនិងដោយសំណើ ។ ឥណពន្ធផ្ទាល់ដោយបង្ខំ ជាការទាមទារឱ្យទូទាត់សងប្រាក់នៅពេលអ្នកទទួលផលបង្ហាញបញ្ជានេះទៅអ្នកសងប្រាក់ ។ ឥណពន្ធផ្ទាល់ដោយសំណើ ជាទម្រង់មួយនៃសារបញ្ជាទូទាត់សងប្រាក់ដែលមិនមានផ្ទុកតម្លៃ (Non Value Payment Order Message) ។ ឥណពន្ធផ្ទាល់នេះត្រូវបាន

[18] Chen, L. (2020), 'Improving Digital Connectivity for E-commerce: A Policy Framework and Empirical Note [ការពង្រឹងការតភ្ជាប់ប្រព័ន្ធឌីជីថលនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក៖ ក្របខ័ណ្ឌគោលនយោបាយ និងការសិក្សាលម្អិត], in Chen, L. and F. Kimura (eds.), *E-commerce Connectivity in ASEAN.* Jakarta, Indonesia: Economic Research Institute for ASEAN and East Asia, pp.7-30.

[19] ធានាជាតិនៃកម្ពុជាបានផ្តល់និយមន័យ បញ្ជាទូទាត់ប្រាក់អេឡិចត្រូនិក សំដៅដល់ការបញ្ជាធនាគារឱ្យធ្វើការសងប្រាក់ ឬទាញយកប្រាក់ក្នុងចំនួនដែលបានកំណត់ចេញពីគណនីដែលបានចង្អុលបង្ហាញឱ្យទៅ ឬសម្រាប់អ្នកទទួលប្រាក់ ឬឱ្យទៅ ឬសម្រាប់គណនីរបស់អ្នកទទួលប្រាក់ និងរួមទាំងការកែប្រែណាមួយនៅលើបញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិកផងដែរ ។ បញ្ជានោះអាចមានកំណត់ថ្ងៃប្រសិទ្ធភាព ប៉ុន្តែមិនត្រូវស្ថិតនៅក្រោមលក្ខខណ្ឌណាមួយក្រៅពីអ្វីដែលធនាគារផ្តើមប្រតិបត្តិការបានព្រមព្រៀងអនុវត្តឡើយ ។

ទទួលយកក្រោមរូបភាពជាសំណើ សារជូនដំណឹងសម្រាប់ទូទាត់សងប្រាក់ប៉ុណ្ណោះ។[20]

រូបភាពទី១

ដំណើរការនៃការទូទាត់ប្រាក់នៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច (E-Commerce)




១. អតិថិជនទិញទំនិញតាមរយៈគេហទំព័ររបស់អ្នកលក់ដែលមាននៅក្នុង E-Commerce

២.គេហទំព័រ E-Commerceនឹងផ្ញើរនូវព័ត៌មានដូចជាលេខកូដទំនិញឬ ចំនួនទឹកប្រាក់សម្រាប់អ្នកផ្តល់សេវាទូទាត់ប្រាក់

៣. Payment Gateway ឬច្រកផ្លូវទូទាត់ចាត់ចែងការទូទាត់លុយដោយដាក់ចូលនូវព័ត៌មាន គណនេយ្យធនាគាររបស់អ្នកទិញ

៤. បន្ទាប់ពីទទួលការព្រមព្រៀងទូទាត់ទំនិញ ច្រកផ្លូវទូទាត់នឹងផ្ទេរលុយទៅឱ្យ គណនេយ្យធនាគារអ្នកលក់។

### កថាខណ្ឌទី៣៖ ការផុតរលត់នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ហាងលក់ទំនិញ ឬសេវាកម្មតាមអេឡិចត្រូនិក ដែលបានបង្កើតតាមកិច្ចសន្យាពាណិជ្ជកម្ម ការធ្វើការលក់នូវទំនិញ ឬសេវាកម្មផ្សេងៗទៀត អោយទៅបុគ្គលទាំងឡាយដែលបានទិញនូវទំនិញ ឬសេវានោះក៏មានលក្ខខណ្ឌ ដែលនាំឱ្យការផុតរលត់ផងដែរ គឺនៅពេលដែលសេវាកម្ម គោលបំណង កម្មវត្ថុរបស់បុគ្គលទាំងអស់នោះ បានសម្រេចទៅតាមឆន្ទៈកិច្ចសន្យារបស់បុគ្គលម្នាក់ៗ។

[20] ធានាជាតិនៃកម្ពុជា.(២០១៥).បញ្ហារទូទាត់តាមអេឡិចត្រូនិក។

**ក. ការទូទាត់ប្រាក់**

នៅពេលដែលទំនាក់ទំនងកិច្ចសន្យាស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក បានបង្កើតឡើង ហើយវាមានសុពលភាព អនុភាព ដែលអាចអនុវត្តបន្តបានហើយនោះ បុគ្គលដែលមាននូវទំនាក់ទំនងនៃកិច្ចសន្យានេះមានកាតព្វកិច្ច និងត្រូវអនុវត្តកិច្ចសន្យានេះឱ្យបានរួចរាល់និងត្រឹមត្រូវ។ បុគ្គលដែលជាអ្នកទិញមានកាតព្វកិច្ចធ្វើការប្រគល់ប្រាក់ អោយទៅបុគ្គលដែលជាអ្នកលក់នូវទំនិញឬសេវានោះ ដើម្បីសម្រេចនូវកម្មវត្ថុនៅក្នុងកិច្ចសន្យាមុនបុគ្គលដែលជាអ្នកលក់ប្រគល់កម្មវត្ថុនៃការលក់មកអោយ។ ការទូទាត់ប្រាក់នៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានវិធីសាស្រ្តខុសគ្នា ក្នុងការទទួលប្រាក់អោយទៅបុគ្គល ដែលជាអ្នកលក់ទំនិញឬសេវា បើទោះបីជាបុគ្គលនោះស្ថិតនៅទីណាក៏ដោយ។ ការទូទាត់ប្រាក់អាចធ្វើឡើងបានតាមរយៈឧបករណ៍ទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក ដែលជាប័ណ្ណ ឬកាតទូទាត់ ឬឧបករណ៍ទូទាត់ទាំងឡាយ ដែលមានទំរង់ជាអេឡិចត្រូនិកហើយមានមុខងារសម្រាប់ទូទាត់ប្រាក់ ឬតាមរយៈឧបករណ៍អេឡិចត្រូនិកចល័ត ឮតាមរយៈឧបករណ៍ទូទាត់ដែលមានមុខងារស្រដៀងគ្នា ដើម្បីបញ្ជាក់ឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុការបង់ពន្ធឬឥណទាន ដូចក្នុងករណីដែលបានលើកឡើងនិងពន្យល់នៅក្នុងកថាខ័ណ្ឌខាងលើ។បន្ទាប់ពីមានការទូទាត់ធ្វើការប្រគល់ប្រាក់ជូនទៅដល់បុគ្គល ដែលជាពាណិជ្ជករដែលបានធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដូចជាការលក់ទំនិញឬសេវារបស់ខ្លួន បុគ្គលដែលជាអ្នកដែលមាន កាតព្វកិច្ចទទួលទំនិញឬសេវា ដែលមានករណីកិច្ចរង់ចាំទទួលនូវទំនិញឬសេវានោះ បន្ទាប់ពីអ្នកលក់បានបញ្ជូនចេញទៅ មានតួនាទីផ្តល់ឬប្រគល់ប្រាក់ជូនទៅបុគ្គលដែលជាពាណិជ្ជករផងដែរ។

**ខ. ការបញ្ជូនចេញ និងការបានទទួល**

បើមានការទូទាត់ ការប្រគល់ប្រាក់ឬផ្ទេរទៅឱ្យបុគ្គលជាអ្នកលក់នូវទំនិញឬសេវារួចហើយ បុគ្គលនោះមានកាតព្វកិច្ចធ្វើការបញ្ជូលនូវទំនិញរបស់ខ្លួន អោយទៅបុគ្គលឬផ្តល់សេវាអោយទៅបុគ្គលដែលជាអ្នកទិញនោះ។ កិច្ចសន្យាពាណិជ្ជកម្ម ដែលភាគីបានព្រមព្រៀងគ្នាបង្កើត ដើម្បីធ្វើពាណិជ្ជកម្មជាមួយគ្នានោះនឹងបញ្ចប់ នៅពេលដែលពាណិជ្ជករដែលជាអ្នកលក់នូវទំនិញឬសេវា ដែលបានបញ្ជូនឱ្យទៅភាគីបានសម្រេច ទៅតាមឆន្ទៈរបស់ភាគីអ្នកបានព្រមព្រៀងគ្នា តាមកិច្ចសន្យានោះ។ អាចរាប់ថាបានបញ្ជូនចេញដោយជោគជ័យ គឺនៅពេលដែលភាគីទំនិញនោះបានទទួលដោយបុគ្គលជាអ្នកទិញនោះ។

ការមកដល់នូវទំនិញឬសេវា មិនថាតាមធ្យោបាយណាមួយ ឬតាមរយៈអន្តរការីហើយបានទៅដល់បុគ្គលដែលជាអ្នកទិញហើយ បុគ្គលទាំងនោះបានទូទាត់ប្រាក់ឬប្រគល់គល់ប្រាក់បានដោយជោគជ័យហើយ នោះទំនាក់ទំនងនៃកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក៏ត្រូវបានបញ្ចប់ដែរ ព្រោះភាគីបានបំពេញនូវកាតព្វកិច្ចឱ្យគ្នាទៅវិញទៅមក រហូតដល់ដំណាក់ការចុងក្រោយនោះហើយ។ ប៉ុន្តែ

បើមានការ កើតឡើងទៅតាមឆន្ទៈរបស់ភាគីដែលនៅតែចង់បន្តទិញនោះទំនាក់ទំនងនៃការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនោះ នឹងនៅតែបន្តកើតមាន រហូតដល់ភាគីព្រមព្រៀងគ្នាបញ្ចប់ ទើបចាត់ទុកថាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនោះត្រូវបានបញ្ចប់ដោយត្រឹមត្រូវ។

នៅក្នុងនោះដែរ សេវាដឹកជញ្ជូនត្រូវបានចូលរួមយ៉ាងសកម្មពីក្រុមហ៊ុនឯកជន ដែលបានបង្កើតឡើងនៅពេលថ្មីៗនេះជាច្រើន ក្រោយពីបាន ប្រគល់ទំនិញឱ្យទៅអ្នកដឹកជញ្ជូនពីអ្នកលក់រួចរាល់ ហើយដំណឹងពេលវេលានៃការមកដល់នៃទំនិញ ការមកដល់យឺតយ៉ាវនៃទំនិញ អតិថិជននឹងទាក់ទងដោយផ្ទាល់ទៅក្រុមហ៊ុនដឹកជញ្ជូននៅក្នុងនោះ។ នៅក្នុងនោះលក្ខខណ្ឌកំណត់របស់ក្រុមហ៊ុនត្រូវបានអនុវត្តដូចជា ការខូចនៃទំនិញ ការដឹកជញ្ជូនទំនិញមានការយឺតយ៉ាវ ករណីគ្មានអ្នកទទួលទំនិញពេលទំនិញមកដល់ជាដើម។ គួរបញ្ជាក់ផងដែរថារយៈពេលនៃដំណាក់កាល ដឹងជញ្ជូនដល់អតិថិជន អតិថិជនអាចតាមដែនទៅលើគេហទំព័ររបស់ក្រុមហ៊ុនដឹកជញ្ជូនដោយដំណាក់កាលនីមួយៗ នៃការដឹកជញ្ជូន ត្រូវបានបញ្ជាក់យ៉ាងច្បាស់លាស់ អំពីពេលពេលវេលាជាក់លាក់នៃការមកដល់នៃទំនិញក៏ត្រូវបានបង្ហាញ។

# ជំពូកទី២

# ក្របខណ្ឌគតិយុត្តិនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នៅកម្ពុជា

# ជំពូកទី២

# ក្របខណ្ឌគតិយុត្តិនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា

នៅក្នុងជំពូកទី២ នេះគឺលើកបង្ហាញអំពី របបគតិយុត្តិទៅលើវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលបង្ហាញអំពីការកំណត់ឡើងនូវបញ្ញត្តិនីមួយៗ ឱ្យសមស្របទៅតាមបរិបទបច្ចុប្បន្ន។ ម្យ៉ាងវិញទៀតវាជួយកាត់បន្ថយវិវាទ និងរក្សាសន្តិសុខសង្គម។ ដូច្នេះទើបយើងលើកយកផ្នែកទាំង ៣ យ៉ាងសំខាន់មកសិក្សា ដោយ**ផ្នែកទី១ ដំណើការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** ដែលសិក្សាទៅលើនិយមន័យ អនុភាពគតិយុត្តិ សារៈសំខាន់ និង របៀបក្នុងការបង្កើតកិច្ចសន្យាទិញលក់តាមប្រព័ន្ធអេឡិចត្រូនិកផងដែរ។ ចំណែកឯ **ផ្នែកទីផ្នែកទី២ ការអនុវត្តនីតិវិធីក្នុងការប្រមូលពន្ធលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** ដែលយើងនឹងធ្វើការពិភាក្សាទៅលើការប្រមូលពន្ធតាមរយៈបរិបទពាណិជ្ជកម្មថ្មីដែលមិនទាន់មានជាការអនុវត្តនូវនីតិវិធីជាក់លាក់នៅឡើយ ប៉ុន្តែវានឹងចូលរួមចំនែកយ៉ាងលើសលប់ក្នុងវិស័យប្រមូលពន្ធនាពេលបច្ចុប្បន្ន និង អនាគតត។ ចំណែកឯ **ផ្នែកទី៣ គឺកិច្ចការពារអ្នកប្រើប្រាស់នៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** សំដៅទៅលើការពារសណ្តាប់ធ្នាប់ ការកើតឡើងនូវបទល្មើសផ្សេងៗ និង ការពារនូវផលប្រយោជន៍គូភាគី ដែលប្រើប្រាស់នូវទំនាក់ទំនងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកផងដែរ។

## ផ្នែកទី១៖ ដំណើការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

នាសម័យបច្ចុប្បន្ន អ៊ិនធឺណែតបានបើកទ្វាឱ្យពិភពលោក និងមនុស្សជាច្រើននៅជុំវិញសកលលោកនូវឱកាសជាច្រើនដែលមិនធ្លាប់មានពីមុនមក។ អ៊ិនធឺណែត គឺជាការបង្ហាញនៃការច្នៃប្រឌិតថ្មីនិងមិនចេះចប់ មិនមានព្រំដែន ដែលនាំមកនូវឱកាសសេដ្ឋកិច្ចយ៉ាងច្រើនសម្រាប់ប្រជាជននៅទូទាំងសកាលលោក។ អ៊ិនធឺណែតអនុញ្ញាតឱ្យមនុស្សមានភាពប្រសើរឡើងនូវគុណភាពជីវិត និងសេដ្ឋកិច្ចក្នុងសង្គម។ ជាពិសេស នៅក្នុងបដិវត្តន៍ឧស្សាហកម្មទី៤ ដែលមានបម្រែបម្រួលយ៉ាងខ្លាំងនៃបដិវត្តន៍ឧស្សាហកម្មមួយនេះបានធ្វើឱ្យពិភពលោក ពឹងផ្អែកទៅលើបច្ចេកវិទ្យាជាចម្បង ដែលគ្រប់គ្រងស្ទើរតែគ្រប់វិស័យ ដើម្បីធ្វើការអភិវឌ្ឍនូវប្រព័ន្ធសេដ្ឋកិច្ចតាមបែបឌីជីថលឬហៅថាសេដ្ឋកិច្ចឌីជីថល និងជាពិសេសការបង្កើតឡើងនូវប្រព័ន្ធអេឡិចត្រូនិក ដែលជាជំហានរីកចម្រើនថ្មី ក្នុងការធ្វើអាជីវកម្មពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមិនថាក្នុង ឬក្រៅប្រទេស ដែលជាហេតុនាំឱ្យយើងសិក្សាទៅលើ៤ កថាខណ្ឌនៃផ្នែកទី ២ នេះ។ **កថាខណ្ឌទី ១ ការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណ** គឺការស្នើសុំនូវអាជ្ញាប័ណ្ណពីក្រសួងពាក់ព័ន្ធដើម្បីទទួលបានការប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកស្របច្បាប់។ **កថាខណ្ឌទី២ គឺ ការបង្កើតពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** សំដៅទៅលើរបៀបដែលធ្វើឱ្យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានសុពលភាព

គតិយុត្តិទៅតាមផ្លូវច្បាប់។ ចំនែកឯ **កថាខណ្ឌទី៣** គឺនិយាយអំពី **ទំនាក់ទំនងប្រតិបត្តិការនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** ដែលពន្យល់អំពី ទំនាក់ទំនង និង ដំណើរប្រតិបត្តិការនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក រវាងភាគីទាំងសងខាង។ ចុងក្រោយកថាខណ្ឌទី ៤ គឺផ្តោតសំខាន់ទៅលើ ការទូទាត់ និង រផ្ទេរប្រាក់ក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលជាផ្នែកសំខាន់ក្នុងប្រតិបត្តិការពាណិជ្ជកម្មនេះ។

### កថាខណ្ឌទី១៖ លក្ខខណ្ឌ និង ការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណ

#### ក. លក្ខខណ្ឌក្នុងការបង្កើតពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ការបង្កើតពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឱ្យសមស្រមទៅតាមលក្ខ័ខ័ណ្ឌ និង តម្រូវការរបស់ប្រទេសនីមួយៗ គឺត្រូវពឹងផ្អែកទៅលើកត្តាជាច្រើន។ នៅពេលដែលច្បាប់នោះ បានទទួលស្គាល់លក្ខណៈគតិយុត្តិហើយ គ្មានបុគ្គលណាម្នាក់ អាចបដិសេធមិនទទួលស្គាល់សុពលភាព អានុភាពគតិយុត្តិ ភាពអាចទទួលយកបាន ដែលអាចយកទៅអនុវត្តបាននៃទំនាក់ទំនងអេឡិចត្រូនិក ដោយគ្រាន់តែសំអាងលើមូលហេតុដែលថាវាធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិក ឬស្ថិតនៅក្នុងទំនាក់ទំនងអេឡិចត្រូនិកឡើយ។[21]

- **លក្ខខណ្ឌតម្រូវជាលាយលក្ខណ៍អក្សរ**

នៅពេលដែលទម្រង់អេឡិចត្រូនិក ឬ ទំនាក់ទំនងអេឡិចត្រូនិកត្រូវបានបង្កើតឡើយ បទប្បញ្ញត្តិណាមួយ តម្រូវឱ្យផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរ ឬធ្វើកំណត់ត្រាជាលាយល័ក្ខណ៍អក្សរត្រូវចាត់ទុកថា លក្ខខណ្ឌតម្រូវនេះត្រូវបានបំពេញរួចរាល់ ប្រសិនបើព័ត៌មាននេះធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិក ឬហៅថាកំណត់ត្រាអេឡិចត្រូនិក ហើយអាចចូលប្រើប្រាស់បាន និងអាចទាញយកទៅប្រើប្រាស់នៅពេលក្រោយបាន។[22] ជាទូទៅ កិច្ចសន្យាទិញលក់មិនតែងតែតម្រូវឱ្យមានជាការលាយល័ក្ខណ៍អក្សរនោះទេ កិច្ចសន្យាទិញលក់អាចធ្វើឡើងដោយផ្ទាល់មាត់បាន។ ដូចគ្នានេះដែរ ការបង្កើតកិច្ចសន្យាទិញលក់តាមប្រព័ន្ធអេឡិចត្រូនិក អាចធ្វើឡើងបានដោយមិនចាំបាច់មានជាលាយល័ក្ខណ៍អក្សរលើក្រដាស់ស្នាមឡើយ ប្រសិនបើគ្មានការតម្រូវ។

- **លក្ខខណ្ឌតម្រូវចំពោះហត្ថលេខា**

នៅពេលដែលមានទំនាក់ទំនងអេឡិចត្រូនិក ណាមួយត្រូវបានកើតឡើងតម្រូវឱ្យមានហត្ថលេខារបស់បុគ្គលណាមួយ ដែលបញ្ជាក់អំពីអត្តសញ្ញាណបុគ្គល ការទទួលខុសត្រូវនឹងរក្សាផលប្រយោជន៍ភាគី

[21] សូមពិគ្រោះ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា នស/រកម/១១១៩/០១៧/, ០២ វិច្ឆិកា ២០១៩, មាត្រា ៥ ។

[22] សូមពិគ្រោះ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា នស/រកម/១១១៩/០១៧/, ០២ វិច្ឆិកា ២០១៩, មាត្រា ៦ កថាខណ្ឌទី១ ។

ទាំងសងខាងពេលមានវិវាទ។[23] លក្ខខណ្ឌតម្រូវនេះត្រូវចាត់ទុកថាបានបំពេញតាមរយៈការចុះហត្ថលេខាអេឡិចត្រូនិកប្រសិនបើ ហត្ថលេខាអេឡិចត្រូនិក ដែលបានឃើញនោះត្រូវបានបង្កើតឡើង តាមមធ្យោបាយដែលច្បាប់បានកំណត់ទុក គឺអាចកំណត់អត្តសញ្ញាណបុគ្គល និងបង្ហាញឯកភាពរបស់បុគ្គលនោះ ទៅលើប្រព័ន្ធព័ត៌មាន ឬកំណត់ត្រា ដែលមាននៅក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះ។ ម្យ៉ាងវិញទៀតអាចជឿទុកចិត្តបានស្របតាមចរិតលក្ខណៈ គោលបំណង និងកាលៈទេសៈ ដែលទំនាក់ទំនងអេឡិចត្រូនិកនោះត្រូវបានបង្កើតឡើងឬត្រូវបានប្រាស្រ័យទាក់ទង។

- **លក្ខខណ្ឌតម្រូវរក្សាព័ត៌មានតាមទម្រង់ដើម**

លក្ខខណ្ឌគតិយុត្តិក្នុងការរក្សាព័ត៌មាន ដែលមិនត្រូវបានធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិកអាចត្រូវបំពេញដោយការរក្សាព័ត៌មាននោះក្រោមទម្រង់អេឡិចត្រូនិក ប្រសិនបើទម្រង់អេឡិចត្រូនិកនោះ ជាមធ្យោបាយ ដែលអាចជឿទុកចិត្តបាន ដើម្បីកំណត់ភាពពេញលេញរបស់ព័ត៌មាននោះ និងព័ត៌មាននោះឯងចូលយកបានដោយងាយស្រួល សម្រាប់យកទៅប្រើប្រាស់បាននៅពេលក្រោយ។[24]

- **ទំរង់បែបបទដែលកំណត់**

នៅពេលដែលបទប្បញ្ញត្តិណាមួយ តម្រូវឱ្យមានព័ត៌មានធ្វើឡើងក្នុងទម្រង់បែបបទណាមួយលក្ខខណ្ឌតម្រូវនោះត្រូវជំនួសដោយការផ្តល់ព័ត៌មានតាមទម្រង់អេឡិចត្រូនិកបាន ប្រសិនបើទម្រង់អេឡិចត្រូនិកនៅត្រូវបានបំពេញលក្ខខណ្ឌទាំងអស់ មានផ្ទុកព័ត៌មានដូចគ្នាឬដូចគ្នាភាគច្រើនទៅនឹងទំរង់បែបបទ ដែលបានកំណត់ដូចជា អាចចូលទៅមើលបាន អាចយល់បាន និងអាចទាញយកប្រើប្រាស់បាននូវពេលវេលាក្រោយ និងអាចឱ្យបុគ្គលដែលទទួលបានព័ត៌មាននោះរក្សាទុកបាន។[25]

- **លក្ខខណ្ឌតម្រូវលើការរក្សាទុកកំណត់ត្រា**

នៅពេលដែលបទប្បញ្ញត្តិណាមួយតម្រូវអោយរក្សាទុកនូវឯកសារ កំណត់ត្រា ឬព័ត៌មានជាក់លាក់ណាមួយ លក្ខខណ្ឌនោះតម្រូវឱ្យចាត់ទុកថាបានបំពេញ ប្រសិនបើការរក្សាទុកនោះបំពេញលក្ខខណ្ឌ ដែលមានដូចជា (១)ព័ត៌មានដែលមាននៅក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះអាចចូលប្រើប្រាស់បាននឹងយកទៅប្រើប្រាស់បាននាពេលអនាគត (២)ទំនាក់ទំនងអេឡិចត្រូនិកត្រូវបានរក្សាទុកក្នុងទម្រង់ដើមដែលត្រូវ

[23] សូមពិគ្រោះ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា នស/រកម/១១១៩/០១៧/, ០២ វិច្ឆិកា ២០១៩, មាត្រា ៧។

[24] សូមពិគ្រោះ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា នស/រកម/១១១៩/០១៧/, ០២ វិច្ឆិកា ២០១៩, មាត្រា ៨។

[25] សូមពិគ្រោះ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា នស/រកម/១១១៩/០១៧/, ០២ វិច្ឆិកា ២០១៩, មាត្រា ៩។

បានបង្កើតឡើងផ្ញើឬទទួលបានឬក្នុងទម្រង់ ដែលអាចត្រូវបាន បង្ហាញពីសុក្រឹតភាពនៃព័ត៌មាននោះ (៣) ព័ត៌មានទាំងនោះត្រូវរក្សាទុកដើម្បីឱ្យបុគ្គលណាម្នាក់ អាចកំណត់បាននូវប្រភពដើមនិងគោលដៅនៃទំនាក់ទំនងអេឡិចត្រូនិកនោះ កាលបរិច្ឆេទ និងពេលវេលាដែលទំនាក់ទំនងអេឡិចត្រូនិកត្រូវបានផ្ញើឬទទួល។[26]

- **លក្ខខណ្ឌតម្រូវស្តីពីភស្តុតាង**

គ្មានបទប្បញ្ញត្តិណាមួយក្នុងការអនុវត្តវិធានស្តីពីផុសតាងអាចជំនួសការយកទំនាក់ទំនងអេឡិចត្រូនិកជាភស្តុតាង ដោយគ្រាន់តែឈរលើមូលដ្ឋាន ដែលថាភស្តុតាងនៅជាទំនាក់ទំនងអេឡិចត្រូនិក ឬភស្តុតាងមិនស្ថិតក្នុងទម្រង់ដើម។[27] ចំនុចនេះបានបើកទូលាយឱ្យទទួលយកនូវកំណត់ត្រាអេឡិចត្រូនិកដើម្បីជាភស្តុតាងស្របច្បាប់ដែលអាចប្រើប្រាស់បានដូចទៅនឹងភស្តុតាងផ្សេងផងដែរ។ យ៉ាងណាមិញនាពេលបច្ចុប្បន្ននេះនៅកម្ពុជាពុំទាន់មានច្បាប់ដាច់ដោយឡែកដែលអនុញ្ញាតយ៉ាងច្បាស់លាស់នូវភាពអាចទទួលយកបាននៃភស្តុតាងអេឡិចត្រូនិកនៅក្នុងតុលាការកម្ពុជា ឬក្នុងចំណាត់ការរដ្ឋបាល ឬនិយ័តកម្មទេ។ ប៉ុន្តែ ការអនុវត្តរបស់តុលាការគឺទទួលយកភស្តុតាងអេឡិចត្រូនិកតាមវិធីដូចគ្នានិងយោងតាមវិធានដូចគ្នា ដែលអនុវត្តលើប្រភេទឯកសារភស្តុតាងផ្សេងទៀត-យោងតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ។ មួយវិញផងដែរ តាមរយៈការបកស្រាយតាមបញ្ញត្តិនេះ យើងអាចយកផស្តុតាងអេឡិចត្រូនិកមកអនុវត្ត នៅក្រោមគោលការណ៍ភស្តុតាងនៃក្រមនីតិវិធីរដ្ឋប្បវេណីផងដែរ។ ឧទាហរណ៍ កិច្ចសន្យាទិញលក់ជាក្រដាស់ ចាត់ចូលជាភស្តុតាងផ្ទាល់ ឬប្រយោល ដូចនេះកំណត់ត្រាអេឡិចត្រូនិកក៏មានសុពលភាពជាភស្តុតាងស្របច្បាប់ដូចគ្នាទៅនឹងកិច្ចសន្យាទិញលក់ជាក្រដាស់។

### ខ. ការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណ

អន្តរការី និងបុគ្គលផ្តល់សេវាកម្មពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវស្នើសុំការអនុញ្ញាតឬអាជ្ញាប័ណ្ណពីក្រសួងពាក់ព័ន្ធក្រសួងពាណិជ្ជកម្ម និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ ក្រសួងពាណិជ្ជកម្មផ្តល់លិខិតអនុញ្ញាតឬអាជ្ញាប័ណ្ណរួមមាន (១)លិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់រូបវន្តបុគ្គល (២)អាជ្ញាបណ្ណឱ្យប្រតិបត្តិការផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក សម្រាប់នីតិបុគ្គល។[28] ចំណែកឯក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ផ្តល់ (១)វិញ្ញាបនបត្រសេវា

[26] សូមពិគ្រោះ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា នស/រកម/១១១៩/០១៧/, ០២ វិច្ឆិកា ២០១៩, មាត្រា ១០។

[27] សូមពិគ្រោះ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា នស/រកម/១១១៩/០១៧/, ០២ វិច្ឆិកា ២០១៩, មាត្រា ១១។

[28] សូមពិគ្រោះ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា នស/រកម/១១១៩/០១៧/, ០២ វិច្ឆិកា ២០១៩, មាត្រា ២៦។

អនឡាញ (២)ការលើកលែង ការកំណត់ប្រភេទអាជ្ញាបណ្ណ បែបបទ និងនីតិវិធីនៃការផ្តល់ការអនុញ្ញាតឬអាជ្ញាបណ្ណដែលកំណត់ដោយអនុក្រឹត្យ។[29]

ការទទួលស្គាល់ទំនាក់ទំនងអេឡិចត្រូនិកដោយក្រសួងស្ថាប័នរដ្ឋ អាចជានាប្រើប្រាស់ទម្រង់អេឡិចត្រូនិកសម្រាប់សកម្មភាពនិងប្រតិបត្តិការដូចជា ការទទួលចុះបញ្ជីឯកសារឬការបំពេញលក្ខខណ្ឌតម្រូវសម្រាប់បង្កើត ឬរក្សាទុកឯកសារ ការចេញអាជ្ញាប័ណ្ណឬលិខិតអនុញ្ញាត ការកំណត់មធ្យោបាយនិងរបៀបក្នុងការទូទាត់ប្រាក់ ឬនៅពេលដែលក្រសួងឬសកម្មភាពផ្សេងទៀតដែលកំណត់ដោយក្រសួងឬស្ថាប័នរដ្ឋ។ នៅពេលដែលក្រសួង ឬស្ថាប័នរដ្ឋសម្រេចប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិក សម្រាប់សកម្មភាពឬប្រតិបត្តិការណាមួយ ក្រសួងឬស្ថាប័ននោះអាចបញ្ជាក់ របៀបនិងទម្រង់ដែលព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិក ត្រូវទទួលចុះបញ្ជីបង្កើតរក្សាទុកឬបោះពុម្ពផ្សាយ។ ប្រភេទនៃហត្ថលេខាដែលតម្រូវឱ្យធ្វើនៅពេលដែលមានការតម្រូវឱ្យចុះហត្ថលេខាក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះ។ របៀបនិងទម្រង់ ដែលហត្ថលេខានោះត្រូវភ្ជាប់ក្នុងទំនាក់ទំនងអេឡិចត្រូនិក។ ដំណើរការគ្រប់គ្រងនីតិវិធីដែលសមស្របដើម្បីធានាសុខភាពសុវត្ថិភាពនិងការរក្សាការសម្ងាត់នៃទំនាក់ទំនងអេឡិចត្រូនិក ឬការទទួលប្រាក់និងលក្ខខណ្ឌកំណត់ផ្សេងទៀត ដែលផ្តល់តម្លៃសមមូលរវាងឯកសារឬការទូទាត់ក្នុងទម្រង់អេឡិចត្រូនិកជាមួយនឹងឯកសារឬការទូទាត់ក្នុងទំរង់ជាលាយលក្ខណ៍អក្សរ។[30]

មិនត្រឹមតែប៉ុណ្ណោះបច្ចុប្បន្ននេះ អគ្គនាយកដ្ឋានពន្ធដារ បានធ្វើទំនើបនីយកម្មយ៉ាងច្រើនលើរដ្ឋបាលសារពើពន្ធដោយបានផ្តល់នូវសេវាកម្មដែលមានសុវត្ថភាព គុណភាព និងភាពងាយស្រួលដូចជា ការចុះបញ្ជីពន្ធដារតាមប្រព័ន្ធអេឡិចត្រូនិក ការបង្វិលសងអាករលើតម្លៃបន្ថែមតាមប្រព័ន្ធអេឡិចត្រូនិក ការស្នើសុំការចៀសវាងការយកពន្ធត្រួតគ្នា (DTA )តាមប្រព័ន្ធអេឡិចត្រូនិក ការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ការដាក់លិខិតប្រកាស់តាមប្រព័ន្ធអេឡិចត្រូនិក (ដាក់ចេញនៅឆ្នាំ២០២០) ផ្នែកសេវាកម្មអតិថិជន (Call Center 1277 GDT និង Live Chat) កម្មវិធីផ្សាយផ្ទាល់(Facebook Live) របស់អគ្គនាយកដ្ឋានពន្ធដារ និងការផ្សព្វផ្សាយតាមរយៈការធ្វើសិក្ខាសាលាដល់អ្នកជាប់ពន្ធ ជាពិសេសអ្នកជាប់ពន្ធតូច និងមធ្យមទូទាំងប្រទេស។ល។[31]

[29] សូមពិគ្រោះ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា នស/រកម/១១១៩/០១៧/, ០២ វិច្ឆិកា ២០១៩, មាត្រា ២៦។

[30] សូមពិគ្រោះ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា នស/រកម/១១១៩/០១៧/, ០២ វិច្ឆិកា ២០១៩, មាត្រា ៤៧។

[31] ក្រសួងពាណិជ្ជកម្ម.(២៥ វិច្ឆិកា ២០២០). *យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក*,២៣។

## កថាខណ្ឌទី២៖ កិច្ចសន្យាទិញលក់តាមប្រព័ន្ធអេឡិចត្រូនិក

### ក. ការអនុវត្តកិច្ចសន្យាអេឡិចត្រូនិក

កិច្ចសន្យាអេឡិចត្រូនិកគឺ ជាការបង្កើតនូវការព្រមព្រៀងរវាងគូភាគី ក្រោមកម្មវត្ថុណាមួយជាក់លាក់ ដែលធ្វើឡើងក្រោមទម្រង់អេឡិចត្រូនិក។[32] ក្នុងនោះ សារអេឡិចត្រូនិក ឬអ៊ីមែលបានក្លាយជាមធ្យោបាយទំនាក់ទំនងដ៏ងាយស្រួល រហ័ស និងដ៏ពេញនិយមទាំងសំរាប់ទំនាក់ទំនងឯកជនផ្ទាល់ខ្លួនទាំងសំរាប់ទំនាក់ទំនងវិជ្ជាជីវៈ និងរហូតអាចក្លាយជាមធ្យោបាយក្នុងការចុះកិច្ចសន្យាផងដែរ។ មិនខុសពីសារអេឡិចត្រូនិក ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបច្ចុប្បន្នមានរួមចំណែកក្នុង ការបង្កើតនូវកិច្ចសន្យាទិញលក់តាមប្រព័ន្ធអេឡិចត្រូនិក។ កិច្ចសន្យាទិញលក់នៅកម្ពុជាមានច្រើនប្រភេទដូចជា កិច្ចសន្យាទិញលក់អចលនវត្ថុ កិច្ចសន្យាទិញលក់ទំនិញ កិច្ចសន្យាកក់ប្រាក់ កិច្ចសន្យាជួល កិច្ចសន្យាហ៊ីប៉ូតែកនានា។ បើទោះបីនាពេលបច្ចុប្បន្ននេះ បច្ចេកវិទ្យាកំពុងមានភាពជុះដាលក៏ពិតក្ដី ប្រភេទនៃកិច្ចសន្យាទាំងអស់នេះមិនទាន់អាចអនុវត្តតាមទម្រង់អេឡិចត្រូនិកនៅឡើយទេ ព្រោះវាមានលក្ខណៈថ្មីសម្រាប់ប្រជាជនកម្ពុជាក្នុងការទទួលស្គាល់សុពលភាព និងទំនុកចិត្ត។ កម្ពុជាមិនទាន់មានច្បាប់សម្រាប់គ្រប់គ្រងនូវកិច្ចសន្យាអេឡិចត្រូនិកនៅឡើយទេ សូម្បីតែនៅប្រទេសអភិវឌ្ឍន៍មួយចំនួនក៏ប្រភេទនៃកិច្ចសន្យាខ្លះ មិនមានសុពលភាពធ្វើឡើងតាមរយៈអេឡិចត្រូនិកដែរ ដូចជាកិច្ចសន្យាហ៊ីប៉ូតែក លិខិតតំណាងឱ្យអាណត្តិ ។ល។ ជាទូទៅ កិច្ចសន្យា ដែលមានហានិភ័យខ្ពស់ ឬមានផលប៉ះពាល់ខ្លាំងដល់សិទ្ធនិងកាតព្វកិច្ចរបស់រូបវ័ន្តបុគ្គល ឬ សណ្ដាប់ធ្នាប់សារធារណៈ គឺមិនអាចធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិកឡើយ។[33] ចំនែកនៅកម្ពុជា កិច្ចសន្យាទិញលក់តាមប្រព័ន្ធអេឡិចត្រូនិកគឺសំដៅលើប្រតិបត្តិការទិញលក់តាមរយៈអនឡាញ ដែលជាការទិញលក់មានលក្ខណៈធម្មតា និងសមញ្ញទៅលើវត្ថុប្រើប្រាស់ ឬសេវាប្រចាំថ្ងៃដែលមិនមានតម្លៃមិនច្រើនលើសលុប។ ឧទាហរណ៏ អ្នកទិញបានចុចប៊ូតុង (Click) ទិញទំនិញ ឬម្ហូបអាហារតាមរយៈម៉ូបាល់អេបផ្សារអ៊ីអន (Aeon mall Mobile App) រួចបានព្រមព្រៀងថាប្រាកដជាទិញទំនិញទាំងនោះតាមការទូទាត់បង់ប្រាក់តាមរយៈសេវាកម្មធនាគារ។ កិច្ចសន្យាទិញលក់លក្ខណៈទូទៅដែលមិនចាំបាច់មានជាលាយល័ក្ខណ៏អក្សរលើក្រដាស់ស្នាមឡើយ ក៏ប៉ុន្តែវេបសាយលក់ទំនិញទាំងនោះមានជាលក្ខណ្ឌ (Term and Condition) ដើម្បីឱ្យអ្នកទិញបានដឹងមុន និងយល់ព្រមបង់ប្រាក់ និងទទួលទំនិញជាដើម។

---

[32] អេឡិចត្រូនិក សំដៅដល់អ្វីដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យាដែលមានចរន្តអគ្គិសនីឌីជីថល ម៉ាញេទិច ជីវមាត្រ អេឡិចត្រូគីមី វ៉ាយអឺឡេស អេឡិចត្រូម៉ាញេទិក ឬបច្ចេកវិទ្យាដែលមានមុខងារប្រហាក់ប្រហែលផ្សេងទៀត។

[33] Dr Yassin Ahmad A.&Dr Raed Mohammad F.(2021). The legal Nature of the Electronic Contract ( Comparative Study) [សារជាតិគតិយុត្តិនៃកិច្ចសន្យាតាមប្រព័ន្ធអេឡិចត្រូនិក]. *PSYCHOLOGY AND EDUCATION ៥៨*(១)៖២២៦០-២២៧៦។

**ខ. ការបង្ហាញឆន្ទៈរបស់ភាគី**

នៅក្នុងច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមិនបាន បញ្ជាក់នូវនិយមន័យ នៃការបង្ហាញឆន្ទៈនោះទេ។ ក៏ប៉ុន្តែ ការធ្វើពាណិជ្ជកម្មជាសកម្មភាពឯកជនដែលរាប់បញ្ចូលក្រោមក្រមរដ្ឋប្បវេណី។ ដូចនេះយើងអាចសិក្សាលើនិយមន័យនៃការបង្ហាញឆន្ទៈតាមរយៈមាត្រា ៣៣១ នៃក្រមរដ្ឋប្បវេណី។ មាត្រា ៣១១ នៃក្រមរដ្ឋប្បវេណីបានចែងថា កិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬ ច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើតកែប្រែ ឬរំលត់នូវកាតព្វកិច្ច។ ការបង្ហាញឆន្ទៈ គឺភាគីមានគោលបំណងបង្កើតអានុភាពគតិយុត្តិ។[34] ការបង្ហាញឆន្ទៈត្រូវមានអានុភាពចាប់ពីពេលដែលការជូនដំណឹងអំពីការបង្ហាញឆន្ទៈនោះបានទៅដល់ភាគីម្ខាងទៀត។[35] ការបង្ហាញឆន្ទៈនឹងមិនមានអានុភាពឡើយប្រសិនបើការបង្ហាញឆន្ទៈនោះមានវិការៈ។ វិការៈនៃការបង្ហាញឆន្ទៈរួមមាន ការភាន់ច្រលំ ការឆបោក ការផ្ដល់ព័ត៌មានមិនពិត ការរំលោភបំពានលើស្ថានភាព ការគម្រាមកំហែង អំពើកេងយកចំណេញហួសហេតុ ឋបនីយផ្លូវចិត្ត ការបង្ហាញឆន្ទៈមិនពិត ភាពខុសច្បាប់ ឬភាពផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ និង អលទ្ធភាពតាំងពីដំបូង ។[36] នៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ការភាន់ច្រលំ និង ការផ្ដល់ព័ត៌មានមិនពិតគឺជាវិការៈនៃការបង្ហាញកិច្ចសន្យាដែលកើតឡើងជាញឹកញាប់។[37] ជាសារជាតិទូទៅនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ ទំនិញគឺត្រូវបានដាក់លក់នៅក្នុងថ្នាលបច្ចេកវិទ្យាមួយដែល អ្នកទិញមិនអាចដឹងពីព័ត៌មានដូចជា គុណភាព រូបរាង បរិមាណ ដោយការប៉ះពាល់ ឬ មើលឃើញនឹងភ្នែកផ្ទាល់ឡើយ។ ដូចនេះហើយប្រតិបត្តិការទិញ លក់នេះតែងតែជួបប្រទះនូវការប៉ាន់ស្មានខុសពីអ្វីដែលអ្នកទិញបានរំពឹងទុកជាមុន និងការផ្ដល់ព័ត៌មានមិនពិតពីអ្នកលក់តាមវិធីសាស្ត្រផ្សព្វផ្សាយផលិតផលរបស់ខ្លួនខុសពីជាក់ស្ដែង។[38] ឧទាហរណ៍ អ្នកទិញទំនិញនៅតាមវេបសាយ AMAZON ជាច្រើនបានធ្វើការមិនពេញចិត្តទៅលើ

---

[34] គណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនទទួលបន្ទុកលើការរៀបចំសេចក្ដីព្រាងក្រមក្រមរដ្ឋប្បវេណីគន្លឹនៃក្រសួងយុត្តិធម៌.(២០១០). *សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី*,ភាគ២: គន្លឹ៥,៤៧។

[35] សូមពិគ្រោះ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,នស/រកម/១២០៧/០៣០/, ២១ វិច្ឆិកា ឆ្នាំ ២០០៧, មាត្រា ៣១០

[36] សូមពិគ្រោះ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,នស/រកម/១២០៧/០៣០/, ២១ វិច្ឆិកា ឆ្នាំ ២០០៧,មាត្រា ៣៤៦-៣៥៥

[37] បកប្រែពី Dr. Padmalatha.(២០២០). E-Commerce Frauds and the role of fraud Detection Tools in managing the risks associated with the frauds [ការឆបោកក្នុងពាណិជ្ជកម្មអេឡិចត្រូនិក និងតួនាទីក្នុងការស្វែងរកវិធានការគ្រប់គ្រងហានិភ័យដែលអាចកើតមាន]. *International Journal of Advanced Science and Technology, 29* (4s) 38-46.

[38] បកប្រែពី Dr. Padmalatha.(២០២០). E-Commerce Frauds and the role of fraud Detection Tools in managing the risks associated with the frauds [ការឆបោកក្នុងពាណិជ្ជកម្មអេឡិចត្រូនិក និងតួនាទីក្នុងការស្វែងរក

ទំនិញរបស់ពួកគេ ក្រោយពីទទួល ព្រោះមានលក្ខណៈខុសពីទំនិញដែលពួកគេបានរំពឹងទុកនៅពេលមើលតាមការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធើណេត។

### កថាខណ្ឌទី៣៖ ការបង្កើតពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

#### ក. ការបង្កើតកិច្ចសន្យានាំឱ្យមានសុពលភាព

សំណើ និង ស្វីការ នាំឱ្យមានកិច្ចសន្យាដែលអាចធ្វើឡើងតាមមធ្យោបាយអេឡិចត្រូនិកបាន។ ដូចគ្នាទៅនឹងកិច្ចសន្យាទូទៅដែរ កិច្ចសន្យាមួយមានអានុភាពដោយសារសំណើ និង ស្វីការត្រូវគ្នា។ កិច្ចសន្យាក្នុងទម្រង់អេឡិចត្រូនិក មានអនុភាពគតិយុត្តិ និងអាចអនុវត្តបាននៅពេលដែលសំណើ និងស្វីការត្រូវគ្នា។ នៅត្រង់ចំនុចនេះ កិច្ចសន្យាពាណិជ្ជកម្មដែលធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិក គឺមានលក្ខណៈគតិយុត្តិដូចទៅនឹងកិច្ចសន្យាទូទៅផងដែរ គឺភាគីនៃកិច្ចសន្យាអាចអនុវត្តគោលការណ៍សេរីភាពក្នុងការបង្កើតកិច្ចសន្យា ហើយក្រៅពីការព្រមព្រៀងនោះ ច្បាប់មិនតម្រូវឱ្យមានល័ក្ខខ័ណ្ឌផ្សេងទៀតទេ។[39] នៅក្នុងប្រតិបត្តិការតាមប្រព្ធ័អេឡិចត្រូនិក ការព្រមព្រៀងរវាងភាគីអ្នកលក់ និង អ្នកទិញគឺអាចធ្វើឡើងបានតាមរយៈប្រព័ន្ធអេឡិចត្រូនិកបាន។[40] នៅក្នុងន័យនេះ គ្មានបុគ្គលណាអាចបដិសេដមិនទទួលស្គាល់អានុភាពគតិយុត្តិនៃការព្រមព្រៀង ឬអនុវត្តប្រតិបត្តិការពាណិជ្ជកម្មដោយសំអាងពីមូលហេតុដែលវាកើតចេញពីប្រព័ន្ធអេឡិចត្រូនិកនោះឡើយ។[41]

ដូចទៅនឹងពាណិជ្ជកម្មទូទៅផងដែរ អ្នកទិញនៅក្នុងប្រព័ន្ធអេឡិចត្រូនិកគឺ ជាអ្នកធ្វើសំណើរដើម្បីស្នើរសុំបង្កើតកិច្ចសន្យាដោយមានឆន្ទៈត្រឹមត្រូវ។ ចំនែកឯអ្នកលក់គឺជាអ្នកធ្វើស្វីការនៅក្នុងការទទួលយកសំណើរដែលបានផ្តល់ដោយអ្នកធ្វើសំណើរ។ ដូចគ្នានេះផងដែរ ប្រសិនបើអ្នកលក់ជាអ្នកស្នើរឱ្យអ្នកទិញជាវនូវទំនិញរបស់ខ្លួនវិញ អ្នកលក់នៅត្រង់ចំនុចនេះនឹងក្លាយទៅជាអ្នកផ្តល់សំណើរ រីឯអ្នកទិញនឹងក្លាយជាអ្នកធ្វើស្វីការវិញ។[42] ដោយឡែក នៅពេលដែលភាគីណាម្ខាងធ្វើការតថ្លៃទៅលើ សំណើរនោះវាចាត់ទុក

---

វិធានការគ្រប់គ្រងហានិភ័យដែលអាចកើតមាន]. *International Journal of Advanced Science and Technology, 29* (4s) 38-46.

[39] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនទទួលបន្ទុកលើការរៀបចំសេចក្តីព្រាងក្រមក្រមរដ្ឋប្បវេណីគន្លឹនៃក្រសួងយុត្តិធម៌.(២០១០). *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី*,ភាគ២: គន្លឹ៤,៣៥។

[40] សូមពិគ្រោះ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា នស/រកម/១១១៩/០១៧/, ០២ វិច្ឆិកា ២០១៩, មាត្រា ៥ ។

[41] សូមពិគ្រោះ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា នស/រកម/១១១៩/០១៧/, ០២ វិច្ឆិកា ២០១៩, មាត្រា ១៦ ។

[42] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនទទួលបន្ទុកលើការរៀបចំសេចក្តីព្រាងក្រមក្រមរដ្ឋប្បវេណីគន្លឹនៃក្រសួងយុត្តិធម៌.(២០១០). *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី*,ភាគ២: គន្លឹ៤, ៣៥។

ថាជាការធ្វើសំណើរថ្មីបកទៅកាន់សំណើរចាស់។ នៅត្រង់ន័យនេះ អ្នកធ្វើសំណើរក្លាយជាអ្នកធ្វើស្វីការ រីឯអ្នកធ្វើស្វីការក្លាយជាអ្នកធ្វើសំណើរវិញ ដែលហៅថា ស្វីការដែលមានបន្ថែមការកែប្រែ។

រាល់ការស្នើសុំធ្វើកិច្ចសន្យាតាមរយៈទំនាក់ទំនងអេឡិចត្រូនិកដែលមិនសំដៅដល់បុគ្គលណាមួយជាក់លាក់ផ្សេងទៀត ត្រូវបានចាត់ទុកថាជាការអញ្ជើញឱ្យធ្វើសំណើបង្កើតកិច្ចសន្យាតែប៉ុណ្ណោះ។ នៅត្រង់ចំនុចនេះ ការដាក់លក់បង្ហាញផលិតផលនៅក្នុងវេបសាយលក់ផលិតផល ឬ ការផ្សព្វផ្សាយពាណិជ្ជកម្មលក់ទំនិញនៅតាមប្រព័ន្ធអេឡិចត្រូនិក គឺមិនមែនជាការផ្តល់សំណើរនោះទេ។[43]ការកំណត់បែបនេះ ជាការអនុវត្តផ្ទាល់នៅក្នុងបរិបទពាណិជ្ជកម្មទូទៅ ជាពិសេសពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះឯងដែលមានការដាក់តាំងលក់ព្រមទាំងផ្សព្វផ្សាយនូវផលិតផលតាមថ្នាលបច្ចេកវិទ្យាអនឡាញ (Online Platform) ឬការដាក់លក់តាមរយៈបណ្តាញទំនាក់ទំនងសង្គមនានា ដើម្បីផ្តល់ជាព័ត៌មានទៅកាន់អ្នកទិញ។ អ្នកលក់មិនមានឆន្ទៈថានឹងផ្តល់សំណើរលក់ផលិតផលរបស់ខ្លួននោះទេ។ ចំណងគតិយុត្តិនៅក្នុងចំនុចនេះ មិនអាចកើតមានឡើយដោយហេតុ ការអញ្ជើញឱ្យធ្វើសំណើមិនមែនជាសំណើរពេញលេញសម្រាប់ការបង្កើតកិច្ចសន្យាបាននោះទេ។[44] ក្នុងករណីនេះ ការឆ្លើយតបទៅនឹងការផ្សាយពាណិជ្ជកម្ម គឺជាសំណើ ហើយអ្នកផ្សាយពាណិជ្ជកម្មភាគច្រើនដែលជាអ្នកលក់ អាចធ្វើការជ្រើសរើសក្នុងការធ្វើស្វីការតបទៅនឹងសំណើទាំងនោះ។[45]

ផ្ទុយទៅវិញ ការស្នើសុំចុះកិច្ចសន្យានោះនឹងត្រូវចាត់ទុកថា ជាសំណើបង្កើតកិច្ចសន្យា ប្រសិនបើការស្នើសុំនោះបានបង្ហាញឱ្យឃើញច្បាស់ពីឆន្ទៈរបស់ខ្លួនថានឹងត្រូវជាប់កាតព្វកិច្ចនៅពេលមានស្វីការពីភាគីម្ខាងទៀត។[46] ការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិសម្រាប់បង្កើតកិច្ចសន្យា កិច្ចសន្យាដែលបង្កើតឡើងដោយអន្តរកម្មរវាងប្រព័ន្ធស្វ័យប្រវត្តិនៃបុគ្គលមួយ ជាមួយនឹងរូបវន្តបុគ្គលណាមួយ ឬជាមួយនឹងប្រព័ន្ធស្វ័យប្រវត្តិនៃបុគ្គលផ្សេងទៀត មិនអាចត្រូវបានបដិសេធអំពីសុពលភាព អនុភាពគតិយុត្តិ ឬភាពដែល

[43] គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និង តុលាការ ដំណាក់កាលទី៤របស់ក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA). (២០១៥, ខែធ្នូ). *មេរៀនស្តីពីក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី*, ភាគ១, ១៩។

[44] គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និង តុលាការ ដំណាក់កាលទី៤របស់ក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA). (២០១៥, ខែធ្នូ). *មេរៀនស្តីពីក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី*, ភាគ១, ១៩។

[45] គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និង តុលាការ ដំណាក់កាលទី៤របស់ក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA). (២០១៥, ខែធ្នូ). *មេរៀនស្តីពីក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី*, ភាគ១, ១៩។

[46] សូមពិគ្រោះ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា នស/រកម/១១១៩/០១៧/, ០២ វិច្ឆិកា ២០១៩, មាត្រា ១៦ ។

អាចអនុវត្តបាននូវការសន្យានឹងឡើយ ដោយសំអាងលើហេតុផលអវត្តមាននៃរូបវន្តបុគ្គល ក្នុងការពិនិត្យឬក្នុងការធ្វើសកម្មភាពដោយផ្ទាល់ក្នុងប្រព័ន្ធស្វ័យប្រវត្តិ ឬក្នុងការបង្កើតកិច្ចសន្យា។[47]

ស្វីការក្នុងការបង្កើតកិច្ចសន្យា គឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើរយល់ព្រមសំពោះសំណើនោះ។[48] ស្វីការមានអានុភាពនៅពេលដែលស្វីការនោះបានទៅដល់អ្នកស្នើ។[49] នៅក្នុងករណីនេះស្វីការនឹងលែងមានអនុភាពប្រសិនបើដំណឹងពីការដកស្វីការបានមកដល់ស្របពេលដែលស្វីការបានទៅដល់អ្នកធ្វើសំណើរ។[50] ការបញ្ជូនចេញ និងការទទួលយកសារអេឡិចត្រូនិក ឬសារទំនាក់ទំនងនេះគឺបានបកស្រាយរួចរាល់នៅក្នុងជំពូក១ ផ្នែកទី២ កថាខ័ណ្ឌទី១ រួចរាល់។

### ខ. កំហុសឆ្គងនៃការបញ្ចូលព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិក

នៅពេល ដែលបុគ្គលបញ្ចូលព័ត៌មានខុសនៅក្នុងទំនាក់ទំនងអេឡិចត្រូនិកជាមួយប្រព័ន្ធស្វ័យប្រវត្តិរបស់ភាគីម្ខាងទៀត ហើយប្រព័ន្ធស្វ័យប្រវត្តនេះមិនផ្តល់ឱកាសឱ្យបុគ្គលនោះធ្វើការកែប្រែនូវព័ត៌មាន ដែលខុសនោះទេ។ បុគ្គលឬភាគីជំនួសមុខឱ្យបុគ្គលដែលផ្តល់ព័ត៌មាននោះ មានសិទ្ធិកែតម្រូវឬដកចេញនូវព័ត៌មានដែលខុសនោះបានក្នុងករណី បុគ្គលមកបានជូនដំណឹងទៅភាគីម្ខាងទៀតអំពីកំហុសដែលបានកើតឡើងឱ្យបានឆាប់បំផុតហើយត្រូវបង្ហាញថាខ្លួនបានបញ្ចូលព័ត៌មានខុសទៅក្នុងទំនាក់ទំនងអេឡិចត្រូនិក។ បុគ្គលនោះផងដែរមិនទទួលបានផលប្រយោជន៍ណាមួយដោយសារការបញ្ចូលព័ត៌មានខុសនេះ មុនពេលដែលខ្លួនធ្វើការជូនដំណឹងទៅឱ្យភាគីម្ខាងទៀត ហើយមិនបង្កការខូចខាតដល់ប្រយោជន៍របស់ភាគីម្ខាងទៀតឬតតិយជន។[51] ការកំនត់បែបនេះ គឺចង់ការពារសិទ្ធរបស់ភាគីក្នុងការបង្ហាញឆន្ទៈពិតប្រាកដរបស់ខ្លួន។ ការបង្កើតកំហុសឆ្គងមិនអាចរារាំងការបង្ហាញឆន្ទៈរបស់ភាគីបានឡើយ បើកាលណាកំហុសឆ្គងនោះកើតឡើងដោយគ្មានចេតនា។

---

[47] សូមពិគ្រោះ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា នស/រកម/១១១៩/០១៧/, ០២ វិច្ឆិកា ២០១៩, មាត្រា ១៧ ។

[48] សូមពិគ្រោះ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,នស/រកម/១២០៧/០៣០/, ២១ វិច្ឆិកា ឆ្នាំ ២០០៧, មាត្រា៦៦៧ ។

[49] សូមពិគ្រោះ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,នស/រកម/១២០៧/០៣០/, ២១ វិច្ឆិកា ឆ្នាំ ២០០៧, មាត្រា 340 ។

[50] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនទទួលបន្ទុកលើការរៀបចំសេចក្តីព្រាងក្រមក្រមរដ្ឋប្បវេណីគន្លឹនៃក្រសួងយុត្តិធម៌.(២០១០). *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី*,ភាគ២: គន្លឹ៥, ៣៥។

[51] សូមពិគ្រោះ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា នស/រកម/១១១៩/០១៧/, ០២ វិច្ឆិកា ២០១៩, មាត្រា ១៨ ។

## កថាខណ្ឌទី៤៖ ហត្ថលេខាអេឡិចត្រូនិក

### ក. ប្រតិបត្តិការហត្ថលេខាអេឡិចត្រូនិក

នៅក្រោមច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ហត្ថលេខាអេឡិចត្រូនិកសំដៅដល់រាល់ហត្ថលេខាដែលត្រូវបានបង្កើតឡើងតាមមធ្យាបាយអេឡិចត្រូនិកសម្រាប់ប្រើប្រាស់កំណត់អត្តសញ្ញាណរបស់ហត្ថលេខីដែលរួមមានហត្ថលេខាឌីជីថល ហត្ថលេខាជីវមាត្រ និង ហត្ថលេខាដ៏ទៃទៀត។[52] បើជានិយមន័យបែបបច្ចេកទេស ហត្ថលេខាអេឡិចត្រូនិក ឬហត្ថលេខាឌីជីថលខុសពីការចុះហត្ថលេខាដោយផ្ទាល់ដៃ ដែលតម្រូវអោយអ្នកចុះហត្ថលេខា លើក្រដាសលិខិត។ ហត្ថលេខាអេឡិចត្រូនិកគ្មានរូបរាងឡើយ វាគឺជាកូដ (Hashing Algorithm )។

នៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកវាជា ការចាំបាច់ដែលត្រូវមានហត្ថលេខាភ្ជាប់មកជាមួយចំពោះប្រតិបត្តិការដែលតម្រូវឱ្យមានហត្ថលេខាភ្ជាប់មកជាមួយ ព្រោះប្រតិបត្តិការនេះមិនមានលក្ខណៈផ្ទាល់។ ដោយនៅក្រោមគោលការណ៏ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក បានបញ្ជាក់យ៉ាងច្បាស់ពីអនុភាពគតិយុត្តិនៃទំនាក់ទំនងប្រតិបត្តិការនេះ ដែលគ្មានការបដិសេធឬការលើកឡើងដោយមិនទទួលស្គាល់សុពលភាពដោយគ្រាន់តែផ្អែកលើមូលហេតុដែលវាបានបង្កើតឡើងតាមទម្រង់អេឡិចត្រូនិក ដូចនេះហត្ថលេខាអេឡិចត្រូនិកនឹងប្រើប្រាស់បានទៅលើកិច្ចសន្យាអេឡិចត្រូនិកដូចគ្នា។ ប្រព័ន្ធគតិយុត្តិសំរាប់ប្រតិបត្តិការ និងហត្ថលេខាអេឡិចត្រូនិកនៅកម្ពុជា នាពេលបច្ចុប្បន្នកំពុងស្ថិតក្នុងការកសាងឱ្យលេចចេញជារូបរាងពេញលេញមួយ។ ដើម្បីឱ្យការប្រើប្រាស់ហត្ថលេខាប្រភេទនេះ មានភាពត្រឹមត្រូវ និងផ្តល់ជាទំនុកចិត្តអ្នកប្រើប្រាស់ត្រូវស្គាល់នូវហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព។ ហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព គឺមានលក្ខខណ្ឌដូចខាងក្រោម៖

- ផ្សារភ្ជាប់ទៅកាន់ហត្ថលេខីតែម្នាក់គត់
- កំណត់បានអត្តសញ្ញាណរបស់ហត្ថលេខី
- ត្រូវបានបង្កើតឡើងដោយប្រើប្រាស់មធ្យោបាយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ហត្ថលេខី
- បញ្ជាក់អំពីពេលវេលា និង កាលបរិច្ឆេទនៃការចុះហត្ថលេខា
- បញ្ជាក់អំពីស្ថានភាពដើមនៃសារ ឬ កំណត់ត្រាអេឡិចត្រូនិកដែលត្រូវបានផ្សារភ្ជាប់ដោយហត្ថលេខានោះ[53]

[52] និយមន័យ ហត្ថលេខាអេឡិចត្រូនិក

[53] សូមពិគ្រោះ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា នស/រកម/១១១៩/០១៧/, ០២ វិច្ឆិកា ២០១៩, មាត្រា ២០(១)។

បញ្ញត្តិខាងលើ មិនកម្រិតលទ្ធភាពរបស់បុគ្គលណាមួយក្នុងការកំណត់លក្ខខណ្ឌបន្ថែមផ្សេងទៀតពាក់ព័ន្ធនឹងភាពអាចជឿជាក់បានរបស់ហត្ថលេខាអេឡិចត្រូនិក។[54] ភាគីនៅក្នុងប្រតិបត្តិការអេឡិចត្រូនិកអាចលើកអំពីភស្តុតាងនៃភាពមិនអាចជឿជាក់នៃហត្ថលេខាអេឡិចត្រូនិកបាន។[55] នៅក្នុងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមិនមានមាត្រាណាមួយកំណត់ច្បាស់លាស់អំពីកាលៈទេសៈ ឬពេលវេលាតម្រូវឱ្យប្រើប្រាស់ហត្ថលេខាតាមអេឡិចត្រូនិកឡើយ។ ជាក់ស្តែងឱ្យតែអ្នកប្រើប្រាស់បានបំពេញលក្ខណ៍ដែលបានក្នុងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក គឺហត្ថលេខានេះនឹងត្រូវបានប្រើប្រាស់ដោយស្របច្បាប់នៅក្នុងសកម្មភាពពាណិជ្ជកម្ម និងសកម្មភាពរដ្ឋប្បវេណីនានាដូចជា ប្រើប្រាស់នៅក្នុងលិខិតគតិយុត្តិ ប្រតិបត្តិការទិញលក់ ការបង្កើតកំនត់ត្រាអេឡិចត្រូនិក ការអនុវត្តកិច្ចសន្យា ការទំនាក់ទំនងតាមអេឡិចត្រូនិក និងការប្រើប្រាស់ដើម្បីជាភស្តុតាងនានា។ ជាមួយនឹងភាពខ្វះចន្លោះក្នុងការបកស្រាយបញ្ញត្តិច្បាប់ស្តីពីពេលវេលាក្នុងការដែលអាចប្រើប្រាស់បាននូវហត្ថលេខាអេឡិចត្រូនិកនេះ វាផ្តល់ជាទិដ្ឋភាពបើកចំហរមួយដែលអានុញ្ញាត្តិឱ្យហត្ថលេខាអេឡិចត្រូនិ ក៏អាចប្រើប្រាស់បានផងដែរចំពោះ

- ការទទួលចុះបញ្ជីឯកសារ ឬ ការបំពេញនូវលក្ខខណ្ឌតម្រូវ សម្រាប់បង្កើតឬរក្សាឯកសារ
- ការចេញអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាត្ត
- ការកំណត់មធ្យោបាយ និង របៀបក្នុងការទូទាត់ប្រាក់
- សកម្មភាពផ្សេងៗទៀតដែលកំនត់ដោយក្រសួង ឬស្ថាប័នរដ្ឋ[56]
- សម្រាប់ចុះបញ្ជីពាណិជ្ជកម្មក្នុងដំណើរការប្រព័ន្ធបញ្ចរតែមួយជាតិ
- ការបង់ពន្ធ[57]

ផ្ទុយទៅវិញដោយហេតុតែហត្ថលេខាអេឡិចត្រូនិកទើបតែត្រូវបានបង្កើតឡើងក្រោមការចូលជាធរមាននៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ ហត្ថលេខាអេឡិចត្រូនិកមិនអាចប្រើប្រាស់បានចំពោះការងារដែលមានហានិភ័យ និងការទទួលខុសត្រូវធ្ងន់ធ្ងរដូចខាងក្រោម៖

- ការបង្កើត និង ការអនុវត្តនូវលិខិតតំណាងដោយអាណត្តិ

[54] សូមពិគ្រោះ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា នស/រកម/១១១៩/០១៧/, ០២ វិច្ឆិកា ២០១៩, មាត្រា ២០(២)។

[55] សូមពិគ្រោះ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា នស/រកម/១១១៩/០១៧/, ០២ វិច្ឆិកា ២០១៩, មាត្រា ២០(២)។

[56] សូមពិគ្រោះ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា នស/រកម/១១១៩/០១៧/, ០២ វិច្ឆិកា ២០១៩, មាត្រា ៣៤(១) ។

[57] ក្រសួងពាណិជ្ជកម្ម.(២៥ វិច្ឆិកា ២០២០). *យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក*,១៣។

- ការបង្កើត និង ការចុះហត្ថលេខាលើលិខិតបណ្តាំ លិខិតបន្ថែមលើមតកសាសន៍ និងលិខិតពាក់ព័ន្ធនឹងមតកសាសន៍
- កិច្ចសន្យាទិញលក់ ផ្ទេរ ការបោះបង់សិទ្ធលើអចលវត្ថុ ឬផលប្រយោជន៍ផ្សេងៗទៀតដែលមានចំពោះវត្ថុនោះ
- ករណីផ្សេងៗទៀតដែលនឹងអាចចែងនៅក្នុងអនុក្រឹត្យ[58]

មួយវិញផងដែរ កម្ពុជាក៏មានអនុក្រឹត្យស្តីពីហត្ថលេខាឌីជីថល(២០១៧) នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលជាបទប្បញ្ញត្តិសំខាន់ដែលមានវិសាលភាពអនុវត្តចំពោះរាល់ប្រតិបត្តិការពាក់ព័ន្ធនឹងទំនាក់ទំនងអេឡិចត្រូនិកនៅកម្ពុជា។[59] មានលក្ខខណ្ឌចំនួន៣(បី) ដែលត្រូវចាត់ទុកថាជាហត្ថលេខាឌីជីថលគឺ (១)ត្រូវបញ្ជាក់អត្តសញ្ញាណរបស់ហត្ថលេខីឌីជីថលដោយត្រឹមត្រូវ និងជាក់លាក់ (២)បញ្ជាក់អំពីស្ថានភាពដើមនៃសារអេឡិចត្រូនិក (៣)បញ្ជាក់អំពីពេលវេលានិងកាលបរិច្ឆេទនៃការចុះហត្ថលេខាឌីជីថល និងចំនុចផ្សេងទៀតដែលកំណត់ដោយក្រសួងប្រៃសណីយ និងទូរគមនាគមន៍។[60] លក្ខខណ្ឌទាំងបីមានលក្ខណៈដូចទៅនឹងកម្មវត្ថុនៃការប្រើប្រាស់ហត្ថលេខាដោយដៃ (Wet Ink) ដែរគឺដើម្បីបញ្ជាក់អត្តសញ្ញាណ ស្ថានភាពដើម និងកាលបរិច្ឆេទនៃលិខិតស្នាមនានា ដោយគ្រាន់តែវាបង្កើតក្រោមទម្រង់អេឡិចត្រូនិក។ សារអេឡិចត្រូនិកដែលមានភ្ជាប់ហត្ថលេខាឌីជីថលបញ្ជាក់ដោយវិញ្ញាតធរហត្ថលេខាឌីជីថល មានតម្លៃគតិយុត្តិស្មើនឹងលិខិតលាយលក្ខណ៍អក្សរ។[61]វាត្រូវបានទទួលស្គាល់យ៉ាងច្បាស់ និងយ៉ាងដាច់ណាត់អំពី សមមូលមុខងារនៃទំនាក់ទំនងអេឡិចត្រូនិកជាមួយហត្ថលេខាឌីជីថល ដែលមានការបញ្ជាក់ ទៅនឹងឯកសារជាក្រដាសស្នាម។[62] ប៉ុន្តែសមមូលមុខងារនៃកំណត់ត្រាអេឡិចត្រូនិក មិនត្រូវបានទទួលស្គាល់ច្បាស់លាស់ដោយច្បាប់ស្តីពីគយ (២០០៧) និងបទប្បញ្ញត្តិគយពាក់ព័ន្ធទេ។[63] បទប្បញ្ញត្តិគយ កម្ពុជា បន្ថយនូវអានុភាពនៃហត្ថលេខាឌីជីថល ឬអេឡិចត្រូនិក និងប្រើជំនួសវិញនូវប្រព័ន្ធបញ្ជាក់

[58] បកប្រែពីNadarashnaraj Sargunaraj. (២០២០). ELECTRONIC AND DIGITAL SIGNATURES IN ASEAN [ហត្ថលេខាអេឡិចត្រូនិក និងហត្ថលេខាឌីជីថលនៅក្នុងសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍]។

[59] អានុក្រឹតស្តីពីហត្ថលេខាឌីជីថល លេខ២៤៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧, មាត្រា៥។

[60] អានុក្រឹតស្តីពីហត្ថលេខាឌីជីថល លេខ២៤៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧, មាត្រា៩។

[61] អានុក្រឹតស្តីពីហត្ថលេខាឌីជីថល លេខ២៤៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧, មាត្រា១០។

[62] បទប្បញ្ញត្តិទាំងនេះយកលំនាំតាមមាត្រា 5,6 និង7 នៃច្បាប់គម្រូស្តីពីពាណិជ្ជកម្មអេឡិចត្រូនិកនៃគណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ (UNCITRAL Model Law on Electronic Commerce (1996))។

[63] ច្បាប់ស្តីពីគយ(២០០៧), សូមមើលផងដែរនូវប្រកាសលេខ ១៤៨៧ស្តីពី*បទប្បញ្ញត្តិ និងនីតិវិធីស្តីពីប្រតិវេទនីគយ* ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៧ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសេចក្តីណែនាំស្តីពីលេខ១៣០៨ ស្តីពី*នីតិវិធីលំអិត និងការកិច្ចទទួលខុសត្រូវក្នុងកិច្ចដំណើរការប្រតិវេទន៍គយ(ឯកសាររដ្ឋបាលតែមួយ) តាមមធ្យោបាយអេឡិចត្រូនិក* នៃអគ្គនាយកដ្ឋានពន្ធគយ និងរដ្ឋាករចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០០៩ ។

និងប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណផ្សេងដូចជា៖ អ្នកប្រើប្រាស់ដែលបានចុះបញ្ជី ឈ្មោះអ្នកប្រើប្រាស់ លេខសម្ងាត់។ ត្រង់ចំនុចនេះ វាមិនមានភាពច្បាស់លាស់ ថាហត្ថលេខាឌីជីថល ដំណើរការត្រឹមកម្រិតណានៅក្នុងបរិស្ថានប្រព័ន្ធបញ្ជរតែមួយជាតិ (NSW) កម្ពុជា។[64] នៅក្រោមអនុក្រឹត្យនេះ ចែងពីប្រព័ន្ធមួយនៃវិញ្ញាបនបត្រឌីជីថល និងហត្ថលេខាឌីជីថលដែលត្រូវបានប្រើដើម្បីបញ្ជាក់និងធានាឱ្យបាននូវទំនុកចិត្តលើការប្រើកំណត់ត្រាអេឡិចត្រូនិក។ ក្នុងនោះដែរ អានុក្រឹត្យក៏បានផ្តល់ជាមតិយោងដល់ការបង្កើតប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធសាធារណៈសំខាន់(Public Key Infrastructure) ដូចជាការដែលវិញ្ញាតធរដែលមានអាជ្ញាប័ណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល នឹងត្រូវអនុញ្ញាតឱ្យចេញវិញ្ញាបនបត្របញ្ជាក់ហត្ថលេខាឌីជីថលជូនអ្នកជាវ ដែលប្រើសំរាប់ហត្ថលេខាឌីជីថលនៅកម្ពុជា។ ក្នុងករណីដែលកម្ពុជាពឹងផ្អែកទាំងស្រុងលើប្រព័ន្ធហេដ្ឋារចនាសម្ពន្ធសាធារណៈសំខាន់ៗមួយដែលគ្រប់គ្រងដោយរដ្ឋាភិបាលសម្រាប់ការចេញវិញ្ញាបនបត្រនិងហត្ថលេខាឌីជីថល វាអាចធ្វើឱ្យប៉ះពាល់ដល់អព្យាក្រឹតភាពបច្ចេកវិទ្យា។[65]

### ខ. អានុភាពគតិយុត្តិនៃហត្ថលេខាអេឡិចត្រូនិក

អានុភាពគតិយុត្តិ ការទទួលស្គាល់ និង ការអនុម័តនូវទំនាក់ទំនងអេឡិចត្រូនិកមិនអាចត្រូវបានបដិសេដដោយផ្អែកលើមូលហេតុដែលវាត្រូវបានបង្កើតឡើងតាមទម្រង់អេឡិចត្រូនិកបានឡើយ។ ដូចគ្នានេះផងដែរ យោងតាមអនុក្រឹត្យលេខ២៤៦ សារអេឡិចត្រូនិកត្រូវបានភ្ជាប់ជាមួយនឹងហត្ថលេខាឌីជីថលដែលទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ច ហើយវាមានអានុភាពគតិយុត្តិដូចទៅនឹងទម្រង់សរសេរផ្ទាល់។ នៅក្រោមច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមិនបានបញ្ជាក់ថា ហត្ថលេខាអេឡិចត្រូនិក និង ហត្ថលេខាឌីជីថលដូចគ្នាឬ ក៏អត់ទេ។ ប៉ុន្តែនៅនៅក្រោមនិយមន័យរបស់ហត្ថលេខាអេឡិចត្រូនិក ហត្ថលេខាឌីជីថលត្រូវបានចាត់ចូលជាប្រភេទមួយនៃហត្ថលេខាអេឡិចត្រូនិក។បើទោះបីជាហត្ថលេខាឌីជីថលត្រូវបានចាត់ចូលជាប្រភេទមួយនៃហត្ថលេខាអេឡិចត្រូនិកក៏ដោយក្តី លក្ខខណ្ឌដើម្បីចាត់ទុកថាហត្ថលេខាឌីជីថលមានសុពលភាពមានភាពតឹងរឹងជាងហត្ថលេខាអេឡិចត្រូនិកធម្មតា។ ដោយនៅក្រោមច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនមានបញ្ញត្តិណាដែលបានបញ្ជាក់ តម្រូវឱ្យមានការចុះក្នុងបញ្ជីចំពោះ ឯកសារដែលមានហត្ថលេខាអេឡិចត្រូនិកឡើយ។ ចំនែកឯនៅក្នុងអនុក្រឹត្យស្តីពីហត្ថលេខាឌីជីថលវិញ បើទោះបីមិនមានបញ្ញត្តិចែងអំពីការចុះបញ្ជីឯកសារដែលមានហត្ថលេខាអេឡិចត្រូ

[64] អគ្គនាយកដ្ឋានគយ និងរដ្ឋាករបានបញ្ជាក់ថាខ្លួនទទួលស្គាល់សារៈសំខាន់នៃហត្ថលេខាឌីជីថល ឬអេឡិចត្រូនិកហើយចំពោះតែប្រតិវេទន៍គយអេឡិកត្រូនិកដែលដាក់ជូនតាមប្រព័ន្ធ ASYCUDA ប៉ុណ្ណោះ(ពោលគឺឯកសាររដ្ឋបាលតែមួយ) ដែលហត្ថលេខាប្រភេទនេះមិនកំពុងត្រូវបានគេប្រើ។

[65] អង្គការសហប្រជាជាតិផ្នែកពាណិជ្ជកម្ម និងវិនិយោគ.(២០១៩).ការវាយតម្លៃត្រៀមខ្លួនរួចរាល់សំរាប់ពាណិជ្ជកម្មឆ្លងកាត់ព្រំដែនដោយមិនចាំបាច់ប្រើក្រដាស់ស្នាម៖ ប្រទេសកម្ពុជា,១៩។

និកក៏ពិតក្តី ប៉ុន្តែនៅក្រោមអនុក្រឹតនេះទទួលស្គាល់សុពលភាពនៃហត្ថលេខាឌីជីថលដែលមានការបញ្ជាក់ដោយវិញ្ញាតធរហត្ថលេខាឌីជីថលប៉ុណ្ណោះ។[66]មិនត្រឹមតែប៉ុណ្ណោះលិខិត ឬ ឯកសារនានាដែលបានព្រីនចេញពីកំនត់ត្រាអេឡិចត្រូនិកដែលអាចទទួលយកថាជាភស្តុតាង គឺមានត្រូវបានទទួលស្គាល់ថាជាទម្រង់ពិតៗ និងមិនអាចត្រូវបានប្រកែកថាមិនមែនជាទម្រង់ដើមបានឡើយ។ទោះជាយ៉ាងណាក្តីនៅក្រោមបញ្ញត្តិដែលបានចែងទាំងពីរនេះ គឺច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង អនុក្រឹត្យលេខ២៤៦ស្តីពីហត្ថលេខាឌីជីថល មានអានុភាពគតិយុត្តិដូចគ្នាឱ្យតែហត្ថលេខាទាំងពីរមានសុពល ភាព។

ចំពោះកំណត់ត្រាអេឡិចត្រូនិកដែលមានប្រភពមកពីបរទេស វាអាចទទួលស្គាល់បានប្រសិនបើត្រូវបានបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសក្រៅនោះ ចំនែកឯប្រព័ន្ធអេឡិចត្រូនិកដែលប្រើដើម្បីជាការកត់ត្រា(កំណត់ត្រាអេឡិចត្រូនិក) ឬសម្រាប់រក្សាទុកកំណត់ត្រាអេឡិចត្រូនិក គឺត្រូវស្របតាមបញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។[67]

## **ផ្នែកទី២៖ ការអនុវត្តនីតិវិធីក្នុងការប្រមូលពន្ធលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

ការទំនើបភាវូបនីយកម្មនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ជាការងារចាំបាច់ដើម្បីបន្តសម្របសម្រួលពាណិជ្ជកម្មឱ្យបានជាអតិបរមា និងបង្កើនការប្រមូលចំណូល។ ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ រាជរដ្ឋាភិបាលបានដាក់ចេញការធ្វើវិចារណកម្ម (Rational) លើគោលនយោបាយសារពើពន្ធដើម្បីឱ្យមានភាពសមប្រកបជាមួយ គោលនយោបាយអភិវឌ្ឍន៍ជាតិ ជំរុញនិងតម្រង់ទិសការវិនិយោគ និងលើកកម្ពស់ឧត្តមភាពក្នុងការប្រកួតប្រជែងនៃសេដ្ឋកិច្ចកម្ពុជា។[68] ដោយហេតុពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកជាក៏ជាប្រភេទនៃពាណិជ្ជកម្មមួយ ដែលទើបតែមានវត្តមានថ្មីថ្មោងនៅក្នុងសេដ្ឋកិច្ចកម្ពុជា ដូចនេះហើយវាក៏មានតួនាទីសំខាន់ក្នុងការប្រមូលពន្ធដែលពាក់ព័ន្ធផងដែរ។

### **កថាខណ្ឌទី១៖ ភាតព្វកិច្ចសារពើពន្ធក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

អគ្គនាយកដ្ឋានពន្ធដារគឺជាសេនាធិការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានតួនាទី និងភារកិច្ចក្នុងការគ្រប់គ្រង និងប្រមូលពន្ធអាករគ្រប់ប្រភេទផ្អែកតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក អ្នកជាប់ពន្ធនិវាសនជន និង អ្នកជាប់ពន្ធអនិវាសនជនមានសិទ្ធនិងកាតព្វកិច្ចស្របតាមច្បាប់ស្តីពីសារពើពន្ធ[69] និងលិខិតបទដ្ឋានជាធរមាន។

---

[66] អានុក្រឹតស្តីពីហត្ថលេខាឌីជីថល, លេខ២៤៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧, មាត្រា១០។

[67] អានុក្រឹតស្តីពីហត្ថលេខាឌីជីថល, លេខ២៤៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧, មាត្រា១៣។

[68] រាជរដ្ឋាភិបាលកម្ពុជា គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ( ០៨ ឧសភា ២០១៩). *យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣*,២៧។

[69] សូមពិគ្រោះ ច្បាប់ស្តីពីសារពើពន្ធ នស/រកម/០២៩៧/០៣/, ២៤ កុម្ភៈ ១៩៩៧, មាត្រា ២,២៦,៧៥,១០១។

យោងតាមមាត្រា ៧៥ ដែលបង្ហាញពីការទទួលខុសត្រូវចំពោះការប្រមូលនិងការបង់ពន្ធអាករនៅកម្ពុជា។ អ្នកនាំចូលឬអ្នកជាប់ពន្ធមានទំនួលខុសត្រូវក្នុងការបង់ពន្ធអាករក្នុងអត្រា ១០% លើតម្លៃជាប់[70] អាករនៃការផ្គត់ផ្គង់ជាប់អាករនីមួយៗនៅកម្ពុជា។ ទោះយ៉ាងណាក៏ដោយនៅក្នុងកថាខណ្ឌទី ២ នៃមាត្រានេះផ្តល់លក្ខខណ្ឌពិសេសអាចអនុវត្តបាននៅពេលអ្នកផ្គត់ផ្គង់ទំនិញឬសេវាកម្មមិនមកធ្វើអាជីវកម្មនៅកម្ពុជាអ្នកទិញត្រូវទទួលខុសត្រូវក្នុងការបង់ពន្ធអាករដែលមានចែងក្នុងអនុក្រឹត្យ។ នៅក្នុងចំណុចនេះ ទំនិញដែលត្រូវទិញលក់តាមរយៈប្រព័ន្ធអេឡិចត្រូនិក គឺមានលក្ខណៈដូចទៅនឹងការជាវទំនិញនៅហាងផ្ទាល់ ដូចនេះកាតព្វកិច្ចរបស់បុគ្គលជាប់ពន្ធគឺមានដូចគ្នាទៅនឹងពាណិជ្ជកម្មទូទៅ។

កម្ពុជាក៏បានអនុម័តផងដែរនូវអនុក្រឹត ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលមានលក្ខណ្ឌពិសេស និងដាក់ចេញនូវយន្តការអនុវត្តអាករលើតម្លៃបន្ថែមលើទំនិញឌីជីថល និងសេវាឌីជីថលដែលធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក សម្រាប់ប្រើប្រាស់ក្នុងព្រះរាជាណាចក្រកម្ពុជា និងការធ្វើការផ្គត់ផ្គង់ដោយអ្នកជាប់ពន្ធអនិវាសនជនដែលមិនមានគ្រឹះស្ថានអចិន្ត្រៃយ៍នៅព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តស្របតាមមាត្រា៧៥ នៃច្បាប់ស្តីពីសារពើពន្ធ។

វិសាលភាពនៃពាណិជ្ជកម្មអេឡិចត្រូនិកទំនិញឬសេវាកម្មដែលជាប់អាករលើតម្លៃបន្ថែមតាមអនុក្រឹត្យនេះមានដូចជា៖

- ដំណើរការនៃការទិញបញ្ជារទិញទមនិញរូបីតាមប្រព័ន្ធអេឡិចត្រូនិក
- ការបញ្ជារទិញនិងការទាញយកទំនិញឌីជីថលតាមប្រព័ន្ធអេឡិចត្រូនិក
- ការបញ្ជាទិញនិងការទាញយកទំនិញឌីជីថលដែលមានសិទ្ធអ្នកនិពន្ធតាមប្រព័ន្ធអេឡិចត្រូនិក សម្រាប់ប្រើប្រាស់ក្នុងគោលដៅពាណិជ្ជកម្ម
- ការធ្វើបច្ចុប្បន្នភាព និងបន្ថែមមុខងារថ្មីៗទៅលើសូហ្វវែរ
- អាជ្ញាបណ្ណប្រើប្រាស់សូហ្វវែរមានកាលកំណត់ និងព័ត៌មានឌីជីថលផ្សេងៗ
- សិទ្ធប្រើប្រាស់តែមួយដងនូវសូហ្វវែរ ឬផលិតផលឌីជីថលផ្សេងៗ
- ការផ្គត់ផ្គត់សេវាបង្ហោះកម្មវិធីសូហ្វវែរ-អាជ្ញាបណ្ណដាច់ដោយឡែកពីគ្នា[71]

[70] សូមពិគ្រោះ ច្បាប់ស្តីពីសារពើពន្ធ នស/រកម/០២៩៧/០៣/, ២៤ កុម្ភ: ១៩៩៧, មាត្រា ៦៤។

[71] សូមពិគ្រោះ ទម្រង់នៃសកម្មភាព ឬប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងសេចក្តីពន្យល់, អនុក្រឹតលេខ៦៥

កាតព្វកិច្ចបង់ពន្ធនៅកម្ពុជាសម្រាប់អ្នកផ្តល់សេវាពាណិជ្ជកម្មអេឡិចត្រូនិកដែលមិនមែនជានិវាសនជន ឬសម្រាប់អ្នកទិញដែលបានទិញទំនិញឬសេវាកម្មពីអ្នកផ្តល់សេវាកម្មពាណិជ្ជកម្មអេឡិចត្រូនិកដែលមិនមែនជានិវាសនជនគឺ៖

- សម្រាប់អាជីវកម្មទៅអ្នកប្រើប្រាស់ (B2C)៖ ប្រសិនជាអនិវាសនជនដែលផ្គត់ផ្គង់ទំនិញឬសេវាកម្មដល់អ្នកប្រើប្រាស់កម្ពុជា ត្រូវមានកាតព្វកិច្ចចុះបញ្ជីពន្ធដារដោយផ្អែកតាមចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស[72] និងមានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ប្រាក់អាករលើតម្លៃបន្ថែមមករដ្ឋបាលសារពើពន្ធ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលបានទូទាត់[73]។
- សម្រាប់អាជីវកម្មទៅអាជីវកម្ម(B2B)៖ អ្នកជាប់ពន្ធនិវាសនជនដែលទទួលការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល ឬរាល់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីអ្នកជាប់ពន្ធអនិវាសនជន ត្រូវប្រមូលអាករតាមវិធីគិតអាករជំនួស ហើយធ្វើកាតប្រកាស និងបង់អាករលើតម្លៃបន្ថែមមករដ្ឋបាលសារពើពន្ធ។[74]

**កថាខណ្ឌទី២៖ ការអនុវត្តកាតព្វកិច្ចសារពើពន្ធនៅកម្ពុជា**

នៅកម្ពុជា មិនទាន់មានក្របខណ្ឌគតិយុត្តិគ្រប់គ្រាន់ក្នុងការប្រមូលចំណូល ពីវិស័យពាណិជ្ជកម្មដែលពេញនិយមនៅកម្ពុជាដូចជាការសហគ្រាសធុនតូច ឬមធ្យមតាមអនឡាញនោះទេ។ អាជីវកម្មបុគ្គលបែបនេះមិនទាន់មានជាការអនុវត្តនូវកាតព្វកិច្ចពន្ធត្រឹមត្រូវនៅឡើយ បើទោះបីជាចំណូលនៃការលក់ផលិតផលតាមអនឡាញនោះមានផលរបរស្រេបតាមចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស[75] ក៏ពិតក្តី។ អគ្គនាយកដ្ឋានពន្ធដារមិនមានបញ្ជី ឬទិន្នន័យពិតប្រាកដពីចំនួនសហគ្រាសធុនតូច និងមធ្យម ជាពិសេសនៅក្នុងវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងវិស័យបច្ចេកវិទ្យាដែលកំពុងប្រតិបត្តិការ និងប្រភពចំណូលរបស់សហគ្រាសទាំងនោះ មុនពេលចូលរួមក្នុងសកម្មភាពពាណិជ្ជកម្មសង្គមបច្ចុប្បន្នទេ។ បញ្ហាចម្បងនៅកម្ពុជាទាក់ទងនឹងអាករលើតម្លៃបន្ថែមទីមួយគឺទាក់ទងនឹងអ្នកផ្គត់ផ្គង់ក្រៅផ្លូវការ។

[72] អនុក្រឹតស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក,លេខ៦៥ អនក្រ បក០៨, មេសា ២០២១មាត្រា ៤,រាជរដ្ឋាភិបាលកម្ពុជា។

[73] អនុក្រឹតស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក,លេខ៦៥ អនក្រ បក០៨, មេសា ២០២១មាត្រា ៥,រាជរដ្ឋាភិបាលកម្ពុជា។

[74] អនុក្រឹតស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក,លេខ៦៥ អនក្រ បក០៨, មេសា ២០២១មាត្រា ៦,រាជរដ្ឋាភិបាលកម្ពុជា។

[75] សូមពិគ្រោះ ប្រកាសស្តីពីការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស លេខ០០៩សហវ.ប្រក នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ,១២ មករា ២០២១,មាត្រា៤។

ដោយសារតែអាករលើតម្លៃបន្ថែម អាចត្រូវបានចេញដោយសហគ្រាសដែលជាអ្នកផ្គត់ផ្គង់ដែលបានចុះបញ្ជីលេខអត្តសញ្ញាណសារពើពន្ធសម្រាប់អ្នកផ្គត់ផ្គង់ក្រៅផ្លូវការដែលពុំមានចេញវិក្កយបត្រអាករលើតម្លៃបន្ថែមឡើយ។ ដូចនេះសហគ្រាសពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវបានតម្រូវឱ្យទូទាត់ប្រាក់ចំនួន ១៥% បន្ថែមជាពន្ធកាត់ទុកទៅឱ្យអគ្គនាយកដ្ឋានពន្ធដារ ដោយសារអត្រាពន្ធកាត់ទុក១៥%នេះត្រូវអនុវត្តចំពោះអ្នកផ្តល់សេវាកម្មដែលពុំបានចុះបញ្ជីដោយសារអ្នកផ្តល់សេវាកម្មជាលក្ខណៈបុគ្គលនេះទទួលបានប្រាក់ចំណូល ប៉ុន្តែពុំមានកាតព្វកិច្ចត្រូវប្រកាសពន្ធលើប្រាក់ចំណូល។ អត្រានេះលើសពីអត្រាទូទៅដែលមានចំនួន១០%ដែលបានតម្រូវ ប្រសិនបើអ្នកផ្គត់ផ្គង់ផ្លូវការចេញវិក្កយបត្រអាករលើតម្លៃបន្ថែមបានត្រឹមត្រូវ។[76]

បន្ថែមពីនេះ ការដោះស្រាយបញ្ហាពន្ធសម្រាប់កម្មវិធីថ្នាល (Platform) ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសលេខ៥៩៧ សហវ.ប្រ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការទទួលស្គាល់ និងកាតព្វកិច្ចសារពើពន្ធមួយចំនួនរបស់ភ្នាក់ងារផ្គត់ផ្គង់ទំនិញ និងសេវាកម្មក្នុងនាមសហគ្រាសដើមដែលចែងអំពីលក្ខខណ្ឌវិនិច្ឆ័យដើម្បីទទួលបានលក្ខណៈសម្បត្តិជាភ្នាក់ងារសេវាកម្ម និងបង់ពន្ធដោយផ្អែកលើកម្រៃជើងសារក៏ដោយ បទប្បញ្ញត្តិនេះប្រហែលមិនអាចអនុវត្តិបានចំពោះស្ថានភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនាពេលបច្ចុប្បន្ននេះទេ ដោយហេតុប្រតិបត្តិករកម្មវិធីថ្នាលនាពេលបច្ចុប្បន្នភាគច្រើនជាក្រុមហ៊ុនតូចដែលទើបនឹងចាប់ផ្តើមដំបូង និងជាងអ្នកផ្គត់ផ្គង់ក្រៅផ្លូវការ។ ជាការអនុវត្តជាក់ស្តែង សហគ្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកតែងតែប្រកាសផលិតផលជាផលិតផលរបស់ខ្លួន និងជួលអ្នកផ្គត់ផ្គង់ជាបុគ្គលិកជំនួសឱ្យការជួលអ្នកផ្គត់ផ្គង់ជាអ្នកធ្វើការឯករាជ្យ។ ទាក់ទងនឹងកាតព្វកិច្ចប្រកាសពន្ធ និងការធ្វើសវនកម្មពន្ធដារ ការទូទាត់ប្រាក់តាមច្រកទូទាត់ប្រាក់ (Payment Gateway) ដូចជា E-payment របស់ធនាគារក៏មានភាពស្រពិចស្រពិល និងខ្វះខាតស្តង់ដារគ្រប់គ្រងជារួម ដើម្បីឱ្យបុគ្គលជាប់ពន្ធមានព្រឹត្តិកម្មស្មើគ្នាចំពោះសិទ្ធ និងកាតព្វកិច្ចសារពើពន្ធ។ ដូចគ្នាផងដែរ លក្ខណៈវិនិច្ឆ័យរួម ឬនិយមន័យរួមជាភាពចាំបាច់ដើម្បីកុំមានភាពបែកខ្ញែកគ្នា ហើយវាគឺជាចំណុចចាប់ផ្តើមយ៉ាងសំខាន់សម្រាប់ការបង្កើតគោលនយោបាយ និងការវាស់វែងទិន្នន័យទាក់ទងសហគ្រាសធុនតូច និងមធ្យម។

ដូចនេះការអនុវត្តពន្ធចំពោះសហគ្រាសធុនតូច ឬអាជីវកម្មតូចទាំងនេះនៅមិនទាន់មានសភាពជាក់លាក់នៅឡើយ ដោយកិច្ចការនេះត្រូវការចូលរួមពីសំណាក់បុគ្គល និងការគាំទ្រយ៉ាងទូលំទូលាយពីអាជ្ញាធរយ៉ាងចាំបាច់។ ទាក់ទងនឹងបញ្ហាពន្ធនេះ យន្តការជំនួយមានភាពយឺតយ៉ាវសម្រាប់សហគ្រាស

---

[76] ក្រសួងពាណិជ្ជកម្ម.(២៥ វិច្ឆិកា ២០២០). *យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក*,២៦។

ធុនតូច និងមធ្យមដែលអាចបង្កើនហានិភ័យក្នុងការរៀបចំគោលនយោបាយមិនចំគោលដៅ។ អគ្គនាយកដ្ឋានពន្ធដារបាននឹងកំពុងធ្វើសិក្ខាសាលាដើម្បីផ្សព្វផ្សាយជូនអ្នកជាប់ពន្ធគ្រប់វិស័យទាំងអស់ និងទូទាំងប្រទេសអំពីខ្លឹមសារ អត្ថប្រយោជន៍ និងនីតិវិធីនានា។ ក៏ប៉ុន្តែការយល់ដឹងទូទៅ និងការចូលរួមនៅមានកម្រិតដោយសារកង្វះការយកចិត្តទុកដាក់។ សហគ្រាសធុនតូច និងមធ្យមនៅក្នុងវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវការការពង្រឹងក្របខ័ណ្ឌអភិវឌ្ឍន៍ជាចាំបាច់ឱ្យស្របទៅតាមការរីកលូតលាស់នូវសេដ្ឋកិច្ចឌីជីថល។[77]យ៉ាងណាមិញ ប្រជាជនជាច្រើននៅកម្ពុជាអាចមានមុខរបរ ទទួលបានប្រភពចំណូល និងការងារផ្ទាល់ខ្លួនពីវិស័យនេះបាន។ ទោះបីជាពេលបច្ចុប្បន្ន ការអនុវត្តកាតព្វកិច្ចបង់ពន្ធមិនទាន់មានលក្ខណៈត្រឹមត្រូវ ប៉ុន្តែវត្តមានច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ជាស្ពានដែលកម្ពុជាអាចរំពឹងទុកបានថានឹងនាំមកនូវការវិនិយោគផ្ទាល់ពីបរទេស ដោយសារក្រុមហ៊ុនអន្តរជាតិដែលធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក អាចបង្កើតនូវបណ្តាញចែកចាយសម្រាប់អ្នកផ្គត់ផ្គង់ ក៏ដូចជាជ្រើសរើសកម្មករ និយោជិតផងដែរ។ នេះក៏អាចផ្តល់ជាចរន្តចម្លងមួយសម្រាប់សហគ្រាសធុនតូច ឬមធ្យមឱ្យប្រែក្លាយទៅជាអ្នកផ្គត់ផ្គង់ផ្ទាល់។[78]

## ផ្នែកទី៣៖ កិច្ចការពារអ្នកប្រើប្រាស់នៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ដោយសារតួនាទីដ៏សំខាន់ ដែលបណ្តាញអ៊ីនធើណេតកំពុងដើរតួនៅក្នុងសេដ្ឋកិច្ចឌីជីថល និងជីវភាពរបស់នៅប្រចាំថ្ងៃរបស់ប្រជាជនទូទៅ សំណួរកើតឡើង អំពីការទទួលខុសត្រូវរបស់បុគ្គលដែលបានធ្វើការបញ្ចេញមតិ ផលិតជាមាតិកា ឬការដាក់លក់ផលិតផលខុសច្បាប់ ឬផលិតផលដែលបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ដែលកំពុងធ្វើចរាចរណ៍លើប្រព័ន្ធអ៊ីនធើណេត ។ យើងមាន៣ កថាខណ្ឌដែលនឹងលើកយកមកនៅក្នុងផ្នែកទី៣នេះ។ **កថាខណ្ឌទី១ គឺច្បាប់ពាក់ព័ន្ធនឹងមាតិកាអ៊ីនធើណេតនៅកម្ពុជា** ដែលកើតមានឡើងដើម្បីធានាឱ្យមានការការពារគ្រប់គ្រាន់ដល់អ្នកប្រើប្រាស់ សិទ្ធិជាមូលដ្ឋាននិងសេរីភាពរបស់អ្នកប្រើប្រាស់។ **កថាខណ្ឌទី២ គឺបទល្មើសក្លែងបន្លំនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** ដែលជាប្រភេទនៃការលួចបន្លំឧក្រិដ្ឋកម្មតាមអ៊ីនធើណេតឬការបោកបញ្ឆោតដែលប្រើប្រាស់អ៊ីនធើណេត ហើយអាចពាក់ព័ន្ធនឹងការលាក់បាំងព័ត៌មានឬការផ្តល់ព័ត៌មានមិនត្រឹមត្រូវក្នុងគោលបំណងឆបោក ឬបន្លំអ្នកប្រើប្រាស់។ រីឯ**កថាខណ្ឌទី៣ ការការពារទិន្នន័យឯកជន** ដែលមានសារៈសំខាន់ សម្រាប់ការការពារទិន្នន័យអ្នកប្រើប្រាស់ដែលបានប្រមូលផ្តុំគ្នាក្នុងពេលធ្វើទំនាក់ទំនងអេឡិចត្រូនិក និង**កថាខណ្ឌទី**

[77] ក្រសួងពាណិជ្ជកម្ម.(២៥ វិច្ឆិកា ២០២០). *យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក*,២៥។

[78] ក្រសួងពាណិជ្ជកម្ម.(២៥ វិច្ឆិកា ២០២០). *យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក*,២២។

**៤ គឺការការពារទិន្នន័យតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា** ដែលចែង ប្បញ្ញត្តិអំពីសិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់អ្នកប្រើប្រាស់ ដែលមានអនុភាពគ្របដណ្តប់ព្រះរាជាណាចក្រកម្ពុជាទាំងមូល។

**កថាខណ្ឌទី១៖ ច្បាប់ពាក់ព័ន្ធនឹងមាតិកាអ៊ីនធើណេតនៅកម្ពុជា**

ការទទួលខុសត្រូវចំពោះមាតិការតាមអ៊ីនធើណេត ជាការចាំបាច់ណាស់ដែលយើងត្រូវធ្វើការវាយតម្លៃពីភាពគ្រប់គ្រាន់ និងប្រសិទ្ធភាពនៃនីតិភាពរបស់ច្បាប់អន្តរជាតិ ហើយជាពិសេសច្បាប់នៃព្រះរាជាណាចក្រកម្ពុជាទាក់ទងនឹងករណីលើកលែងការទទួលខុសត្រូវ ដែលផ្តល់ដោយច្បាប់ស្តីពាណិជ្ជកម្មអេឡិចត្រូនិក ច្បាប់ស្តីពីកិច្ចការអ្នកប្រើប្រាស់ និងច្បាប់ស្តីពិសិទ្ធិមនុស្ស ដើម្បីធានាការការពារគ្រប់គ្រាន់ដល់អ្នកប្រើប្រាស់និងសិទ្ធិជាមូលដ្ឋាននិងសេរីភាពរបស់ពួកគេ ឧទាហរណ៍ សេរីភាពនៃការការបញ្ចេញមត។ វានៅមានបញ្ហាប្រឈមជាច្រើនដែលយើងគប្បីលើកយកមកធ្វើការសិក្សា ពិនិត្យឡើងវិញនូវបញ្ហាប្រឈមផ្នែកច្បាប់ និងបទប្បញ្ញត្តិសំខាន់ៗដែលទាក់ទងនឹងប្រតិបត្តិការរបស់មាតិការ និងរិះរកអតិភាពក្នុងការលើកទឹកចិត្តដល់ម្ចាស់មាតិការ និងតតិយជនផ្សេងទៀត ដើម្បីរកដកចេញ និងលុបចោលនូវមាតិការខុសច្បាប់ ឬផលិតផលដែលបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់។ ដើម្បីបង្កើតជាចំណាត់ការដែលអាចត្រូវបានប្រើសម្រាប់គោលបំណងនៃបទប្បញ្ញត្តិច្បាប់ វាទាមទារឱ្យមានការពិភាក្សាអំពីសញ្ញាណនៃមាតិការអ៊ីនធើណេត និងការព្យាយាមចាត់ថ្នាក់តាមលក្ខណៈវិនិច្ឆ័យរួមដែលច្បាប់កំណត់ ។ រាជរដ្ឋាភិបាលគួរសិក្សានិងកំណត់ព្រំដែនអ៊ីនធើណេត និងធ្វើវាយតម្លៃប៉ាន់ស្មានអំពីផលប៉ះពាល់របស់មាតិការដែលមាននៅកម្ពុជាទាំងអស់ដោយយកច្បាប់រឹងនិងទន់ដែលមាន ព្រមទាំងច្បាប់អន្តរជាតិមកពិចារណាអនុវត្ត។ យើងឃើញថា នៅសហភាពអឺរ៉ុបមានក្របខ័ណ្ឌមួយដ៏ជាក់លាក់សម្រាប់ទទួលខុសត្រូវចំពោះមាតិការអ៊ីនធើណេតដែលមានប្រតិបត្តិនិងអនុស្សរណៈនៃការយោគយល់ថ្នាក់ជាតិដែលចូលរួមពីអ្នកតំណាងឧស្សាហកម្មបច្ចេកវិទ្យា និងស្ថាប័នរដ្ឋាភិបាលសម្រាប់សម្របសម្រួលឬត្រួតពិនិត្យទៅលើបញ្ហានេះ។[79]

នៅកម្ពុជាមិនទាន់មានបទប្បញ្ញត្តិជាក់លាក់ដែលចែងពីការទទួលខុសត្រូវតាមមាតិកា ឬកិច្ចសហការឯកជនណាមួយសម្រាប់ពង្រឹងការបញ្ចេញនូវមាតិការខុសច្បាប់ឡើយ។ យ៉ាងណាមិញ មាតិកាអ៊ីធឺណេតដែលទាក់ទងជាមួយពាណិជ្ជកម្មអាចធ្វើការបកស្រាយបានតាមរយៈ ច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់ដែលបានផ្តល់នូវបទដ្ឋាននិយ័តកម្មកិច្ចការពារអ្នកប្រើប្រាស់ក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិច

[79] Fisher, Bonnie S.; Lab, Steven. Encyclopedia of Victimology and Crime Prevention [សព្វវចនាធិប្បាយស្តីពីភាពរងគ្រោះ និង ការរារាំងឧក្រិដ្ឋកម្ម] (១)៤៩៣។

ត្រូនិក។[80] ច្បាប់នេះបានតម្រូវឱ្យបុគ្គលទាំងអស់ដែលធ្វើអាជីវកម្មនៅកម្ពុជា ត្រូវបង្ហាញព័ត៌មានអប្បបរមាដល់អ្នកប្រើប្រាស់។ ក្រសួងមានសមត្ថកិច្ច មានសិទ្ធអំណាចក្នុងការរៀបចំស្តង់ដារព័ត៌មានអ្នកប្រើប្រាស់ក្នុងវិស័យក្រោមសមត្ថកិច្ចរបស់ខ្លួន ហើយរៀបចំស្តង់ដារនេះអាចពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិកិច្ចការពារអ្នកប្រើប្រាស់ប្រសិនបើចាំបាច់។ស្តង់ដារព័ត៌មានអ្នកប្រើប្រាស់ដែលត្រូវបានអនុម័តដោយប្រកាស និងផ្សព្វផ្សាយដោយក្រសួងមានសមត្ថកិច្ច ឬគណៈកម្មាធិការជាតិកិច្ចការពារអ្នកប្រើប្រាស់នឹងមានប្រសិទ្ធភាពផ្លូវច្បាប់ជាបទប្បញ្ញត្តិសម្រាប់អនុវត្តច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។[81]ការអនុវត្តស្តង់ដារព័ត៌មានអ្នកប្រើប្រាស់ដូចមានចែងក្នុងមាត្រា ២៧នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអ៊ីនធើណេត នឹងយកទៅអនុវត្តជាមួយក្រុមហ៊ុនពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយមានសង្គតិភាពជាមួយបទប្បញ្ញត្តិមួយចំនួនទៀត។ មិនត្រឹមតែប៉ុណ្ណោះនៅក្នុងមាត្រា ៣៣នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកតម្រូវឱ្យបុគ្គលដែលប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកសម្រាប់សកម្មភាពពាណិជ្ជកម្មជាមួយអ្នកប្រើប្រាស់ចាំបាច់ត្រូវអនុលោមតាមបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតទាក់ទងនឹងកិច្ចការពារអ្នកប្រើប្រាស់។ នៅត្រង់ចំនុចនេះ មាតិកានៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវបានការពារ និងគ្រប់គ្រងដោយផ្ទាល់នៅក្រោមបញ្ញត្តិនៃច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ លើសពីនេះទៅទៀត បញ្ញត្តិអន្តរក្រសួងនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងពាណិជ្ជកម្មនឹងរៀបចំក្រមសីលធម៌វិជ្ជាជីវៈ និងបទប្បញ្ញត្តិសម្រាប់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រមសីលធម៌វិជ្ជាជីវៈ ត្រូវបង្កើត និងអនុម័តដោយប្រកាសអន្តរក្រសួងខាងលើ និងមានការរៀបចំឱ្យមានការចូលរួមពីសមាគមដែលតំណាងឱ្យអន្តរការី អ្នកផ្តល់សេវាកម្មពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឬអ្នកប្រើប្រាស់។ ក្រមសីលធម៌វិជ្ជាជីវៈ គួរតែរួមបញ្ចូលការការពារទិន្នន័យ និងលក្ខណ្ឌស្តីពីកាតព្វកិច្ចសុវត្ថិភាព និងតម្លាភាពរបស់បុគ្គលគ្រប់គ្រងទិន្នន័យ និងបុគ្គលធ្វើប្រព្រឹត្តិកម្មទិន្នន័យ (Data Controllers and Processor) និងកំណត់មូលដ្ឋានច្បាប់សម្រាប់ការប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួន និងការផ្តល់សិទ្ធជាក់លាក់ដល់ម្ចាស់ទិន្នន័យក្នុងការចូលយកទិន្នន័យ កែទិន្នន័យ និងលុបទិន្នន័យ។ល។

### កថាខណ្ឌទី២៖ បទល្មើសក្លែងបន្លំនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ការបោកប្រាស់តាមអ៊ិនធឺណេត គឺជាប្រភេទនៃឧក្រិដ្ឋកម្មតាមអ៊ីនធើណេតឬការបោកបញ្ឆោតដោយប្រើប្រាស់អ៊ីនធើណេត ដែលពាក់ព័ន្ធនឹងការលាក់បាំងព័ត៌មានឬការផ្តល់ព័ត៌មានមិនត្រឹមត្រូវក្នុង

[80] សូមពិគ្រោះ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា នស/រកម/១១១៩/០១៧/, ០២ វិច្ឆិកា ២០១៩, មាត្រា ២៧។

[81] ក្រសួងពាណិជ្ជកម្ម.(២៥ វិច្ឆិកា ២០២០). *យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក*,១៣។

គោលបំណងឆបោកជនរងគ្រោះ។ ភាពស្របច្បាប់ ឬមិនស្របច្បាប់របស់ការលួចបន្លំតាមអ៊ីនធឺមានភាពខុសប្លែកគ្នានៅតាមយុត្តាធិការនានានៅទូទាំងបពិភពលោក។ ឧទាហរណ៍ ការប្រព្រឹត្តទំនាក់ទំនងអាជីវកម្មតាមអ៊ីនធើណេតជាសមកម្មភាពស្របច្បាប់ នៅប្រទេសបារាំង ប៉ុន្តែត្រូវបានចាត់ទុកថាខុសច្បាប់នៅក្នុងសហរដ្ឋអាមេរិក។ ការពិពណ៌នាអំពីសារជាតិនៃការក្លែងបន្លំតាមអ៊ីនធើណេតភាគច្រើនលើអាស្រ័យលើកាលៈទេសៈនៃប្រភេទនៃឧក្រិដ្ឋកម្មនេះ និងយុត្តាធិការដែលសកម្មភាពនេះប្រព្រឹត្តិទៅ។ករណីជាច្រើនចំពោះការក្លែងបន្លំតាមអ៊ីនធើណេតបានកើតឡើង ព្រោះជនរងគ្រោះស្ម័គ្រចិត្តនិងផ្តល់ព័ត៌មានទាក់ទងនឹងព័ត៌មានគណនេយ្យធនាគាររបស់ខ្លួនដោយចេតនាដល់ជនល្មើស។ ទោះបីជាគេហទំព័រអ៊ីម៉ែលបន្លំ និងក្លែងបន្លំមិនមែនជាការគំរាមកំហែងថ្មីដល់សហគមន៍ឌីជីថលក៏ដោយ វិចទ័រវាយប្រហារដែលដាក់ពង្រាយដោយអ្នកបោកប្រាស់បានប្រែទៅជាមានភាពចម្រុះនិងទំនើបនៅកម្ពុជា។ ទម្រង់នៃការឆបោកតាមអ៊ីនធើណេតនៅកម្ពុជាដែលទាក់ទងនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានដូចជាៈ

- **ឆបោកជាទម្រង់សប្បុរសធម៌**

ជនឆបោក បានបន្លំជាអង្គការសប្បុរសធម៌ដែលសុំការបរិច្ចាគដើម្បីជួយជនរងគ្រោះដោយសារគ្រោះធម្មជាតិ ឬការវាយប្រហារភេរវកម្មផ្សេងៗ ដូចជាការព្រឹត្តិការណ៍វាយប្រហារប្រឆាំងភាវរកម្មថ្ងៃទី ៩/១១ ព្យុះកាទ្រីណា និងរលកយក្សស៊ូណាមិឆ្នាំ២០០៤ ការរៃអង្គាសប្រាក់សម្រាប់ជំងឺមហារីកការស្រាវជ្រាវអេដស៍ មណ្ឌលកុមារកំព្រា ជាដើម។ នាពេលបច្ចុប្បន្នការបោកប្រាស់ដែលមានប្រជាប្រិយបំផុតមួយចំនួនដែលកំពុងដំណើរការនៅពេលនេះគឺ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយកូវីដ-១៩ ដែលមានការកេងចំណេញពីវិបត្តិសុខភាពនិងហិរញ្ញវត្ថុ។ ដោយហេតុយុទ្ធនាការចាក់វ៉ាក់សាំងកំពុងដំណើរការ ដែលក្នុងនោះមានការបំពេញទម្រង់បែបបទឬទូទាត់ប្រាក់ជាមុន ឬ បង់ថ្លៃសេវាសម្រាប់ចាក់វ៉ាក់សាំង ដូចនេះហើយវាអាចមានជាការ បង្កើតនូវគេហទំព័រមិនពិតសម្រាប់បោកប្រាស់អ្នកប្រើប្រាស់ឱ្យបង់ថ្លៃសេវា ឬជាមូលនិធិសម្រាប់អ្នកជំងឺកូវីដ-១៩ជាដើម។[82] ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ករណីឆបោកក្រោមមូលហេតុសប្បុរសធម៌ ជាវិធីសាស្ត្រឆបោកដ៏ពេញនិយមរបស់អ្នកបោកប្រាស់តាមប្រព័ន្ធអ៊ីនធើណេត។ ជនរងគ្រោះគឺជាបុគ្គលសប្បុរសធម៌ដែលជឿថាជនឆបោកទាំងនោះកំពុងជួយបុព្វហេតុណាមួយសមហេតុផល ហើយជនរងគ្រោះមិនរំពឹងអ្វីមកវិញក្រៅពីធ្វើមូលនិធិ ដែលជាហេតុធ្វើឱ្យការឆបោកនេះមិនសូវជា

[82] តេឡេក្រាមចុងក្រោយបង្អស់របស់ Bitdefender បានបង្ហាញថាការបោកប្រាស់ដែលបង្កឡើងដោយវីរុសគឺនៅតែមានភាពខ្លាំងក្លា។ ៦១,៦៨% នៃការឆ្លើយឆ្លងដែលទាក់ទងទៅនឹងCOVID-19 ត្រូវបានគេសម្គាល់ថាជាសារឥតបានការនៅថ្ងៃទី ២៦ ខែកុម្ភៈដែលបង្ហាញថាអ្នកផ្ញើសារឥតបានការនិងឧក្រិដ្ឋជនអ៊ីនធើណេតមិនចេះអស់ក្នុងការប៉ុនប៉ងទាញយកផលប្រយោជន៍ពីការរីករាលដាលនៃជំងឺរាតត្បាត។

បានដឹងឮអំពីបញ្ហានេះ។ ការឆបោកនេះតែងតែចេញលេចមកលើអ៊ីនធើណេតដែលអ្នកប្រើប្រាស់កំពុងចូល។ ជាពិសេសនៅក្រៅប្រទេសដែលការឆបោកទម្រង់នេះ តែងតែកើតមានជាញឹកញាប់ដែលជនឆបោកបន្តសុំឱ្យមានការផ្តល់មូលនិធិជារៀងរាល់ខែ។ [83]

- **ឆបោកជាលក្ខណៈលក់ទំនិញអនឡាញ**

ដោយមានសន្ទុះនៃការទិញលក់ទំនិញតាមអនឡាញជាពិសេសការលក់ទំនិញតាមប្រព័ន្ធបណ្តាញសង្គមហ្វេសបុក អ្នកទិញទំនិញភាគច្រើនបានទទួលរងនូវការចាញ់បោកអ្នកលក់ចំពោះទំនិញក្លែងក្លាយតាមរយៈរូបភាពបង្ហោះ ឬមានបុគ្គលដែលក្លែងបន្លំជាអ្នកលក់ជាដើម។ មានករណីជាច្រើនដែលអ្នកមានបំណងឆបោកអ្នកទិញទំនិញតាមអនឡាញជាច្រើនបានបង្កើតជាវេបសាយលក់ទំនិញ និងយករូបភាពទំនិញពីអ៊ីនអឺណេតមកផ្សព្វផ្សាយលក់ ទាំងដែលមិនមានទំនិញពិតប្រាកដ។ នៅពេលដែលអ្នកទិញបានផ្តល់លុយ ឬវេរលុយតាមគណនេយ្យធនាគាររបស់ខ្លួនរួចរាល់ដើម្បីជាវទំនិញនោះ វេបសាយទាំងនោះក៏លែងមានដំណើរការ ហើយអ្នកទិញទំនិញនៅត្រង់នេះមិនបានស្គាល់ពីអត្តសញ្ញាណអ្នកលក់ឡើយ ក៏មិនអាចចូលទៅកាន់គេហទំព័រនោះបន្តទៀត។ ក្រៅពីនេះអ្នកលក់បោកប្រាស់តាមបណ្តាញសង្គមហ្វេសបុកនៅខ្មែរមួយចំនួនបានធ្វើការប្លុកអ្នកទិញ នៅពេលដែលអ្នកទិញបានវេរលុយរួចរាល់។

- **ឆបោកជាលក្ខណៈផ្តល់រង្វាន់**

ទម្រង់នៃការឆបោកនេះតែងតែកើតឡើងនៅកម្ពុជា ដោយបានសម្របខ្លួនទៅនឹងការផ្លាស់ប្តូរសង្គមនយោបាយ និងសេដ្ឋកិច្ច។ ដោយហេតុតែប្រជាជនខ្វះការយល់ដឹងជ្រៅជ្រះ ហើយតែងតែលង់ជឿនូវការបញ្ចុះបញ្ចូល និងត្រេកត្រអាលពីការឈ្នះរង្វាន់ និងងប់ងល់បង់លុយជាវផលិតផលនានាដើម្បីឈ្នះរង្វាន់តាមបណ្តាញសង្គម ការខលទូរស័ព្ទ ឬតាមប្រព័ន្ធអ៊ីនធើណេតនានា។ សំណួរជាច្រើនបានសួរថាហេតុអ្វីបានជាកម្ពុជានៅតែចាញ់បោកវិធីសាស្ត្របោកប្រាស់លក្ខណៈបុរាណ ដែលសភាពនៃការគំរាមកំហែងឌីជីថលសព្វថ្ងៃ? ការបញ្ចុះបញ្ចូលពីលេខទូរស័ព្ទ ឬសារអាណាមឹកថានឹងឈ្នះទឹកប្រាក់រាប់លានដុល្លារ រថយន្តទំនើប ឬ ឧបករណ៍បច្ចេកវិទ្យាថ្មី គឺបានធ្វើឱ្យអ្នកប្រើប្រាស់បណ្តាញសង្គមខ្វះការពិចារណា និងវិនិច្ឆ័យ។ នៅក្នុងប្រភេទនៃការឆបោកនេះ តម្រូវឱ្យអ្នកប្រើប្រាស់ដែលជាជនរងគ្រោះផ្ញើរប្រាក់ទៅកាន់ពួកគេជាមុនសិនក្នុងថ្លៃដំណើរការទទួលបានរង្វាន់។ ក្នុងកាលៈទេសៈដែលគ្រោះថ្នាក់បំផុតនោះ គឺអ្នកប្រើប្រាស់បានផ្តល់ជាព័ត៌មានគណនីធនាគារ ឬ លេខសន្តិសុខគណនេយ្យ។

[83] Fisher, Bonnie S.; Lab, Steven. Encyclopedia of Victimology and Crime Prevention [សព្វវចនាធិប្បាយស្តីពីភាពរងគ្រោះ និង ការរារាំងឧក្រិដ្ឋកម្ម] (១)៩៩២។

- **ការឆបោកតាមទីផ្សារពាណិជ្ជកម្ម**

នៅកម្ពុជា អ៊ីមែលដែលមិនបានស្នើសុំរាប់ពាន់លានត្រូវបានផ្ញើទៅប្រអប់ទទួលជារៀងរាល់ថ្ងៃ។ ខណៈពេលដែលសារមួយចំនួនអាចមានគ្រោះថ្នាក់ចំពោះការផ្សព្វផ្សាយពាណិជ្ជកម្មពីអ្នកលក់ ឧក្រិដ្ឋជនតាមបណ្តាញអ៊ីនធើណេតក៏ប្រើអ៊ីម៉ែលនៅក្នុងយុទ្ធនាការបន្លំតាមទីផ្សារពាណិជ្ជកម្មផងដែរ។ ពួកគេប្រើបច្ចេកទេសវិស្វកម្មសង្គមដូចជា Clickbait និងកលល្បិចដើម្បីបញ្ចុះបញ្ចូលអ្នកទទួលឱ្យចូលទៅកាន់តំណភ្ជាប់បន្លំ ឬ ឯកសារភ្ជាប់ដែលមានបំណងទុច្ចរិត។ ការបញ្ចុះបញ្ចូលនេះរួមមាន ចាប់ពីការបញ្ចុះតម្លៃដ៏ច្រើនរហូតដល់កិច្ចព្រមព្រៀងវិស្សមកាល និង ការផ្តល់ការងារនានា ។ ប្រអប់សាររបស់អ្នកប្រើប្រាស់បានរកឃើញថាមានការឆ្លើយឆ្លងក្លែងបន្លំពេញមួយឆ្នាំ។ ជាពិសេសការអានសារ ឬការចុចចូលតំណដែលអ្នកបានទទួលពីបុគ្គលអាណាមិក ឬ ក្រុមហ៊ុនដែលអ្នកមិនស្គាល់នោះគឺអ្នកឆបោកអាចទាញយកផលប្រយោជន៍ពីអ្នកយ៉ាងស្វ័យប្រវត្តិ។[84]

- **ការឆបោកតាមទំនាក់ទំនងបណ្តាញសង្គម**

នៅចន្លោះថ្ងៃទី ២២ និង ២៣ ខែកុម្ភៈក្រុមហ៊ុន Bitdefender បានរកឃើញថាច្រើនជាង ២០% នៃសារឥតបានការ (SPAM Message) បានចូលទៅក្នុងទាក់ទងមិត្តភាព និងការណាត់ជួបតាមអ៊ីនធើណេត។

អ្នកឆបោកតែងតែបង្កើតគណនេយ្យអ៊ីនធើណេតក្លែងក្លាយ ហើយបានស្នើសុំលេខទូរស័ព្ទ និងអាសយដ្ឋានអ៊ីម៉ែល ជាពិសេសព័ត៌មានអត្តសញ្ញាណផ្ទាល់ខ្លួនដូចជា ថ្ងៃខែឆ្នាំកំណើត ទីកន្លែងស្នាក់នៅ និងព័ត៌មានបុគ្គលជាច្រើនទៀតដែលអាចធ្វើការចូលទៅកាន់គណនេយ្យផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់បាន ។ មិនត្រឹមតែប៉ុណ្ណោះជនឆបោកទាំងនេះ បានបង្កើតនូវអារម្មណ៍ដ៏ជឿទុកចិត្តដល់អ្នកបោកប្រាស់ រួចមកក៏ចាប់ផ្តើមស្នើសុំជំនួយហិរញ្ញវត្ថុ រហូតដល់មានការការគំរាមកំហែង ឬ ជំរិតទារប្រាក់ជាដើម។

- **ការផ្តល់ទំនិញក្លែងក្លាយ**

អ្នកលក់នៅកម្ពុជាភាគច្រើនបានធ្វើការបោកបន្លំអ្នកទិញថាទំនិញរបស់ខ្លួនជាទំនិញពិតប្រាកដជាពិតប្រាកដ ជាពិសេសទំនិញតាមការលក់អនឡាញភាគច្រើនដែលមានរូបរាងដូចទំនិញពិតៗ។ អ្នកទិញនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមិន មានហានិភ័យខ្ពស់ក្នុងការដែលមិនអាចបានមើលដោយផ្ទាល់ភ្នែក ឬស្ទាបដោយផ្ទាល់ដៃថាតើវាជាទំនិញពិតប្រាកដដែលខ្លួនចង់បាន ឬក៏អត់។ នៅត្រង់

---

[84] Bitdefender.(២០២១,ថ្ងៃទី៣ខែមិនា). ការឆបោក ១០១៖ អ្វីដែលអ្នកត្រូវដឹងដើម្បីការពារប្រឆាំងនឹងការបោកប្រាក់តាមអនឡាញនិងអត្តសញ្ញាណប័ណ្ណ. ដកស្រង់ចេញពី https://www.bitdefender.com.kh/post/scams-101-all-you-need-to-know-to-protect-against-online-fraud-and-identity-theft/. ថ្ងៃទី ២១ សីហា ២០២១។

បញ្ហានេះ អ្នកលក់ទំនិញមានភាពងាយស្រួលដោយគ្រាន់តែដាក់ផ្សព្វផ្សាយទំនិញរបស់ខ្លួនតាមអ៊ីនធើណេតដើម្បីឱ្យអ្នកទិញបានមើលឃើញរួចមកក៏បញ្ជូនទំនិញក្លែងក្លាយទៅកាន់អតិថិជន។ នេះជាបញ្ហាចម្បងក្នុងបរិបទ និង ការអនុវត្តប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

**កថាខណ្ឌទី៣៖ ការការពារទិន្នន័យឯកជនតាមច្បាប់ព្រះរាជាណាចក្រកម្ពុជា**

ប្រទេសកម្ពុជាមិនទាន់បានអនុម័តច្បាប់ការពារទិន្នន័យបុគ្គល និង ការការពារអ្នកប្រើប្រាស់តាមបណ្ដាញអ៊ីធើណេតឱ្យបានគ្រប់ជ្រុងជ្រោយ និងពេញលេញនៅឡើយទេ។ ការធ្វើបច្ចុប្បន្នភាពថ្មីបំផុតចំពោះការពារទិន្នន័យរបស់ប្រទេសកម្ពុជាបានកើតមានឡើងក្រោមច្បាប់ស្តីពី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលមានបទប្បញ្ញត្តិ សម្រាប់ការការពារទិន្នន័យអ្នកប្រើប្រាស់ដែលកើតមានអំឡុងពេលទំនាក់ទំនងអេឡិចត្រូនិក។ ដោយហេតុនេះច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិកត្រូវបានរឹតត្បិតក្នុងការការពារទិន្នន័យនិម្មិត និងឌីជីថល។ក្រៅពីនេះ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានអញ្ជើញដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សានីតិកម្មលើសេចក្ដីព្រាងច្បាប់ស្ដីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន ដែលជាច្បាប់ស្ដីពីឧក្រិដ្ឋកម្មអ៊ីនធើណេត (Cyber Crime Law) ដែលនឹងមាន០៧ ជំពូក ៤៨មាត្រា។ សេចក្ដីព្រៀងច្បាប់នេះ ជំរុញនិងលើកទឹកចិត្តលើការវិនិយោគនិងអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ស្របតាមផែនការមេស្ដីពីបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានរបស់កម្ពុជាឆ្នាំ២០២០។[85]

បើទោះបីជាមិនទាន់មានច្បាប់ដើម្បីការពារបញ្ហានេះផ្ទាល់ ការការពារទិន្នន័យឯកជនត្រូវគ្របដណ្ដប់ និងអាចធ្វើការបកស្រាយន័យច្បាប់តាមរយៈរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្រមរដ្ឋប្បវេណីកម្ពុជាព្រះរាជាណាចក្រកម្ពុជា និងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

**ក. គោលការណ៍រដ្ឋធម្មនុញ្ញ**

ជាទូទៅរដ្ឋធម្មនុញបានទទួលស្គាល់សិទ្ធិឯកជនរបស់ពលរដ្ឋខ្លួន។ យោងតាមមាត្រា ៤០ រដ្ឋធម្មនុញ្ញបានចែងថាប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិឯកជនភាពក្នុងការរស់នៅ និងការរក្សាការសម្ងាត់នៃការឆ្លើយឆ្លងតាមលិខិត សារទូរលេខ ទូរពុម្ព ទូរគមនាគមន៏ និងទូរសព្ទ័។ យ៉ាងណាក៏ដោយប្រទេសកម្ពុជាមិនទាន់មានច្បាប់ជាក់លាក់ណាមួយបកស្រាយលម្អិតអំពីអត្ថន័យឬវិសាលភាពនៃមាត្រា ៤០ នៃរដ្ឋធម្មនុញ្ញឬផ្ដល់វិធានការអនុវត្តណាមួយជាក់ស្តែងស្តីពីសិទ្ធិឯនឡើយ។ យោងតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញសិទ្ធិដែលមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ (UN CHARTER) និងសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស (UDHR) ត្រូវបានទទួលស្គាល់និងផ្ដល់សច្ចាប័នឱ្យមានវិធានស្របតាមច្បាប់កម្ពុជាចំពោះ

[85] សេចក្ដីបំភ្លឺទាក់ទងនឹងសេចក្ដីព្រៀងច្បាប់ស្ដីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៏ និងព័ត៌មាន (ICT)លេខ ៦៥៧។

ការគោរពសិទ្ធបុគ្គល រួមទាំងទិន្នន័យឯកជនផងដែរ។[86] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស បានកំណត់ថា គ្មានមនុស្សណាម្នាក់ត្រូវរងការរំលោភំពានជ្រៀតជ្រែកតាមអំពើរចិត្តក្នុងជីវិតឯកជន គ្រួសារ ទីលំនៅ ការឆ្លើយឆ្លង ឬការប៉ះពាល់ដល់កិត្តិយស និងកេរ្ត៍ឈ្មោះរបស់ខ្លួនបានឡើយ។ ជនគ្រប់រូបមានសិទ្ធទទួលការកាពារច្បាប់ប្រឆាំងនឹងការជ្រៀតជ្រែក ឬការប៉ះពាល់ទាំងនេះ។[87]

**ខ. ច្បាប់ស្តីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

ច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិក កំណត់ការបង្ហាញជាមូលដ្ឋានសម្រាប់ការការពារទិន្នន័យរបស់អ្នកប្រើប្រាស់ដែលធ្វើប្រតិបត្តិការតាមរយៈប្រព័ន្ធអេឡិចត្រូនិក។ ច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិកត្រូវបានអនុវត្តយ៉ាងទូលំទូលាយចំពោះរាល់សកម្មភាពពាណិជ្ជកម្មនិងស៊ីវិល រួមទាំងប្រតិបត្តិការទាំងឡាយណាដែលត្រូវបានអនុវត្តតាមរយៈប្រព័ន្ធអេឡិចត្រូនិក លើកលែងតែបញ្ហាដែលពាក់ព័ន្ធនឹងសិទ្ធអំណាចនៃមេធាវី មតកសាសន៍ និង អចលនទ្រព្យ ដូចដែលបានរៀបរាប់នៅផ្នែកទី ២ហត្ថលេខាឌីជីថល។

នៅក្រោមច្បាប់នេះ ការការពារទិន្នន័យឯកជនមានដូចតទៅ៖

- **ការប្រមូលទិន្នន័យអ្នកប្រើប្រាស់៖** ច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិក កំណត់និយមន័យពាក្យថាទិន្នន័យជាក្រុមតួរលេខ អក្សរ និមិត្តសញ្ញា រូបភាព សំឡេងវីដេអូព័ត៌មាន ឬកម្មវិធីអេឡិចត្រូនិកដែលរៀបចំក្នុងទម្រង់សមស្របសម្រាប់ប្រើប្រាស់ក្នុងប្រព័ន្ធទិន្នន័យឬប្រព័ន្ធអេឡិចត្រូនិក ។ វាអាចជឿជាក់បានថាទិន្នន័យណាមួយដែលប្រមូលបានក្នុងកំឡុងពេលប្រតិបត្តិការតាមអ៊ីនធើណេតអាចត្រូវបានអាជ្ញាធរត្រួតពិនិត្យមើលឃើញថាជាទិន្នន័យផ្ទាល់ខ្លួន។ ទិន្នន័យផ្ទាល់ខ្លួន ក្នុងន័យសាមញ្ញ ជាឈ្មោះ លេខអត្តសញ្ញាណជាតិ លេខលិខិតឆ្លងដែន រូបថត រូបភាព លេខទូរស័ព្ទ អាស័យដ្ឋានអ៊ីមែលផ្ទាល់ខ្លួន អាស័យដ្ឋាន IP និងអត្តសញ្ញាណបណ្តាញផ្សេងទៀតអាចជាទិន្នន័យផ្ទាល់ខ្លួនក្រោមច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិក។ មុនពេលប្រមូលទិន្នន័យផ្ទាល់ខ្លួនច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិក បានកំណត់តម្រូវការដែលអ្នកលក់ទាំងអស់គួរតែចែករំលែកព័ត៌មានមូលដ្ឋានជាមួយអតិថិជនរបស់ពួកគេមុនពេលចូលរួមក្នុងប្រតិបត្តិការពាណិជ្ជកម្ម។ បុគ្គលណាដែលប្រើទំនាក់ទំនងអេឡិចត្រូនិកដើម្បីលក់ទំនិញត្រូវផ្តល់ឈ្មោះស្របច្បាប់ និងឈ្មោះក្រុមហ៊ុន អាស័យដ្ឋានអាជីវកម្ម លេខទូរស័ព្ទទំនាក់ទំនង ការពិពណ៌នាអំពីប្រភេទទំនិញ ដែលត្រូវលក់ និងលក្ខខណ្ឌមូលដ្ឋានទាក់ទងនឹងប្រតិបត្តិការ។ បុគ្គលដែលប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិក

[86] CDRI.(២០២០, ខែមករា). Cybergovernance in Cambodia: Risk Based Approach to Cybersecurity [ការគ្រប់គ្រងតាមអ៊ីនធឺណិតនៅកម្ពុជា៖ វិធីសាស្ត្រផ្អែកលើហានិភ័យចំពោះសុវត្ថិភាពអ៊ីនធឺណិត] Special report ១៨,៧។

[87] មាត្រា១២ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR)

ដើម្បីលក់ទំនិញ ឬសេវាកម្មទៅឱ្យអ្នកប្រើប្រាស់មានកាតព្វកិច្ចជាទូទៅដើម្បីទទួលបានការយល់ព្រម មុនពេលប្រមូលនិងរក្សាទុកទិន្នន័យផ្ទាល់ខ្លួនពីអ្នកប្រើប្រាស់ផងដែរ។[88] ជាក់ស្តែងការយល់ព្រមនេះតែងតែទទួលបានតាមរយៈការទទួលយកលក្ខខ័ណ្ឌតាមអ៊ីនធើណេត ដែលតាមរយៈការប្រើប្រាស់ហត្ថលេខាអេឡិចត្រូនិក។ យោងតាមមាត្រា ៧ នៃច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិក ហត្ថលេខាអេឡិចត្រូនិកអាចអនុញ្ញាតបានតាមច្បាប់នៅពេលដែលអាចកំណត់អត្តសញ្ញាណអ្នកចុះហត្ថលេខា ហើយហត្ថលេខាត្រូវបានប្រមូលតាមរយៈមធ្យោបាយដែលអាចទុកចិត្តបាន។

- **ការថែរក្សាទុកទិន្នន័យ៖** ច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិកកំណត់កាតព្វកិច្ចការពារទិន្នន័យឯកជនរបស់អ្នកផ្តល់សេវាកម្មពាណិជ្ជកម្មអេឡិចត្រូនិក និងអន្តរការីដូចគ្នា។ មិនមានដែនកំណត់ពេលវេលាអតិបរមាកំណត់សម្រាប់ការរក្សាទុកទិន្នន័យផ្ទាល់ខ្លួនទេហើយប្រសិនបើបុគ្គលណាមួយបានជូនដំណឹងយ៉ាងច្បាស់អំពីទិន្នន័យរបស់ខ្លួន អំពីការរក្សាទុកទិន្នន័យផ្ទាល់ខ្លួនគ្មានដែនកំណត់ ការរក្សាទុកត្រូវបានអនុញ្ញាតដោយច្បាប់។ ខណៈដែលច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិកក៏មិនបានកំណត់ពីពេលវេលាកំណត់អប្បបរមាសម្រាប់ការរក្សាទុកទិន្នន័យ នេះសរបញ្ជាក់ថានៅពេលអន្តរការី ឬអ្នកផ្តល់សេវាកម្មដឹងថាព័ត៌មាននៅក្នុងកំណត់ត្រាអាចនាំឱ្យមានការទទួលខុសត្រូវស៊ីវិល ឬព្រហ្មទណ្ឌពួកគេត្រូវដកចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួនហើយឈប់ផ្តល់សេវាទាក់ទងនឹងព័ត៌មាននោះ រួមទាំងរក្សាទុកព័ត៌មានជាភស្តុតាង និងជូនដំណឹងដល់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ឬស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធអំពីអង្គហេតុ និងអត្តសញ្ញាណនៃជនសង្ស័យ។[89]កាតព្វកិច្ចរក្សានេះបង្ហាញថា អ្នកផ្តល់សេវាកម្ម និងអន្តរការីត្រូវបានគេរំពឹងថានឹងរក្សាទុកទិន្នន័យដែលប្រមូលបានក្នុងរយៈពេលសមរម្យ។ ថ្វីបើច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិក មិនបានចែងអំពីរយៈពេលអប្បបរមា ឬអតិបរមាសម្រាប់ការរក្សាទុកទិន្នន័យឯកជន ឬឯកសារដែលមានទិន្នន័យឯកជនក៏ដោយក៏ច្បាប់ផ្សេងទៀតផ្តល់នូវគោលការណ៍ណែនាំជាមូលដ្ឋានមួយចំនួនសម្រាប់រយៈពេលដែលព័ត៌មានជាទូទៅគួររក្សាទុកនៅគ្រប់វិស័យ។ កំណត់ត្រាគណនេយ្យ វិក័យប័ត្រពន្ធ និងកំណត់ត្រានាំចូល និងនាំចេញគួរតែត្រូវបាន

[88] សូមពិគ្រោះ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា នស/រកម/១១១៩/០១៧/, ០២ វិច្ឆិកា ២០១៩, មាត្រា ២៩។

[89] សូមពិគ្រោះ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា នស/រកម/១១១៩/០១៧/, ០២ វិច្ឆិកា ២០១៩, មាត្រា ២៥។

រក្សាទុកយ៉ាងហោចណាស់ដប់ឆ្នាំ។ឧទាហរណ៍ ខណៈដែលបញ្ជីបើកប្រាក់ខែគួរតែត្រូវបានរក្សាទុកយ៉ាងហោចណាស់បីឆ្នាំ។

- **ការការពារទិន្នន័យអ្នកប្រើប្រាស់៖** អ្នកផ្តល់សេវាកម្មដែលរក្សាទុកព័ត៌មានឯកជនរបស់អ្នកប្រើប្រាស់តាមអេឡិចត្រូនិកត្រូវចាត់វិធានការសុវត្ថិភាព សមហេតុផលទាំងអស់ដើម្បីចៀសវាងការបាត់បង់ ការកែប្រែ ការលេចធ្លាយ និង ការមិនអនុញ្ញាតឱ្យមានការបង្ហាញទិន្នន័យអ្នកប្រើប្រាស់។ ដោយឡែកនៅក្នុងករណីមួយចំនួនដែលទិន្នន័យឯកជន អាចអនុញ្ញាតបានដោយមានការយល់ព្រមពីអាជ្ញាធរ ឬដោយមានការយល់ព្រមពីបុគ្គល ដែលទិន្នន័យរបស់ខ្លួនកំពុងត្រូវបានបង្ហាញ។[90] ច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិកក៏ហាមឃាត់រាល់ការប្រើប្រាស់ទិន្នន័យឯកជនធ្វើជាភស្តុតាងសម្រាប់ការចោទប្រកាន់ឬបទល្មើសណាមួយ។ កាតព្វកិច្ចនេះមានសក្តានុពលអនុញ្ញាតឱ្យអាជ្ញាធ និងរដ្ឋាភិបាលយកបាននូវទិន្នន័យដែលជាប់ពាក់ព័ន្ធក្នុងការស៊ើបអង្កេត។ ច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិកក៏ហាមឃាត់រាល់ទម្រង់នៃឧក្រិដ្ឋកម្មតាមអ៊ិនធរណេត រួមទាំងការជ្រៀតជ្រែកជាមួយប្រព័ន្ធអេឡិចត្រូនិកណាមួយ ក្នុងគោលបំណងចូលប្រើទាញយកចម្លង ដកស្រង់ លុប ឬកែប្រែទិន្នន័យដែលបានរក្សាទុកដោយមិនស្មោះត្រង់ឬដោយគ្មានការអនុញ្ញាតឡើយ ។

### ៣.៣ គោលការណ៍ក្រមរដ្ឋប្បវេណី

ទោះបីជាប្រទេសកម្ពុជាមិនបានអនុម័តច្បាប់ការពារទិន្នន័យគ្រប់ជ្រុងជ្រោយក៏ដោយក៏ទិន្នន័យឯកជន របស់បុគ្គលម្នាក់ៗអាចត្រូវបានការពារក្រោមក្រមរដ្ឋប្បវេណីដែលជាផ្នែកមួយ នៃសិទ្ធបុគ្គល។ បុគ្គលម្នាក់ៗមានសិទ្ធិទទួលបានសិទ្ធបុគ្គល ដែលសំដៅលើសិទ្ធដែលមានអត្ថន័យពាក់ព័ន្ធនឹងជីវិត រូបកាយ សុខភាព សេរីភាព នាម កិត្តិយស ភាពឯកជន ឬសិទ្ធផ្សេងទៀតដែលជាផលប្រយោជន៏ទាក់ទង[91]នឹងលក្ខណបុគ្គល។ នៅក្នុងផ្នែកច្បាប់នេះអាចត្រូវបានបកស្រាយថាជាការការពារទិន្នន័យផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗដែលជាផ្នែកមួយនៃសិទ្ធិបុគ្គល។ បុគ្គលម្នាក់ៗមាននូវសិទ្ធិទាមទារឱ្យបញ្ឈប់នូវការរំលោភសិទ្ធិ ប្រសិនបើមានការបារម្ភថា នឹងអាចមានការរំលោភសិទ្ធបុគ្គលដោយខុសច្បាប់ ឬមានការបារម្ភថា ការរំលោភសិទ្ធបុគ្គលដែលបានកើតឡើងហើយនោះនឹងអាចបន្តរ ឬនឹងអាចកើតឡើងទៀតដោយខុសច្បាប់ អ្នកកាលនឹងបន្តឬកើតឡើងម្តងទៀតដោយខុសច្បាប់។[92] ដូចគ្នាផងដែរ ប្រសិនបើ

---

[90] សូមពិគ្រោះ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា នស/រកម/១១១៩/០១៧/, ០២ វិច្ឆិកា ២០១៩, មាត្រា ៣២។

[91] សូមពិគ្រោះ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,នស/រកម/១២០៧/០៣០/, ០៨ ធ្នូ ២០០៧, មាត្រា១០។

[92] សូមពិគ្រោះ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,នស/រកម/១២០៧/០៣០/, ០៨ ធ្នូ ២០០៧, មាត្រា១១។

ទិន្នន័យផ្ទាល់ខ្លួនដែលជាសិទ្ធិបុគ្គល ម្ចាស់សិទ្ធិអាចស្នើសុំដីកាពីតុលាការដើម្បីបញ្ឈប់ការរំលោភបំពានដោយខុសច្បាប់នូវការរំលោភបំពានទិន្នន័យផ្ទាល់ខ្លួន។ ឧទាហរណ៍ការប្រមូលទិន្នន័យដោយគ្មានការយល់ ព្រម។ នៅក្នុងបរិបទទិន្នន័យឯកជន ក្រមរដ្ឋប្បវេណីបានផ្ដល់ជារនាំងការពារទិន្នន័យឯកជនសម្រាប់បុគ្គលម្នាក់ៗយ៉ាងមានប្រសិទ្ធភាព ព្រមទាំង អនុញ្ញាតឱ្យបុគ្គលម្នាក់ទាមទារចំពោះអំពើអនីត្យានុកូលណាមួយដែលបណ្ដាលមកពីការរំលោភសិទ្ធិឯកជនរបស់ពួកគេ។[93]

**កថាខណ្ឌទី៤៖ កិច្ចអភិវឌ្ឍក្របខណ្ឌកិច្ចការពារអ្នកប្រើប្រាស់នៅកម្ពុជា**

កក្ដាសន្តិសុខ ទូរគមនាគមន៍ បច្ចេកវិទ្យា គមនាគមន៍ និង ព័ត៌មាន ជាចំនុចសំខាន់ដើម្បីពង្រឹងសុវត្ថិភាពដល់អ្នកប្រើប្រាស់នៅក្នុងសង្គមឌីជីថលនេះ។ ស្របតាមគោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលតី៤ និងនីតិកាលទី៥ ក៏ដូចជាក្នុងគោលដៅត្រៀមរៀបចំមូលដ្ឋានសម្រាប់ការឈានឡើងរបស់កម្ពុជាទៅកាន់ដំណាក់កាលថ្មីនៃការអភិវឌ្ឍ ពិសេសការធានាភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុងវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលមានការចូលរួមយ៉ាងសំខាន់ពីរដ្ឋាភិបាលកម្ពុជាក្នុងការបន្តជំរុញការអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានឱ្យមានកិច្ចការពារអ្នកប្រើប្រាស់អ៊ីនធើណេតយ៉ាងល្អប្រសើរ មានលក្ខណៈទំនើប ទាន់សម័យ មានគុណភាពខ្ពស់ស្របតាមស្តង់ដារអន្តរជាតិ មានការប្រកួតប្រជែងខ្ពស់ និងមានសេវាគ្របដណ្ដប់នៅទូទាំងប្រទេស ដែលប្រជាជនទូទៅអាចប្រើប្រាស់បានដោយមានសុវត្ថភាព និងទទួលបានផលប្រយោជន៍គ្រប់ៗគ្នាពីសេវានេះតាមរយៈការពង្រឹងក្របខ័ណ្ឌគតិយុត្តិ ការកសាងសមត្ថភាពស្ថាប័ន ការធ្វើតំនើបកម្មមូលដ្ឋានសម្ភារៈបច្ចេកទេស ជាមួយឆ្អឹងខ្នងយ៉ាងរឹងមាំរដ្ឋបាលអេឡិចត្រូនិក។[94]

**ក. ក្របខ័ណ្ឌគតិយុត្តិ និងស្ថាប័នសម្របសម្រួល**

ទាក់ទងនឹងកិច្ចការពារអ្នកប្រើប្រាស់ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំសេចក្ដីព្រៀងច្បាប់ និងបទប្បញ្ញត្តិដែលទាក់ទងនានាជាច្រើនដើម្បីចូលរួមផ្ដល់ជាការប្រើប្រាស់ឬធ្វើប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឱ្យមានសុវត្ថភាព ដូចជាច្បាប់ស្ដីពីគមនាគមន៍ ច្បាប់ស្ដីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ច្បាប់ស្ដីពីសិទ្ធអ្នកនិពន្ធ និងសិទ្ធប្រហាក់ប្រហែល និងបទប្បញ្ញត្តិពាក់ព័ន្ធនានាត្រូវបានអនុម័តរួចរាល់។ ទោះបីជាមានភាពរីកចម្រើនគួរឱ្យកត់សម្គាល់ក្ដី កម្ពុជានៅបន្តខ្វះចន្លោះក្របខណ្ឌគោលនយោបាយ ដើម្បីឆ្លើយតបទៅនឹងស្ថានភាព និងនិន្នាការនៃការវិវត្តយ៉ាងឆាប់រហ័សខាងផ្នែកបច្ចេកវិទ្យា រួមមាន៖

[93] សូមពិគ្រោះ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,នស/រកម/១២០៧/០៣០/, ០៨ ធ្នូ ២០០៧, មាត្រា១៣។

[94] ទីស្ដីការគណៈរដ្ឋមន្ត្រី លេខ ៧៧៣សជណ.(២០១៦ ខែមេសា). "ឆ្ពោះទៅសន្តិភាព និងកម្មញភាពនៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន". *គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ បច្ចេកវិទ្យទូរគមនាគមន៍ និង ព័ត៌មានឆ្នាំ២០២០* ហៅកាត់ (ទ.ប.គ.ព.)។

- ក្របខ័ណ្ឌគោលនយោបាយនិងគតិយុត្តិដើម្បីធានាបាននូវប្រសិទ្ធភាព ស្ថិរភាព សន្តិសុខ និងភាពបន្សុីគ្នានៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ ដើម្បីកុំឱ្យមានបទល្មើសតាមអ៊ីនធើណេត និងធានាបាននូវទំនុកចិត្តក្នុងការប្រើប្រាស់ ការទាក់ទាញការវិនិយោគ និងបង្កើនការប្រកួតប្រជែងលើវិស័យទូរគមនាគមន៍ក្នុងស្រុក ក៏ដូចជារក្សាបាននូវឧត្តមភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងវិស័យកិច្ចការពារអ្នកប្រើប្រាស់របស់កម្ពុជាក្នុងតំបន់ និង ក្នុងពិភពលលោក។
- យន្តការនៃការគ្រប់គ្រង ត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើការប្រើប្រាស់ធនធានទូរគមនាគមន៍កម្រជាអាទ៍ វិសាលគមន៍ប្រេកង់ស៊ីវិទ្យុ ក្បាលលេខទូរគមនាគមន៍ អាសយដ្ឋានអេឡិចត្រូនិក និងអាសយដ្ឋានឌីអិនអេស ដើម្បីធានានូវប្រសិទ្ធភាពនៃការប្រើប្រាស់ និងបរិយាបន្ន័នៃវិស័យទូរគមនាគមន៍ បច្ចេកវិទ្យា និងព័ត៌មាន ក្នុងការគៀគរចំណូលថវិកាជាតិ ព្រមទាំងកាត់បន្ថយបទល្មើសដែលកើតឡើងតាមអ៊ីនធើណេតជាយថាហេតុ។

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍មានតួនាទីគ្រប់គ្រងលើវិស័យនេះ មានតួរនាទីសំខាន់ដូចជា ការបង្កើតគោលនយោបាយ ការគ្រប់គ្រងសហគ្រាសជាតិ និងការសម្របសម្រួលកិច្ចការអន្តរជាតិក្នុងវិស័យទូរគមនាគមន៍នេះផងដែរ។ ទោះជាយ៉ាងនេះក្តី កម្ពុជាមិនទាន់បានកំណត់ភារកិច្ចសម្របសម្រួលបច្ចេកទេស ឱ្យមានលក្ខណៈរួមមួយសម្រាប់ការការពារចរាចរណ៍មាតិការនៅក្នុងវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅឡើយ រួមទាំងយន្តការការងារលម្អិតបន្ថែមដល់ក្រសួងឱ្យបានជាក់លាក់នៅឡើយក្នុងការសម្របសម្រួលជាមួយក្រសួងស្ថាប័នរដ្ឋដទៃទៀតនៅក្នុងក្របខ័ណ្ឌនៃការប្រើប្រាស់ និងរក្សាសន្តិសុខនៃប្រព័ន្ធទូរមនាគមន៍នេះ។ កង្វះខាតនេះ អាចធ្វើឱ្យកម្ពុជាប្រឈមធ្ងន់ធ្ងរទៅនឹងការមិនអាចភ្ជាប់ទំនាក់ទំនងបានរវាងប្រព័ន្ធសូហ្វវែរកម្មវិធីដែលបានរៀបចំ និងប្រើប្រាស់ដាច់ដោយឡែកពីគ្នា ព្រមទាំងហានិភ័យផ្នែកសន្តិសុខទិន្នន័យឯកជនដែលជាកក្តាចម្បងនៃកិច្ចការពារអ្នកប្រើប្រាស់។

### ខ. ប្រព័ន្ធសន្តិសុខទូរគមនាគមន៍ បច្ចេកវិទ្យា និងព័ត៌មានវិទ្យា

សន្តិសុខនៃបណ្តាញទំនាក់ទំនងអ៊ីនធើណេត ជាកក្តាមួយដែកវាស់វែងអំពីភាពរួចរាល់របស់កម្ពុជាក្នុងការប្រើប្រាស់ទូរគមនាគមន៍ បច្ចេកវិទ្យា និងព័ត៌មានវិទ្យានៅក្នុងវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ ដោយហេតុថាការគំរាមកំហែងបែបណាមួយទៅលើប្រព័ន្ធព័ត៌មាននៅយុគសម័យអ៊ីនធើណេតនេះ ជាការប៉ះពាល់ដល់សុវត្ថិភាពទិន្នន័យឯកជន និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់ រួមទាំងមានផលវិជ្ជមានដល់សេដ្ឋកិច្ចជាតិទាំងមូល។ ការវាយប្រហារទៅលើប្រព័ន្ធអ៊ីនធើណេត និងទូរគមនាមន៍នៅកម្ពុជា បានកើតឡើងជាបន្តបន្ទាប់ និងមានគោលបំណងដោយឡែកពីគ្នាដែលមួយចំនួនមានការ

ពាក់ព័ន្ធទៅនឹងរឿងនយោបាយ សេដ្ឋកិច្ច ឧក្រិដ្ឋកម្ម ភេរវកម្ម ចារកម្ម និងសន្តិសុខជាតិជាដើម។[95] រីឯឧបករណ៍ដែលប្រើប្រាស់ និងបច្ចេកទេសសម្រាប់ការប្រព្រឹត្តិបទល្មើស និងសកម្មភាពវាយប្រហារនានានៅក្នុងប្រព័ន្ធអ៊ីនធើណេត មានលក្ខណៈកាន់តែទំនើប ពិបាកក្នុងការការពារ និងទប់ស្កាត់។ នាពេលកន្លងមក មានការវាយប្រហារខ្នាតធំជាច្រើនកើតឡើងទៅលើហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់ប្រទេសមួយចំនួន ដូចជាការវាយប្រហារទៅក្នុងប្រព័ន្ធគ្រប់គ្រងរោងចក្រនុយក្លេអ៊ែររបស់ប្រទេសអ៊ីរ៉ង់ក្នុងឆ្នាំ ២០១០ ការវាយប្រហារទៅលើប្រព័ន្ធចម្រោះទឹកស្អាតនៅសហរដ្ឋអាមេរិច ព្រឹត្តិការណ៍លួចលុយពីប្រព័ន្ធកុំព្យូទ័រធនាគារពី៣០០ទៅ៩០០លានដុល្លានៅលើពិភពលោកដោយក្រុមហ៊ុនអេឃ្វេសិន (Equatio) ក្នុងឆ្នាំ ២០១៥ និងការលួចឬបំផ្លាញទិន្នន័យឯកជនរបស់អ្នកប្រើប្រាស់ជាង ៦០០ លានករណីជាដើម ។ល។ ទន្ទឹមនឹងការវិវត្តទៅមុខឥតឈប់ឈររបស់បច្ចេកវិទ្យានេះ បញ្ហាសន្តិសុខ និងឯកជនភាពគឺជាចំណុចចម្បងមួយក្នុងចំណោមចំណុចជាច្រើននៃការព្រួយបារម្ភរបស់ឧស្សាហកម្មទូរគមនាគមន៍ បច្ចេកវិទ្យា និងព័ត៌មានវិទ្យា។[96]

ការកើនឡើងនូវសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងប្រតិបត្តិការហិរញ្ញវត្ថុដែលជាការទូទាត់ប្រាក់តាមប្រព័ន្ធអ៊ីនអឺណេតសម្រាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងចរន្តនៃការវិវត្តទៅរកការប្រព័ន្ធអ៊ីនធើណេតនៃវត្ថុ ដែលមនុស្ស និងវត្ថុជាច្រើនត្រូវបានតភ្ជាប់ទៅនឹងប្រព័ន្ធអ៊ីនធើណេត គឺជាកត្តាមួយដ៏សំខាន់ដែលជំរុញឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ទន្ទឹមនឹងនោះ សន្តិសុខនៅក្នុងការប្រើប្រាស់សេវា ទូរគមនាគមន៍ បច្ចេកវិទ្យា និងព័ត៌មានវិទ្យា គឺជាបញ្ហាសំខាន់មួយដែលត្រូវយកចិត្តទុកដាក់ខ្ពស់បំផុត ដើម្បីធានាឱ្យបាននូវផលវិជ្ជមានពីការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យានេះ។ នារយៈកាលកន្លងមក កម្ពុជាបានបង្កើតមជ្ឈមណ្ឌលឆ្លើយតបទៅនឹងបញ្ហាបន្ទាន់នៃកុំព្យូទ័រ (CamCERT) ដើម្បីឆ្លើយតបទៅនឹងបញ្ហាបន្ទាន់នានាដែលទាក់ទងទៅនឹងសន្តិសុខទូរគមនាគមន៍។ កិច្ចប្រឹងប្រែងនេះបានធ្វើឱ្យភាពរួចរាល់របស់កម្ពុជាខាងផ្នែកសន្តិសុខព័ត៌មាន មានភាពប្រសើរឡើងជាលំដាប់។ ភាពរួចរាល់ផ្នែកសន្តិសុខព័ត៌មាននៅកម្ពុជាដែលត្រូវបានវាស់វែងក្នុងឆ្នាំ២០១៤ ដោយសហគមន៍ទូរគមនាគមន៍អន្តរជាតិមានចំនួន 0.១១៨ គឺស្មើនឹង១.១៨%។ សន្ទស្សន៍នេះ បានមកពីការពិនិត្យលើក្របខ័ណ្ឌគតិយុត្តិ អង្គភាព

[95] ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ៧៧៣សជណ.(២០១៦ ខែមេសា). "ឆ្ពោះទៅសន្តិភាព និងកម្មញភាពនៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន". *គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ បច្ចេកវិទ្យទូរគមនាគមន៍ និង ព័ត៌មានឆ្នាំ២០២០* ហៅកាត់ (ទ.ប.គ.ព.)។

[96] ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ៧៧៣សជណ.(២០១៦ ខែមេសា). "ឆ្ពោះទៅសន្តិភាព និងកម្មញភាពនៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន". *គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ បច្ចេកវិទ្យទូរគមនាគមន៍ និង ព័ត៌មានឆ្នាំ២០២០* ហៅកាត់ (ទ.ប.គ.ព.)។

បច្ចេកទេស ស្ថាប័នសម្របសម្រួល ការបណ្តុះបណ្តាលសមត្ថភាព និងកិច្ចសហប្រតិបត្តិការ អន្តរជាតិលើវិស័យនេះ។

បច្ចុប្បន្នកម្ពុជាកំពុងប្រឈមនឹងបញ្ហានឹងបញ្ហាជាច្រើនទាក់ទងនឹងវិស័យនេះ ដូចជាក្របខ័ណ្ឌគតិយុត្តិ កង្វះយន្តការសម្របសម្រួលថ្នាក់ជាតិលើផ្នែកសន្តិសុខទូរគមនាគមន៍ កង្វះស្តង់ដារសន្តិសុខ កង្វះប្រព័ន្ធត្រួតពិនិត្យផ្នែកសន្តិសុខ និងកង្វះយន្តការបញ្ជ្រាបការយល់ដឹងអំពីបញ្ហានេះដល់សាធារណៈជនជាដើម។ ការដោះស្រាយបញ្ហាប្រឈមជាមូលដ្ឋានទាំងនេះ គឺជាភាពចាំបាច់បំផុតមួយដើម្បីធានាសម្រេចបាននូវគោលដៅខាងលើ។

# ជំពូកទី ៣

# ឧបសគ្គនៃការរីកចម្រើនវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា

# ជំពូកទី៣

# ឧបសគ្គនៃការរីកចម្រើនវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ទោះបីជាវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានការរីកចម្រើនលឿននាសម័យបច្ចុប្បន្នក៏ពិតមែនក្តី ប៉ុន្តែនៅមានបញ្ហាមួយចំនួនដែលកំពុងប្រឈមផងដែរ ។ វិបត្តិកូវីដ ១៩ បានពន្លឿនការពង្រីកពាណិជ្ជកម្មតាមអេឡិចត្រូនិកឆ្ពោះទៅរកក្រុមហ៊ុនថ្មី អតិថិជនថ្មី និងផលិតផលថ្មី។ វាបានផ្តល់ឱ្យអតិថិជននូវលទ្ធភាពទទួលបាននូវផលិតផលជាច្រើនប្រភេទដើម្បីផ្តល់ភាពងាយស្រួល និង សុវត្ថិភាពដល់ការរស់នៅរបស់ពួកគេ និងបានអនុញ្ញាតឱ្យក្រុមហ៊ុននានា អាចបន្តប្រតិបត្តិការទោះបីជាមានការរឹតត្បិតទំនាក់ទំនងនិងវិធានការឃាត់ឃាំងផ្សេងៗក៏ដោយ។ ថ្វីបើមានភាពខុសប្លែកគ្នាពីបណ្តារប្រទេសក្នុងសកលលោកក៏ដោយ វិបត្តិកូវីដ ១៩ បានធ្វើឱ្យមានភាពរឹងមាំនៅក្នុងវិស័យពាណិជ្ជកម្មអេឡិចត្រូនិកនៅទូទាំងប្រទេស និងបានពង្រីកវិសាលភាពនៃពាណិជ្ជកម្មអេឡិចត្រូនិក រួមទាំងពង្រឹងនូវសក្តានុពលក្រុមហ៊ុនថ្មីៗខាងផ្នែកអ្នកប្រើប្រាស់ និងផលិតផល ។ ទន្ទឹមនឹងនេះការធ្វើពាណិជ្ជកម្មតាមអេឡិចត្រូនិកនៅក្នុងប្រទេសជាច្រើន បានផ្លាស់ប្តូរមួយផ្នែកពីទំនិញ និងសេវាកម្មប្រណីតទៅជាតម្រូវការប្រចាំថ្ងៃដែលទាក់ទងនឹងបុគ្គលមួយចំនួនធំ។ ដោយនៅក្នុងជំពូកទី៣ នេះគឺយើងស្វែងយល់ទៅលើ ៣ ផ្នែកសំខាន់ៗគឺ **ផ្នែកទី១ គឺបញ្ហាប្រឈមនៃវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា** ដែលផ្តោតសំខាន់ទៅលើកត្តាមួយចំនួន ដែលមិនទាន់មានភាពសម្បូរបែប និង ជឿនលឿន ចំណែកឯ **ផ្នែកទី២គឺ ផលប៉ះពាល់នៃជំងឺកូវីត-១៩ ទៅលើវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** សំដៅទៅលើកត្តាផ្សេងៗ ដែលទទួលរងឥទ្ធិពលពីជំងឺកូវីត-១៩ ទាំងផលវិជ្ជមាន និងអវិជ្ជមាន។ រីឯ**ផ្នែកទី៣ ឥទ្ធិពល នៃវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា** ដែលបង្ហាញពីបទពិសោធន៍ និង ការឆ្លងការនូវនៅទំនាក់ទំនងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នាពេលរីករាលដាលនៃជំងឺកូវីត-១៩។

## ផ្នែកទី១៖ បញ្ហាប្រឈមនៃវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា

អាជីវកម្មខ្នាតតូច និងមធ្យមត្រូវបានគេចាត់ទុកថាជាកម្លាំងជំរុញដល់កំណើនសេដ្ឋកិច្ចសម្រាប់បណ្តារប្រទេសមានសេដ្ឋកិច្ចកំពុងរីកលូតលាស់ ដោយបានជំរុញនូវការបង្កើតការងារនៅទូទាំងប្រទេស។ សន្ទុះកំណើនអាជីវកម្មខ្នាតតូច និង មធ្យមជាហេតុធ្វើឱ្យអត្រាគ្មានការងារបានថយចុះគួរឱ្យកត់សម្គាល់ដែលជាលទ្ធផលបណ្តាលឱ្យមានការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេស។ ដូចគ្នាទៅនឹងប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀតដែរអាជីវកម្មខ្នាតតូច និង មធ្យមជាឆ្អឹងខ្នងនៃកំណើនសេដ្ឋកិច្ចកម្ពុជាដែលបានចូលរួមដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច ស្ថេរភាពសង្គម និងរួមចំណែកនៃវិស័យឯកជនយ៉ាងខ្លាំង។ វាជាការពិតណាស់ដែលពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកគឺពឹងផ្អែកទាំងស្រុង ទៅលើហេដ្ឋារចនាសម្ព័ន្ធនៃបច្ចេកវិទ្យា

ដែលជាទូទៅមានតម្លៃថ្លៃសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ដែលមានសេដ្ឋកិច្ចនៅមានកម្រិត។[97] ហេតុនេះហើយទើបសិក្សាទៅលើ **កថាខណ្ឌទី១ ចរាចរណ៍ប្រព័ន្ធអ៊ីនធើណេត និង សេដ្ឋកិច្ចអាជីវកម្មនៅកម្ពុជា** គ្រប់ប្រភេទ និង ទំហំនៃអាជីវកម្ម ដែលមានសារៈសំខាន់សេដ្ឋកិច្ច ម្យ៉ាងវិញទៀតចំពោះព្រោះអតិថិជនអាចមានជម្រើសជាច្រើនក្នុងការទិញទំនិញ និង ជាកត្តាសំខាន់នៅក្នុងវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ព្រោះពាណិជ្ជកម្មនេះពឹងផ្អែកទាំងស្រុងទៅលើវិស័យអ៊ីនធើណេត។ **កថាខណ្ឌទី៣ ការប្រើប្រាស់សេវាធនាគារនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា** និង **កថាខណ្ឌទី៣ ហេដ្ឋារចនាសម្ព័ន្ធភស្តុភារពាណិជ្ជកម្មក្នុងស្រុក** គឺបង្ហាញអំពីការរៀបចំ លេខកូដតំបន់ និងអាស័យដ្ឋានត្រឹមត្រូវជាកត្តាសំខាន់ដែលធ្វើឱ្យវិស័យនេះឈានទៅមុខបានយ៉ាងឆាប់រហ័សព្រោះ វាផ្តល់ នូវទំនាក់ទំនងល្អក្នុងការគ្រប់គ្រងរដ្ឋបាលក្នុងតំបន់ឱ្យមានប្រសិទ្ធភាព និង ស្ថេរភាពក្នុងការរស់នៅឱ្យមានស្តង់ដារខ្ពស់ក្នុងសង្គមបច្ចុប្បន្ន និង រៀបចំកសាងនូវរចនាសម្ព័ន្ធរដ្ឋបាលថ្មីនៃការរៀបចំលេខកូដតំបន់ និងអាស័យដ្ឋានត្រូវការសិក្សាលម្អិតពីទីតាំង អ្នកជំនាញត្រឹមត្រូវ កក្តាចម្បងសម្រាប់ឱ្យការផ្លាស់ប្តូរនេះបានទទួលជោគជ័យ។

## កថាខណ្ឌទី១៖ ចរាចរណ៍ប្រព័ន្ធអ៊ីនធើណេត និង សេដ្ឋកិច្ចអាជីវកម្មនៅកម្ពុជា

### ក. សេដ្ឋកិច្ចអាជីវកម្មនៅកម្ពុជា

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានសារៈសំខាន់ចំពោះគ្រប់ប្រភេទ និង ទំហំនៃអាជីវកម្ម ព្រោះអតិថិជនអាចមានជម្រើសជាច្រើនក្នុងការទិញទំនិញ។ នៅកម្ពុជានាពេលបច្ចុប្បន្នការលក់ទំនិញប្រើប្រាស់តាមរយៈអនឡាញ គឺត្រូវបានរាប់បញ្ចូលជាអាជីវកម្មខ្នាតតូច ដោយការលក់ទំនិញទាំងនេះគឺការផ្សព្វផ្សាយលក់ផលិតផលដោយអ្នកលក់ផ្ទាល់ ដោយការនិយមប្រើប្រាស់បណ្តាញសង្គមហ្វេសប៊ុក និងអ៊ីនស្តាក្រាមសម្រាប់ជាថ្នាលដាក់លក់ផលិតផលនិងទំនាក់ទំនងផ្ទាល់ជាមួយអតិថិជនក្នុងស្រុក។ ការលក់ទំនិញតាមរយៈ ប្រព័ន្ធអេឡិចត្រូនិករបៀបនេះបានផ្តល់ការងាយស្រួល និងមានភាពឆាប់រហ័សដល់អ្នកប្រើប្រាស់ និងអតិថិជនក្នុងស្រុក។វាបានធ្វើឱ្យមានលំហូរនៃការទិញលក់ផលិតផលក្នុងស្រុកកើនឡើងជាលំដាប់។ ផ្ទុយទៅវិញ អាជីវកម្មខ្នាតតូចដែលមានលក្ខណៈជាឯកជនបែបនេះ បានធ្វើឱ្យផលិតផលមិនអាចបញ្ចេញទៅទីផ្សារក្រៅប្រទេសបានឡើយ ជាសាមញ្ញមានតែអតិថិជនក្នុងស្រុកប៉ុន្នោះដែលបានស្គាល់ និង អាចចូលទៅកាន់គេហទំព័រ ឬ គណនេយ្យលក់ផលិតផលនោះបាន។ វាមានចំនួន

[97] Yun Seon Kim និង Sok Sonita Khoeurn. (២០១៧,ខែសីហា). Barrier to E-Commerce Business Model in Cambodia and The Suggestion [ការរារាំងនូវគំរូអាជីវកម្មនៃពាណិជ្ជកម្មអេឡិចត្រូនិកនៅកម្ពុជាជាមួយនឹងការផ្តល់យោបល់]. *Asia Pacific Journal of Business Review* ៧(១):៦៩-៨៥។

តិចតួចណាស់ដែលអាជីវកម្មធុនតូច ឬ មធ្យមមានវត្តមាននៅក្នុងវេបសាយជាក់លាក់មួយសម្រាប់ឱ្យអតិថិជនគ្រប់ប្រភេទបានចូលទៅទស្សនា។

### ខ. ហេដ្ឋារចនាសម្ព័ន្ធអ៊ីនធើណេត

កង្វះខាតហេដ្ឋារចនាសម្ព័ន្ធអ៊ីនធើណេត គឺជាកត្តាឧបសគ្គនៅក្នុងការធ្វើឱ្យអាជីវកម្មខ្នាតតូចឱ្យមានភាពរីកដុះដាល ក្នុងប្រព័ន្ធអេឡិចត្រូនិកព្រោះនៅក្នុងសម័យកាលឌីជីថលនេះ អ៊ីនធើណេតគឺជាម៉ាស៊ីនជំរុញឱ្យមានតំណរភ្ជាប់ព័ត៌មាន និង ទិន្នន័យ។ ជាសមញ្ញ ការរីកចម្រើននៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវការអ៊ីនធើណេតដែលមានគុណភាពល្អ ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកប្រើប្រាស់។ នៅក្នុងតំបន់អាស៊ាន គុណភាពទូទៅនៃហេដ្ឋារចនាសម្ព័ន្ធអ៊ីនធើណេតមានលក្ខណៈសមប្រកម ជាមួយនឹងអត្រាទូទៅនៅក្នុងពិភពលោក។ ទោះយ៉ាងណាក៏ដោយការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទាក់ទងនឹងព័ត៌មានវិទ្យាក្នុងប្រទេសនៃអាស៊ានមួយចំនួនក៏នៅតែមានកង្វះខាត ហេដ្ឋារចនាសម្ព័ន្ធល្អផងដែរ។ ក្នុងនោះមានកម្ពុជាផងដែរ ជាពិសេសការតភ្ជាប់អ៊ីនធើណេតទៅកាន់តំបន់ដាច់ស្រយាល ឬតាមបណ្តារខេត្តមួយចំនួន។

ជាទូទៅកត្តា ៥ ដែលត្រូវបានលើកយកមកពិចារណាក្នុងការធ្វើឱ្យប្រសើរឡើងនូវការតភ្ជាប់បណ្តាញអ៊ីនធើណេតដូចជា (១) បណ្តាញគ្របដណ្តប់ល្អ, (២) ល្បឿននៃការតភ្ជាប់អ៊ីនធើណេត, (៣) តម្លៃសមរម្យ, (៣) មាតិកាតាមអ៊ីនធើណេត។ ចំពោះ បណ្តាញគ្របដណ្តប់ល្អនៃប្រព័ន្ធអ៊ីនធើណេត ត្រូវការជាវយក និង ប្រើប្រាស់សេវាកម្មអ៊ីនធើណេតអ៊ិនថេរក្នុងតំបន់ (Fixed Line Broadband)។ ចំពោះបញ្ហានេះមិនត្រឹមតែ កម្ពុជាទេ ដែលមានកម្រិតប្រើប្រាស់ទាប ប្រទេសនៅក្នុងអាស៊ានភាគច្រើនគឺនៅមានកម្រិតទាបផងដែរបើប្រៀបជាមួយនឹងប្រទេសអភិវឌ្ឍផ្សេងៗដូចជា ប្រទេសកូរ៉េ និងជប៉ុនជាដើម។ មូលហេតុមកពី ប្រជាជនភាគក្នុងតំបន់ភាគច្រើនពេញនិយមការប្រើប្រាស់ប្រព័ន្ធ 3G/4G។ ជាភាពវិជ្ជមាន កម្ពុជា ឡាវ និង មីយ៉ាន់ម៉ាមានអត្រា ៦០%(ហុកសិបភាគរយ) នៃប្រជាជនសរុបដែលអាចប្រើប្រាស់សេវាអ៊ីនធើណេតតាមទូរស័ព្ទដៃ។[98] យ៉ាងណាមិញ កម្ពុជាត្រូវតែខិតខំបន្តទៀតដើម្បីឱ្យមានបណ្តាញគ្របដណ្តប់ឱ្យបានពេញលេញ ដូចជានៅប្រទេសសិង្ហបុរី និងប្រទេសថៃដែលមានអត្រា ៩៨% (កៅសិបប្រាំបួនភាគរយ) នៃចំនួនសប្រជាជនរុប។ ដូចគ្នានេះផងដែរតម្រូវការរីកដុះដាលចំពោះអគ្គីសនីជាភាពចាំបាច់សម្រាប់ ការពន្លឿនវិស័យអីនធីណេត។ នៅប្រទេសកម្ពុជាទោះបីជាអ្នករស់នៅទីក្រុងទាំងអស់មានលទ្ធភាពប្រើប្រាស់អគ្គិសនីក៏ដោយ ៨០% (ប៉ែតសិបភាគរយ) នៃប្រជាជនដែលរស់នៅតាមតំបន់ជនបទដែលតិចជាង ២/៥

[98] Kalvin Bahia and Stefano Suardi.(2019).The State of Mobile Internet Connectivity 2019 [ស្ថានភាពនៃការភ្ជាប់បណ្តាញអ៊ីនធើណេត]. GSMA, ៤២។

មានអគ្គិសនីគ្រប់គ្រាន់ដើម្បីប្រើប្រាស់។[99] មួយវិញផងដែរ គុណភាពនៃការតភ្ជាប់បណ្តាញអ៊ីនធើណេតល្បឿនលឿន គឺជាកត្តាសំខាន់មួយទៀតនៃសង្គមឌីជីថល។ ដោយយោងតាមទិន្នន័យ សហភាពទូរគមនាគមន៍អន្តរជាតិ(ITU) បានបញ្ជាក់ថា នៅសិង្ហបុរីមានអ៊ីនធើណេតល្បឿន លឿនជាង ១០ ដងនៅកម្ពុជានៅពេលប្រើប្រាស់ទូរស័ព្ទដើម្បីទាញយកព័ត៌មានដូចគ្នា។[100] យ៉ាងណាមិញ ការសិក្សាបានបង្ហាញថាជាប្រព័ន្ធអ៊ីនធើណេតនៅកម្ពុជាបានឈានដល់កម្រិតដែលអនុញ្ញាតឱ្យប្រើប្រាស់ឧបករណ៍ព័ត៌មានវិទ្យាថ្មី និង បានបំពេញតាមតម្រូវការអប្បបរមាសម្រាប់កម្មវិធីបច្ចេកវិទ្យាព័ត៌មាន ។ លទ្ធភាពនៃការផ្គត់ផ្គង់អ៊ីនធើណេតតម្លៃសមរម្យ ក៏ជាកត្តាសំខាន់មួយទៀតដែលគួរពិចារណាក្នុងការរីកចម្រើននៃវិស័យនេះ។ យោងតាម សមាគមប្រព័ន្ធទំនាក់ទំនងចល័តសកលបានកំណត់យក “តម្លៃសមរម្យ” ជាសូចនាករសំខាន់នៃការអភិវឌ្ឍសន្ទស្សន៍នៃការផ្សារភ្ជាប់ប្រព័ន្ធចល័តក្នុង និង ក្រៅតំបន់។ បើធៀបនឹងប្រទេសម៉ាឡេស៊ី និង សិង្ហបុរីតម្លៃនៃការប្រើប្រាស់ទិន្នន័យចល័ត ១ GB គឺស្មើនឹង0.01% ទៅ 0.03% នៃប្រាក់ឈ្នួលអប្បរមាសម្រាប់មនុស្សម្នាក់ខណៈពេលដែលការចំណាយនៃការប្រើប្រាស់ចំនួនទិន្នន័យដូចគ្នា នៅប្រទេសកម្ពុជា ឡាវ ហ្វីលីពីន និង វៀតណាម គឺមានតម្លៃខ្ពស់។ ជាពិសេសនៅតាមជនបទ ដែលការប្រើប្រាស់អ៊ីនធើណេតមានតំលៃថ្លៃ ព្រោះកង្វះខាតនៃការកសាងបណ្តាញអ៊ីនធើណេតនៅតាមតំបន់ជនបទ។ ការចូលរួមអន្តរាគមន៍ និងការទ្រទ្រង់នូវគោលនយោបាយមួយចំនួន នឹងមានមានប្រយោជន៍ដើម្បីកាត់បន្ថយការហានិភ័យទីផ្សារចំពោះក្រុមហ៊ុនផ្តល់សេវាអ៊ីនធើណេតនៅតាមបណ្តារខេត្ត ឬ ជនបទ។ បន្ថែមពីនេះ មាតិកាតាមអ៊ីនធើណេតចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ប្រទេសកម្ពុជា និងមីយ៉ាន់ម៉ាហាក់ដូចជាដើរយឺត ខណៈសិង្ហបុរី និងម៉ាឡេស៊ីមានមាតិកាអនឡាញសម្បូរបែប អាចឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកប្រើប្រាស់ ផ្តល់ព័ត៌មានប្រយោជន៏សម្រាប់អ្នកទស្សនា ជាពិសេសមានភាពទាក់ទាញសម្រាប់វិស័យពាណិជ្ជកម្ម បើប្រៀបធៀបទៅនឹងប្រទេសជាសមាជិកអាស៊ានដទៃទៀ។ ទីផ្សារពាណិជ្ជកម្មអេឡិចត្រូនិកដែលមានការអភិវឌ្ឍ ត្រូវការមាតិកាពាណិជ្ជកម្មអេឡិចត្រូនិកដែលមានលក្ខណៈល្អប្រសើរ និងជួយដោះស្រាយបញ្ហារបស់អ្នកលក់ និង អ្នកទិញដែលជាតួរអង្គសំខាន់ក្នុងវិស័យនេះ។ សេវាកម្មសាធារណៈវិស័យរដ្ឋ(E-Government) តាមប្រព័ន្ធអេឡិចត្រូនិកក៏ជាខ្លឹមផ្នែកសំខាន់នៃមាតិកាពាណិជ្ជកម្មអេឡិចត្រូនិកផងដែរ។ ផ្នែកនេះតម្រូវឱ្យមានការចូលរួម យ៉ាងសស្រាក់សស្រានពីបណ្តារប្រជាពលរដ្ឋ និង

[99] World Bank. (2019). *World Development Indicators 2019* [អ្នកបង្ហាញការអភិវឌ្ឍពិភពលោកឆ្នាំ ២០១៩] Washington, DC: World Bank.

[100] Based on EUI. (2019). The Inclusive Internet Index [សន្ទស្សន៏អ៊ីនធើណេត, ៤១។

ស្ថាប័នរដ្ឋដើម្បីជួយបង្កើនការយល់ដឹងអំពីគោលនយោបាយ និងបទបញ្ញានានាទាក់ទងនឹងការធ្វើពាណិជ្ជកម្មស្របច្បាប់ និងមានការអនុវត្តត្រឹមត្រូវពីអ្នកប្រើប្រាស់ក្នុងស្រុក និងអ្នកវិនិយោគទុនបរទេស។

### គ. សន្តិសុខចរាចរណ៍ប្រព័ន្ធអ៊ីនធើណេតតែមួយ

វិធានការស្តីពីសន្តិសុខតាមអ៊ីនធើណេតគឺចាំបាច់ដើម្បីធានាបាននូវលំហូរទិន្នន័យដោយសេរីនិងជឿជាក់។ ការគំរាមកំហែងតាមអ៊ីនធើណេតរួមមានការលួចអត្តសញ្ញាណ ទិន្នន័យឯកជន និងអាចកំបាំងការរំលោភលើកម្មសិទ្ធបញ្ញា ការបដិសេធសេវាកម្ម ការលេចធ្លាយព័ត៌មានឯកជន; និងការរំខានផ្សេងៗនៃការប្រើប្រាស់ប្រព័ន្ធអ៊ីនធើណេត។ កម្រិតនៃការរៀបចំ និងភាពស្មុគស្មាញនៃការគំរាមកំហែងតាមអ៊ីនធើណេតបានកើតមានឡើងកើនឡើងគួរឱ្យកត់សម្គាល់[101] ដូចជានៅកម្ពុជាយើងផ្ទាល់មានករណីឆបោកប្រាក់មជាច្រើនតាមរយៈការខលទូរស័ព្ទដែលឈ្នះរង្វាន់ ការក្លែងបន្លំជាម្ចាស់គណនេយ្យ ការក្លែងវេបសាយពាណិជ្ជកម្ម។ល។ ដូចនេះសុវត្ថិភាពតាមអ៊ីនធើណេត និងការការពារអ្នកប្រើប្រាស់ពីការរំខានតាមរយៈសកម្មភាពអ៊ិនធើណេតព្យាបាទមានសារៈសំខាន់ក្នុងការធ្វើឱ្យប្រសើរឡើងនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអ៊ីនធើណេត។

ជាក់ស្តែង ចរាចរណ៍ប្រព័ន្ធអ៊ីនធើណេត គឺជាកត្តាសំខាន់នៅក្នុងវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ព្រោះពាណិជ្ជកម្មនេះពឹងផ្អែកទាំងស្រុងទៅលើវិស័យអ៊ីនធើណេត។ នៅតាមបណ្តារប្រទេសរីកចម្រើនប្រព័ន្ធអ៊ីនធើណេតត្រូវបានចងជាប្រព័ន្ធ និងត្រូវបានបញ្ជូនចូលតាមរយៈស្ថាប័នបញ្ញត្តិករដែលមានតួនាទីត្រួតពិនិត្យនិងតាមដានសកម្មភាពអនឡាញមុនពេលបញ្ជូនទៅកាន់អ្នកប្រើប្រាស់។ វាជាបញ្ហាចោទមួយយ៉ាងសំខាន់ចំពោះការរីកចម្រើននូវផ្នែកពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ ព្រោះកាលបើដែលគ្មាននូវប្រព័ន្ធគ្រប់គ្រងរួមមួយនៃការបញ្ជូនចេញ និង ទទួលចូលនៃព័ត៌មានទាក់ទងនឹងវិស័យពាណិជ្ជកម្មតាមរអេឡិចត្រូនិកនេះទេ ប្រតិបត្តិការពាណិជ្ជកម្មនៅក្នុងផ្នែកនេះនឹងមានលក្ខណៈរប៉ាត់រប៉ាយ គ្មានការធានានូវសុវត្ថិភាព គ្មានការទទួលខុសត្រូវច្បាស់លាស់ គ្មានការកំណត់ព័ត៌មានជាក់លាក់ដែលធ្វើឱ្យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជាគ្មានភាពប្រក្រតីទាំងក្នុងវិស័យសេដ្ឋកិច្ច និងក្របខ័ណ្ឌគតិយុត្តិ។

ដូចគ្នានេះផងដែរ នាពេលបច្ចុប្បន្ន (២០២១) កម្ពុជាបានចេញនូវអនុក្រឹតស្តីពីការបង្កើត ច្រកទ្វារអ៊ីនធើណេតជាតិ (National Internet Gateway) ក្នុងគោលបំណងជួយសម្រួល និង ការគ្រប់គ្រងការ

[101] OECD. (2012). Cybersecurity Policy Making at a Turning Point: Analysing a New Generation of National Cybersecurity Strategies for the Internet Economy [ការបង្កើតគោលនយោបាយសន្តិសុខតាមអ៊ីនធឺណិតនៅចំណុចរបត់មួយ៖ វិភាគលើមនុស្សជំនាន់ថ្មីដើម្បីសិក្សាលើយុទ្ធសាស្ត្រសន្តិសុខតាមអ៊ីនធឺណិតសម្រាប់សេដ្ឋកិច្ចអ៊ីនធឺណិត]. *OECD Digital Economy Papers, 211*.។

ភ្ជាប់អ៊ីនធើណេតប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពលើការកៀរគរចំណូល សន្តិសុខសង្គម ថែរក្សារបៀបរៀបរយ សណ្តាប់ធ្នាប់សង្គម វប្បធម៌ និង អារ្យធម៌ឱ្យល្អប្រសើរ ដើម្បីធានាដំណើរការអាជីវកម្មល្អរបស់អតិថិជន។[102] អនុក្រឹត្យនេះមានគោលបំណងកំណត់អំពីការបង្កើតច្រកទ្វារអ៊ីនធើណេតជាតិដើម្បីសម្រួលដល់ការតភ្ជាប់អ៊ីនធើណេតពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការកៀរគរចំណូលជាតិ ការការពារសន្តិសុខជាតិ និងការថែរក្សារបៀបរៀបរយសណ្តាប់ធ្នាប់សង្គម។ ការបង្កើតនូវអនុក្រឹត្យនេះ គឺតម្រូវឱ្យមានបញ្ចូលគ្នានូវការផ្តល់សេវាកម្មប្រព័ន្ធអ៊ីនធើណេតដើម្បីឱ្យស្ថិតនៅក្រោមច្រកទ្វាតែមួយជាមួយប្រព័ន្ធតែមួយដើម្បីស្រួលក្នុងការគ្រប់គ្រងព័ត៌មាននានាដែលបានបញ្ជូនចេញពីអ្នកប្រើប្រាស់។ ការអនុម័តនៅច្បាប់នេះនឹង ធ្វើឱ្យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជាមានជំនឿទុកចិត្តពីអ្នកប្រើប្រាស់ និងស្របតាមច្បាប់ត្រឹមត្រូវ មានភាពច្បាស់លាស់ក្នុងការធានានូវសុវត្ថិភាពរបស់អតិថិជនដោយគ្មានការបោកបន្លំ។ វាជាការប្រសើរដែលរាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់បង្កើតនូវច្បាប់សារធាតុនានាដើម្បីជំរុញនូវវិស័យនេះឱ្យមានដំណើរការទៅមុខយ៉ាងឆាប់រហ័ស ឱ្យដូចនឹងបណ្តារប្រទេសរីកចម្រើន។ វាជាការខិតខំយ៉ាងសស្វិតស្វាញពីបណ្តារស្ថាប័នរដ្ឋដែលគ្រប់គ្រងនូវប្រព័ន្ធនេះឱ្យបានចេញនូវសមិទ្ធផលជាក់ស្តែង និងគ្មានការពន្យាពេលយឺតយ៉ាវ ព្រោះនាពេលបច្ចុប្បន្នការលក់និងទិញទំនិញតាមអេឡិចត្រូនិកកំពុងមានភាពល្បីល្បាញ និងពេញនិយមនៅកម្ពុជា។ ដូចគ្នានេះផងដែរ ប្រជាជនក៏ត្រូវមានចំនេះដឹងគ្រប់គ្រាន់ក្នុងការអនុវត្តរួមគ្នាជាមួយស្ថាប័នរដ្ឋក្នុងការជម្រុញឱ្យវិស័យនេះមានភាពជឿនលឿនជាលំដាប់។

ផ្ទុយទៅវិញការបង្កើតនូវប្រព័ន្ធច្រកទ្វារអ៊ីនធើណេតជាតិនេះ នឹងត្រូវការបច្ចេកវិទ្យាជឿនលឿន និងអ្នកជំនាញប្រតិបត្តិករសម្រាប់គ្រប់គ្រងប្រព័ន្ធនេះជាប្រចាំ។ បញ្ហាទាំងនេះវារនាំងឃាត់ឃាំងនូវការរីកចម្រើនរបស់វិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅប្រទេសកំពុងអភិវឌ្ឍន៍ ដោយហេតុតម្លៃនៃការចំណាយទៅលើអ៊ីនធើណេតប្រចាំខែនៅមានតម្លៃថ្លៃ ព្រមទាំងការផ្គត់ផ្គង់នៃអគ្គីសនីជាដើម ដែលជាហេតុផ្តល់ផលលំបាក និងបញ្ហាចម្បងនៃការប្រតិបត្តិការអេឡិចត្រូនិក។ មិនត្រឹមតែប៉ុណ្ណោះ កង្វះខាតនៃការផ្គត់ផ្គង់ប្រព័ន្ធអ៊ីនធើណេតនៅតាមជនបទក៏ជាផលលំបាកមួយផងដែរ ក្នុងការឱ្យប្រជាជនបែរងាកមកប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកដើម្បីលក់ និង ទិញទំនិញ គឺមានតែនៅតាមបណ្តារទីក្រុងនោះទេដែលមានភាពងាយស្រួលក្នុងការប្រតិបត្តិនូវបច្ចេកវិទ្យានេះ។ បន្ថែមពីនេះផងដែរ វាក៏ជាបញ្ហាមួយដែលអ្នកប្រើប្រាស់អាចនឹងមានទស្សនៈវិជ្ជមានទៅលើ ប្រព័ន្ធច្រកទ្វារអ៊ីនធើណេតជាតិនេះជា អាចប៉ះពាល់សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធើណេត។ យ៉ាងណាមិញបើយើងសង្កេតមើល ប្រទេសអភិវឌ្ឍន៍

[102] ម៉ៃ គុណាមករា.(២០២១ ថ្ងៃទី១៨ ខែកុម្ភៈ). កម្ពុជាអនុម័តបង្កើតច្រកទ្វារអ៊ីនធើណេតជាតិ ដើម្បីងាយស្រួលគ្រប់គ្រងការតភ្ជាប់អ៊ីនធើណេត. *ភ្នំពេញប៉ុស្តិ៍*។

ផ្នែកអ៊ីនធើណេតគឺគេមានច្បាប់បែបនេះ ដើម្បីឱ្យដំណើរការទូទៅនៃអ៊ីនធើណេតមានលក្ខណៈសុវត្ថិភាព និង គេចផុតបានល្អពីឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធើណេត វាជាការចាំបាច់ណាស់ដែលប្រទេសមួយត្រូវមានប្រព័ន្ធគ្រប់គ្រងមួយដ៏សមស្រប និងមានទំនុកចិត្តសម្រាប់បម្រើដល់ផលប្រយោជន៍រួមរបស់ប្រជាជនដែលជាអ្នកប្រើប្រាស់ និងសង្គម។

## កថាខណ្ឌទី២៖ ការប្រើប្រាស់សេវាធនាគារនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា

### ក. ការវាយតម្លៃលើប្រតិបត្តិការធនាគារទូទៅ

នៅក្នុងប្រទេសអភិវឌ្ឍន៍ការទិញលក់តាមរយៈប្រព័ន្ធអេឡិចត្រូនិកគឺតម្រូវឱ្យមានធនាគារពាណិជ្ជកម្មដើរតួរជាអន្តរការី ឬ ជាតតិយជនសម្រាប់ជាមជ្ឈមណ្ឌលប្រតិបត្តិការ។ វាជាគោលការណ៍យ៉ាងចាំបាច់ដើម្បីធានាបាននូវសុវត្ថិភាពរបស់ភាគីនៅក្នុងបរិបទពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា ឱ្យមានតម្លាភាព និងការទទួលខុសត្រូវដ៏ពិតប្រាកដ។ នៅក្នុងន័យនេះធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុធានាជាជំនួយដល់អ្នកលក់ អ្នកទិញក្នុងការចាត់ចែងការទូទាត់ទិញ លក់ទំនិញឱ្យបានត្រឹមត្រូវដោយការពារភាគីទាំងសងខាងពីការកេងប្រវ័ញ្ច និង បោកបន្លំប្រាក់ពីគ្នាទៅវិញទៅមក។ វាក៏ជាបញ្ហាចោទមួយដែលដែលនៅប្រទេសកំពុងអភិវឌ្ឍន៍ខ្លះ ក៏ដូចជាប្រទេសកម្ពុជាដែលការលក់ទំនិញតាមរយៈប្រព័ន្ធអេឡិចត្រូនិកភាគច្រើន ជាពិសេសការផ្សព្វផ្សាយលក់តាមរយៈបណ្តាញទំនាក់ទំនងសង្គមហ្វេសបុក គឺជាមានការចូលរួមរវាងអ្នកលក់ និងអ្នកទិញតែប៉ុណ្ណោះ គ្មានការចូលរួមត្រឹមត្រូវពីភាគីធនាគារ ឬ គ្រឹះស្ថានហិរញ្ញវត្ថុឡើយ ព្រោះពួកគេមិនចង់ចំនាយថវិការច្រើនក្នុងការបង់ពន្ធ និង កម្រៃជើងសារដោយយកពីធនាគារ។[103] នៅក្នុងប្រតិបត្តិការទិញលក់ដោយផ្ទាល់របៀបនេះធនាគារនឹងមិនទទួលខុសត្រូវចំពោះបញ្ហាដែលអាចកើតមាននៅក្នុងការទូទាត់ឡើយ ដូចជាការដែលអ្នកលក់មិនបានទទួលប្រាក់ទិញទំនិញពីអ្នកទិញ ឬការបាត់បង់ប្រាក់នានា។ ជាការពិតដែលការប្រើប្រាស់សេវាធនាគារពាណិជ្ជកម្មនៅកម្ពុជា ភាគច្រើនមានភាពបុរាណនិយម បើទោះបីជាវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជាបាននឹងកំពុងលូតលាស់។ មូលហេតុគឺដោយសារតែប្រជាជនភាគច្រើនមិនសូវមានទំនុកចិត្តទៅលើប្រតិបត្តិការទូទាត់ប្រាក់តាមរយៈអនឡាញ។

[103] សុខ ចាន់. (២០១៧, ថ្ងៃទី១៨ ខែមករា). E-commerce Challenges still big: report ជារបាយការណ៍ចេញដោយការិយាល័យទីផ្សារ MANGO TANGO ASIA គាំទ្រដោយសភាពាណិជ្ជកម្មអង់គ្លេសនៅកម្ពុជា.*ខ្មែរថែមស៍*។ អាចស្វែងរកនៅ https://www.khmertimeskh.com/60345/e-commerce-challenges-still-big-report/.

មួយវិញផងដែរការរីកចម្រើនវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក គឺមានកត្តាជាច្រើនចូលរួម ជាមួយគ្នាផងនោះអត្រាតុល្យភាពឥណទានក៏ជាកត្តាមួយដែលធ្វើឱ្យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជាមានការរីកចម្រើនទៅមុខបានឆាប់រហ័ស។ អត្រាតុល្យភាពឥណទានគឺជាការបង្ហាញនូវអត្រាចំនាយរបស់អ្នកនៅក្នុងទៅលើចំនួនទឹកប្រាក់ដែលអ្នកមានសរុបក្នុងកាតឥណទាន។ ការបង្ហាញនូវការចំនាយតាមរយៈកាតឥណទាននេះជួយជំរុញឱ្យលំហូរនៃប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិកមានលក្ខណៈសកម្ម និងស្វិតស្វាញជារៀងរាល់ពេល។ ជាក់ស្តែង ការទិញលក់រវាងទំនិញអនឡាញនៅកម្ពុជាមានលក្ខណៈជាបែបបុរាណនៅឡើយដោយប្រើប្រាស់លុយសុទ្ធក្នុងការទូទាត់ប្រាក់។ ប្រជាជនកម្ពុជាប្រកាន់នូវទំលាប់បង់ប្រាក់តាមរយៈប្រាក់សុទ្ធនៅពេលដែលអ្នកដឹកជញ្ជូនយកឥវ៉ាន់មកដល់។ ដោយហេតុអ្នកប្រើប្រាស់ភាគច្រើនមិនទាន់ទម្លាប់នឹងការប្រើប្រាស់ប្រព័ន្ធទូទាត់លុយតាមរយៈអេឡិចត្រូនិកនៅឡើយ ដូចនេះវាជាការងាយស្រួលរបស់ពួកគាត់ក្នុងការប្រើប្រាស់សាច់ប្រាក់ផ្ទាល់។អ្នកទិញនិយមចង់មើលនិងស្គាល់ទំនិញឱ្យបានជាក់លាក់សិន មុននឹងផ្តល់ប្រាក់ ដែលជាការពិតការទិញទំនិញរបៀបនេះដូចជាការទិញផ្ទាល់ និងមិនមែនជាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឡើយ។

## រូបភាពទី២ ចំនួនប្រជាជនដែលគ្មានកាតឥណទានត្រឹមត្រូវ(គិតជាអត្រាភាគរយនៃរូបវ័ន្តបុគ្គលមានអាយុ ១៥+)




ប្រភព៖ World Bank's Global Findex database 2017

យោងតាមរូបភាពខាងលើនេះ យើងសង្កេតឃើញថាកម្ពុជាជាប្រទេសដែលមានអត្រាខ្ពស់នៃចំនួនប្រជាជនដែលមិនមានកាតឥណទានត្រឹមត្រូវ។ នៅត្រង់ចំនុចនេះ គេអាចសង្កេតឃើញបានថា ប្រជាជនកម្ពុជាមានការព្រួយបារម្ភ និងខ្វះទំនុកចិត្តពីការប្រើប្រាស់កាតឥណទានក្នុងប្រតិបត្តិការទូទាត់ទំនិញ

ព្រោះភាគច្រើនពួកគាត់មិនមានចំណេះដឹងគ្រប់គ្រាន់ និង យល់ច្បាស់ពីការប្រើប្រាស់កាតឥណទាននៅឡើយទេ។ បន្ថែមពីនេះបើយោងតាមទិន្នន័យរបស់ធនាគារពិភពលោកឆ្នាំ ២០១៧ ប្រជាជនកម្ពុជាចំនួន ១៧,៨ ភាគរយដែលមានអាយុលើសពី ១៤ ឆ្នាំមានគណនីធនាគារ[104] ក៏មិនមិនមានន័យថាពួកគេនិយមប្រើប្រាស់កាតឥណទានដើម្បីទូទាត់ការទិញទំនិញជាជាងប្រាក់សុទ្ធដែរ មូលហេតុពួកគេអាចប្រើប្រាស់សេវាកម្មធានាគារសន្សំប្រាក់ ឬគ្រាន់តែបង្កើតគណនេយ្យធនាគារទុកចោល ព្រោះចំនួនអ្នកប្រើប្រាស់មានចំនួនតិចពួកគេមិនអាចប្រើប្រាស់កាតឥណទានរបស់ពួកគេធ្វើប្រតិបត្តិការទៅវិញទៅមកបានទេ។

បន្ថែមពីនេះ អ្នកលក់ទំនិញតាមរយៈប្រព័ន្ធអេឡិចត្រូនិកមួយចំនួន ក៏មិនបានដាក់ចេញនូវពីវិធីបង់ប្រាក់ ឬជម្រើសបង់ប្រាក់សម្រាប់អតិថិជនដែរ ព្រោះពួកគេមិនបានយល់ច្បាស់ពីសារៈប្រយោជន៍ដែលពួកគេទទួលបានពីការរៀបចំបច្ចេកវិទ្យាក្នុងការលក់ឱ្យបានត្រឹមត្រូវ។ ពួកគេមិនបានគិតគូរដល់ការរៀបចំរដ្ឋបាលល្អមួយនៃការលក់ទំនិញ ដើម្បីឱ្យការលក់របស់ពួកគេកាន់តែមានសន្ទុះឆាប់រហ័សឡើយ។ អ្នកលក់ទំនិញតាមរយៈអនឡាញភាគច្រើនជាពិសេសអាជីវកម្មតូចតាច គឺបង្កើតអាជីវកម្មដែលមានសភាពប្រហាក់ប្រហែលគ្នា ដោយយល់ឃើញថាអាចនឹងលក់ដាច់ ព្រមទាំងទទួលចំណូលខ្ពស់ឱ្យតែបានដាក់លក់តាមរយៈបណ្តាញសង្គមហ្វេសបុកគឺនឹងអាចទទួលបានអ្នកទិញបានច្រើន ។ សភាពនេះអ្នកលក់ផ្តោតតែលើប្រាក់ចំណេញបានមកពីចំនួនអតិថិជន ក៏ប៉ុន្តែមិនបានគិតដល់វិធីសាស្ត្រក្នុងការផ្តល់ភាពងាយស្រួលដល់អតិថិជនដើម្បីបង្កើនចំនួនអតិថិជនឡើយ។ មិនត្រឹមតែប៉ុណ្ណោះអ្នកលក់មានតួនាទីចាំបាច់សម្រាប់ការសហការជាមួយបណ្តាញធនាគារក្នុងស្រុកដើម្បីបង្កើតនូវជម្រើសដ៏ល្អសម្រាប់មធ្យោបាយទូទាត់ប្រាក់ជាមួយនឹងអតិថិជន។ ផ្ទុយទៅវិញ អ្នកលក់មួយភាគធំពិបាកក្នុងការបង្កើតនូវវិធីសាស្ត្របែបនេះ ពួកគេមិនមានធនធានចំណេះដឹងគ្រប់គ្រាន់សម្រាប់ការបង្កើតនូវការគ្រប់គ្រងប្រតិបត្តិការលក់ ឬ ផ្តល់ព័ត៌មានដល់អតិថិជន និង ការបង្កើតនូវថ្នាលសម្រាប់ការផ្សព្វផ្សាយលក់ផលិតផលរបស់ខ្លួនឱ្យមានភាពសមស្របទៅតាមបច្ចេកវិទ្យាទំនើបនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

[104] World Bank. (2017). The Global Findex Database 2017 [មូលដ្ឋានទិន្នន័យ ឆ្នាំ ២០១៧]. អាចស្វែងរកនូវ http://globalfintech.worldbank.org

## រូបភាពទី ៣ តម្លៃនៃប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលត្រូវបានប្រើប្រាស់




ប្រភព៖ World Bank’s Global Findex database 2017

យោងតាមរូបភាពខាងលើបានបញ្ជាក់ឱ្យឃើញថា អាត្រានៃការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកដើម្បីធ្វើប្រតិបត្តិការពាណិជ្ជកម្មដូចជាការទូទាត់ទិញលក់ទំនិញនៅប្រទេសកម្ពុជាមានកម្រិតទាបបំផុតបើប្រៀបធៀបជាមួយបណ្តាប្រទេសជិតខាង និងប្រទេសអភិវឌ្ឍន៍នៅក្នុងតំបន់អាស៊ាន។ ត្រង់ចំនុចនេះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកអាចចាត់ទុកថាជាថ្នាលផ្តល់សេវា (Service Platform) ជាជាងបណ្តាញទូទាត់ (Payment Network) ដែលអាចធានាសុវត្ថិភាពប្រតិបត្តិការ ឬ តាមដានកំណត់ត្រាឥណទាន ឬ ផ្តល់ការការពារអតិថិជន។ សុវត្ថិភាព ការសម្ងាត់ ទំនុកចិត្ត ប្រសិទ្ធភាពជាកត្តាសំខាន់សម្រាប់ការធ្វើឱ្យប្រតិបត្តិការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ទទួលបានការទទួលស្គាល់ច្រើនពីអ្នកប្រើប្រាស់គ្រប់ជាន់ថ្នាក់។ ក្នុងន័យនេះការកសាងនិងថែរក្សាប្រតិបត្តិការទូទាត់តាមអេឡិចត្រូនិកគឺពឹងផ្អែកលើធនធាន ដូចជា គម្រោងដើមទុន បច្ចេកវិទ្យា ធនធានមនុស្សដែលអាចជាបញ្ហាប្រឈមចំពោះប្រទេសដែលមានវិស័យធនាគារ និងហិរញ្ញវត្ថុដែលស្ថិតក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍ។ លើសពីនេះទៅទៀត វាជាការលំបាកក្នុងការផ្លាស់ប្តូរនូវផ្នត់គំនិតរបស់ប្រជាជនដែលតែងតែនិយមប្រើប្រាស់វិធី

សាស្ត្របែបប្រពៃណីនៅក្នុងការរស់នៅ និងគោលជំហរគោលនយោបាយក៏អាចជាឧបសគ្គចម្បងចំពោះការទទួលយកប្រព័ន្ធឌីជីថលមកដាក់ក្នុងសង្គម។ កិច្ចខិតខំប្រឹងប្រែងដាក់ចេញនូវគោលនយោបាយ ក៏ដូចជាការបង្កើតស្តង់ដាររួមនៃឧស្សាហកម្ម រួមទាំងបទប្បញ្ញត្តិសុខដុមនីយកម្ម អាចជួយជម្រុញឱ្យសម្រេចបាននូវទំហំសេដ្ឋកិច្ច និងការគាំទ្រការអភិវឌ្ឍដ៏ត្រចះត្រចង់។

**ខ. ការលើកកម្ពស់បច្ចេកវិទ្យាហិរញ្ញវត្ថុ** (Fintech) **នៅកម្ពុជា**

យើងសង្កេតឃើញថាប៉ុន្មានឆ្នាំចុងក្រោយនៃការរីកដុះដាលយ៉ាងស្គុះស្គាននូវពាណិជ្ជតាមប្រព័ន្ធអេឡិចត្រូនិកនេះ ក្រុមហ៊ុនសញ្ជាតិកម្ពុជា និង ក្រុមហ៊ុនបរទេសជាច្រើនមានវត្តមាន និង បន្តមានវត្តមាននៅកម្ពុជា។ វិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ (Fintech) ត្រូវបានគេឱ្យតម្លៃថាជាផ្នែកសំខាន់មួយក្នុងការសម្រួលដល់ការអភិវឌ្ឍលើទៅលើវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិច។ បច្ចេកវិទ្យាហិរញ្ញវត្ថុ (Fintech) សម្តៅទៅលើការរួមបញ្ចូលនូវបច្ចេកវិទ្យាទៅក្នុងវិស័យហិរញ្ញវត្ថុក្រោមរូបភាពជាការបង់ថ្លៃទំនិញ សេវាកម្ម ឬការប្រើប្រាស់សេវាកម្មធនាគារតាមប្រព័ន្ធទូរស័ព្ទជាដើម។ វាជាបរិយាប័ន្នពាណិជ្ជកម្មថ្មីមួយនៅកម្ពុជាដែលជាប្រទេសដែលកំពុងតែមានតម្រូវការផ្នែកនេះយ៉ាងចាំបាច់ ដែលជួយជំរុញឱ្យ ប្រទេសកម្ពុជាអាចបញ្ចប់ឈ្មោះជាប្រទេសមួយដែលមិនមានគណនីធនាគារ (underbanked) ច្រើនជាងគេបំផុតនៅក្នុងតំបន់។[105] ការចូលខ្លួននៃបច្ចេកវិទ្យានេះជាដំណោះស្រាយយ៉ាងល្អ ដើម្បីផ្លាស់ប្រែនូវប្រតិបត្តិការបែបប្រពៃណីដែលប្រជាជនជនកម្ពុជានិយមប្រើប្រាស់ និងស្របទៅតាមទំនើបកម្មនៃសាកលភាវូបនីយកម្មនៃពិភពលោក។ បើទោះបីជាពេលបច្ចុប្បន្ននេះ បច្ចេកវិទ្យាហិរញ្ញវត្ថុនេះមិនទាន់បានជំនួសនូវប្រតិបត្តិការបែបប្រពៃណីទាំងស្រុង បច្ចេកវិទ្យានេះនឹងបន្តដំណើរការរបស់ខ្លួនឱ្យសាបព្រួសនៅក្នុងបរិបទពាណិជ្ជកម្មដ៏មានសក្តានុពលនេះដោយមានការរំពឹងទុកយ៉ាងរឹងមាំ ថា៖

> ខ្ញុំមើលឃើញពីការផ្លាស់ប្តូរក្នុងរយៈពេល ៥ ទៅ ៦ ឆ្នាំខាងមុខ។ ប្រជាជនវ័យក្មេងយ៉ាងច្រើនដែលត្រៀមខ្លួនជាស្រេចដើម្បីចូលមកក្នុងផ្នែកសេវាកម្មហិរញ្ញវត្ថុ។ ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិកនឹងក្លាយជាបទដ្ឋានមួយ ខណៈដែលយុវវ័យចាប់ផ្តើមចែកចាយពីរបៀបប្រើទៅកាន់មនុស្សគ្រប់វ័យ។[106]

[105] Husain Haider.(២០២១,ថ្ងៃទី០៣ខែកុម្ភៈ). Fintech បង្ហាញពីវិធីសាស្ត្រឆ្ពោះទៅកាន់បរិយាប័ន្នហិរញ្ញវត្ថុពេញលេញសម្រាប់ប្រជាជនកម្ពុជា. *ខ្មែរថៃមស៍*។

[106] ប្រសាសន៍របស់លោក ថម៉ានូ វ៉ាចាន់ អគ្គនាយកនៃធនាគារឯកទេសវីង។

បដិវត្តន៍វិស័យហិរញ្ញវត្ថុរួមបញ្ចូលជាមួយនឹងបច្ចេកវិទ្យានេះ បានផ្តល់នូវលទ្ធភាពមួយសម្រាប់ប្រជាជនកម្ពុជាគ្រប់វ័យ នូវទំនុកចិត្តដ៏រឹងមាំសម្រាប់អ្នកប្រើប្រាស់។ ដោយហេតុ យើងសង្កេតឃើញថាមានក្រុមឆ្លៀតឱកាសជាច្រើនបានព្យាយាមលួចលុយ ឬលួចព័ត៌មានផ្ទាល់ខ្លួនជាច្រើនតាមរយៈប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអ៊ិនធឺណែតដែលគ្មានស្តង់ដារ និងសុវត្ថិភាពខ្ពស់ដែលនាំឱ្យ អ្នកប្រើប្រាស់ជាច្រើនគ្មានទំនុកចិត្តនឹងការវេរប្រាក់តាមអន្តរការីដែលគ្មាននីតិបុគ្គលត្រឹមត្រូវ និង បច្ចេកវិទ្យាច្បាស់លាស់ Fintech បានចូលខ្លួនជាឧបករណ៍ដ៏ល្អសម្រាប់ដោះស្រាយបញ្ហានេះ។ វាមានលក្ខណៈពិសេសដោយហេតុបច្ចេកវិទ្យានេះមានគោលដៅចម្បងដើម្បីការ "*កាត់បន្ថយការចំណាយលើតម្លៃសេវាកម្ម ពេលវេលា ជាពិសេសបង្កើនសុវត្ថិភាពដល់អ្នកប្រើប្រាស់ ដែលរាប់បញ្ចូលតាំងពីអ្នកជំនួញប្រាក់រាល់លាន រហូតដល់កម្មករនិយោជិតទូទៅ*"។[107] មិនត្រឹមតែផ្តល់ភាពងាយស្រួលដល់អ្នកលក់ និងអ្នកទិញក្នុងពាណិជ្ជកម្មតាមអេឡិចត្រូនិកប៉ុណ្ណោះទេ វានឹងជួយដល់កំណើនសេដ្ឋកិច្ចកម្ពុជាបន្ថែមដល់ ៦% ទៅលើកំណើនផលិតផលក្នុងស្រុកសរុបប្រចាំឆ្នាំ (GDP) ក្នុងរយៈពេលខ្លីទៅមុខ។[108] ប្រភពនៃកំណើននេះ បានមកពីអ្នកវិនិយោគទុនបរទេសជាច្រើនដែលមានចំណាប់អារម្មណ៍លើវិស័យពាណិជ្ជកម្មកម្ពុជា ដោយសារកម្ពុជាមាននូវបច្ចេកវិទ្យាទំនើប ដែលផ្តល់ភាពងាយស្រួល និងដំណើរការទៅមុខនៃអាជីវកម្មគ្រប់ប្រភេទ។

ទន្ទឹមនឹងការអភិវឌ្ឍវិស័យនេះ វាទាមទារការសហការពីគ្រប់អាជ្ញាធរ ទាំងអាជ្ញាធរគ្រប់គ្រងប្រព័ន្ធធានារ៉ាប់រង ក្រសួងសេដ្ឋកិច្ច ក៏ដូចជាអាជ្ញាធរគ្រប់គ្រងទីផ្សារមូលបត្រ ដើម្បីចូលរួមផ្តល់ការគាំទ្រជាថវិកាជួយបង្កើនការរីកចម្រើនលូតលាស់នៅលើវិស័យនេះឱ្យកាន់តែរីកចម្រើនទៅមុខ។ ម្យ៉ាងទៀត វាទាមទារឱ្យមានការកំណត់គោលនយោបាយ និងនិយ័តកម្មនានា ដើម្បីជំរុញឱ្យវិស័យនេះដើរបានប្រសើរ ដើម្បីឱ្យប្រជាជនកម្ពុជាមានភាពស៊ាំ និងចាប់ផ្តើមទម្លាប់ប្រើប្រាស់នូវបច្ចេកវិទ្យាដែលមានសារៈប្រយោជន៍នេះ។

## កថាខណ្ឌទី៣៖ ហេដ្ឋារចនាសម្ព័ន្ធឥស្សរការពាណិជ្ជកម្មក្នុងស្រុក

នៅតាមបណ្តារប្រទេសកំពុងអភិវឌ្ឍន៍ បញ្ហាទូគមនាគមន៍ជាបញ្ហាកត្តាភូមិសាស្ត្រយ៉ាងសំខាន់ដែលត្រូវទទួលបានដំណោះស្រាយជាបន្ទាន់ដើម្បីការអភិវឌ្ឍន៍បច្ចេកវិទ្យានៅក្នុងតំបន់។ នៅក្នុងបរិបទពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក លេខកូដតំបន់ និងអាស័យដ្ឋានត្រឹមត្រូវជាកត្តាសំខាន់ដែលធ្វើឱ្យវិស័យនេះឈានទៅមុខបានយ៉ាងឆាប់រហ័សព្រោះ វាផ្តល់ នូវទំនាក់ទំនងល្អក្នុងការគ្រប់គ្រងរដ្ឋបាលក្នុងតំបន់ឱ្យមានប្រសិទ្ធភាព និង ស្ថេរភាពក្នុងការរស់នៅឱ្យមានស្តង់ដារខ្ពស់ក្នុងសង្គមបច្ចុប្បន្ន។ ចំនែកឯ

[107] សាសន៍របស់លោក លោក ចូចូ ម៉ាឡូឡូស អគ្គនាយកនៃធនាគារឯកទេសវីង

[108] យោងទៅការស្រាវជ្រាវដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ADB

ក្នុងន័យពាណិជ្ជកម្ម វាផ្តល់ភាពងាយស្រួលដល់ការដឹកជញ្ជូនទំនិញ ការទាញយកទិន្នន័យទូទៅ ឬ សម្រាប់ការបង្កើននូវ ខ្សែរសង្វាក់ផលិតកម្មទៅតាមតម្រូវការ និងទីផ្សារក្នុងតំបន់។

**ក. ការរៀបចំរដ្ឋបាលភូមិសាស្ត្រ**

គឺត្រូវធ្វើឡើងដោយក្រសួងនគរូបនីយកម្ម និង សំណង់ក្នុងការចាត់ចែងរៀបចំនូវហេដ្ឋារចនាសម្ព័ន្ធរដ្ឋបាលទីក្រុងឱ្យមានសណ្តាប់ធ្នាប់ល្អ ជាពិសេសគឺការកំនត់នូវលេខកូដតំបន់ជាផ្លូវការសម្រាប់ផ្តល់ភាពងាយស្រួល និងជាក់លាក់ក្នុងការស្វែងរកទីតាំង។ នៅតាមបណ្តារប្រទេសអភិវឌ្ឍន៍ ទីតាំងតំបន់មិនមែនជាបញ្ហាធំសម្រាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឡើយ ព្រោះគេមានវិធានការ និងគំរូស្តង់ដាររួចជាស្រេចក្នុងការកំនត់នូវលេខកូដតំបន់មិនឱ្យមានការភាន់ច្រលំ និង ពិបាកក្នុងការស្វែងរក។ ក្នុងការកំនត់នូវលេខកូដតំបន់ត្រូវបានគ្រប់គ្រងដោយអាជ្ញាធរតំបន់ដែលមានសមត្ថកិច្ចសម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃដូចជា ការផ្តល់នូវសេវាដឹកជញ្ជូន ការដាក់ជូននូវវិក័យប័ត្រ ការដាក់ជូនសំបុត្រដោយប្រតិបត្តិករប្រៃយ៍សណីយ។[109] ក្រឡេកមើលមកវិញ មិនត្រឹមតែប្រទេសកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែក៏មានប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនទៀតដែលមិនមាននូវការកំនត់នូវបញ្ញត្តិ ឬលក្ខណ៍ជាផ្លូវការ ឬ ស្តង់ដារជាក់លាក់ប្រកដមួយសម្រាប់ការអនុវត្តវិធាននេះឱ្យបានសមប្រកបទៅនឹងសន្ទុះនៃប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅឡើយទេ។ ចំនុចពីរសំខាន់សម្រាប់សម្រាប់ដំណើរការថ្មីនៃលេខកូដតំបន់នេះគឺ ការដាក់ឈ្មោះផ្លូវ និង លេខផ្ទះឱ្យមានលក្ខណៈជាឯកសណ្ឋានទូទាំងទីក្រុង។

យើងសង្កេតឃើញថានៅទីក្រុងភ្នំពេញគឺនៅមិនទាន់មានលេខកូដតំបន់ណាមួយជាក់ជាក់សម្រាប់ធ្វើជាព័ត៌មានក្នុងការផ្តល់ទីតាំងនៅឡើយទេ។ ប្រាកដណាស់ដែលយើងមានឈ្មោះខ័ណ្ឌ សង្កាត់សម្រាប់ជាព័ត៌មានបញ្ជាក់ទីតាំង ក៏ប៉ុន្តែវាមិនទាន់អាចគ្រប់គ្រាន់នៅឡើយទេសម្រាប់ការយល់ដឹងពីភូមិសាស្ត្រមួយឱ្យមានភាពជាឯកសណ្ឋានសម្រាប់អ្នកដំណើរបរទេស ឬកំនត់នូវអាស័យដ្ឋានមួយឱ្យច្បាស់សម្រាប់ការបញ្ជូនទំនិញពីប្រទេសក្រៅ។ មិនត្រឹមតែប៉ុណ្ណោះអាស័យដ្ឋាននៅតាមគេហដ្ឋានឯកជនឬស្ថាប័នសាធារណៈមួយចំនួនមិនមាននូវលេខផ្លូវ ការសញ្ញាសម្រាប់កំនត់ផ្លូវដើម្បីងាយស្រួលក្នុងការចំណាំឡើយ។ ប្រជាជនក្នុងតំបន់ស្គាល់ផ្លូវតាមរយៈការហៅឈ្មោះតរៗគ្នាដោយមិនមានការកំនត់ពីរដ្ឋបាលទីក្រុងច្បាស់លាស់ទេ។ ជាក់ស្តែង យើងអាចមើលឃើញថាលេខ ផ្លូវខ្លះមានតែលេខ ផ្លូវខ្លះមានលេខផងអក្សរផង រីឯផ្លូវខ្លះទៀតមានលេខផង អក្សរផង ឈ្មោះផង។ វាដូចគ្នាទៅនឹងផ្ទះលេខផងដែរ ដែលផ្ទះ

[109] ក្រសួងសាធារណការ និងដឹកជញ្ជូន លេខាធិការដ្ឋាន.(២០២០, ថ្ងៃ០៦ ខែមករា). សេចក្តីប្រកាសព័ត៌មានកិច្ចប្រជុំលើកទី១ក្រុមប្រឹក្សាជាតិភស្តុភារកម្មស្តីពីសេចក្តីព្រាងផែនការមេអន្តរកាលស្តីពី "ការតភ្ជាប់ប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយ និងភស្តុភារកម្ម"។

លេខមួយចំនួនធំ នៅទីក្រុងភ្នំពេញភាគច្រើនមានលេខជាន់គ្នា ខ្លះទៀតមានលេខជាភាសារឡាតាំង ហើយខ្លះទៀតមានភាសារខ្មែរ។

នៅក្នុងបញ្ហានេះ ក៏បូករួមផងដែរនូវសេវាកម្មប្រៃសណីយ៍ ក្រុមហ៊ុនដឹកជញ្ជូន ការបញ្ជូនបន្តរទំនិញ និងឃ្លាំងស្តុកទំនិញ។ ប្រៃសណីយ៍កម្ពុជា គឺជាប្រតិបត្តិករដែលមានសិទ្ធអំណាចតែមួយគត់សម្រាប់សេវាកម្មដឹកជញ្ជូននៅភ្នំពេញ។រីឯសេវាកម្មដឹកជញ្ជូនវិញ គឺមានក្រុមហ៊ុនដឹកជញ្ជូនជាច្រើនរាប់ចាប់ពីប្រតិបត្តិករជាតិ និងអន្តរជាតិខ្នាតមធ្យមក៏ដូចជាសេវាកម្មដឹកជញ្ជូនក្នុងស្រុកនានា។ស្របទៅតាមនិន្នាការដែលបានអង្កេតនៅតាមតំបន់សេវាកម្មភស្តុភារកម្មត្រូវបានផ្តត់ផ្គង់ជាចម្បងដោយភាគីទីបីនៅក្នុងប្រទេសកម្ពុជា ហើយសមាមាត្រនៃការដឹកជញ្ជូនដោយភាគីទីបីអាចមានរហូតដល់ ៦៨%។[110]នេះជាករណីសម្រាប់វិស័យឯកជនទូទៅ ប៉ុន្តែមិនទាន់ប្រើប្រាស់សម្រាប់សម្រាប់វិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅឡើយទេ ដោយក្រុមហ៊ុនក្នុងវិស័យនេះភាគច្រើនមានទំហំតូច និងមានសមាហរណកម្មបន្ទាត់ឈរខ្ពស់ (Vertical Integration)។[111] មូលហេតុចម្បងដែលលើកឡើងដោយក្រុមហ៊ុនគឺចង់ផ្តោតលើដំណើរការអាជីវកម្មស្នូលដោយផ្ទាល់ និងដាក់បន្ទុកលើការដោះស្រាយជាមួយនីតិរដ្ឋបាលដល់ប្រតិបត្តិករជំនាញ។

### ខ. ការផ្តួចផ្តើមចេញនូវរចនាសម្ព័ន្ធភូមិសាស្ត្រថ្មី

ដោយហេតុការរៀបចំកសាងនូវរចនាសម្ព័ន្ធរដ្ឋបាលថ្មីនៃការរៀបចំលេខកូដតំបន់ និងអាស័យដ្ឋានត្រូវការការសិក្សាលម្អិតពីទីតាំង អ្នកជំនាញត្រឹមត្រូវ កត្តាចម្បងសម្រាប់ឱ្យការងារផ្លាស់ប្តូរនេះបានទទួលជោគជ័យគឺ ការរៀបចំដែលមានផែនការត្រឹមត្រូវ ការដាក់ចេញនូវវិធានការភ្លាម និងឆាប់រហ័សក្នុងការកែប្រែ ការចូលរួមពីសាលាក្រុងឬអាជ្ញាធរទទួលបន្ទុកក្នុងការធ្វើគម្រោងផ្លាស់ប្តូរ និង ការសម្រេចនូវការប្រើប្រាស់កញ្ចប់ថវិការរដ្ឋ អ្នកប្រឹក្សាសេវាបច្ចេកទេសដែលមានជំនាញ និងវិធីសាស្ត្រសមស្រប ការធ្វើបច្ចុប្បន្នភាពនៃទិន្នន័យដោយការប្រើប្រាស់កម្មវិធីកុំព្យូទ័រសម្រាប់ជួយសម្រួល និងគ្រប់គ្រងដល់គម្រោងការផ្លាស់ប្រែនេះ រួមទាំងចូលរួមសហការជាមួយភាគីដែលពាក់ព័ន្ធរដ្ឋ ឬឯកជនក៏ដូចជាប្រីសណីយស៏កម្ពុជាជាគោល។ សូចនាករសំខាន់ៗដែលត្រូវបានប្រើដើម្បីវាយតម្លៃលទ្ធផលនៃគម្រោងទាំងនេះគឺមានដូចជា

---

110 ផែនការមេភស្តុភារកម្មជាតិ។

111 ការធ្វើសមាហរណកម្មបន្ទាត់ឈរគឺយោងលើមូលហេតុថា ក្របខ័ណ្ឌអាជីវកម្មនៅកម្ពុជាមិនអនុញ្ញាតឱ្យក្រុមហ៊ុនប្រើប្រាស់អ្នកដឹកជញ្ជូនដែលមិនមែនជាបុគ្គលិក (Freelance) (ឧទាហរណ៍ អ្នកដឹកជញ្ជូនម្ហូបរបស់ភោជនីយដ្ឋាន) ដោយអ្នកដឹកជញ្ជូនបែបនេះគឺជាអ្នកផ្តល់សេវាក្រៅផ្លូវការ ហើយមិនអាចផ្តល់ជូននូវវិក័យបត្រ VAT។ ហេតុដូចនេះ សហគ្រាសមិនមានជម្រើស ហើយចាំបាច់ត្រូវតែជួលអ្នកផ្គត់ផ្គង់ជាបុគ្គល ដើម្បីគ្រប់គ្រងបញ្ហាទាក់ទងនឹងពន្ធកាត់ទុក។

ថវិកានៃប្រតិបត្តិការនៃការដាក់ចេញនូវគម្រោងថ្មីនេះ ចំនួនអាគារ (ភាគរយនៃចំនួនគ្រួសារដែលមាន) ។ល។ ក្នុងរយៈពេលវែងដែលអាចប៉ាន់ស្មានដឹងអំពី អត្រាកំណើនសេវាកម្មក្នុងស្រុក ដូចជាការប្រមូលពន្ធ និងសេវាកម្មប្រៃសណីយ៍គឺត្រូវបានបញ្ជាក់ពីភាពជោគជ័យនៃគម្រោងផ្លាស់ប្តូរនេះ។[112]មួយវិញទៀតវាជាការចាំបាច់ដែលប្រជាពលរដ្ឋត្រូវតែចូលរួមប្រើប្រាស់ និង យល់ដឹងពីការប្រើប្រាស់លេខកូដតំបន់ និង អាស័យដ្ឋានរបស់ខ្លួនឱ្យបានត្រឹមត្រូវទើបការផ្លាស់ប្រែនូវគម្រោងទីតាំងភូមិសាស្ត្រនេះមានប្រសិទ្ធភាព។ នៅពេលដែលកម្ពុជាមានរចនាសម្ព័ន្ធទីតាំងនៅតាមភូមិស្រុក និងតំបន់និមួយៗហើយ វិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនឹងរីកចម្រើនបានយ៉ាងឆាប់រហ័សព្រោះគ្មានទៀតទេការឧបសគ្គដែលរាំងនូវដំណើរការល្អប្រសើរនៃវិស័យនេះ។

ថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងគ្រោងបង្កើតមជ្ឈមណ្ឌលភស្តុភារកម្មភ្នំពេញដើម្បីសម្រេចបាននូវផែនការអភិវឌ្ឍន៍ជាតិ និងប្រែក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០។[113] មិនត្រឹមតែប៉ុណ្ណោះក្រសួងសាធារណការ និងដឹកជញ្ជូនដោយមានជំនួយពី JICA បានបង្កើតផែនការមេភស្តុភារកម្មជាតិ។ ផែនការមេនេះគឺជា គំនិតផ្តួចផ្តើមអភិវឌ្ឍន៍ដ៏សំខាន់តែមួយគត់ សម្រាប់កែលម្អហេដ្ឋារចនាសម្ព័ន្ធភស្តុភារកម្មពាណិជ្ជកម្មរបស់ប្រទេសដោយរួមបញ្ចូលការផ្តោតលើវិស័យដូចខាងក្រោម៖

- ស្តង់ដារនៃអាសយដ្ឋាន និងការកែលម្អប្រព័ន្ធលេខកូដប្រៃសណីយ៍
  - អភិវឌ្ឍអាសយដ្ឋានថ្មី និងប្រព័ន្ធលេខកូដប្រៃសណីយ៍
  - ធ្វើតេស្តសាកល្បងប្រព័ន្ធថ្មី
  - អនុម័តជាផ្លូវការលើប្រព័ន្ធថ្មី
  - ដាក់ឱ្យប្រើលេខកូដប្រៃសណីយ៍ថ្មី
- ការធ្វើសេរីភាវូបនីយកម្មទីផ្សារដឹកជញ្ជូនកញ្ចប់ឥវ៉ាន់ក្នុងស្រុក និងការលើកកម្ពស់សេវាកម្មប្រៃសណីយ៍ក្នុងស្រុក៖
  - ធ្វើសន្និធិបទប្បញ្ញត្តិដែលមានស្រាប់ទាក់ទងនឹងសេវាកម្មក្នុងស្រុក

---

112 Mohamed EL.(២០២១). Urban Addressing Practice and Geocoding Algorithm Validity in Developing Countries. *International Journal of Advanced Computer Science and Applications* [ការអនុវត្តនគរូបនីយកម្ម និងហេដ្ឋារចនាស័ន្ធភូមិសាស្ត្រនៅប្រទេសកំពុងអភិវឌ្ឍន៍] *១២*(២): 559 ។

113 ក្រសួងសាធារណការ និងដឹកជញ្ជូន. (២០២០, ថ្ងៃទី៩ ខែកញ្ញា). រាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងគ្រោងបង្កើតមជ្ឈមណ្ឌលភស្តុភារកម្មភ្នំពេញដើម្បីសម្រេចបាននូវផែនការអភិវឌ្ឍន៍ជាតិ និងប្រែក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០។

- ធ្វើសន្និធិសេវាកម្មដែលមានសក្ដានុពលសម្រាប់ការដឹកជញ្ជូនក្នុងស្រុក (ឧទាហរណ៍ ការប្រើប្រាស់ស្ថានីយ៍ប្រេងឥន្ធនៈក្នុងស្រុកជាចំណុចបង្គោលដើម្បីទទួលយកកញ្ចប់ឥវ៉ាន់)
- កែប្រែច្បាប់ដែលពាក់ព័ន្ធ
- កែសម្រួលច្បាប់

- ការកែលម្អប្រព័ន្ធទូទាត់ហិរញ្ញវត្ថុ និងសភាផាត់ទាត់៖
  - ធ្វើសន្និធិបញ្ហារំពឹងទុក និងដោះស្រាយបញ្ហាទាំងនេះដើម្បីជួយដល់ភស្តុភារកម្មដល់គោលដៅចុងក្រោយ
  - ពិចារណាលើយន្តការធានា និងយន្តការដោះស្រាយវិវាទដោយសភាផាត់ទាត់
  - ធ្វើឱ្យប្រសើរឡើងនូវប្រតិបត្តិការហិរញ្ញវត្ថុតាមរយៈកាតឥណទាន និងប្រតិបត្តិការអេឡិចត្រូនិក
  - ការធ្វើឱ្យប្រសើរឡើងនូវប្រតិបត្តិការហិរញ្ញវត្ថុតាមរយៈទូរសព្ទចល័ត
  - ការអនុវត្តច្បាប់ថ្មីរួមទាំងច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- ការពង្រឹងសមត្ថភាពអ្នកផ្តល់សេវាដឹកជញ្ជូនដោយគាំទ្រការប្រើប្រាស់ឧបករណ៍ GPS និង លើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធតាមដានដែលមានភាពងាយស្រួល
- ការពង្រឹងសន្តិសុខ និងសុវត្ថិភាពចរាចរណ៍
- លើកកម្ពស់ភាពអាចជឿទុកវចិត្តបានៃសេវាកម្មដឹកជញ្ជូន
- លើសពីនេះទៀតតំបន់ដែលមាននវានុវត្តន៏ខាងក្រោមនឹងត្រូវបានរកឃើញតាមរយៈផែនការមេ៖
  - បន្តរដាក់មុខងារសំខាន់ៗតាមអ៊ីនធើណេតដូចជា QR កូដផ្អែកលើព័ត៌មានចុះបញ្ជីយានយន្ត ប័ណ្ណបើកបរ ប័ណ្ណត្រួតពិនិត្យបច្ចេកទេសយានយន្ត។ល។
  - ត្រៀមរៀបចំឱ្យមានគោលនយោបាយដឹកជញ្ជូនរួមគ្នាដូចជា Grab, PassApp
  - ការរៀបចំប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអំពីព័ត៌មានកំពង់ផែ
  - ការដាក់ពង្រាយកម្មវិធីថែទាំផ្លូវសម្រាប់ទូរស័ព្ទចល័ត
  - សិក្សាលទ្ធភាពបង្កើតរថភ្លើងស្វ័យប្រវត្តិនៅភ្នំពេញ។[114]

[114] ក្រសួងពាណិជ្ជកម្ម.(២៥ វិច្ឆិកា ២០២០). *យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក*,៦៨។

## កថាខណ្ឌទី៤៖ ការរួមបញ្ចូលនូវប្រព័ន្ធឌីជីថលអេកូឡូជី

### ក.. និយមន័យប្រព័ន្ធឌីជីថលអេកូឡូជី

ដើម្បីឱ្យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានការរីកចម្រើនជាលំដាប់ វាត្រូវការកិច្ចខិតខំប្រឹងប្រែងបន្ថែមដើម្បីធ្វើការផ្សារភ្ជាប់ទំនាក់ទំនងរវាងបណ្តារប្រទេសជិតខាង និងមានការចូលរួមសម្របសម្រួលអន្តរកម្មក្នុងចំណោមបណ្តាញមុខងារទាំងបីដែលមានដូចជា ព័ត៌មាន និងលំហូរសាច់ប្រាក់ ដែលបានលើកឡើងខាងលើ។ ប្រព័ន្ធឌីជីថលអេកូឡូជី ជាកម្មញភាព(ការផ្សារភ្ជាប់)នៃពហុកិច្ចសហប្រតិបត្តិការរួម ដែលមានដូចជាគូរសហការឯកជន និង សាធារណៈ កិច្ចសហប្រតិបត្តិការអន្តរស្ថាប័ន កិច្ចសហប្រតិបត្តិការអនុតំបន់ និងការសម្របសម្រួលភារកិច្ចផ្សេងៗរបស់រដ្ឋាភិបាលក្នុងតំបន់ និងក្រៅតំបន់ដើម្បីធ្វើឱ្យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានការអភិវឌ្ឍល្អប្រសើរ។[115] ប្រព័ន្ធឌីជីថលអេកូឡូជី ត្រូវការផ្សារភ្ជាប់យ៉ាងជិតដិតរវាងផ្នែកអនឡាញ(virtual) និងផ្នែកកាយវប្បកម្ម(Physical) វាមានសារៈសំខាន់យ៉ាងខ្លាំងចំពោះដំណើរការនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងសេដ្ឋកិច្ចទាំងមូល។ ការបង្កើតច្បាប់ជាតិ និងបទប្បញ្ញត្តិជាតិនានាដែលទាក់ទងនឹងដំណើរការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ ជាវិធីសាស្ត្រដ៏ប្រសើរដើម្បីជួយជំរុញម៉ាស៊ីនទីផ្សារ និង ពង្រឹងប្រព័ន្ធឌីជីថលអេកូឡូជីមានដំណើរការទៅមុខមានភាពរលូន ។

ដោយក្រឡេកមើលបណ្តារប្រទេសដែលមានការរីកចម្រើនខ្លាំងនូវវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ គឺគេមាននូវគោលនយោបាយ និង ផែនការសំខាន់សម្រាប់ដំណើរការល្អមានប្រសិទ្ធភាព ដោយយកចិត្តទុកដាក់ទៅលើ គោលដៅរួមជាច្រើននៃការអភិវឌ្ឍព័ត៌មានវិទ្យា(ICT) ដូចជាហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍សម្រាប់អ៊ីនធើណេតល្បឿនលឿន ការគ្របដណ្តប់នៃអ៊ីនធើណេតពាស់ពេញតំបន់ កម្រិតខ្ពស់នៃការប្រើប្រាស់ប្រព័ន្ធអ៊ីនធើណេតដែលមានតម្លៃសមរម្យ និង ចំនួនមនុស្សដែលមានសមត្ថភាពប្រើប្រាស់អ៊ីនធើណេត ដែលមូលហេតុទាំងនេះផ្តល់ជាមូលដ្ឋានរឹងមាំសម្រាប់
កិច្ចសហប្រតិបត្តិក្នុងតំបន់ដើម្បីលើកកម្ពស់ប្រព័ន្ធឌីជីថលអេកូឡូជី។ ដោយប្រទេសកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៏ កង្វះខាតនូវកត្តាដែលបានរៀបរាប់ខាងលើគឺជាបញ្ហាចម្បងដែលរាជរដ្ឋាភិបាលកម្ពុជាបាន នឹងកំពុងប្រឹងប្រែងយ៉ាងស្វិតស្វាញ ដើម្បីផ្សាភ្ជាប់នូវទំនាក់ទំងទាំងនោះឱ្យមានងរចន្តភាពជាបន្តរបន្ទាប់

---

[115] Chen, L. (2020), 'Improving Digital Connectivity for E-commerce: A Policy Framework and Empirical Note [ការពង្រឹងការតភ្ជាប់ប្រព័ន្ធឌីជីថលនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក៖ ក្របខ័ណ្ឌគោលនយោបាយ និងការសិក្សាលម្អិត], in Chen, L. and F. Kimura (eds.), *E-commerce Connectivity in ASEAN.* Jakarta, Indonesia: Economic Research Institute for ASEAN and East Asia, pp.7-30.

ដោយធ្វើការសិក្សាល្អិតល្អន់ពីប្រភព និងភាពទន់ខ្សោយដែលបណ្ដាលឱ្យមានកង្វះខាត តាមរយៈគោលនយោបាយដ៏មានសក្ដានុពលពីប្រទេសអភិវឌ្ឍជិតខាង។

**ខ. កិច្ចសហប្រតិបត្តិការនៅក្នុងតំបន់អាស៊ាន**

កម្ពុជា ដែលនឹងរួមចំនែកនូវការរក្សាកំនើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចរីភាព និង បរិយាប័ន្ន។[116] ទន្ទឹមនឹងនេះ កម្ពុជាក៏ជាប្រទេសមួយក្នុងចំណោមបណ្ដារប្រទេសក្នុងអាស៊ានដែលបានចូលរួមចំនែកសិក្សា និង ដាក់ចេញនូវ "ផែនការមេឌីជីថលអាស៊ានឆ្នាំ២០២៥" ដើម្បីជំរុញសហប្រតិបត្តិការពាណិជ្ជកម្មក្នុងតំបន់អាស៊ានពីឆ្នាំ២០២១ដល់២០២៥។ គម្រោងនេះនឹងផ្ដោតលើការងារអាទិភាពដើម្បឱ្យអាស៊ាន ងើបចេញពីជំងឺកូវីដ១៩ តភ្ជាប់ការធ្វើធុរកិច្ច និងជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មក្រៅប្រទេស និងកសាងសង្គមឌីជីថល ដើម្បីក្លាយជាសហគមន៍ឌីជីថលឈានមុខគេ និងប្លុកសេដ្ឋកិច្ចដំណើរការ ដោយសេវាកម្មឌីជីថល ប្រកបដោយសុវត្ថិភាព និងផ្លាស់ប្ដូរសេវាកម្មឌីជីថល បច្ចេកវិទ្យា និងប្រព័ន្ធអេកូឡូស៊ី។ ការសិក្សានេះបានផ្ដោតលើ ការពង្រឹងគោលនយោបាយ និងការធ្វើកិច្ចសហប្រតិបត្តិការអោយកាន់តែស៊ីជម្រៅលើបច្ចេកវិទ្យាឌីជីថលដោយធ្វើការយល់ស្របលើការផ្លាស់ប្ដូរ និងការធ្វើប្រតិបត្តិការលើការអភិវឌ្ឍន៍គោលនយោបាយឌីជីថល ការច្នៃប្រឌិតឌីជីថល ហេដ្ឋារចនាសម្ព័ន្ធឌីជីថល សុវត្ថិភាពឌីជីថល និងការកសាងសមត្ថភាពឌីជីថលក្នុងឆ្នាំ២០២១។[117]

ភាពជាដៃគូផ្ទាល់រវាងអាជ្ញាធរជាតិទាំងនេះអាចបង្កើនប្រសិទ្ធភាពចំពោះកិច្ចសហប្រតិបត្តិការលើវិស័យផ្សេងៗដែលទាក់ទងនឹងការធ្វើឱ្យប្រសើរឡើងនូវកម្មញភាពឌីជីថលក្នុង និង ក្រៅប្រទេសដោយការរៀបចំហេដ្ឋារចនាសម្ព័ន្ធអ៊ីនធើណេតត្រឹមត្រូវរហូតដល់ការបង្កើតច្បាប់គ្រប់គ្រងយ៉ាងមានប្រសិទ្ធភាព។ ជាងនេះទៅទៀតការសម្របសម្រួលស្ថាប័នតាមវិស័យដូចជា គណៈកម្មាធិការសម្របសម្រួលពាណិជ្ជកម្មអេឡិចត្រូនិកនៃអាស៊ាន (ASEAN Coordinating Committee of E-Commerce) គណៈកម្មាធិការសម្របសម្រួលកម្មញភាពអាស៊ាននិងអាស៊ាន ( ASEAN Coordinating Committee of Connectivity) និង គណៈកម្មាធិការសម្របសម្រួលសហគ្រាសធុនតូចនិងមធ្យម (ASEAN Coordinating Committee

[116] ទីស្ដីការគណៈរដ្ឋមន្ត្រី លេខ ៧៧៣សជណ.(២០១៦ ខែមេសា). "ឆ្ពោះទៅសន្តិភាព និងកម្មញភាពនៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន". *គោលនយោបាយអភិវឌ្ឍន៏វិស័យទូរគមនាគមន៍ បច្ចេកវិទ្យទូរគមនាគមន៍ និង ព័ត៌មានឆ្នាំ២០២០* ហៅកាត់ (ទ.ប.គ.ព.)។
[117] គង់ លាងហួរ.(២០២១, ថ្ងៃទី២៥ ខែមករា). រដ្ឋមន្ត្រីបណ្ដាប្រទេសអាស៊ានឯកភាពគ្នាអនុម័តលើផែនការមេឌីជីថលដើម្បីជំរុញពាណិជ្ជកម្មក្នុងតំបន់. *Cambodia Financial Times*។

of Small and Medium Enterprises) អាចជួយសម្រួលដល់កិច្ចសហការចំណោមរដ្ឋជាសមាជិកពីវិមាត្រនៃស្ថាប័នតំបន់។[118]

ថ្នាក់តំបន់ អាស៊ានបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្របខ័ណ្ឌអ៊ី-អាស៊ាន (E-ASEAN) នៅក្នុងឆ្នាំ ២០០០ និងបានប្រកាសពីគោលដៅយុទ្ធសាស្ត្រដើម្បីលើកកម្ពស់ផលិតភាពអេឡិចត្រូនិកអាស៊ាន 'e-space' តាមរយៈ (១) លើកកំពស់ការប្រកួតប្រជែងផ្នែកព័ត៌មានវិទ្យា (២) កាត់បន្ថយការបែងចែកឌីជីថលនៅក្នុងចំណោមរដ្ឋសមាជិកអាស៊ាននីមួយៗ (៣) លើកកម្ពស់ភាពជាដៃគូរវាងសាធារណជន និងវិស័យឯកជន និង (៤) សេរីភាវូបនីយកម្មពាណិជ្ជកម្មនិងវិនិយោគសេវាកម្ម និង ទំនិញព័ត៌មានវិទ្យា។[119] សហគមន៍សេដ្ឋកិច្ចអាស៊ាន (ASEAN ECONOMIC COMMUNITY "AEC") ដែលមានគម្រោងយក្សនាឆ្នាំ២០២៥ បានបញ្ជាក់ពីការអភិវឌ្ឍលើបច្ចេកវិទ្យា វិស័យគមនាគមន៍ និងព័ត៌មានវិទ្យាដើម្បីក្លាយជាកម្លាំងចលករដ៏សំខាន់នៅក្នុងសេដ្ឋកិច្ចនិងសង្គមរបស់អាស៊ាន។[120] មិនត្រឹមតែប៉ុណ្ណោះ នៅឆ្នាំ២០១៨ អាស៊ានបានចុះហត្ថលេខា ក្របខ័ណ្ឌសមាហរណកម្មឌីជីថលអាស៊ានត្រូវបានចុះហត្ថលេខា និងកិច្ចព្រមព្រៀងអាស៊ានស្តីពីពាណិជ្ជកម្មអេឡិចត្រូនិកផងដែរ ។ នៅឆ្នាំ ២០១៩ ក្នុងអំឡុងពេលកិច្ចប្រជុំ AEC លើកទី ១៨ រដ្ឋមន្ត្រីអាស៊ានបានផ្តល់សច្ចាប័នលើការបញ្ចប់ផែនការសកម្មភាពក្របខ័ណ្ឌសមាហរណកម្មឌីជីថលឆ្នាំ ២០១៩-២០២៥។[121]

ទោះយ៉ាងណាក៏ដោយការអនុវត្តកិច្ចព្រមព្រៀង និងផែនការសកម្មភាពទាំងនេះនឹងមានបញ្ហាប្រឈម។ ឧទាហរណ៍៖ បញ្ហាចម្បងបំផុតគឺ របៀបគ្រប់គ្រងលំហូរទិន្នន័យ ជាពិសេសទិន្នន័យឯកជន។ បណ្តាប្រទេសអាស៊ានមិនមានជំហររួមក្នុងការធ្វើនិយ័តកម្មលំហូរទិន្នន័យឆ្លងដែនទេ វាមានរយៈពេលយូរក្នុងការកំណត់ច្បាប់ក្នុងស្រុក។ ជាក់ស្តែងបណ្តារប្រទេសក្នុងតំបន់អាស៊ានដូចជា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន និងថ្មីៗនេះសិង្ហបុរីបានអនុម័តច្បាប់ថ្មីទាក់ទងនឹងបញ្ហារនេះ ស្របពេលដែលប្រទេសថៃកំពុង

---

118 Chen, L. (2020), 'Improving Digital Connectivity for E-commerce: A Policy Framework and Empirical Note [ការពង្រឹងការតភ្ជាប់ប្រព័ន្ធឌីជីថលនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក៖ ក្របខ័ណ្ឌគោលនយោបាយ និងការសិក្សាលម្អិត], in Chen, L. and F. Kimura (eds.), *E-commerce Connectivity in ASEAN.* Jakarta, Indonesia: Economic Research Institute for ASEAN and East Asia, pp.7-30.

119 មាត្រា៣ (២០០០).កិច្ចព្រមព្រៀងក្របខ័ណ្ឌអ៊ីអាស៊ាន (E-ASEAN Framework Agreement ). ទីក្រុងចាកាតា៖ *លេខាធិការដ្ឋានសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍។*

120 មាត្រា C2, C3, និង D1(២០១៥). AEC 2015 Blueprint. ទីក្រុងចាកាតា៖ *លេខាធិការដ្ឋានសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍។*

121 ផែនការសកម្មភាពក្របខ័ណ្ឌសមាហរណកម្មឌីជីថលអាស៊ានផ្តោតលើ (១) ការសម្រួលពាណិជ្ជកម្ម (២) ការការពារទិន្នន័យសម្រាប់ពាណិជ្ជកម្មឌីជីថល (៣) ការទូទាត់តាមឌីជីថល (៤) កម្លាំងពលកម្មឌីជីថលនិង (៤) ភាពជាសហគ្រិនឌីជីថល។

ពិចារណាលើច្បាប់ទាំងនេះ។ ដោយឡែកប្រទេសប្រ៊ុយណេ ឡាវ កម្ពុជា និង មីយ៉ាន់ម៉ា មិនទាន់មានច្បាប់ និងបទប្បញ្ញត្តិស្តីពីការការពារទិន្នន័យឯកជននៅឡើយទេ។

ខណៈប្រទេសអភិវឌ្ឍន៍ដូចជាសិង្ហបុរីមានភាពប្រឆាំងយ៉ាងខ្លាំងចំពោះការធ្វើមូលដ្ឋានបនីយកម្មទិន្នន័យ ប្រទេសជាច្រើនទៀតដូចជា ប្រទេសឥណ្ឌូនេស៊ី និងវៀតណាមបាននឹងកំពុងពិចារណាលើការអនុម័តច្បាប់ដែលអាចគ្រប់គ្រងទិន្នន័យក្នុងស្រុក ដើម្បីរក្សាទុកក្នុងព្រំដែនភូមិសាស្ត្ររបស់ខ្លួន និងត្រូវស្ថិតនៅក្រោមច្បាប់ក្នុងស្រុក។ មូលដ្ឋានបនីយកម្មទិន្នន័យនៅត្រង់នេះសំដៅលើការរក្សាទុកទិន្នន័យឱ្យស្ថិតនៅក្រោមអធិបតេយ្យភាពរបស់ប្រទេសនិមួយៗ ដែលមិនអាចមានការប្រើប្រាស់ពីប្រទេសជិតខាង បើទោះបីជាតំបន់អាស៊ានកំពុងព្យាយាមបង្កើតនិយ័តកម្មលំហូរទិន្នន័យឆ្លងដែនក៏ដោយ។ ឧទាហរណ៍ សេចក្តីព្រៀងច្បាប់ស្តីពីសន្តិសុខអ៊ីនធើណេតដែលនឹងត្រៀមខ្លួនចូលមកនៅកម្ពុជានាពេលបច្ចុប្បន្នក អនុញ្ញាតឱ្យរដ្ឋាភិបាលកម្ពុជាអាចគ្រប់គ្រងវិធីសាស្ត្រដំណើរការទិន្នន័យរបស់ក្រុមហ៊ុនបច្ចេកវិទ្យាដែលមានប្រតិបត្តិការនៅកម្ពុជា និងរឹតត្បិតការតភ្ជាប់អ៊ីនធើណេតរបស់អ្នកប្រើប្រាស់ដែលមានមាតិកា“ ហាមឃាត់” តាមអ៊ីនធើណេតមិនស្របច្បាប់។

ជាការពិតណាស់ការកែលម្អប្រព័ន្ធឌីជីថលអេកូឡូជីក្នុងតំបន់វាត្រូវការផ្លាស់ប្តូរផ្នត់គំនិតតាមបែបប្រពៃណីមួយចំនួនដែលគ្មានប្រសិទ្ធភាព និងអនុម័តគោលនយោបាយបើកចំហបន្ថែមទៀតដូចជា (១)បទប្បញ្ញត្តិដើម្បីគាំទ្រប្រព័ន្ធឌីជីថលអេកូឡូជី (២)ផែនការសកម្មភាពគោលនយោបាយដើម្បីអនុញ្ញាតឱ្យមានបច្ចេកវិទ្យាថ្មីៗ និងគំរូអាជីវកម្មបម្រើឱ្យការរួមបញ្ចូលគ្នា និង (៣) ការរួមបញ្ចូលគ្នានៃយុទ្ធសាស្ត្រជាតិ និងកិច្ចសហប្រតិបត្តិការក្នុងតំបន់។[122]

## ផ្នែកទី២៖ ផលប៉ះពាល់នៃជំងឺកូវីដ-១៩ លើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

វិបត្តិកូវីដ-១៩ ធ្វើឱ្យប្រជាជននៅក្នុងប្រទេសជាច្រើនដាក់កម្រិតយ៉ាងខ្លាំងលើអន្តរកម្មរាងកាយ។ ការរក្សាគម្លាតសង្គមដោយខ្លួនឯង ដើម្បីចៀសវាងការរីករាលដាល រួមជាមួយវិធានការណ៍បង្ខាំងយ៉ាងតឹងរ៉ឹង ដែលបានអនុវត្តនៅក្នុងប្រទេស ជាច្រើនបានដាក់ចំណែកដ៏ធំនៃការលក់រាយនិង ការលក់តាមប្រពៃណីស្ទើរតែត្រូវបានផ្អាក ឆ្នាំ ២០២០ ។ដូចនេះផ្នែកទី២ **កថាខណ្ឌទី១ គឺផលប៉ះពាល់វិជ្ជមាននៃជំងឺកូវីត-១៩ លើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** ដែលធ្វើឱ្យវិស័យនេះមានការរីកចម្រើនយ៉ាង ឆាប់រហ័ស និង សម្រួលការរស់នៅ ការធ្វើអាជីវកម្ម និង សេដ្ឋកិច្ចឱ្យមានភាពធូរស្រាល នាក្នុងបរិបទនៃជំងឺកូវី១៩នេះ

[122] Chen, L. (2020). Improving Digital Connectivity for E-commerce: A Policy Framework and Empirical Note [ការពង្រឹងការតភ្ជាប់ប្រព័ន្ធឌីជីថលនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក៖ ក្របខ័ណ្ឌគោលនយោបាយ និងការសិក្សាលម្អិត], in Chen, L. and F. Kimura (eds.), *E-commerce Connectivity in ASEAN.* Jakarta, Indonesia: Economic Research Institute for ASEAN and East Asia, pp.7-30.

ផងដែរ។ ចំណែកក**កថាខណ្ឌទី២ គឺផលប៉ះពាល់អវិជ្ជមាននៃជំងឺកូវីត-១៩ លើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** ដែលបង្ហាញពីភាពប៉ះពាល់អវិជ្ជមាន ទៅលើវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឬបង្ហាញពីភាពរីកចម្រើន ប្រសិនបើគ្មានជំងឺកូវីដ-១៩។

### កថាខណ្ឌទី១៖ ផលប៉ះពាល់វិជ្ជមាននៃជំងឺកូវីត-១៩ លើវិពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

សម្រាប់សេវាកម្មអ៊ីនធើណេតនិងទិន្នន័យចល័តក៏មានតម្រូវការក៏បានកើនឡើងផងដែរ។សមត្ថភាពបណ្តាញនិង វិសាលភាពសង្គម ដើម្បីសម្របសម្រួលការផ្លាស់ប្តូរទៅសកម្មភាពតាមអ៊ីនធើណេតបានបន្ទាន់ត្រូវសម្របសម្រួលដោយទាំងប្រតិបត្តិករនិងរដ្ឋាភិបាល។

យោងតាម GlobalData បានលើកឡើងថា កូវីដ១៩ មានឥទ្ធិពលវិជ្ជមានរយៈពេលវែង លើពាណិជ្ជកម្មអេឡិចត្រូនិក។ ពាណិជ្ជកម្មអេឡិកត្រូនិកកំពុងដើរតួយ៉ាងសំខាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ដោយអ្នកលក់ធ្វើការទិញលក់ ឬផ្តល់សេវា តាមអ៊ីនធើណេតជួបប្រទះនូវការបញ្ហាទិញពីអតិថិជនដែលត្រូវបានគេបង្ខាំងទុកនៅផ្ទះ។ជំងឺកូវីត-១៩ ហាក់បីដូចជាអ្នកបង្រៀនឱ្យប្រជាជនភាគច្រើនប្រើប្រាស់នូវវិស័យឌីជីថល ក្នុងការប្រស្រ័យទាក់ទង និងជាកតាលីករជំរុញនូវវិស័យនេះឱ្យកាន់តែរីកចម្រើន ទម្ងឹងនឹងនេះគុណវិបត្តិ និង គុណសម្បត្តិកើតមានឡើងព្រមគ្នា។

#### ក. ផលប៉ះពាល់វិជ្ជមាន ចំពោះរដ្ឋាភិបាល

លក្ខណៈសកលនៃកូវីដ -១៩ និងផលប៉ះពាល់របស់វាទៅលើពាណិជ្ជកម្មអេឡិចត្រូនិកអាចលើកទឹកចិត្តឱ្យពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិនិងការអភិវឌ្ឍ បន្ថែមទៀតនៃគោលនយោបាយសម្រាប់ការទិញតាមអ៊ីនធើណេតនិងការផ្គត់ផ្គង់។ ឆោគរាតត្បាតបានបញ្ជាក់យ៉ាងច្បាស់ថាពាណិជ្ជកម្មតាមអេឡិចត្រូនិកអាចជាឧបករណ៍ ឬដំណោះស្រាយសំខាន់។

កូវីដ១៩ នេះបានបណ្តាលឱ្យមានការកើនឡើងនៃការលក់ពីអាជីវកម្មទៅអ្នកប្រើប្រាស់ (B2C) និងការកើនឡើង និង ការធ្វើពាណិជ្ជកម្មតាមអេឡិចត្រូនិកពីជំនួញទៅធុរកិច្ច (B2B) ការកើនឡើងនៃការលក់ B2C ត្រូវបានបង្ហាញជាពិសេស នៅក្នុងការលក់តាមអ៊ិនធរណេតនៃការផ្គត់ផ្គង់វេជ្ជសាស្ត្ររបស់របរប្រើប្រាស់ក្នុងផ្ទះនិងផលិតផលម្ហូបអាហារ។[123]

វិធានការណ៍និងសកម្មភាព ដែលនាំទៅដល់ការបំពេញតម្រូវការអេឡិចត្រូនិកនៃទំនិញនៅក្នុងការឆ្លើយតបទៅកូវីដ-១៩ ដើម្បីអនុវត្តប្រកបដោយប្រសិទ្ធភាពនូវវិធានការឃ្លាតឆ្ងាយពីសង្គមដែលមាន

[123] OECD. (2020). Connecting businesses and consumers during COVID-19: trade in parcels [ការផ្សារភ្ជាប់ពាណិជ្ជកម្ម និងអតិថិជនអំឡុងពេលកូវីដ១៩] *OECD Policy Responses to Coronavirus (COVID-19)* ។

គោលបំណងទប់ស្កាត់បន្ថែមទៀត។ ការរីករាលដាលនៃជំងឺកូវីដ-១៩ រដ្ឋាភិបាលជាច្រើននៅជុំវិញពិភពលោកបានលើកទឹកចិត្តឱ្យទិញតាមអ៊ីនធើណេត ជាជម្រើសមួយសម្រាប់ការដើរទិញឥវ៉ាន់តាមតម្រូវការ ហើយអ្នកប្រើប្រាស់បានសមស្រប តាមលំនាំនៃការដើរទិញឥវ៉ាន់របស់ពួកគេ ដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លងមេរោគ។

រោគរាតត្បាតបានគូសបញ្ជាក់ ពីតំរូវការជំគ្រចះត្រចង់ ដើម្បីភ្ជាប់ការបែងចែកឌីជីថលទាំងក្នុងនិងក្រៅប្រទេសនៅទូទាំងប្រទេស ដោយសារតួនាទីកណ្តាលសេដ្ឋកិច្ចឌីជីថលបានដើរតួក្នុងកំឡុងពេលមានវិបត្តិ។ឧបសគ្គប្រពៃណី ជាច្រើនត្រូវបានសង្កត់ធ្ងន់ហើយបានបន្តរាំងកាន់តែខ្លាំង ការចូលរួមក្នុងសកម្មភាពពាណិជ្ជកម្មតាមអេឡិចត្រូនិក ដោយអ្នកផលិតអ្នកលក់និងអ្នកប្រើប្រាស់ខ្នាតតូច ប្រទេសកំពុងអភិវឌ្ឍន៍ជាពិសេសប្រទេសអភិវឌ្ឍ តិចតួច (LDCs) ។ នេះបានគូសបញ្ជាក់តម្រូវការបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពនិងតម្លៃសមរម្យ (អាយធីស៊ី) សេវាកម្មដូចជាទូរគមនាគមន៍កុំព្យូទ័រ និងសេវាកម្មអាយធីដទៃទៀតនិងកំពុងរីកចម្រើនបច្ចេកវិទ្យា។

រដ្ឋាភិបាលបានអនុម័តវិធានការថ្មី ហើយវិស័យឯកជនក៏បានធ្វើសកម្មភាពផងដែរ ដើម្បីឆ្លើយតបដើម្បីធានាថាពាណិជ្ជកម្មតាមអេឡិចត្រូនិក អាចជួយបន្ធូរបន្ថយបញ្ហាប្រឈមមួយចំនួនដែលកំពុងជួបប្រទះប្រយុទ្ធប្រឆាំងនឹងមេរោគ។ ទាំងនេះបានរួមបញ្ចូលការបង្កើនសមត្ថភាពបណ្តាញដោយផ្តល់ជូនការពង្រីកសេវាកម្មទិន្នន័យដោយចំណាយតិចឬច្រើនកាត់បន្ថយឬ កាត់បន្ថយថ្លៃប្រតិបត្តិការលើការទូទាត់តាមឌីជីថលនិងការផ្ទេរប្រាក់តាមទូរស័ព្ទការធ្វើឱ្យប្រសើរឡើងនូវសេវាកម្មដឹកជញ្ជូននិងការដឹកជញ្ជូនផ្សេងៗ ដោយប្រើប្រាស់ឌីជីថលឧបករណ៍ដើម្បីអនុវត្តវិធានការនិងផ្សព្វផ្សាយព័ត៌មានលើកកម្ពស់សេវាកម្មទូរគមនាគមន៍និងប្រើប្រាស់ សម្រាប់ការឃ្លាំមើល។[124]

### ខ. ផលប៉ះពាល់វិជ្ជមាន ចំពោះប្រជាពលរដ្ឋ

ជំងឺរាតត្បាតកូវីដ -១៩ បានបង្កើនការផ្លាស់ប្តូរឌីជីថល។ ដំណោះស្រាយឌីជីថលកាន់តែត្រូវការដើម្បីបន្តសកម្មភាពសេដ្ឋកិច្ចនិងសង្គមពីចម្ងាយ។ ពួកគេមានសារៈសំខាន់ចំពោះការព្យាបាលតាមទូរគមនាគមន៍ និងការអប់រំតាមអ៊ីនធើណេតយ៉ាងហោចណាស់ដើម្បីរក្សាទំនាក់ទំនងក្នុងសង្គមរបស់យើងក្នុងគ្រាដែលមានការឃ្លាតឆ្ងាយពីគ្នា។ យើងក៏បានឃើញពីកំណើនពាណិជ្ជកម្មអេឡិចត្រូនិកនៅក្នុងប្រទេសកំពុងអភិវឌ្ឍផងដែរ ដោយមានផលប៉ះពាល់រយៈពេលវែង ទោះយ៉ាងណាក៏ដោយលុះត្រាតែមានការដោះស្រាយឱ្យបានគ្រប់គ្រាន់។ ការបែងចែកឌីជីថល ដែលមានស្រាប់ទំនងជានាំឱ្យមានវិសមភាព

[124] OECD. (2020). Connecting businesses and consumers during COVID-19: trade in parcels [ការផ្សារភ្ជាប់ពាណិជ្ជកម្ម និងអតិថិជនអំឡុងពេលកូវីដ១៩], *OECD Policy Responses to Coronavirus (COVID-19)* ។

កាន់តែច្រើន។ ការអនុវត្តវិធានការរក្សាគម្លាតសង្គម ការចាក់សោរនិងវិធានការផ្សេងទៀតដើម្បីឆ្លើយតបទៅនឹង ការរីករាលដាលនៃជំងឺកូវីដ-១៩ បាននាំឱ្យអ្នកប្រើប្រាស់បង្កើនការទិញទំនិញតាមអ៊ីនធើណេតការប្រើប្រាស់បណ្តាញសង្គមទូរស័ព្ទ តាមអ៊ីនធើណេតនិងការជួបប្រជុំតាមទូរសព្ទ័និងការផ្សាយវីដេអូ និងភាពយន្ត។

ជំងឺកូវីដ-១៩ បានរុញច្រានវិស័យពាណិជ្ជកម្មតាមប្រព័ប្ធអេឡិចត្រូនិក តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គមនិងមធ្យោបាយផ្សេងទៀត តាមទូរស័ព្ទទំនាក់ទំនងរបស់អ្នកសម្របសម្រួលនៃផលិតផលម្ហូបអាហារផ្សេងៗគ្នានៅតាមទីផ្សារផ្សេងៗ ដើម្បីឱ្យអ្នកប្រើប្រាស់អាចទូរស័ព្ទទៅនិងបញ្ជាទិញគ្រឿងទេស។ បន្ទាប់មកអ្នកប្រើប្រាស់បង់ប្រាក់តាមទូរស័ព្ទ (ឧទាហរណ៍តាមរយៈទូរស័ព្ទដៃរបស់ពួកគេ)ហើយឱ្យការទិញរបស់ពួកគេត្រូវបានបញ្ជូនដោយតាក់ស៊ីកង់និងម៉ូតូដែលគេស្គាល់ថាតុកតុក។ ឧទាហរណ៍ដោយ Foodpanda, Eget, Nham24 ឬជម្រើសស្រដៀងគ្នាផ្សេងទៀត។ការពង្រីកសេវាកម្មដឹកជញ្ជូននេះមានមានផលប៉ះពាល់ ចំពោះការបង្កើនការងារទោះបីជាការងារទាំងនេះអាចជាបណ្តោះអាសន្នក៏ដោយ។ លើសពីនេះទៀត អ្នកផ្តល់សេវាទូរគមនាគមន៍ជាច្រើនបានផ្តល់សេវាកម្មទិន្នន័យដែលមានតិចតួចបំផុតគ្មានការចំណាយ។ ចំណែកការលក់រាយតាមអ៊ីនធើណេតរបស់ចិនបានកើនឡើងពី ១៩,៤% ដល់ ២៤,៦% នៅចន្លោះខែសីហាឆ្នាំ ២០១៩ ដល់ខែសីហាឆ្នាំ ២០២០។

ជំងឺរាតត្បាតនេះក៏បានបង្ហាញពីសារៈសំខាន់នៃការធានា ឱ្យបាននូវភាពស្អិតស្អេរនិងជៀសវាងការចម្លងនៅក្នុងកិច្ចប្រឹងប្រែងអន្តរជាតិ។ ក្នុងរយៈពេលបួនឆ្នាំកន្លងមកនេះ e-Trade សម្រាប់ទាំងអស់គ្នា បានបង្ហាញពីសក្តានុពលនៃកិច្ចសហការ ដើម្បីបន្ថែមតម្លៃជាពិសេសនៅក្នុងប្រទេស LDCs ។ គំនិតផ្តួចផ្តើមនេះនឹងបន្តដើរតួនាទីរបស់ខ្លួនដោយការគាំទ្រវិធីសាស្ត្រគោលនយោបាយពាក់ព័ន្ធគាំទ្រការវាយតម្លៃអំពីបរិយាកាសពាណិជ្ជកម្មតាមអេឡិចត្រូនិកថ្នាក់ជាតិ និងជំរុញកិច្ចសហការរវាងភាគីពាក់ព័ន្ធជាតិនិងអន្តរជាតិ ដើម្បីបង្កើនការរួមបញ្ចូលគ្នាដែលអាចរួមចំណែកដល់ការធ្វើឱ្យពាណិជ្ជកម្មអេឡិចត្រូនិកមានការអភិវឌ្ឍ។

### កថាខណ្ឌទី២៖ ផលប៉ះពាល់អវិជ្ជមាននៃជំងឺកូវីត-១៩លើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

មិនមែនអ្នកលក់តាមអ៊ិនធឺណែត និងប្រភេទផលិតផលទាំងអស់ទទួលបានអត្ថប្រយោជន៍ពីការកើនឡើងនៃនៃវិបត្តិកូវីដ-១៩ ទេ។ ឥទ្ធិពលនៃវិបត្តិកូវីដ -១៩ លើពាណិជ្ជកម្មអេឡិចត្រូនិកមិនមានភាពដូចគ្នាចំពោះប្រភេទផលិតផលឬអ្នកលក់ឡើយ គឺអាស្រ័យទៅតាមប្រភេទនៃទំនិញខ្លះប៉ុណ្ណោះ។ ទោះ

យ៉ាងណាក៏ដោយតម្រូវការបានធ្លាក់ចុះសម្រាប់សេវាកម្មជាក់លាក់ជាមួយសមាសធាតុតាមអ៊ីនធើណេតធំៗ ដូចជាសេវាកម្មទេសចរណ៍ជាដើម។

**ក. ផលប៉ះពាល់អវិជ្ជមាន ចំពោះរដ្ឋាភិបាល**

ខណៈពេលដែលសក្តានុពលអាចប្រែប្រួលនៅទូទាំងប្រទេស ទិន្នន័យទាំងនេះបង្ហាញថាទោះបីជាមានការផ្លាស់ពាណិជ្ជកម្មប្តូរទៅជាពាណិជ្ជកម្មតាមអេឡិចត្រូនិក ក៏ដោយក៏ចំណែកដ៏សំខាន់នៃអ្នកលក់អេឡិចត្រូនិកកំពុងប្រឈមនឹងផលប៉ះពាល់សេដ្ឋកិច្ចដូចអ្នកលក់ តាមប្រពៃណីបន្ទាប់ពីការកាត់បន្ថយការចំណាយរបស់បុគ្គលិកម្នាក់ៗ។

ថ្វីបើមានការខិតខំប្រឹងប្រែងពីរដ្ឋាភិបាលខ្លះក្នុងការជំរុញពាណិជ្ជកម្មតាមអេឡិចត្រូនិកក្នុងកំឡុងពេលមានវិបត្តិកូវីដ-១៩ ក៏ដោយឌីជីថលជាប់លាប់បែងចែកថាមិនមែនគ្រប់គ្នាអាចចូលរួមបានទេ។ លើសពីនេះបទប្បញ្ញត្តិដែលមិនត្រូវបានសម្របទៅនឹងពាណិជ្ជកម្មអេឡិចត្រូនិក អាចបង្កើតឧបសគ្គដល់ក្រុមហ៊ុនដូចជាក្នុងករណីគំរូនៃការលក់ ឆានែលកំពុងលេចចេញឬរបៀបនៃការចែកចាយថ្មី។ ខណៈពេលដែលបញ្ហាប្រឈមទាំងនេះមានមុនពេលកូវីដ ១៩ វិបត្តិបច្ចុប្បន្ននិងតួនាទីថ្មីនៃពាណិជ្ជកម្មអេឡិចត្រូនិកសម្រាប់បុគ្គលនិងក្រុមហ៊ុនបានបង្កើនតម្រូវការសម្រាប់សកម្មភាពគោលនយោបាយ។

ពាណិជ្ជកម្មអេឡិចត្រូនិកសម្រាប់ពាណិជ្ជកម្មទំនិញ និងសេវាកម្ម ត្រូវបានជះឥទ្ធិពលអាក្រក់ដោយកត្តាដូចគ្នា ដែលបណ្តាលឱ្យមានការរំខាននៅក្នុងការផ្គត់ផ្គង់និងតម្រូវការរួម។ ការរំខានបែបនេះបានកើតឡើង នៅក្នុងការពន្យារពេលនៃការដឹកជញ្ជូន ឬការលុបចោលការបញ្ជាទិញភ្លាមៗ។ ទាក់ទងនឹងពាណិជ្ជកម្មអេឡិចត្រូនិកមួយចំនួនផ្សេងទៀត បញ្ហាប្រឈមបានកើតឡើងឬត្រូវបានពង្រីកបន្ថែមទៀតក្នុងអំឡុងពេលមានជំងឺរាតត្បាតនេះ។ ទាំងនេះរួមបញ្ចូលទាំងតម្លៃការវាយដំ (ឧទាហរណ៍ការដំឡើងថ្លៃដល់កំរិតខ្ពស់ដោយមិនសមហេតុផល) កង្វល់សុវត្ថិភាពផលិតផលការអនុវត្តបោកបញ្ឆោតកង្វល់អំពីសន្តិសុខតាមអ៊ីនធើណេតតម្រូវការសម្រាប់ការបង្កើតម្រិតបញ្ជូននិងកង្វល់ទាក់ទងនឹងការអភិវឌ្ឍ។

ការការពារអ្នកប្រើប្រាស់តាមអ៊ីនធើណេតគឺជាបញ្ហាប្រឈមមួយដែលជំងឺរាតត្បាតកូវីដ -១៩ បានលើកឡើង។ មានសេចក្តីរាយការណ៍អំពីការអនុវត្តក្លែងបន្លំ និងការបោកបញ្ឆោតដោយអ្នកលក់តាមអ៊ីនធើណេតខ្លះផ្តល់ជូនក្លែងក្លាយ ឬទឹកលាងដៃដែលមិនមានសុវត្ថិភាពរបាំងមុខវះកាត់ឬថ្នាំសម្លាប់មេរោគសម្រាប់លក់និងការអនុវត្តការបញ្ចុះតំលៃ ដោយក្រុមហ៊ុនផលិតនិងអ្នកលក់រាយមួយចំនួនស្វែងរកប្រាក់និងចំណេញពីការកើនឡើងនៃតម្រូវការ។ ការកើនឡើងនៃកញ្ចប់តូចដែលកុម្ម៉ង់ដោយផ្ទាល់ដល់អ្នកប្រើប្រាស់បានបង្កើនបញ្ហាប្រឈមជាមួយ ទាក់ទងនឹងការអនុលោមតាមបទបញ្ជាសុខភាពនិងសុវត្ថិភាព

នៅក្នុងប្រទេសនាំចូលក៏ដូចជាការគោរព ដើម្បីការពារសុខភាពរបស់កម្មករដែលពាក់ព័ន្ធនឹងការគ្រប់គ្រង និងត្រួតពិនិត្យទំនិញ។

**ខ. ផលប៉ះពាល់អវិជ្ជមាន ចំពោះប្រជាពលរដ្ឋ**

ផលប៉ះពាល់ជាពិសេសគឺអ្នកលក់ដែលមានបញ្ជីផលិតផលតិចតួច ខណៈដែលអ្នកលក់ដែលមានបញ្ជីផលិតផលច្រើនជាង បានឃើញមានការកើនឡើងវិជ្ជមាន។ នេះបញ្ជាក់ពីរបៀបដែលវិបត្តិកូវីដ -១៩ អាចពាក់ព័ន្ធនឹងការផ្លាស់ប្តូរតម្រូវការពីអ្នកលក់ខ្នាតតូចនិងអ្នកជំនាញទៅជាអ្នកលក់ធំ ។ វិបត្តិកូវីដ -១៩ ក៏បង្ហាញពីការបំពេញបន្ថែមរវាងបណ្តាញលក់តាមអ៊ីនធើណេតនិងក្រៅអ៊ីនធើណេតផងដែរ។

ជំងឺរាតត្បាតកូវីដ -១៩ បានសាកល្បងសេវាកម្មលក់ដុំនិងដឹកជញ្ជូននិងលក្ខណៈពិសេសផ្សេងទៀតនៃការផ្គត់ផ្គង់សង្វាក់ដូចជាគ្មានព្រឹត្តិការណ៍ផ្សេងទៀតនៅក្នុងប្រវត្តិសាស្ត្រថ្មីៗ ដោយសារតែការបិទទ្វារត្រូវបានបង្កើតឡើងដើម្បីទប់ស្កាត់បន្ថែមទៀត។ ការរីករាលដាលនៃមេរោគអេឡិចត្រូនិកពាណិជ្ជកម្មទំនិញបានប្រឈមមុខនឹងការរំខានដល់សង្វាក់ផ្គត់ផ្គង់។ ក្រុមហ៊ុន ជាច្រើនមានបន្តជួបប្រទះបញ្ហាប្រឈមផ្នែកផ្គត់ផ្គង់ ដែលជាលទ្ធផលនៃការផ្អាកសកម្មភាពផលិត ការកាត់បន្ថយផលិតកម្មនិងកង្វះកម្លាំងពលកម្ម។ អ្នកដែលមានកន្លែងផ្ទុកទំនិញនៅក្នុងតំបន់ ដែលរងផលប៉ះពាល់ បានប្រឈមមុខនឹងការសម្រេចចិត្តដ៏លំបាកអំពីរបៀបឬថាតើត្រូវបន្តផលិតផលិតផលរបស់ខ្លួនឬយ៉ាងណា។ នេះដូច្នេះជំងឺរាតត្បាតបាននាំមកនូវភាពងាយរងគ្រោះនៃសង្វាក់ផ្គត់ផ្គង់និងសាកល្បងសមត្ថភាពអាជីវកម្ម ដើម្បីកែសម្រួលយ៉ាងឆាប់រហ័ស។ សេវាកម្មដឹកជញ្ជូននិងភស្តុភារអន្តរជាតិ ដែលពាណិជ្ជកម្មអេឡិចត្រូនិកទាំងអស់និងពាណិជ្ជកម្មបែបប្រពៃណី ការពឹងផ្អែកលើប្រតិបត្តិការក៏ត្រូវបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរផងដែរដោយការណែនាំអំពីបទបញ្ជាសុខភាពថ្មីដែល បានរំខានដល់ការដឹកជញ្ជូនទំនិញតាមផ្លូវគោកសមុទ្រនិងផ្លូវអាកាស។ ការលុបចោលជាងមួយលានជើងហោះហើរអ្នកដំណើរចំនួន ៦ ដែលជាធម្មតាត្រូវបានប្រើដើម្បីដឹកជញ្ជូនការដឹកជញ្ជូនតាមប្រៃសណីយ៍និងខ្នាតតូចផ្សេងទៀត ការដឹកជញ្ជូនបានកាត់បន្ថយសមត្ថភាពដឹកជញ្ជូននិងបង្កើនថ្លៃដឹកជញ្ជូនសម្រាប់ ប្រតិបត្តិការឆ្លងដែន B2C និង B2B ។ នេះបើយោងតាមសមាគមដឹកជញ្ជូនផ្លូវអាកាសអន្តរជាតិ(IATA) និងសហភាពប្រៃសណីយ៍សកល (UPU) បញ្ហាត្រូវបានធ្វើឱ្យកាន់តែធ្ងន់ធ្ងរឡើងដោយរដ្ឋបាលនិង ការរាំងស្ទះដល់បទប្បញ្ញត្តិក៏ដូចជាលក្ខខណ្ឌនៃការ ដាក់ឱ្យនៅដាច់ដោយឡែករបស់នាវិកដែលរារាំងការហោះហើរទំនិញ រក្សាល្បឿនជាមួយនឹងតម្រូវការ។ ពាណិជ្ជកម្មអេឡិចត្រូនិក B2B ពឹងផ្អែកលើការនាំចូលទ្រង់ទ្រាយធំតាមរយៈ ការដឹកជញ្ជូនតាមសមុទ្រក៏រងផលប៉ះពាល់ដែរ។ ដូច្នេះអតិថិជនត្រូវប្រឈមមុខនឹងការពន្យារពេលឬ ការលុបចោលការបញ្ជាទិញរបស់ពួកគេសូម្បីតែនៅថ្ងៃដឹកជញ្ជូនក៏ដោយ។

នៅសហរដ្ឋអាមេរិកការលក់សេវាកម្មលក់រាយ និងម្ហូបអាហារនៅចន្លោះខែកុម្ភៈ ខែមេសាឆ្នាំ ២០២០ បានធ្លាក់ចុះ ៧,៧% បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៩។[125] ទោះយ៉ាងណាការលក់បានកើនឡើងសម្រាប់ហាងលក់គ្រឿងទេស និងអ្នកលក់រាយ ដែលមិនមែនជាហាង តែភាគច្រើនជាអ្នកផ្តល់ការទិញលក់ពាណិជ្ជកម្មតាមអេឡិចត្រូនិកមានការកើនឡើង ១៦ % និង ១៤,៨% រៀងគ្នា។ នៅសហភាពអឺរ៉ុប ការលក់រាយតាមរយៈផ្ទះបញ្ជាទិញតាមអ៊ីមែល ឬអ៊ិនធឺណេតនៅខែមេសាឆ្នាំ ២០២០ កើនឡើង ៣០% បើប្រៀបធៀបទៅនឹងខែមេសាឆ្នាំ ២០១៩ ខណៈការលក់រាយសរុបថយចុះ ១៧,៩%។ [126]

នៅប្រទេសអាឡឺម៉ង់ ការលក់តាមអ៊ីនធើណេតបានកើនឡើងគួរឱ្យកត់សម្គាល់ សម្រាប់ថ្នាំនិងគ្រឿងទេស ដែលជាវិស័យយឺតយ៉ាវជាប្រវត្តិសាស្ត្រទាក់ទងនឹងពាណិជ្ជកម្មអេឡិចត្រូនិក ខណៈការលក់តាមអ៊ិនធរណេតសរុបធ្លាក់ចុះប្រហែល ១៨ ភាគរយនៅក្នុងខែមីនាឆ្នាំ ២០២០ បើប្រៀបធៀបទៅនឹងឆ្នាំមុន (OECD ឆ្នាំ ២០១៩ )។

សម្រាប់ក្រុមហ៊ុន អ្នកបង្កើតគោលនយោបាយគួរតែកាត់បន្ថយភាពមិនច្បាស់លាស់នៃបទបញ្ញាដើម្បីគាំទ្រដល់ការបង្កើតគំរូអាជីវកម្មប្រកបដោយភាពច្នៃប្រឌិត។ នៅក្នុងបរិបទនៃទំនាក់ទំនងបំពេញបន្ថែមរវាងយុទ្ធសាស្ត្រលក់ក្រៅបណ្តាញនិងអនឡាញ រដ្ឋាភិបាលក៏ត្រូវដោះស្រាយតម្រូវការជាក់លាក់ផងដែរ ដោយរួមបញ្ចូលទាំងមាន ការធានាឱ្យមានការប្រកួតប្រជែងដោយយុត្តិធម៌នៅក្នុងបរិបទនៃសេវាកម្មកម្រិតមធ្យម (ឧទាហរណ៍វេទិកាតាមអ៊ីនធើណេត) ។ ការធានាឱ្យមានការប្រកួតប្រជែងគ្រប់គ្រាន់ នៅក្នុងវិស័យលក់រាយនិងបរិយាកាសអំណោយផល សម្រាប់ដំណើរការពាណិជ្ជកម្មអេឡិចត្រូនិករួមទាំងសេវាកម្មទំនាក់ទំនងភស្តុភារឬពាណិជ្ជកម្មក៏មានសារៈសំខាន់ផងដែរ។[127]

សម្រាប់អ្នកប្រើប្រាស់ បញ្ហាប្រឈមជាប្រព័ន្ធទាក់ទងនឹងការតភ្ជាប់ ការបញ្ចូលហិរញ្ញវត្ថុជំនាញ និងការជឿទុកចិត្ត ឧទាហរណ៍សន្តិសុខឌីជីថលភាពឯកជននិងការការពារអ្នកប្រើប្រាស់ ត្រូវបាននាំមក

[125] OECD. (២០២០,ថ្ងៃ២ ខែមិថុនា). Food Supply Chains and COVID-19: Impacts and Policy Lessons [ចង្វាក់ផ្គត់ផ្គង់អាហារ និងកូវីដ១៩៖ ផលប៉ះពាល់ និងការសិក្សាពីគោលនយោបាយ, *OECD Policy Responses to Coronavirus (COVID-19)*។ អាចស្វែងរកបាន https://www.oecd.org/coronavirus/policy-responses/food-supply-chains-and-covid-19-impacts-and-policy-lessons-71b57aea/

[126] OECD. (២០២០,ថ្ងៃ៧ ខែតុលា). E-commerce in the time of COVID-19[ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅអំឡុងពេលកូវីដ១៩], *Policy Responses to Coronavirus (COVID-19)*។អាចស្វែងរកបាន https://www.oecd.org/coronavirus/policy-responses/e-commerce-in-the-time-of-covid-19-3a2b78e8/#section-d1e109

[127] OECD. (២០២០). COVID-19 and the retail sector: impact and policy responses [កូវីដ១៩ និងការលក់រាយ៖ផលប៉ះពាល់ និងគោលនយោបាយ], OECD Policy Responses to Coronavirus (COVID-19), OECD Paris, អាចស្វែងរកបាន https://www.oecd.org/coronavirus/policy-responses/covid-19-and-the-retail-sector-impact-and-policy-responses-371d7599/

នូវភាពធូរស្រាល។ ដើម្បីដោះស្រាយបញ្ហានេះរដ្ឋាភិបាលអាចពង្រីកអ៊ីនធើណេត ដែលមានតំលៃសមរម្យ និងមានគុណភាពទៅកាន់តំបន់ជនបទនិងតំបន់គ្មានសេវាកម្មបង្កើនការរួមបញ្ចូលផ្នែកហិរញ្ញវត្ថុ និង ជំរុញការជឿទុកចិត្តនិងការទទួលបានជំនាញដើម្បីចូលរួមក្នុងពាណិជ្ជកម្មអេឡិចត្រូនិក។

**ផ្នែកទី៣៖ ឥទ្ធិពលនៃវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

នៅក្នុងផ្នែកនេះដែរ យើងសិក្សាទៅលើ**កថាខណ្ឌទី១ គឺ សក្តានុពល និង ផលប៉ះពាល់នៃពាណិជ្ជកម្មអេឡិចត្រូនិក** និង **កថាកណ្ឌទី២ ការគ្រប់គ្រងហានិភ័យ** ឱ្យទទួលបានការសម្រេចបាននូវបរិវត្តកម្មឌីជីថលនៃសេដ្ឋកច្ច និង សង្គមកម្ពុជាទាមទារនូវកិច្ចខិតខំប្រឹងប្រែង និងសម្រេចឱ្យបាននូវវិធានការគោលនយោបាយទាំងឡាយ ដែលបានគិតគូរ និង ដាក់ចេញដោយក្រសួងស្ថាប័នពាក់ព័ន្ធ ក្នុងស្មារតីទទួលខុសត្រូវ និង ប្រកបដោយប្រសិទ្ធិភាព និង សក្តិសិទ្ធិភាពខ្ពស់។

**កថាខណ្ឌទី១៖ សក្តានុពល និង ផលប៉ះពាល់នៃពាណិជ្ជកម្មអេឡិចត្រូនិក**

**ក. សក្តានុពលនៃពាណិជ្ជកម្មអេឡិចត្រូនិកទៅលើសេដ្ឋកិច្ច និងសង្គម**

សក្តានុពលនៃពាណិជ្ជកម្មអេឡិចត្រូនិក ដែលបង្ហាញពីសក្តានុពលទៅលើសេដ្ឋកិច្ច និង សង្គម នៅក្នុងចលនាតំបន់ និង សកលឆ្ពោះទៅកាន់បដិវត្តតន៍ឧស្សាហកម្មទី៤ ពិសេសការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិជំងឺ កូវីដ-១៩ និង ជាកាតាលីករនៃការជំរុញការអភិវឌ្ឍឱ្យមានកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និង បរិយាបន្នកម្ម និង ការលើកកម្ពស់សុខុមាលភាពសង្គម។[128]

❖ **សក្តានុពលទៅលើសេដ្ឋកិច្ច**

កម្ពុជា រំពឹងថា នឹងជំរុញវិស័យពាណិជ្ជកម្មអេឡិចត្រូនិក ក្នុងសន្ទុះ និង ល្បឿនថ្មី ដោយចាប់យកវិស័យឌីជីថលជាមូលដ្ឋាន ដើម្បីចាប់យកកាលានុវត្តភាពថ្មីៗផង និង ជំរុញផលិតភាព ប្រសិទ្ធភាព និង ភាពប្រកួតប្រជែងសេដ្ឋកិច្ចផង ។ សក្តានុពលសំខាន់ៗ រួមមាន៖

- **ការជំរុញសកម្មភាពពាណិជ្ជកម្ម និង ធុរកិច្ច៖** ប្រសិទ្ធភាពនៃប្រតិបត្តិការទិញ-លក់ទំនិញនិង សេវាជាពិសេសពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកតាមរយៈការទូទាត់កាន់តែងាយស្រួល និង រហ័សគួបផ្សំនឹងការដឹកជញ្ជូនលឿន និង មានថ្លៃសមរម្យ នឹងត្រូវបានលើកកម្ពស់ ។ បន្ថែមលើនេះ ការគ្រប់គ្រងអាជីវកម្មនិង ផលិតកម្ម នឹងកាន់តែមានប្រសិទ្ធភាព ដោយសារការប្រើប្រាស់ច្ចេកវិទ្យាឌីជីថល បូកផ្សំនឹងកម្លាំងពលកម្មប្រកបដោយជំនាញ ។ ជាមួយគ្នានេះការរៀបចំ

[128] ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ. (១៨ ឧសភាឆ្នាំ២០២១).*ក្របខណ្ឌ គោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា*, រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា,៦។

ពិព័រណ៍តាមប្រព័ន្ធអេឡិចត្រូនិក និង ការរៀបចំថ្នាលសម្រាប់ដាក់លក់ និង ផ្សព្វផ្សាយផលិតផល ដើម្បីជំរុញការនាំចេញនិង ការផ្សារភ្ជាប់ទីផ្សារឱ្យដល់អតិថិជនចុងក្រោយ ក៏អាចប្រព្រឹត្តទៅ បាន តាមបច្ចេកវិទ្យាឌីជីថល ។

- **ការបង្កើត ការងារ ជំនាញ និង ការវិនិយោគ៖** ការងារ និង កម្រិតជំនាញ ត្រូវបានរំពឹងថា នឹងកើន ឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃទីផ្សារ តាមរយៈយន្តការរដ្ឋ កម្មវិធីបណ្តុះបណ្តាល បច្ចេកទេសវិជ្ជាជីវៈ និង ការបណ្តុះបណ្តាលជំនាញបន្ថែមដោយវិស័យឯកជន ។ ជាមួយគ្នានេះ ការលើកកម្ពស់ សហគ្រិនភាព និង នវានុវត្តន៍ នឹងរួមចំណែកក្នុងការបង្កើត ធុរកិច្ចថ្មី និង ការទាក់ ទាញការវិនិយោគ នៅក្នុងស្រុកនិងក្រៅស្រុក នៅក្នុងវិស័យពាណិជ្ជកម្មអេឡិចត្រូនិក ។

❖ **សក្តានុពលទៅលើសង្គម**

ទន្ទឹមនឹងការគាំទ្រដល់ការអភិវឌ្ឍ និងការជំរុញកំណើនសេដ្ឋកិច្ច វណ្ណភាពសង្គមកម្ពុជាអាច សម្រេចបានតាមរយៈការរៀបចំ នូវសង្គមឌីជីថលមួយដែលមានការចូលរួមពីកោសិកាសង្គមទាំង អស់ពោលគឺបុគ្គលគ្រប់រូបអាចប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការប្រាស្រ័យទាក់ទងរវាងបុគ្គល ក្នុងគ្រួសារនិងសហគមន៍ការចូលរួមចំណែកក្នុងការរីកចម្រើនលើពាណិជ្ជកម្មអេឡិចត្រូនិក។

- **ការលក់ទិញ ឬការទទួលបានសេវា កាន់តែងាយស្រួល និងទូលំទូលាយតាមរយៈថាបច្ចេកវិទ្យាឌី ជីថល៖** កោសិកាសង្គមបាននឹងកំពុងតែប្រើប្រាស់ថ្នាលបច្ចេកវិទ្យាឌីជីថល ដើម្បីទទួលបានសេវា ការទិញ លក់ទំនិញទៅលើពាណិជ្ជកម្មអេឡិចត្រូនិក ដោយសេរី និងមានភាពងាយក្នុងការ សម្រួលជីវភាព ប្រជាពលរដ្ឋឱ្យធូស្រាលមួយកម្រិតទ្វេឡើងទៀត ពិសេសជាងនេះពាណិជ្ជកម្មអេ ឡិចត្រូនិកក បានជួយសម្រាលបន្ទុក ទៅដល់សង្គមយ៉ាងច្រើន នាកំលុងពេលនៃការរីករាល ដាលនៃជំងឺកូវីត-១៩ផងដែរ ។
- **ការពង្រឹងទំនាក់ទំនង និងចែករំលែកក្នុងសង្គម កាន់តែស៊ីជម្រៅក្នុងការធ្វើអាជីវកម្មអេឡិចត្រូនិក ៖** បុគ្គលម្នាក់ៗចាប់ផ្តើមមានទំនាក់ទំនង ដែលផ្សារភ្ជាប់គ្នាទៅមក និង អន្តរសកម្មកាន់តែស្និត ស្នាល និងបើកចំហដោយពុំខ្វល់ខ្វាយពីភាពខុសគ្នានៃឋានៈសង្គម ភូមិសាស្ត្រ ភេទ សាសនា និង ជាតិសាសន៍។ ក្នុងបរិការណ៍នេះក៏ឆ្លាត ជាពិសេសឧបករណ៍ចល័ត គួបផ្សំនឹងវិសាលភាពនៃការ តភ្ជាប់បណ្តាញ និងសេវាទូរគមនាគមន៍ ក្នុងតំបន់នីមួយៗ គឺជាកត្តាកំណត់ការភ្ជាប់បណ្តាញ សង្គមឌីជីថល ជាពិសេសការកសាងសង្គមឌីជីថលផ្ទាល់ ដើម្បីទាក់ទាញយកអត្ថប្រយោជន៍ពី សភាពសកលភាវូបនីយកម្ម ទៅតាមធនធានដែលមាន។ សម្រាប់កម្ពុជាចំនួនការភ្ជាប់ internet តាមឧបករណ៍ចល័ត ជាពិសេសទូរស័ព្ទចល័តមានរហូតទៅដល់ដល់ ១២៨ ភាគរយនៃចំនួន

ប្រជាជនសរុប ហើយភាគច្រើនជាអ្នកប្រើប្រាស់ថ្នាល ឬប្រព័ន្ធសង្គម។ តួលេខនេះបានបង្ហាញពីការចូលរួមរបស់ប្រជាពលរដ្ឋកម្ពុជាកាន់តែសកម្ម និងទូលំទូលាយក្នុងសង្គមឌីជីថលដោយបានប្រែក្លាយជាសកម្មភាពនៃជីវភាពប្រចាំថ្ងៃ។

### ខ. ផលប៉ះពាល់នៃពាណិជ្ជកម្មអេឡិចត្រូនិកទៅលើសេដ្ឋកិច្ច និងសង្គម

❖ **ផលប៉ះពាល់ទៅលើសេដ្ឋកិច្ច**

- **ការផ្លាស់ប្តូររចនាសម្ព័ន្ធកម្លាំងពលកម្មនិងការងារ៖** ការងារដែលប្រពៃណីមួយចំនួនអាចប្រឈមខ្ពស់នឹងការបាត់បង់ខណៈសេដ្ឋកិច្ចឌីជីថល និងបង្កើត ប្រភេទការងារថ្មី ដែលទាមទារឱ្យមានចំណេះដឹងនិងជំនាញខ្ពស់ជាងមុន ជាពិសេសគឺជំនាញឌីជីថល។ ជាមួយគ្នានេះដែរវិស័យពាណិជ្ជកម្មអេឡិចត្រូនិក អាចនាំមកនូវការផ្លាស់ប្តូររបៀបធ្វើការការជំនួសការងារដោយម៉ាស៊ីនស្វ័យប្រវត្តិ និងគ្រឿងយន្ត ការពង្រឹងខ្សែច្រវ៉ាក់ផលិតកម្ម និងការរីកកាន់តែធំនៃគម្លាតឌីជី ថលក្នុងចំនោមតួរអង្គពាក់ព័ន្ធ។ ក្នុងន័យនេះ កម្លាំងពលកម្មដែលមានសមត្ថភាព សម្របនឹងចរន្តឌីជីថលនឹងទទួលបានអត្ថប្រយោជន៍ ចំណែកឯអ្នកដែលមិនអាចសម្របខ្លួនបាន ប្រឈមនឹងការបាត់បង់ការងារ ដែលនាំទៅរកស្ថានភាពគ្មានការងារធ្វើ នៅក្នុងវិស័យមួយចំនួន ឬនិកម្មភាពចលនាសម្ព័ន្ធណាសម្ព័ន្ធជាក់ស្តែងសេដ្ឋកិច្ចឌីជីថល ហាក់ចាប់បង្ខំប្រភេទពលកម្មដែល គ្មានជំនាញឬជំនាញទាប ឱ្យចាប់យកជំនាញឌីជីថលកម្រិតមូលដ្ឋាន ដើម្បីរក្សាការងារឬមុខរបរទាំងនោះ។ ឧទាហរណ៍អ្នករត់ម៉ូតូឌុប និងអ្នកបើករ៉ឺម៉ក ត្រូវចេះប្រើប្រាស់កម្មវិធីដូចជា កម្មវិធីផែនទីការទូទាត់តាមប្រព័ន្ធធនាគារ ពាណិជ្ជករ ឬអាជីវករខ្នាតតូចត្រូវចេះប្រើប្រាស់កុំព្យូទ័រ និងទូរស័ព្ទឆ្លាតវៃក្នុងការទិញលក់ទំនិញឬសេវាតាមប្រព័ន្ធអេឡិចត្រូនិក និងទទួលយកការទូទាត់សងប្រាក់តាមប្រព័ន្ធធនាគារ។ ជាងនេះទៅទៀត ការវិវត្តនិងភាពប្រកួតប្រជែងគ្នានៃបច្ចេកវិទ្យាឌីជីថល និងបង្កើតឱ្យមានការផ្ទេរនូវចំណេះដឹងនិងជំនាញជាច្រើន ប៉ុន្តែក៏លុយធ្វើឱ្យមានគម្លាតនៃឌីជីថលរីកកាន់តែធំដោយអ្នកមានលទ្ធភាពទាប និងឱកាសតិចតួចមិនអាចប្រកួតប្រជែងក្នុងទីផ្សារ ការងារបាន។
- **ការប្រែប្រួលមូលដ្ឋាននៃការប្រមូលចំណូលពន្ធ** ៖ វិស័យពាណិជ្ជកម្មអេឡិចត្រូនិក ការធ្វើបដិវត្តន៍បដិវត្តកម្មឌីជីថលក្នុងសេដ្ឋកិច្ចភ្នំពេញថានឹងបង្កើនកាលានុភាពនៃចំនួនពន្ធរបស់រាជរដ្ឋាភិបាលតាមរយៈការជំរុញ និងការបង្កើតនូវសកម្មភាពសេដ្ឋកិច្ច។ ទោះជាយ៉ាងណាក្តីហេតុការណ៍នេះក៏បានបង្កើតជាបច្ច័យអវិជ្ជមានមួយចំនួនដល់ការប្រមូលចំណូលសារពើពន្ធអាក្នុងរូបភាពជាការបាត់បង់ចំណូលពន្ធ និងមូលដ្ឋានពន្ធ ដោយសារអវត្តមានរូបវន្តបុគ្គលអាជីវកម្មក្នុងស្រុក ព្រោះថា

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ពុំមានដែនកំណត់ឡើយ។ ការកំណត់និយមន័យចំណូលមិនទាន់មានភាពច្បាស់លាស់ខណៈពុំទាន់មានយន្តការណា ល្អប្រសើរក្នុងការដោះស្រាយបញ្ហាដែលកើតមានឡើង និងយន្តការប្រមូលអាករលើតម្លៃបន្ថែមមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមិនទាន់មានប្រសិទ្ធភាពខ្ពស់ ក្នុងបរិការណ៍នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

- **ការបង្វែរអទិភាពនៃចំណែកវិនិយោគសាធារណៈ៖** នៅក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមដែលជាថតពីរដ្ឋាភិបាលមានតួនាទីសំខាន់ ក្នុងការដឹកនាំនិងការជំរុញការកសាង វិស័យពាណិជ្ជកម្មអេឡិចត្រូនិក ឆ្លើយតបទៅនឹងការតម្រូវការដែលនោះទាមទារឱ្យមានការគៀងគរក៏ធនធានសម្រាប់ការវិនិយោគជាលទ្ធផលការនេះនឹងក្លាយជាបន្ទុកសម្រាប់ការប្រមូលចំណូល ដើម្បីបំពេញតម្រូវការនៃការវិនិយោគព្រមទាំងនឹងក្លាយជាសម្ពារលើការចែករំលែកធនធានដែលមានកំណត់តាមសម្រាប់ការអភិវឌ្ឍវិស័យនេះដែលតម្រូវឱ្យមានការថ្លឹងថ្លែងលើអាទិភាពវិនិយោគសាធារណៈទាំងមូល[129]។

❖ **ផលប៉ះពាល់ទៅលើសង្គម**

- **ការបាត់បង់ឯកជនភាពនៃទិន្នន័យផ្ទាល់ខ្លួន និងព័ត៌មានមិនពិត និងព័ត៌មានក្លែងក្លាយ៖** ទិន្នន័យផ្ទាល់ខ្លួនកាន់តែច្រើនកំពុងត្រូវបានប្រមូលនិងដោះដូរ ជាពិសេសតាមប្រព័ន្ធអ៊ីនធើណេតនៃវត្ថុខណៈដែលបុគ្គលជាម្ចាស់ទិន្នន័យមិនបានដឹង ឬមិនអាចគ្រប់គ្រងលំហូរទិន្នន័យនេះបានដោយការប្រើប្រាស់កម្មវិធី ឬឧបករណ៍ឌីជីថលដូចជាការប្រើប្រាស់បច្ចេកវិទ្យា សម្គាល់មុខការធ្វើអន្តរកម្មលើប្រព័ន្ធសង្គម ការប្រើប្រាស់ម៉ាស៊ីនស្វែងរក និងថាប្រើប្រាស់ឧបករណ៍ឆ្លាតផ្សេងៗជាមួយគ្នានេះ។ ក្រុមហ៊ុនគ្រប់គ្រងប្រព័ន្ធនិងបច្ចេកវិទ្យាទាំងនោះ អាចតាមដានរាល់ប្រតិបត្តិការនិងទំនាក់ទំនងដែលកើតកើតមានឡើងនៅលើប្រព័ន្ធ និងបច្ចេកវិទ្យារបស់ខ្លួន ដែលនេះជាការរំលោភបំពានលើឯកជនភាព របស់អ្នកប្រើប្រាស់។ បន្ថែមពីលើនេះការចែកចាយព័ត៌មានមិនពិតនិងព័ត៌មានក្លែងក្លាយ គឺជាបញ្ហាដ៏ធំមួយ ដែលធ្វើឱ្យអ្នកប្រើប្រាស់ទទួលបានព័ត៌មានមិនច្បាស់លាស់ និងបង្កឱ្យមានការភ័ន្តច្រឡំដែលអាចបណ្តាលឱ្យមានការខាតបង់ទាំងពេលវេលានិងថវិកាព្រមទាំងផ្តល់ផលប៉ះពាល់ដល់សតិអារម្មណ៍របស់ប្រជាពលរដ្ឋទូទៅ ឬបង្កជាការបាក់បែកចរាចរណ៍ឬពិតពិតភាពបាតុភាពក្នុងសង្គម។

[129] ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ. (១៨ ឧសភាឆ្នាំ២០២១). *ក្របខណ្ឌ គោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា*, រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា, ៨។

- **ឧក្រិដ្ឋកម្មនិងការគំរាមកំហែងតាមប្រព័ន្ធអ៊ីនធើណេត៖** ឧបករណ៍ដែលបានភ្ជាប់ជាមួយនឹងប្រព័ន្ធ internet អាចជាគោលដៅសម្រាប់ការប្រតិបត្តិឧក្រិដ្ឋកម្ម តាមរយៈការហេតុឧក្រិដ្ឋជនអាចចូលទៅមើលលួច និងក្លែងបន្លំព័ត៌មានសំខាន់ៗរបស់បុគ្គល ឬអង្គភាពក្នុងរូបភាពទីអាទិ៍ការរំលោភបំពានលើឯកជនភាព ការលួចអត្តសញ្ញាណ ការក្លែងបន្លំអត្តសញ្ញាណ។ ឧក្រិដ្ឋកម្មទាំងអស់នេះ អាចមានផលប៉ះពាល់ដល់សុវត្ថិភាពអ្នកប្រើប្រាស់ប្រព័ន្ធឌីជីថល ផ្នែកហិរញ្ញវត្ថុ និងផ្ទាល់ខ្លួនព្រមទាំងអាចបណ្ដាលឱ្យបាត់បង់ភាពជឿជាក់ ពីសំណាក់អ្នកប្រើប្រាស់ បន្ថែមពីនេះការវាយប្រហារមកលើបុគ្គលឯកជន តាមរយៈការផ្ញើសារគម្រាមដោយផ្ទាល់ ឬដោយប្រយោល ដែលអាចប៉ះពាល់ដល់សតិអារម្មណ៍ និងការបង្កជាហានិភ័យដល់សុខភាពផ្លូវចិត្ត និងផ្លូវកាយគឺជាផលវិបាកនៃការគំរាមកំហែងតាមប្រព័ន្ធអេឡិចត្រូនិក។

**កថាខណ្ឌទី២៖ ការគ្រប់គ្រងហានិភ័យ**

ការសម្រេចបាននូវវិស័យពាណិជ្ជកម្មអេឡិចត្រូនិក ក្នុងបរិវត្តកម្មឌីជីថលនៅសេដ្ឋកិច្ច និងសង្គមកម្ពុជា ទាមទារនូវកិច្ចខិតខំប្រឹងប្រែងនិងសម្រេចអត់បាននូវវិធានការ គោលនយោបាយទាំងឡាយបានគិតគូរបានដាក់ចេញ ដោយក្រសួងស្ថាប័នពាក់ព័ន្ធក្នុងស្មារតីទទួលខុសត្រូវនិងប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពខ្ពស់។ ជាមួយគ្នានេះដែរ ការអភិវឌ្ឍការវិវត្តន៍ឥតឈប់ឈរនៃស្ថានការណ៍សេដ្ឋកិច្ច និងសង្គមនៅក្នុងប្រទេសតំបន់ និងសកលនឹងក្លាយទៅជាហានិភ័យ ដែលអាចជះឥទ្ធិពលទាំងវិជ្ជមាន និងអវិជ្ជមានដោយផ្ទាល់ និងដោយប្រយោលទៅលើគោលដៅនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមហានិភ័យទាំងនេះ មកអះដល់ការចូលរួមក៏ដូចជាការធ្វើឱ្យរាំងស្ទះឬបង្អង់ល្បឿនក្នុងការអនុវត្តនុងការសម្រេចឱ្យបាននូវចក្ខុវិស័យចម្បងនៃក្របខ័ណ្ឌគោលនយោបាយនេះ។

**ក. ហានិភ័យក្នុងប្រទេស**

- **ភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ចនៅក្នុងស្រុក៖** ការរាតត្បាតនៃជម្ងឺកូវីដ-១៩ ដែលហាក់មិនទាន់បង្ហាញសញ្ញាថម ថយក៏ដូចជាបច្ច័យអវិជ្ជមានមកលើសេដ្ឋកិច្ចកម្ពុជាមានទំហំធំ ដែលអាចជះឥទ្ធិពលដល់ដំណើរការទៅ ដោយហេតុនេះ ទាមទារឱ្យមានការវិនិយោគដ៏ធំសម្បើមទៅលើហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដែលមានលក្ខណៈបំពេញបន្ថែម និងគាំទ្រដល់ប្រតិបត្តិការនានាក្នុងយុគសម័យថ្មីនេះ។ ភាពមិនប្រាកដប្រជានៃស្ថានភាពសេដ្ឋកិច្ចក្នុងរយៈពេលខ្លីទៅមធ្យម ក៏ដូចជាការធ្វើវិចារណកម្មចំណាយសាធារណៈ ក្នុងន័យរក្សាលំនឹងនិងជីវភាពរបស់ប្រជាពលរដ្ឋ និងអាជីវកម្មក៏ដូចជាការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ នេះបានកាត់បន្ថយលទ្ធភាពថវិការបស់រាជរដ្ឋាភិបាល ក្នុងការវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា។ ការនេះទាមទារឱ្យមាន

ការគិតគូរយ៉ាងម៉ត់ចត់ក្នុងការវិនិយោគនៅការកសាងមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ច ដាក់អនុវត្តនូវយន្តការមួយចំនួនជាអាទិ៍និងការភាពជាដៃគូរវាងរដ្ឋ និងឯកជនដែលមានប្រសិទ្ធភាពនិងលទ្ធភាពខ្ពស់ក្នុងការជំរុញវិញបដិវត្តន៍កម្មឌីជីថលឱ្យទៅមុខ។ ទន្ទឹមនឹងនេះរាជរដ្ឋាភិបាលត្រូវគ្រប់គ្រងវិភាគនិងជំរុញការប្រើប្រាស់ធនធានជាតិឱ្យកាន់តែមានប្រសិទ្ធភាព និងសក្តិសិទ្ធិភាពខ្ពស់។

- **វំហូរកម្លាំងពលកម្មមានជំនាញពីប្រទេសជិតខាងនិងការប្រកួតប្រជែងក្នុងទីផ្សារការងារ៖** នៅក្នុងបរិបទបរិការណ៍ ដែលវិស័យពាណិជ្ជកម្មអេឡិចត្រូនិក កំពុងក្លាយទៅជាទិសដៅរួមរបស់ប្រទេសមួយចំនួននៅក្នុងតំបន់និងសកលគួបផ្សំនឹងនិន្នាការសកលភាវូបនីយកម្ម កម្លាំងពលកម្មត្រូវបានសង្កេតឃើញមានការបំលាស់ទីពីប្រទេស ដែលមានអតិរេកកម្លាំងពលកម្មមានជំនាញ ទៅកាន់ប្រទេសដែលកំពុងអភិវឌ្ឍ។ ស្រដៀងគ្នានេះដែលកម្ពុជានឹងប្រឈមនឹងការហូរចូលនូវអ្នកជំនាញពីក្រៅប្រទេស ដែលបង្កើតលក្ខខណ្ឌមិនសមស្របក្នុងការអភិវឌ្ឍធនធានមនុស្សនៅក្នុងស្រុក ទោះបីជាការហូរចូលធនធានមនុស្សពីបរទេស អាចជួយជំរុញការផ្ទេរចំណេះដឹងនិងជំនាញដល់កម្ពុជាក៏ដោយ រដ្ឋាភិបាលចាំបាច់ត្រូវដាក់ចេញនូវគោលការណ៍នយោបាយ ពាក់ព័ន្ធសំដៅរក្សាតុល្យភាពនៃការនាំចូលអ្នកជំនាញនិងអភិវឌ្ឍធនធានមនុស្សនៅក្នុងស្រុក។
- **ការដួលរលំនៃអាជីវកម្មខ្នាតតូច ដែលមានសមត្ថភាពចាប់យកនិងការបំលែងខ្លួនក្នុងរយៈពេលខ្លី** ៖ វិស័យពាណិជ្ជកម្មអេឡិចត្រូនិក នឹងនាំមកនូវចរន្តនៃការរីកចម្រើនផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាត្រូវជះឥទ្ធិពលយ៉ាងខ្លាំង ទៅលើការកំណត់ឡើងវិញ នូវកត្តាផលលិតកម្មទំនាក់ទំនងផលិតកម្ម និងឥរិយាបទនៃការប្រើប្រាស់ផលិតកម្ម និងអាជីវកម្មនៅក្នុងស្រុក ដែលភាគច្រើនមានលក្ខណៈជាប្រតិកម្មបែបប្រពៃណី និងប្រើប្រាស់ពលកម្ម ដែលមានជំនាញទៀតអាចនឹងមានសមត្ថភាពតិចតួចនិងធ្វើឱ្យមានការរារាំង ក្នុងការចាប់យកវិស័យពាណិជ្ជកម្មអេឡិចត្រូនិក និងការចូលរួមក្នុងសេដ្ឋកិច្ចឌីជីថល ជាពិសេសនៅក្នុងរយៈពេលខ្លីការនេះតម្រូវឱ្យរាជរដ្ឋាភិបាលត្រូវគិតគូររៀបចំច្បាប់ និងបទដ្ឋានគតិយុត្តិ ពាក់ព័ន្ធដើម្បីបង្កើនការត្រៀមខ្លួនរបស់ផលិតកម្មនិងអាជីវកម្មនៅក្នុងស្រុក ក្នុងការទទួលយកវិស័យពាណិជ្ជកម្មអេឡិចត្រូនិក និងសេដ្ឋកិច្ចឌីជីថលដូចជា ជំរុញឱ្យមានការចាប់ផ្តើមប្រើប្រាស់និងការរក្សាការងាររបស់ប្រជាពលរដ្ឋ។

**ខ. ហានិភ័យក្រៅប្រទេស**

- **ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកលនឹងភាពតានតឹងផ្នែកពាណិជ្ជកម្ម៖** ក្នុងបរិការណ៍ដែលជំងឺកូវីដ១៩ កំពុងរីករាលដាល និងការផ្លាស់ប្តូរនៅភូមិសាស្ត្រនយោបាយក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ សេដ្ឋកិច្ចតំបន់ និងសកល បន្តស្ថិតក្នុងភាពមិនប្រាកដប្រជា ដោយសារសង្គ្រាម

ពាណិជ្ជកម្មដែលកើតមានឡើង ដោយសារការអនុវត្តគោលនយោបាយគាំពារនិយមរបស់មហាអំណាចធំៗប្រក្រតីកម្មនៃគោលនយោបាយ រូបិយវត្ថុរបស់ប្រទេសអភិវឌ្ឍ កំណើនឥណទាន និងឆាប់រហ័សក្នុងប្រទេសចិន និងបញ្ហានានាពាក់ព័ន្ធនឹងភូមិសាស្ត្រ នយោបាយ ភេរវកម្មនិងសន្តិសុខសកល។ នៅក្នុងបរិការណ៍នេះគួបផ្សំនឹងសេដ្ឋកិច្ចកម្ពុជា មានភាពដោយផ្អែកលើកត្តាខាងក្រៅ សម្រាប់ជំរុញការអភិវឌ្ឍ ប្រទេសកម្ពុជាត្រូវប្រឈមយ៉ាងខ្លាំងទៅនឹងការប្រែប្រួល ជាអវិជ្ជមានណាមួយនៅក្នុងសេដ្ឋកិច្ចសកល ដែលអាចបង្កផលប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការធ្វើដំណើរការវិស័យពាណិជ្ជកម្មអេឡិចត្រូនិក និងការធ្វើបរិវត្តកម្មឌីជីថលសេដ្ឋកិច្ច និងសង្គមជាតិ។

- **ការប្រកួតប្រជែងកាន់តែខ្លាំង ក្នុងការអភិវឌ្ឍវិស័យពាណិជ្ជកម្មអេឡិចត្រូនិក នៅក្នុងតំបន់ និងទូទាំងពិភពលោក៖** ទោះបីជាប្រទេសអភិវឌ្ឍន៍ជាច្រើន នៅលើពិភពលោកហើយសម្រេចវឌ្ឍនភាពច្រើនមកហើយ ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងវិស័យពាណិជ្ជកម្មអេឡិចត្រូនិករបស់ខ្លួន ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនរួមបញ្ចូលទាំងកម្ពុជាផងដែរ ទើបបាននិងកំពុងចាប់ផ្តើមគិតគូរនិងអនុវត្តក្នុងជំហានដំបូងប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាក្តីការផ្ទុះឡើងនៃជំងឺកូវីដ-១៩ ដែលជំរុញអោយមានអនុវត្តវិធាន ការគម្លាតសង្គម និងការចាប់យកប្រក្រតីភាពថ្មីបានរុញច្រានឱ្យប្រទេសជាច្រើននៅពិភពលោក គិតគូរឡើងវិញលើការជំរុញនិងពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ឬវិស័យពាណិជ្ជកម្មអេឡិចត្រូនិក ។ ក្នុងន័យនេះការរត់ប្រណាំងបច្ចេកវិទ្យា ការស្រាវជ្រាវ និងវានុវត្តន៍នឹងការកើនឡើងកាន់តែខ្លាំង ខណៈដែលប្រទេសដែលមានលទ្ធភាព និងសមត្ថភាពខ្ពស់អាចទទួលបានផលភោគពីបដិវត្តន៍កម្មឌីជីថលនេះបានយ៉ាងលើសលុប ជាងប្រទេសដែលមានទិដ្ឋភាពមានគម្រិត។ ទន្ទឹមនឹងនេះភាពខុសគ្នានៃលទ្ធភាព ក្នុងការជំរុញវិស័យពាណិជ្ជកម្មអេឡិចត្រូនិកបែបថ្មីនេះនឹងជំរុញឱ្យមានគម្លាតកាន់តែធំរវាងប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍន៍។
- **ភាពជឿនលឿននៃបច្ចេកវិទ្យាប្រព្រឹត្តទៅក្នុងល្បឿនមួយមិនធ្លាប់មាន៖** វិបត្តិកូវីដ-១៩ បាននិងកំពុងជំរុញឱ្យនិន្នាការមួយ កំពុងលេចឡើងលើការអភិវឌ្ឍវិស័យពាណិជ្ជកម្មអេឡិចត្រូនិក ដែលធ្វើឱ្យមានការប្រែប្រួលដល់ សេដ្ឋកិច្ច និងពាណិជ្ជកម្មតំបន់ និងសកល។ ផ្អែកលើមូលដ្ឋាននេះបណ្តាលប្រទេសជាច្រើន ជាអាទិ៍ សហភាពអឺរ៉ុបបានដាក់នូវវិធាននិងការស្តារសេដ្ឋកិច្ចឡើងវិញពីវិបត្តិជំងឺកូវីដ-១៩ ដោយផ្តោតលើការអភិវឌ្ឍវិស័យពាណិជ្ជកម្មអេឡិចត្រូនិក របស់ខ្លួនឱ្យកាន់តែលឿនជាងមុន។ ការនេះរំពឹងថានឹងផ្លាស់ប្តូរនូវជីវភាពនៃសេដ្ឋកិច្ច ពិភពលោក ហើយភាពជឿនលឿននៃបច្ចេកវិទ្យា នឹងប្រព្រឹត្តទៅក្នុងល្បឿនមួយ ដែលមិនធ្លាប់ជួបប្រទះពីរដ្ឋាភិបាលត្រូវ

បន្តពង្រឹងមូលដ្ឋានសេដ្ឋកិច្ច ការរៀបចំខ្លួនជាស្រេចសម្រាប់ការធ្វើវិស័យពាណិជ្ជកម្មអេឡិចត្រូនិក និងការធ្វើបដិវត្តន៍តិកម្មឌីជីថលសេដ្ឋកិច្ច និងសង្គម ដែលអាចនឹងមានភាពបត់បែនខ្លាំងក្នុងក្របខណ្ឌប្រទេសតំបន់ និងសកល។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយខាងលើសបញ្ជាក់ឱ្យឃើញថា ស្របពេលដែលពាណិជ្ជកម្មបែបអេឡិកត្រូនិក (E-Commerce) ត្រូវបានគេជជែកពិភាក្សាជាញឹកញាប់ អ្នកជំនាញនិងដៃគូអភិវឌ្ឍន៍នានាទាំងក្នុងវិស័យឯកជន ស្ថាប័នអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលលើកស្ទួយការអភិវឌ្ឍបច្ចេកវិទ្យានៅកម្ពុជា បង្ហាញទស្សនៈសុទិដ្ឋិនិយម លើការវិវត្តនៃវិស័យបច្ចេកវិទ្យានៅកម្ពុជា។ ការអនុម័តច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកគឺដើម្បីមូលដ្ឋានដ៏សំខាន់មួយក្នុងការជំរុញពាណិជ្ជកម្មលើប្រព័ន្ធអេឡិចត្រូនិកក្នុង និងក្រៅប្រទេសប្រកបដោយទំនុកចិត្ត តាមរយៈការទទួលស្គាល់សុពលភាព អនុភាព ភាពអាចអនុវត្តបាននៅក្នុងផ្នែកច្បាប់ សុក្រឹតភាព និងភាពអាចទទួលយកបាននៃទំនាក់ទំនងអេឡិចត្រូនិក កំណត់ត្រាអេឡិចត្រូនិក និងកិច្ចសន្យាតាមប្រព័ន្ធអេឡិចត្រូនិក។ ច្បាប់នេះនឹងរួមចំណែកក្នុងការអភិវឌ្ឍវិស័យឌីជីថលនៅកម្ពុជា ដោយធ្វើយ៉ាងណាធានាបាននូវការប្រកបអាជីវកម្មស្របតាមក្របខណ្ឌច្បាប់ ដែលគាំទ្រវាល់សកម្មភាព និងប្រតិបត្តិការអាជីវកម្មគ្រប់ទម្រង់តាមប្រព័ន្ធអនឡាញ រួមទាំងលើកកំពស់ទំនុកចិត្តដល់សាធារណជនក្នុងការប្រើប្រាស់ពាណិជ្ជកម្មនៅទស្សវត្សថ្មីនេះ។ ជារួមមកដើម្បីការសិក្សាស្រាវជ្រាវទៅលើប្រធានបទ "សមាហរណកម្មនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា" អាចធ្វើការសង្ខេបជា ៣(បី)ចំនុចចម្បង។

ជាដំបូង ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានសញ្ញាណមួយដ៏ពិសេស ពីពាណិជ្ជកម្មតាមបែបប្រពៃណី ឬពាណិជ្ជកម្មតាមបែបទូទៅ។ ពាណិជ្ជកម្មប្រភេទនេះ បានបែងចែកជាទម្រង់ផ្សេងៗគ្នាដោយវាស្ថិតនៅក្រោមប្រភេទអេឡិចត្រូនិកតែមួយ ក្នុងនោះរួមមាន B2B B2C C2B C2C និង B2G។ នៅប្រទេសកម្ពុជា ទម្រង់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក B2C មានភាពពេញនិយម និងសម្បូរបែបពីសំណាក់អ្នកប្រើប្រាស់នៅកម្ពុជា ព្រោះទម្រង់ប្រភេទនេះមានលក្ខណៈសមស្របទៅនឹងទីផ្សារពាណិជ្ជកម្ម និងបរិបទសេដ្ឋកិច្ចអាជីវកម្មនៅកម្ពុជា ដោយប្រជាជនដែលជាអាជីវករបានចូលរួមប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកដើម្បីដាក់លក់ ឬសេវាកម្មជាសាធារណៈទៅដល់អ្នកប្រើប្រាស់តាមថ្នាលអ៊ីនធើណែតដូចជា វេបសាយ ឬគណនេយ្យបណ្តាញសង្គមផ្ទាល់ខ្លួន។ អ្នកប្រើប្រាស់នៅកម្ពុជា ក៏ពេញនិយមទិញទំនិញតាមការដាក់លក់បែបនេះដែរ ដែលប្រតិបត្តិការទិញលក់បែបនេះបានឆ្លើយតបជាផ្នែកមួយយ៉ាងសំខាន់នឹងការកើនឡើងនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ទន្ទឹមនឹងការដែលពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកំពុងតែមានសក្តានុពលនៅក្នុងវិស័យពាណិជ្ជកម្មកម្ពុជា វិស័យធនាគារមានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើជា អន្តរការីនៃប្រតិបត្តិការទូទាត់ប្រាក់ក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ។ យើងសង្កេត

ឃើញថា វិស័យធនាគារនាពេលបច្ចុប្បន្នមានសន្ទុះយ៉ាងកត់សម្គាល់ ដោយបង្កើតនូវសេវាកម្មធនាគារថ្មីៗ ដែលផ្តល់ភាពងាយស្រួលសម្រាប់អ្នកប្រើប្រាស់នៅក្នុងវិស័យនេះដូចជា សេវាកម្មផ្ទេរប្រាក់ ABA Wing Truemoney E Money AEON ។ទាំនាក់ទំនងនៃវិស័យទាំងពីរនេះត្រូវបានស្ថិតក្រោមក្រសួងដែលមានសមត្ថកិច្ចធំៗសម្រាប់គ្រប់គ្រងដំណើរការនៃប្រតិបត្តិការទាំងមូលគឺ ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងប្រៃសណីយ និងទូរគមនាគមន៏ ដែលមានមុខងារ និង តួរនាទីដោយឡែកពីគ្នា។

លើសពីនេះទៅទៀត កម្ពុជាជាប្រទេសដែលមាននីតិរដ្ឋ ដែលរាល់សកម្មភាពទាំងអស់ដែលទាក់ទងនឹងជីវភាពរស់នៅរបស់ប្រជាជន ត្រូវគោរពតាមគោលការណ៏ស្របច្បាប់ និងសមធម៌។ វិស័យពាណិជ្ជកម្ម ព្រមទាំងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានរបបគត្តិយុត្តិត្រឹមត្រូវ ជាពិសេសការបង្កើតកិច្ចសន្យាទៅលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឱ្យមានអានុភាព និងសុពលភាពត្រឹមត្រូវដូចទៅនឹងដំណើរការប្រតិបត្តិពាណិជ្ជកម្មទូទៅដែរ។ ចំនុចសំខាន់ៗនៃអនុភាពគត្តិយុត្តិចំពោះពាណិជ្ជកម្មដ៏ថ្មីនេះ គឺផ្អែកទៅលើក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រដែលជាច្បាប់គោលមានអាទិភាពគ្រប់គ្រងនូវសញ្ញាណឬបញ្ញត្តិនានាដែលមានទាក់ទងនឹងវិស័យឯកជន។ ដូចគ្នាផងដែរធាតុផ្សំនៃកិច្ចសន្យាគឺ សំណើ និងស្វីការដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ក៏មានអានុភាពអានុវត្តផងដែរចំពោះ ការបង្កើតកិច្ចសន្យាទិញលក់នៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ មួយវិញផងដែរចំនុចពិសេស នៃលក្ខណៈគតិយុត្តិក៏ដូចជាគោលការណ៏គោលដែលប្រកាន់ខ្ជាប់ចំពោះពាណិជ្ជកម្មមួយប្រភេទនេះ គឺការទទួលស្គាល់នូវសុពលភាពរបស់ប្រតិបត្តិការពាណិជ្ជកម្មដែលកើតមានតាមប្រព័ន្ធអេឡិចត្រូនិក។ យោងតាមច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៃព្រះរាជាណាចក្រ និង ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៃសន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍន៍ (UNCTAD- E-commerce) បានបញ្ជាក់ថា គ្មានបុគ្គលណាម្នាក់អាចបដិសេដមិនទទួលស្គាល់អានុភាពគតិយុត្តិ ឬសុពលភាព ដោយសំអាងលើមូលហេតុដែលថាវាគ្រាន់តែបានធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិក ឬដែលស្ថិតនៅក្នុងទំនាក់ទំនងអេឡិចត្រូនិកឡើយ។ ការកំណត់នេះ ត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បីឱ្យមានសមភាពរវាងពាណិជ្ជកម្មទូទៅ និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក បើទោះបីពាណិជ្ជកម្មទាំងពីរមានលក្ខណៈខុសគ្នានៅត្រង់ចំនុចខ្លះក៏ដោយ ក៏ពួកគេនៅតែមានអានុភាពគតិយុត្តិដូចគ្នាដែរ។របបគតិយុត្តិនេះ ផ្តល់នូវកិច្ចការពារអ្នកប្រើប្រាស់ ដែលជាតួរអង្គងាយនឹងទទួលហានិភ័យចំពោះប្រតិបត្តិពាណិជ្ជកម្មតាមប្រព័ន្ធអឡិចត្រូនិចជាងគេ។

ទន្ទឹមនឹងការវិវត្តិឥតឈប់ឈរនៃវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ ក៏ប្រទេសកម្ពុជានូវមានកង្វះខាតជាច្រើនផ្តល់ជាឧបសគ្គក្នុងការដែលធ្វើឱ្យការអភិវឌ្ឍវិស័យនេះនៅមានកម្រិត។ បើទោះបីជាមានការផ្លាស់ប្តូរពីពាណិជ្ជកម្មបែបប្រពៃណី ហេតុក្លាយជាការពេញនិយមក្នុងការប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក៏ដោយក្តី ក៏ការអនុវត្ត និងដំណើរការនៃវិស័យនេះមិនទាន់ឈានដល់កម្រិតដែលអាចមានការប្រកួតប្រជែងនៅក្នុងបណ្តារប្រទេសជិតខាង និងក្នុងអាស៊ានឡើយ។ មូលហេតុចម្បងដែលរាំងការរីកចម្រើនយ៉ាងឆាប់សរហ័សនៃវិស័យពាណិជ្ជកម្មប្រភេទនេះ គឺការយល់ដឹងទូទៅរបស់ប្រជាជនកម្ពុជាទៅលើការប្រើប្រាស់បច្ចេកវិទ្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះមិនទាន់មានតុល្យភាពរវាងយុវ័យ ប្រជាជនវ័យកណ្តាល និងប្រជាជនវ័យចំណាស់ឡើយ។ ត្រង់ចំនុចនេះ ប្រជាជនភាគច្រើននៅតែនិយមប្រើប្រាស់ពាណិជ្ជកម្មបែបប្រពៃណី។ មួយវិញផងដែរ ការផ្លាស់ប្តូរនៃរចនាសម្ព័ន្ធនៃអ៊ីនធើណេត និង រចនាសម្ព័ន្ធរដ្ឋបាលភូមិសាស្ត្រល្អក៏ជាកក្តាសំខាន់ក្នុងការពន្លឿនវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះឱ្យដើរតាមទាន់បដិវត្តន៏ឧស្សាហកម្មទី៤។

អត្ថប្រយោជន៏នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ ថាវាមានសារៈប្រយោជន៏សម្រាប់សេដ្ឋកិច្ចកម្ពុជា នឹងអាចជួយជំរុញឱ្យលំហូរនៃការទិញ លក់ និងប្រតិបត្តិការពាណិជ្ជកម្មនានានៅកម្ពុជាមានការកើនឡើងជាលំដាប់។ ប្រៀបទៅនឹងប្រទេសនានានៅក្នុងតំបន់អាស៊ាន ប្រទេសកម្ពុជាត្រូវពន្លឿនការអភិវឌ្ឍរបស់ខ្លួនឱ្យតាមទាន់ ប្រទេសនានាក្នុងតំបន់អាស៊ានដែលយកវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ ជាសកម្មភាពប្រចាំថ្ងៃក្នុងការរស់នៅរបស់ប្រជាជនគេ។ ប្រទេសដែលមានលំដាប់ខ្ពស់ក្នុងវិស័យនេះដូចជា ប្រទេសសិង្ហបុរី ប្រទេសឥណ្ឌូនេស៊ី មាឡេស៊ី និង វៀតណាម ក៏បានបន្តពង្រឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ ឱ្យកាន់តែមានចីរភាពជាបន្តទៅមុខទៀត ស្របតាមសម័យកាលដែលបច្ចេកវិទ្យាជាឧបករណ៏ជំនួយ និងដោះស្រាយការលំបាកក្នុងរស់នៅរបស់ប្រជាជន។ យុវជនដែលជាធនធានមនុស្សយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍសង្គមជាតិ នឹងចូលរួមយ៉ាងមមាញឹកដោយមានប្រសិទ្ធភាពក្នុងការធ្វើទំនើបកម្មពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ ដោយប្រែក្លាយកម្ពុជាជាប្រទេសសម្បូរបែបផ្នែកពាណិជ្ជកម្ម និងមានភាពលេចធ្លោលើឆាកអន្តរជាតិ។

# អនុសាសន៍

# អនុសាសន៍

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកភាគ គឺជាវិស័យដែលមានភាពរស់រវើកបំផុតនៅក្នុងបដិវត្តន៍ឧស្សាហកម្ម៤.០។ ក្នុងរយៈពេល ៥-១០ ឆ្នាំខាងមុខទីផ្សារពាណិជ្ជកម្មអេឡិចត្រូនិកក្នុងតំបន់ត្រូវបានព្យាករណ៍ថានឹងកើនឡើងជាមធ្យមអត្រា ២៥-៣៥% ក្នុងមួយឆ្នាំ។ នៅឆ្នាំ ២០២៥ ពាណិជ្ជកម្មអេឡិចត្រូនិកនឹងតំណាងឱ្យទីផ្សារលើសពី ១០០ ដុល្លារអាមេរិកពាន់លានដុល្លារកើនឡើងពី ២០ ពាន់លានដុល្លារអាមេរិកក្នុងឆ្នាំ ២០១៧។ វាជាមូលហេតុយ៉ាងមហិមាដែលធ្វើឱ្យបណ្តាប្រទេសជាច្រើនមិនត្រឹមតែតំបន់អាស៊ានទេ គឺបណ្តារប្រទេសក្នុងពិភពលោកបានបង្ហាញពីកិច្ចខិតខំប្រឹងយ៉ាងតំណំលើការត្រៀមខ្លួន ឬសឹងតែកំពុងស្ថិតក្នុងដំណាក់កាលនៃការអនុវត្តគោលនយោបាយរបស់ខ្លួនសម្រាប់ការចូលមកដល់នៃគំរូសេដ្ឋកិច្ចឌីជីថល ដើម្បីធានានូវការទទួលយកនូវអត្ថប្រយោជន៍ដែលបានមកពីឱកាសដ៏ត្រចះត្រចង់នេះសម្រាប់ប្រទេសរបស់ពួកគេ។

ដូចនេះដើម្បីឆ្លើយតបជាដំណោះស្រាយបញ្ហាប្រឈមនិងឧបសគ្គដែលជារនាំងនៃការអភិវឌ្ឍវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក យើងខ្ញុំសូមលើកឡើងនូវអានុសាសន៍ដូចខាងក្រោម៖

**ក. ការឆ្លើយតបនឹងការពង្រឹងច្បាប់គ្រប់គ្រង និងនិយ័តកម្មនានា**

ដោយហេតុតែប្រទេស កម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍ វិស័យច្បាប់មានសារៈសំខាន់ណាស់នៅក្នុងការគ្រប់គ្រងសកម្មភាពអ្នកប្រើប្រាស់ប្រព័ន្ធអ៊ីនធើណេត និងដំណើរការពាណិជ្ជកម្មនៅក្នុងប្រព័ន្ធអេឡិចត្រូនិក ដើម្បីផ្តល់ទំនុកចិត្ត និងសុវត្ថិភាពដែលជាកត្តាចម្បងក្នុងការប្រមែលប្រមូលឱ្យចំនួនអ្នកប្រើប្រាស់កើនឡើងជាលំដាប់ និង មិនផ្តល់ផលពិបាកផ្សេងៗសម្រាប់អ្នកប្រើប្រាស់។ ការគាំទ្រលើការចុះបញ្ជី និងការលើកទឹកចិត្តផ្នែកសារពើពន្ធ ដែលមានគោលបំណងផ្តោតលើការសម្របសម្រួលក្នុងការទទួលបានព័ត៌មានថ្មីៗពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវជាក់លាក់អំពីការចុះបញ្ជី និងការផ្តល់អាជ្ញាប័ណ្ណសម្រាប់សហគ្រាសពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ទន្ទឹមនឹងនេះ ការយល់ដឹងរបស់មន្ត្រីក្រសួងពាក់ព័ន្ធនឹងប្រតិបត្តិការនៃពាណិជ្ជកម្មនេះត្រូវតែពង្រឹងឱ្យកាន់តែប្រសើរផងដែរ។

មិនត្រឹមតែប៉ុណ្ណោះ នៅពេលដែលមានគោលនយោបាយដែលផ្តោតការយកចិត្តទុកដាក់ និងពេញលេញគ្រប់បញ្ហាដែលមានក្នុងវិស័យនេះ វាធានាបាននូវព័ត៌មានដែលគ្មានការក្លែងបន្លំ ឬកេងចំនេញផលប្រយោជន៍ពីអ្នកប្រើប្រាស់ឡើយទាំងក្នុងស្រុក និងក្រៅប្រទេស។ វាផ្តល់នូវសមភាពសម្រាប់ការទទួលបាន និងប្រើប្រាស់ព័ត៌មានដែលមានសន្តិសុខល្អក្នុងការទូទាត់ប្រាក់ក្នុងការធ្វើពាណិជ្ជកម្មដោយសេរី និង

ទទួលបានចំណាប់អារម្មណ៍ក្នុងការធ្វើវិនិយោគទុនធំៗពីក្រៅប្រទេស។ វាក៏ពាក់ព័ន្ធបទប្បញ្ញត្តិតាមបែបប្រពៃណីផ្សេងៗដែលគ្របដណ្តប់លើបញ្ហាពាណិជ្ជកម្មអន្តរជាតិផងដែរដូចជាពន្ធគយ និងការលើកលែងពន្ធគយ ការសម្របសម្រួលផ្នែកពាណិជ្ជកម្ម ការការពារអ្នកប្រើប្រាស់ និងកម្មសិទ្ធិបញ្ញាជាដើម។ ព្រមទាំងបញ្ហាថ្មីដូចជា លំហូរព័ត៌មានឆ្លងដែន ការការពារទិន្នន័យឯកជន ការធ្វើមូលដ្ឋាននីយកម្មទិន្នន័យ ការបង្ហាញប្រភពកូដ។ល។ ដូចនេះ ការពង្រឹងច្បាប់នាំឱ្យមានសក្តានុពលទីផ្សារ និងការប្រកួតប្រជែងដោយយុត្តិធម៌។ឧទាហរណ៍ មានភាពសកម្មជាមួយនឹងប្រទេសដែលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក ដោយផ្តួចផ្តើមគំនិតបង្កើតសេចក្តីថ្លែងការណ៍រួមស្តីពី ប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកអន្តរតំបន់ ដើម្បីផ្តល់ឱ្យមានសមាហរណកម្មនៃវិស័យនេះរវាងប្រទេសក្នុងតំបន់ និង ក្នុងពិភពលោក។

**ខ. ការឆ្លើយតបនឹងការពង្រឹងសមត្ថភាពនៃរចនាសម្ព័ន្ធអ៊ីនធើណេតក្នុងស្រុក**

ការតភ្ជាប់ល្អប្រសើរ នឹងបង្កើនការផ្គត់ផ្គង់ប្រព័ន្ធអ៊ីនធើណេតជាសាធារណៈទាំងបរិមាណ គុណភាព និងការកាត់បន្ថយលទ្ធភាពនៃការបែងចែកប្រព័ន្ធឌីជីថល។ វិស័យសាធារណៈ និងវិស័យឯកជនគួរតែនាំមុខក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធឱ្យបានគ្រប់គ្រាន់ និងប្រកបដោយនិរន្តរភាព។ សម្រាប់ប្រទេសក្នុងអាស៊ាន ឧបករណ៍គោលនយោបាយ និងភាពជាដៃគូកិច្ចសហប្រតិបត្តិការអន្តររដ្ឋាភិបាលការវិនិយោគបរទេស មានសារៈសំខាន់ដូចគ្នាដើម្បីបង្កើតឱ្យមានការអភិវឌ្ឍយ៉ាងឆាប់រហ័ស។ការចូលរួមរបស់វិស័យឯកជនក្នុងតំបន់នឹងជួយនូវធនធាន បច្ចេកវិទ្យានិងហិរញ្ញវត្ថុដែលជាតម្រូវការចាំបាច់ក្នុងការកសាងរចនាសម្ព័ន្ធអ៊ីនធើណេតល្អក្នុងស្រុក។ វិស័យពាណិជ្ជកម្មឌីជីថល ត្រូវការវិស័យឯកជនធ្វើការសម្របសម្រួល និងសហការបង្កើតគោលគំនិត គោលជំហរនានា និងការប្រឹក្សាដែលអាចជាប្រយោជន៍ជួយដល់វិស័យសាធារណៈក្នុងការបំពេញភាពចន្លោះប្រហោងនៅកម្រិតគោលនយោបាយ រួមផ្សំជាមួយវិស័យនេះងាយទទួលផលប៉ះពាល់ទើបទាមទារឱ្យមានការជួយជ្រោមជ្រែងយ៉ាងពេញទំហឹង និងក្នុងរូបភាពពហុផ្នែក។ឧទាហរណ៍ ការវិនិយោគទុនក្នុងវិស័យអ៊ីនធើណេតឬវិស័យសំណង់របស់ប្រទេសដែលមានសេដ្ឋកិច្ចយក្សដូចជាចិននិងជប៉ុនដើម្បីរុករកទីផ្សារក្រៅប្រទេសរាជរដ្ឋាភិបាលទាំងពីរបានមានឆន្ទៈក្នុងការអត្រាការប្រាក់ទាបសម្រាប់ការឱ្យខ្ចី ឬជំនួយហិរញ្ញវត្ថុនានាទៅក្នុងប្រទេសដែលបានត្រូវបានវិនិយោទុនដើម្បីផ្តល់ជាការគាំទ្រនូវគម្រោងអភិវឌ្ឍនានាដោយមានការចូលរួមពីក្រុមហ៊ុនក្រៅស្រុកទាំងនោះ។

**គ. ការឆ្លើយតបនឹងការពង្រឹងនូវធុរកិច្ចថ្មី (Start-Up)**

អាជីវកម្មបង្កើតថ្មីនៅក្នុងវិស័យពាណិជ្ជកម្ម ហិរញ្ញវត្ថុ និងបច្ចេកវិទ្យាមានសន្ទុះកើនឡើងការប្រកួតប្រជែងយ៉ាងកត់សម្គាល់ចំពោះបរិយាកាសសេដ្ឋកិច្ច ជាពិសេសនៅក្នុងប្រទេសសិង្ហបុរី និងឥណ្ឌូនេ

ស៊ីតែម្តង។ នៅកម្ពុជាយើង ក៏មានផងដែរនៅក្រុមហ៊ុនអាជីវកម្មបង្កើតថ្មីដូចជាក្រុមហ៊ុនទូរស័ព្ទចល័ត SMART NHAM 24 FOOD PANDA និងក្រុមហ៊ុនសាខា របស់សិង្ហបុរីដូចជា Grab Passapp ជាដើមដែលមានវត្តមានផ្តល់ជាភាពងាយស្រួលដល់ការរស់នៅរបស់ប្រជាជនកម្ពុជា។ អាជីវកម្មបង្កើតថ្មីនេះអាចនឹងធ្វើប្រជាជនងាកមិនផុតពីការប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឡើយ ព្រោះវានឹងធ្វើឱ្យការប្រើប្រាស់នូវសកម្មភាពប្រចាំថ្ងៃមានស្តង់ដារមួយកម្រិតធំ ។ ការបំផុសឱ្យ យុវជនមានការប្រកួតប្រជែងដោយពង្រឹងសមត្ថភាពខ្លួនឯង ស្វែងរកគំនិតថ្មីៗ បង្កើតធុរកិច្ចដោះស្រាយរបៀបរបបរស់នៅរបស់មនុស្ស ដោយសង្កេតមើលពីនិន្នាការសកលលោក ឬក្នុងបរិបទកម្ពុជា ជាកត្តាសំខាន់ណាស់សម្រាប់ធ្វើឱ្យអាជីវកម្មបង្កើតថ្មីនៅកម្ពុជា មានភាពលេចធ្លោ។ មិនត្រឹមតែប៉ុណ្ណោះ រាជរដ្ឋាភិបាលគួរតែលើកតម្កើងវិស័យនេះឱ្យបានពេញនិយមខ្លាំងនៅកម្ពុជា ជាពិសេសយុវវ័យដែលមានភាពវៃឆ្លាត និងគំនិតច្នៃប្រឌិតខ្ពស់ ដោយផ្តល់ជាកញ្ចប់ថវិការសម្រាប់ការអភិវឌ្ឍសហគ្រិនភាព ក៏ដូចជាធនធានឥតសំណង(seed funding) គាំទ្រដល់ការចាប់ផ្តើមបង្កើតនូវអាជីវកម្មផ្នែកនេះ។ ជាមួយគ្នានេះ សកលវិទ្យាល័យនានាត្រូវរៀបចំកម្មវិធីសិក្សាទាន់សម័យកាលបច្ចេកវិទ្យាថ្មី ដែលអាចឱ្យយុវជនមានសមត្ថភាពដល់ការបង្កើតអាជីវកម្មបង្កើតថ្មីផ្នែកបច្ចេកវិទ្យា (TechStartup) ប្រកបដោយនវានុវត្តន៍ និង ជាធុរកិច្ចដើម្បីសម្រួល ឬផ្លាស់ប្តូររបៀបរបបរស់នៅរបស់មនុស្ស តាមរយៈគំនិតច្នៃប្រឌិត។

# ឯកសារយោង

# ឯកសារយោង

## ១ លិខិតបទដ្ឋានគតិយុត្តិ

### ១.១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

### ខ. លិខិតឧបករណ៍អន្តរជាតិ

- E-ASEAN framework agreement.
- EU Directives on Electronic Commerce.
- United Nations Conference on Trade and Development.
- UNCITRAL Model Law on Electronic Commerce.
- UNCITRAL Uniform Rules on Electronic Signatures.
- Universal Declaration of Human Rights.

### គ. ច្បាប់

- ក្រមនីតិវិធីរដ្ឋប្បវេណី,ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។
- ក្រមរដ្ឋប្បវេណី,ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។
- ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់,ព្រះរាជក្រមលេខ នស/រក/១១១៩/០១៦, ០២ វិច្ឆិការ ២០១៩។
- ច្បាប់ស្តីពីទូរគមនាគមន៍,ព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧, ២១ ធ្នូ ២០១៥។
- ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក,ព្រះរាជក្រមលេខ នស/រក/១១១៩/០១៧, ០២ វិច្ឆិការ ២០១៩។
- ច្បាប់ស្តីពីសារពើពន្ធ១៩៩៧,ព្រះរាជក្រមលេខ នស/រក/០២៩៧/០៣, ២៤ កុម្ភៈ ១៩៩៧។
- សេចក្តីព្រាងច្បាប់ស្តីពី បទល្មើសបច្ចេកវិទ្យាព័ត៌មាន។

### ១.៤ អនុក្រឹត្យ

- អនុក្រឹតស្តីពីហត្ថលេខាឌីជីថល, លេខ២៤៦ អនក្រ.បក, ២៩ ខែធ្នូ ឆ្នាំ២០១៧។
- អនុក្រឹតស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ៦៥ អនក្រ បក, ០៨, មេសា ២០២១។

## ១.៥ ប្រកាស

- ប្រកាសស្តីពីការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស,លេខ០០៩ សហវ.ប្រក, ១២ មករា ២០២១។
- ប្រកាសស្តីពីការទទួលស្គាល់ និងកាតព្វកិច្ចសារពើពន្ធមួយចំនួនរបស់ភ្នាក់ងារផ្គត់ផ្គង់ទំនិញ និងសេវាកម្មក្នុងនាមសហគ្រាសដើម,លេខ៥៩៧ សហវ.ប្រ, ២៧ ខែធ្នូ ឆ្នាំ ២០១៨។

## ១.៥ គោលនយោបាយ

- ក្របខណ្ឌ គោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥,ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, ១៨ ឧសភាឆ្នាំ២០២១។
- គោលនយោបាយអភិវឌ្ឍន៏វិស័យទូរគមនាគមន៏ បច្ចេកវិទ្យទូរគមនាគមន៏ និង ព័ត៌មានឆ្នាំ ២០២០ "ឆ្ពោះទៅសន្តិភាព និងកម្មញភាពនៃបច្ចេកវិទ្យាគមនាគមន៏ និងព័ត៌មាន",ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ៧៧៣សជណ,២០១៦ ខែមេសា។
- ផែនការមេស្តីពីបច្ចេកវិទ្យាគមនាគមន៏និងព័ត៌មានរបស់ កម្ពុជាឆ្នាំ២០២០។
- យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣, គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ,០៨ ឧសភា ២០១៩។

## ១.៦ លិខិតបទដ្ឋានគតិយុត្តិដទៃផ្សេងទៀត

- យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក,ក្រសួងពាណិជ្ជកម្ម,២៥ វិច្ឆិកា ២០២០។
- ការវាយតម្លៃត្រៀមខ្លួនរួចរាល់សំរាប់ពាណិជ្ជកម្មឆ្លងកាត់ព្រំដែនដោយមិនចាំបាច់ប្រើក្រដាស់ស្នាម៖ ប្រទេសកម្ពុជា,អង្គការសហប្រជាជាតិផ្នែកពាណិជ្ជកម្ម និងវិនិយោគ, ២០១៩។
- សេចក្តីណែនាំសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៏ជាតិ ២០១៩-២០២៣(ផ.យ.អ.ជ. ២០១៩-២០២៣,ក្រសួងផែនការ,២០១៨, ខែឧសភា។
- សេចក្តីប្រកាសព័ត៌មានស្តីពីសេចក្តីព្រាងផែនការមេអន្តរកាលស្តីពី ការតភ្ជាប់ប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយ និងភស្តុភារកម្ម, ០៦ មករា ២០២០។
- សេចក្តីបំភ្លឺសេចក្តីបំភ្លឺទាក់ទងនឹងសេចក្តីព្រៀងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៏ និងព័ត៌មាន(ICT),លេខ ៦៥៧។

## ២. សៀវភៅ


- សេចក្តីពន្យល់មាត្រានីមួយៗនៃក្រមរដ្ឋប្រវេណីភាគ១ គន្លឹទី២ ដោយគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកលើសេចក្តីព្រាងក្រមរដ្ឋប្បវេណី,២០១០។
- សេចក្តីពន្យល់មាត្រានីមួយៗក្រមរដ្ឋប្បវេណីភាគ២ គន្លឹទី៤ដោយគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកលើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, ២០១០។
- សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ១ តែសម្រួលនូវការបោះពុម្ពលើកទី១ ដោយគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកលើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, ២០១៣។
- វចនានុក្រមខ្មែរសម្តេចសង្ឃរាជជួនណាត បោះពុម្ពលើកទី១ ដោយភ្នំពេញពុទ្ធសាសបណ្ឌិត ២៩៦៧។
- សារណាបញ្ចប់ថ្នាក់អនុបណ្ឌិតអំពីបទដ្ឋានច្បាប់សម្រាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅអាស៊ានច្បាប់គំរូឆ្នាំ ២០០៦ ( E-commerce legal framework for ASEAN)។
- សារណាបញ្ចប់ការសិក្សា របបគតិយុត្តិនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ស្រាវជ្រាវដោយនិស្សិតឈ្មោះ បូរ គឹមហុង ដែលដឹកនាំដោយសាស្ត្រាចារ្យណែនាំ លោក ជិន វណ្ណា៉ នៅឆ្នាំ ២០១៩។
- អត្ថបទជំនួយស្មារតី *បដិវត្តន៍ឧស្សាហកម្មទី៤* ដោយមជ្ឈមណ្ឌលអភិវឌ្ឍកម្ពុជា០៤, ខែមិថុនា ឆ្នាំ ២០១៩។
- CDRI. (January, 2020). Cybergovernance in Cambodia: Risk Based Approach to Cybersecurity [ការគ្រប់គ្រងអ៊ីនធើណេតនៅកម្ពុជា៖ វិធីសាស្ត្រផ្អែកលើហានិភ័យចំពោះសុវត្ថិភាពអ៊ីនធើណេត]
- Chen, L. (2020). ‘Improving Digital Connectivity for E-commerce: A Policy Framework and Empirical Note [ការពង្រឹងការតភ្ជាប់ប្រព័ន្ធឌីជីថលនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក៖ ក្របខ័ណ្ឌគោលនយោបាយ និងការសិក្សាលម្អិត], in Chen, L. and F. Kimura (eds.), *E-commerce Connectivity in ASEAN.* Jakarta, Indonesia: Economic Research Institute for ASEAN and East Asia, pp.7-30។

- Impact of COVID-19 on E-commerce Market. (March 2020). [ផលប៉ះពាល់នៃកូវីដ១៩ ទៅលើទីផ្សារពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក] ។
- Kalvin Bahia and Stefano Suardi. (2019).The State of Mobile Internet Connectivity 2019 [ស្ថានភាពនៃការភ្ជាប់បណ្ដាញអ៊ីនធើណេត]. GSMA ។
- Mekong Strategic Partners. (August 2021). Cambodia Fintech 2021: 10 KEYS TRENDS SHAPING CAMBODIA'S FINTECT LANDSCAPE [ បច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាឆ្នាំ ២០២១៖ គន្លឹះ ១០ យ៉ាងដែលមានសក្តានុពលលើវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា]។
- UN-ESCAP. (2021). G2P and International Digital Remittances During COVID-19: Early Lessons from Cambodia [រាជរដ្ឋាភិបាលទៅកាន់ប្រជាជន និងការផ្ញើរប្រាក់ជាសាកលអំឡុងពេលកូវីដ១៩៖មេរៀនតំបូងសិក្សាពីកម្ពុជា], United Nations Economic and Social Commision for Asia and the Pacific Macroeconomic Policy and Financing for Development Division Project Report.
- UNITED NATION. (2020).COVID-19 AND E-COMMERCE: a global review [កូវីដ១៩ និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។
- UNITED NATION. (2020). Digital Identity for Trade and Development " Train for Trade casae studies in South-East Asia"[អត្តសញ្ញាណឌីជីថលសម្រាប់ពាណិជ្ជកម្មនិងការអភិវឌ្ឍន៍] ។
- World Trade Organization.(2017). WTO (2017), 20 Years of the Information Technology Agreement: Boosting trade, innovation and digital connectivity [២០ ឆ្នាំនៃកិច្ចព្រមព្រៀងព្រៀងព័ត៌មានវិទ្យា] ។
- Yun Seon Kim និង Sok Sonita Khoeurn. (២០១៧,ខែសីហា). Barrier to E-Commerce Business Model in Cambodia and The Suggestion [ការរាំងនូវគំរូអាជីវកម្មនៃពាណិជ្ជកម្មអេឡិចត្រូនិកនៅកម្ពុជាជាមួយនឹងការផ្តល់យោបល់]. *Asia Pacific Journal of Business Review*។

# ឧបសម្ព័ន្ធ

# ច្បាប់
# ស្តីពី
# ពាណិជ្ជកម្មតាម
# ប្រព័ន្ធអេឡិចត្រូនិក

# ព្រះរាជក្រម

នស/រកម/១១១៩/ ០១៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភា លើកទី៣ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ច្បាប់

## ស្តីពី

## ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា១ .- គោលបំណង**

ច្បាប់នេះមានគោលបំណង៖

១. គ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងព្រះរាជាណាចក្រកម្ពុជានិងជាមួយអន្តរជាតិ។

២. បង្កើតភាពប្រាកដប្រជាផ្នែកគតិយុត្តក្នុងប្រតិបត្តិការពាណិជ្ជកម្មនិងរដ្ឋប្បវេណី តាមប្រព័ន្ធអេឡិចត្រូនិក។

៣. ផ្តល់ទំនុកចិត្តដល់សាធារណជនក្នុងការប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិក។

**មាត្រា២ .- គោលដៅ**

ច្បាប់នេះមានគោលដៅដូចខាងក្រោម៖

១. កំណត់អំពីយថាភូតភាព សុក្រឹតភាព និងភាពអាចជឿទុកចិត្តបាននៃទម្រង់អេឡិចត្រូនិក។

២. ជំរុញការអភិវឌ្ឍក្របខ័ណ្ឌគតិយុត្តនិងធុរកិច្ច ដើម្បីអនុវត្តពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកប្រកបដោយសុវត្ថិភាព។

៣. បង្ការនិងបង្ក្រាបអំពើដែលបង្កការខូចខាតដល់ទិន្នន័យនិងប្រព័ន្ធព័ត៌មាន។

៤. លុបបំបាត់ឧបសគ្គទាំងឡាយដែលរាំងស្ទះដល់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ហើយដែលកើតចេញពីភាពមិនប្រាកដប្រជានៃលក្ខខណ្ឌតម្រូវចំពោះលិខិតជាលាយលក្ខណ៍អក្សរនិងហត្ថលេខា។

៥. សម្រួលដល់ការតម្កល់ឯកសារតាមប្រព័ន្ធអេឡិចត្រូនិកជាមួយស្ថាប័នសាធារណៈ និងលើកកម្ពស់ការផ្តល់សេវាកម្មប្រកបដោយប្រសិទ្ធភាពរបស់ស្ថាប័នសាធារណៈ តាមរយៈការប្រើប្រាស់កំណត់ត្រាតាមប្រព័ន្ធអេឡិចត្រូនិកដែលអាចជឿទុកចិត្តបាន។

៦. បង្កើតវិធាន បទប្បញ្ញត្តិ និងស្តង់ដា ដែលទាក់ទងនឹងយថាភូតភាពនិងសុក្រឹតភាពរបស់កំណត់ត្រាតាមប្រព័ន្ធអេឡិចត្រូនិក។

**មាត្រា៣ .- វិសាលភាព**

ច្បាប់នេះត្រូវអនុវត្តលើសកម្មភាព ឯកសារ និងប្រតិបត្តិការពាណិជ្ជកម្មនិងរដ្ឋប្បវេណីទាំងអស់ដែលធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិក លើកលែងតែសកម្មភាព ឯកសារ និងប្រតិបត្តិការទាក់ទងនឹង៖

១. ការបង្កើតឬការអនុវត្តលិខិតប្រគល់សិទ្ធិ។

២. ការបង្កើតឬការចុះហត្ថលេខាលើមតកសាសន៍ លិខិតកែមតកសាសន៍ ឬបញ្ហាផ្សេងៗទៀតទាក់ទិននឹងសន្តតិកម្ម។

៣. រាល់កិច្ចសន្យាសម្រាប់ការលក់ ការផ្ទេរ ឬការបោះបង់សិទ្ធិលើអចលនទ្រព្យឬផលប្រយោជន៍ផ្សេងៗទៀតក្នុងទ្រព្យនោះ។

៤. ការផ្ទេរអចលនវត្ថុឬផលប្រយោជន៍ណាមួយដែលពាក់ព័ន្ធនឹងអចលនវត្ថុនោះ។

៥. ករណីលើកលែងផ្សេងទៀតដែលត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៤ .- និយមន័យ**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះត្រូវបានកំណត់និយមន័យដូចមានក្នុងសទ្ទានុក្រមដែលមានចែងក្នុងឧបសម្ព័ន្ធនៃច្បាប់នេះ។

## ជំពូកទី២
## សុពលភាពនៃទំនាក់ទំនងអេឡិចត្រូនិក

**មាត្រា៥ .- ការទទួលស្គាល់លក្ខណៈគតិយុត្តនៃទំនាក់ទំនងអេឡិចត្រូនិក**

គ្មានបុគ្គលណាម្នាក់អាចបដិសេធមិនទទួលស្គាល់សុពលភាព អានុភាពគតិយុត្ត ភាពអាចទទួលយកបានឬភាពដែលអាចយកទៅអនុវត្តបាននៃទំនាក់ទំនងអេឡិចត្រូនិក ដោយគ្រាន់តែសម្អាងលើមូលហេតុដែលថាវាធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិកឬស្ថិតនៅក្នុងទំនាក់ទំនងអេឡិចត្រូនិកឡើយ។

**មាត្រា៦ .- លក្ខខណ្ឌតម្រូវជាលាយលក្ខណ៍អក្សរ**

១. នៅពេលដែលបទប្បញ្ញត្តិណាមួយ តម្រូវឱ្យផ្ដល់ព័ត៌មានជាលាយលក្ខណ៍អក្សរ ឬធ្វើកំណត់ត្រាជាលាយលក្ខណ៍អក្សរ ត្រូវចាត់ទុកថា លក្ខខណ្ឌតម្រូវនេះត្រូវបានបំពេញប្រសិនបើព័ត៌មាននេះធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិក ហើយអាចចូលប្រើប្រាស់បាន និងអាចទាញយកទៅប្រើប្រាស់នៅពេលក្រោយបាន។

២. នៅពេលដែលលក្ខខណ្ឌក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើ ត្រូវយកមកអនុវត្តលក្ខខណ្ឌតម្រូវតាមច្បាប់ដែលទាមទារឱ្យបុគ្គលណាមួយផ្ដល់សំណៅចម្លងច្រើនច្បាប់ក្នុងពេលតែមួយស្ដីអំពីព័ត៌មានណាមួយឬកិច្ចការណាមួយទៅឱ្យបុគ្គលមួយផ្សេងទៀត បុគ្គលដែលផ្ដល់អាចបំពេញលក្ខខណ្ឌនេះដោយគ្រាន់តែផ្ដល់ក្រោមទម្រង់អេឡិចត្រូនិកតែមួយច្បាប់បាន។

**មាត្រា៧ .- លក្ខខណ្ឌតម្រូវចំពោះហត្ថលេខា**

១. នៅពេលដែលមានបទប្បញ្ញត្តិណាមួយតម្រូវឱ្យមានហត្ថលេខារបស់បុគ្គលណាមួយ លក្ខខណ្ឌតម្រូវនេះត្រូវចាត់ទុកថាបានបំពេញតាមរយៈការចុះហត្ថលេខាអេឡិចត្រូនិក ប្រសិនបើហត្ថលេខាអេឡិចត្រូនិកដែលបានប្រើនោះ ត្រូវបានបង្កើតឡើងតាមរយៈមធ្យោបាយដែលៈ

ក. អាចកំណត់អត្តសញ្ញាណបុគ្គល និងបង្ហាញការឯកភាពរបស់បុគ្គលនោះលើព័ត៌មានឬកំណត់ត្រាដែលមាននៅក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះ។

ខ. អាចជឿជាក់បាន ស្របតាមចរិតលក្ខណៈ គោលបំណង និងកាលៈទេសៈ ដែលទំនាក់ទំនងអេឡិចត្រូនិកនោះត្រូវបានបង្កើតឡើងឬត្រូវបានប្រាស្រ័យទាក់ទង។

២. ទោះបីជាបទប្បញ្ញត្តិណាមួយកំណត់អំពីលក្ខខណ្ឌតម្រូវឱ្យមានចុះហត្ថលេខា ឬគ្រាន់តែកំណត់អំពីផលវិបាកនៃការមិនចុះហត្ថលេខាក៏ដោយ ក៏បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើត្រូវយកមកអនុវត្តផងដែរ។

**មាត្រា៨ ._ លក្ខខណ្ឌតម្រូវសម្រាប់រក្សាព័ត៌មានតាមទម្រង់ដើម**

លក្ខខណ្ឌគតិយុត្តក្នុងការរក្សាព័ត៌មានដែលមិនត្រូវបានធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិក អាចត្រូវបានបំពេញដោយការរក្សាព័ត៌មាននោះក្រោមទម្រង់អេឡិចត្រូនិក ប្រសិនបើ៖

១. ទម្រង់អេឡិចត្រូនិកនោះជាមធ្យោបាយដែលអាចជឿទុកចិត្តបានដើម្បីកំណត់ភាពពេញលេញរបស់ព័ត៌មាននោះ។ និង

២. ព័ត៌មាននោះអាចចូលយកបានដោយងាយស្រួល សម្រាប់យកទៅប្រើប្រាស់បានពេលក្រោយ។

**មាត្រា៩ ._ ទម្រង់បែបបទដែលកំណត់**

នៅពេលដែលបទប្បញ្ញត្តិណាមួយតម្រូវឱ្យព័ត៌មានធ្វើឡើងក្នុងទម្រង់បែបបទណាមួយ លក្ខខណ្ឌតម្រូវនោះត្រូវជំនួសដោយការផ្តល់ព័ត៌មានតាមទម្រង់អេឡិចត្រូនិកបាន ប្រសិនបើទម្រង់អេឡិចត្រូនិកនោះត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

១. មានផ្ទុកព័ត៌មានដូចគ្នាឬដូចគ្នាភាគច្រើនទៅនឹងទម្រង់បែបបទដែលបានកំណត់។

២. អាចចូលទៅមើលបាន អាចយល់បាន និងអាចទាញយកមកប្រើប្រាស់បាននៅពេលក្រោយ។ និង

៣. អាចឱ្យបុគ្គលដែលទទួលបានព័ត៌មាននោះរក្សាទុកបាន។

**មាត្រា១០ ._ លក្ខខណ្ឌតម្រូវលើការរក្សាទុកកំណត់ត្រា**

១. នៅពេលដែលបទប្បញ្ញត្តិណាមួយតម្រូវឱ្យរក្សាទុកនូវឯកសារ កំណត់ត្រា ឬព័ត៌មានជាក់លាក់ណាមួយ លក្ខខណ្ឌតម្រូវនោះត្រូវចាត់ទុកថាបានបំពេញ ប្រសិនបើ ការរក្សាទុកនោះបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

ក. ព័ត៌មានដែលមាននៅក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះអាចចូលប្រើប្រាស់បាន និងសម្រាប់យកទៅប្រើប្រាស់នាពេលអនាគត។

ខ. ទំនាក់ទំនងអេឡិចត្រូនិកត្រូវបានរក្សាទុកក្នុងទម្រង់ដើមដែលត្រូវបានបង្កើតឡើង ផ្ញើ ឬទទួលបាន ឬក្នុងទម្រង់ដែលអាចត្រូវបានបង្ហាញពីសុក្រឹតភាពនៃព័ត៌មាននោះ។ និង

គ. ព័ត៌មានទាំងនោះត្រូវរក្សាទុកដើម្បីឱ្យបុគ្គលណាម្នាក់អាចកំណត់បាននូវប្រភពដើម និងគោលដៅនៃទំនាក់ទំនងអេឡិចត្រូនិកនោះ កាលបរិច្ឆេទ និងពេលវេលាដែលទំនាក់ទំនងអេឡិចត្រូនិកនោះត្រូវបានផ្ញើឬទទួល។

២. កាតព្វកិច្ចក្នុងការរក្សាឯកសារ កំណត់ត្រា ឬព័ត៌មានស្របតាមកថាខណ្ឌ១ មិនរាប់បញ្ចូលព័ត៌មានណាមួយ សម្រាប់តែធ្វើការបញ្ជូនឬទទួលសារនោះឡើយ។

**មាត្រា១១ ._ លក្ខខណ្ឌតម្រូវស្តីពីភស្តុតាង**

គ្មានបទប្បញ្ញត្តិណាមួយក្នុងការអនុវត្តវិធានស្តីពីភស្តុតាង អាចជំទាស់ការទទួលយកទំនាក់ទំនងអេឡិចត្រូនិកជាភស្តុតាង ដោយគ្រាន់តែឈរលើមូលដ្ឋានដែលថា៖

១. ភស្តុតាងនោះជាទំនាក់ទំនងអេឡិចត្រូនិក។ ឬ

២. ភស្តុតាងនោះមិនស្ថិតក្នុងទម្រង់ដើម។

**មាត្រា១២ .- ការបង្កើតកិច្ចសន្យានិងសុពលភាពកិច្ចសន្យា**

១. សំណើ ស្ទីការ និងកិច្ចសន្យា អាចធ្វើឡើងតាមមធ្យោបាយអេឡិចត្រូនិកបាន។

២. កិច្ចសន្យាក្នុងទម្រង់អេឡិចត្រូនិកដូចមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើ មានសុពលភាព អានុភាពគតិយុត្ត និងភាពអាចអនុវត្តបាន នៅពេលដែលសំណើនិងស្ទីការត្រូវគ្នា។

**មាត្រា១៣ .- អានុភាពរវាងគូភាគី**

អ្នកផ្ញើនិងអ្នកទទួលនៃទំនាក់ទំនងអេឡិចត្រូនិក មិនត្រូវបដិសេធអានុភាពគតិយុត្ត សុពលភាព និងភាពអាចអនុវត្តបាននៃការបង្ហាញឆន្ទៈ ឬសេចក្តីថ្លែងផ្សេងៗរបស់ខ្លួនឡើយ។

**មាត្រា១៤ .- ការអនុវត្តដោយឡែកតាមការព្រមព្រៀងរបស់គូភាគី**

១. តាមការព្រមព្រៀង គូភាគីដែលចូលរួមក្នុងការបង្កើត ការផ្ញើ ការទទួល ការរក្សាទុក ឬដំណើរការទំនាក់ទំនងអេឡិចត្រូនិក អាចអនុវត្តផ្សេងពីបទប្បញ្ញត្តិដូចមានចែងនៅក្នុងជំពូកទី២ នៃច្បាប់នេះ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

២. ទោះជាមានបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី២ គូភាគីនៃកិច្ចសន្យា ឬប្រតិបត្តិការណាមួយអាច៖

ក. មិនប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិក ទំនាក់ទំនងអេឡិចត្រូនិក ឬហត្ថលេខាអេឡិចត្រូនិកក្នុងកិច្ចសន្យា ឬប្រតិបត្តិការណាមួយតាមការព្រមព្រៀងគ្នា។ ឬ

ខ. ដាក់លក្ខខណ្ឌតម្រូវបន្ថែមផ្សេងៗដែលពាក់ព័ន្ធនឹងទម្រង់ ឬយថាភូតភាពនៃកិច្ចសន្យា ឬប្រតិបត្តិការតាមការព្រមព្រៀងគ្នា។

## ជំពូកទី៣
## ដំណើរការនៃទំនាក់ទំនងអេឡិចត្រូនិក

**មាត្រា១៥ .- ពេលវេលានិងទីកន្លែងនៃការបញ្ជូនចេញនិងការទទួលព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិក**

១. ព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកមួយត្រូវចាត់ទុកថា បានបញ្ជូនចេញនៅពេលដែល៖

ក. ព័ត៌មាននោះ បានចាកចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកផ្ញើឬរបស់ភាគីដែលផ្ញើជំនួសក្នុងនាមអ្នកផ្ញើ។ ឬ

ខ. ក្នុងករណីដែលព័ត៌មាននោះ ត្រូវបានបញ្ជូនតែមិនទាន់បានចាកចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតក្រោមការគ្រប់គ្រងរបស់អ្នកផ្ញើឬរបស់ភាគីដែលផ្ញើជំនួសព័ត៌មាន ត្រូវចាត់ទុកថា បានបញ្ជូនចេញនៅពេលដែលព័ត៌មាននោះត្រូវបានទទួលក្នុងពេលណាមួយ។

២. ព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកមួយត្រូវបានសន្មតថាបានបញ្ជូនចេញពីទីតាំងអាជីវកម្មរបស់អ្នកផ្ញើ ទោះបីព័ត៌មាននោះត្រូវបានផ្ញើចេញពីទីតាំងណាក៏ដោយ។

៣. ពេលវេលានៃការទទួលព័ត៌មានគឺពេលដែលព័ត៌មាននោះ អាចទាញយកបានដោយអ្នកទទួលនៅក្នុងអាសយដ្ឋានអេឡិចត្រូនិកដែលអ្នកទទួលបានបញ្ជាក់ជាមុន។ ព័ត៌មានត្រូវបានសន្មតថាបានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល។

៤. ប្រសិនបើអាសយដ្ឋានអេឡិចត្រូនិកមិនត្រូវបានផ្តល់ដោយអ្នកទទួល នោះពេលវេលាទទួលបានព័ត៌មាន គឺជាពេលវេលាដែលអ្នកទទួលបានដឹងអំពីការផ្ញើចេញនិងអាចទាញយកព័ត៌មាននោះ តាមរយៈអាសយដ្ឋានអេឡិចត្រូនិកណាមួយ ហើយសន្មតថាបានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល។

៥. ប្រសិនបើអាសយដ្ឋានអេឡិចត្រូនិកត្រូវបានផ្តល់ដោយអ្នកទទួល ព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកត្រូវបានសន្មតថាបានទទួលនៅពេលព័ត៌មាននោះបានទៅដល់អាសយដ្ឋានអេឡិចត្រូនិករបស់អ្នកទទួល ហើយត្រូវបានចាត់ទុកថាបានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល។

**មាត្រា១៦ .- សំណើបង្កើតកិច្ចសន្យា**

រាល់ការស្នើសុំចុះកិច្ចសន្យា តាមរយៈទំនាក់ទំនងអេឡិចត្រូនិកដែលមិនសំដៅតែដល់បុគ្គលណាមួយជាក់លាក់ផ្សេងទៀត ត្រូវបានចាត់ទុកថាជាការអញ្ជើញឱ្យធ្វើសំណើបង្កើតកិច្ចសន្យាតែប៉ុណ្ណោះ។ ការស្នើសុំចុះកិច្ចសន្យានោះ នឹងត្រូវចាត់ទុកថាជាសំណើបង្កើតកិច្ចសន្យា ប្រសិនបើការស្នើសុំនោះបានបង្ហាញឱ្យឃើញច្បាស់អំពីឆន្ទៈរបស់ខ្លួនថានឹងត្រូវជាប់កាតព្វកិច្ចនៅពេលមានស្វីការពីភាគីម្ខាងទៀត។

**មាត្រា១៧ .- ការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តសម្រាប់បង្កើតកិច្ចសន្យា**

កិច្ចសន្យាដែលបង្កើតឡើងដោយអន្តរកម្មរវាងប្រព័ន្ធស្វ័យប្រវត្តនៃបុគ្គលមួយ ជាមួយរូបវន្តបុគ្គលណាមួយឬជាមួយប្រព័ន្ធស្វ័យប្រវត្តនៃបុគ្គលផ្សេងទៀត មិនអាចត្រូវបានបដិសេធអំពីសុពលភាព អានុភាពគតិយុត្ត ឬភាពអាចអនុវត្តបាននៃកិច្ចសន្យានោះឡើយ ដោយសម្អាងលើហេតុផលអវត្តមាននៃរូបវន្តបុគ្គលក្នុងការពិនិត្យឬក្នុងការចូលធ្វើសកម្មភាពដោយផ្ទាល់ក្នុងប្រព័ន្ធស្វ័យប្រវត្តឬក្នុងការបង្កើតកិច្ចសន្យា។

**មាត្រា១៨ .- កំហុសឆ្គងនៃការបញ្ចូលព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិក**

នៅពេលដែលបុគ្គលបញ្ចូលព័ត៌មានខុសនៅក្នុងទំនាក់ទំនងអេឡិចត្រូនិកជាមួយប្រព័ន្ធស្វ័យប្រវត្តរបស់ភាគីម្ខាងទៀត ហើយប្រព័ន្ធស្វ័យប្រវត្តនេះមិនផ្តល់ឱកាសឱ្យបុគ្គលនោះធ្វើការកែប្រែនូវព័ត៌មានដែលខុស បុគ្គលឬភាគីដែលជំនួសមុខឱ្យបុគ្គលដែលបញ្ចូលព័ត៌មាននោះមានសិទ្ធិកែតម្រូវ ឬដកចេញនូវព័ត៌មានដែលខុសនោះបាន ក្នុងករណី៖

១. បុគ្គលនោះបានជូនដំណឹងទៅភាគីម្ខាងទៀតអំពីកំហុសដែលបានកើតឡើងឱ្យបានឆាប់បំផុត ហើយត្រូវបង្ហាញថាខ្លួនបានបញ្ចូលព័ត៌មានខុសនៅក្នុងទំនាក់ទំនងអេឡិចត្រូនិក។ និង

២. បុគ្គលនោះមិនទទួលបានផលប្រយោជន៍ណាមួយ ដោយសារការបញ្ចូលព័ត៌មានខុសនេះ មុនពេលដែលខ្លួនធ្វើការជូនដំណឹងទៅឱ្យភាគីម្ខាងទៀត ហើយមិនបង្កការខូចខាតដល់ផលប្រយោជន៍របស់ភាគីម្ខាងទៀតឬតតិយជនណាមួយ។

បញ្ញត្តិដែលមានចែងក្នុងមាត្រានេះ មិនអនុវត្តចំពោះវិស័យមូលបត្រឡើយ។

## ជំពូកទី៤

## កំណត់ត្រាអេឡិចត្រូនិកនិងហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព

**មាត្រា១៩ .-** កំណត់ត្រាអេឡិចត្រូនិកដែលមានសុវត្ថិភាព

កំណត់ត្រាអេឡិចត្រូនិកមួយត្រូវបានចាត់ទុកថាជាកំណត់ត្រាអេឡិចត្រូនិកដែលមានសុវត្ថិភាព លុះត្រាតែបានអនុវត្តស្របតាមនីតិវិធីសុវត្ថិភាពត្រឹមត្រូវ ដែលធានាបានថាកំណត់ត្រាអេឡិចត្រូនិកនោះ មិនត្រូវបានកែប្រែ គិតចាប់ពីពេលវេលាកំណត់ជាក់លាក់ណាមួយរហូតដល់ពេលធ្វើការពិនិត្យផ្ទៀងផ្ទាត់។

**មាត្រា២០ .-** ហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព

១. ហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព លុះត្រាតែគោរពទៅតាមលក្ខខណ្ឌខាងក្រោម៖

ក. ផ្សារភ្ជាប់ទៅកាន់ហត្ថលេខីតែម្នាក់គត់។

ខ. កំណត់បានអត្តសញ្ញាណរបស់ហត្ថលេខី។

គ. ត្រូវបានបង្កើតឡើងដោយប្រើប្រាស់មធ្យោបាយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ហត្ថលេខី។

ឃ. បញ្ជាក់អំពីពេលវេលានិងកាលបរិច្ឆេទនៃការចុះហត្ថលេខា។ និង

ង. បញ្ជាក់អំពីស្ថានភាពដើមនៃសារ ឬកំណត់ត្រាអេឡិចត្រូនិកដែលត្រូវបានផ្សារភ្ជាប់ដោយហត្ថលេខានោះ។

២. បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើ មិនកម្រិតលទ្ធភាពរបស់បុគ្គលណាមួយក្នុងទំនាក់ទំនងអេឡិចត្រូនិកឡើយ ក្នុងការ៖

ក. កំណត់លក្ខខណ្ឌបន្ថែមផ្សេងទៀតពាក់ព័ន្ធនឹងភាពអាចជឿជាក់បានរបស់ហត្ថលេខាអេឡិចត្រូនិក។ ឬ

ខ. លើកភស្តុតាងអំពីភាពមិនអាចជឿជាក់បាននៃហត្ថលេខាអេឡិចត្រូនិក។

**មាត្រា២១ .-** ការសន្មតទាក់ទងនឹងកំណត់ត្រានិងហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព

១. លើកលែងតែមានភស្តុតាងផ្ទុយ ក្នុងដំណើរការដែលពាក់ព័ន្ធនឹងកំណត់ត្រាអេឡិចត្រូនិកដែលមានសុវត្ថិភាព កំណត់ត្រាអេឡិចត្រូនិកដែលមានសុវត្ថិភាពត្រូវបានសន្មតថាជាកំណត់ត្រាអេឡិចត្រូនិកដែលមិនត្រូវបានកែប្រែចាប់តាំងពីពេលជាក់លាក់ណាមួយ។

២. លើកលែងតែមានភស្តុតាងផ្ទុយ ក្នុងដំណើរការពាក់ព័ន្ធនឹងហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព ហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាពត្រូវបានសន្មតដូចខាងក្រោម៖

ក. ហត្ថលេខាអេឡិចត្រូនិកនោះ គឺជាហត្ថលេខារបស់បុគ្គលពាក់ព័ន្ធ។ និង

ខ. ហត្ថលេខាអេឡិចត្រូនិកនោះ ត្រូវបានចុះហត្ថលេខាដោយបុគ្គលមានឆន្ទៈក្នុងការចុះហត្ថលេខា ឬបានឯកភាពលើកំណត់ត្រាអេឡិចត្រូនិកនោះ។

៣. ក្នុងករណីដែលគ្មានកំណត់ត្រាអេឡិចត្រូនិកសុវត្ថិភាព ឬហត្ថលេខាអេឡិចត្រូនិកសុវត្ថិភាព គ្មានបញ្ញត្តិណាមួយនៅក្នុងជំពូកទី៤ អាចសន្មតបានជាមុនអំពីយថាភូតភាព ឬសុក្រឹតភាពនៃកំណត់ត្រាអេឡិចត្រូនិក ឬហត្ថលេខាអេឡិចត្រូនិកនោះឡើយ។

**មាត្រា២២ .- ការលួចប្រើប្រាស់អត្តសញ្ញាណ**

បុគ្គលទាំងឡាយមិនត្រូវប្រើប្រាស់អត្តសញ្ញាណ កំណត់ត្រា ហត្ថលេខាអេឡិចត្រូនិក អាសយដ្ឋានអេឡិចត្រូនិក លេខសម្ងាត់ ឬភិនភាគសម្គាល់របស់បុគ្គលផ្សេងទៀតដោយទុច្ចរិត ឬដោយគ្មានការអនុញ្ញាត ក្នុងប្រតិបត្តិការពាណិជ្ជកម្ម ឬមិនមែនពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

**មាត្រា២៣ .- ស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រងនីតិវិធីសុវត្ថិភាព**

១. ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងនីតិវិធីសុវត្ថិភាព សម្រាប់កំណត់ត្រាអេឡិចត្រូនិកនិងហត្ថលេខាអេឡិចត្រូនិក។

២. ការគ្រប់គ្រងនីតិវិធីសុវត្ថិភាពសម្រាប់កំណត់ត្រាអេឡិចត្រូនិកនិងហត្ថលេខាអេឡិចត្រូនិកត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត។

## ជំពូកទី៥
## អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

**មាត្រា២៤ .- ការទទួលខុសត្រូវរបស់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

១. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនទទួលខុសត្រូវផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌពាក់ព័ន្ធនឹងព័ត៌មានដែលមានក្នុងកំណត់ត្រាអេឡិចត្រូនិកដែលពាក់ព័ន្ធនឹងការផ្តល់សេវារបស់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនោះឡើយ ក្នុងករណីដែលខ្លួនមិនមែនជាអ្នកធ្វើកំណត់ត្រានោះ និងក្នុងករណីដែលៈ

ក. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនោះមិនបានដឹងថាព័ត៌មានដែលបានធ្វើនោះបង្កឱ្យមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌ។

ខ. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនោះមិនបានដឹងអំពីអង្គហេតុឬកាលៈទេសៈដែលអាចឱ្យស្មានទុកថាព័ត៌មាននោះអាចបង្កឱ្យមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌ។ ឬ

គ. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានដឹងនាពេលក្រោយថាព័ត៌មាន ឬអង្គហេតុ ឬកាលៈទេសៈដែលអាចឱ្យស្មានទុកថា ព័ត៌មាននោះ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

អាចបង្កឱ្យមានការទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ហើយបានអនុវត្តតាមនីតិវិធីចំពោះព័ត៌មានខុសច្បាប់ និងការបរិហាកេរ្តិ៍ដូចមានចែងក្នុងមាត្រា២៥ ខាងក្រោម។

២. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនតម្រូវឱ្យតាមដានត្រួតពិនិត្យកំណត់ត្រាអេឡិចត្រូនិកណាមួយដែលដំណើរការដោយប្រព័ន្ធអេឡិចត្រូនិកដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួននោះឡើយ ទោះបីជាដំណើរការនៃកំណត់ត្រាអេឡិចត្រូនិកនោះអាចបង្កើតជាបទល្មើស ឬនាំឱ្យមានការទទួលខុសត្រូវរដ្ឋប្បវេណីក៏ដោយ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

៣. បញ្ញត្តិនៃមាត្រានេះមិនត្រូវយកមកអនុវត្តដើម្បីឱ្យអន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករួចផុតពី៖

ក. កាតព្វកិច្ចដែលបង្កើតឡើងដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តនានា។

ខ. កាតព្វកិច្ចអនុលោមតាមបទបញ្ជា ឬសេចក្តីបង្គាប់របស់តុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត។ ឬ

គ. កាតព្វកិច្ចតាមកិច្ចសន្យា។

**មាត្រា២៥ .- ការទទួលខុសត្រូវផ្នែកព័ត៌មានឬហេតុការណ៍**

១. ក្នុងករណីដែលអន្តរការី ឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានដឹងថាព័ត៌មានក្នុងកំណត់ត្រាអាចបង្កឱ្យមានការទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌ អន្តរការី ឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវចាត់វិធានការជាបន្ទាន់ដូចខាងក្រោម៖

ក. ដកព័ត៌មានចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតក្រោមការគ្រប់គ្រងរបស់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ហើយឈប់ផ្តល់សេវាពាក់ព័ន្ធនឹងព័ត៌មាននោះ។

ខ. រក្សាទុកព័ត៌មានជាភស្តុតាងនិងជូនដំណឹងដល់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនានាអំពីអង្គហេតុនិងអត្តសញ្ញាណនៃជនសង្ស័យ។

២. ក្នុងករណីដែលអន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដឹងអំពីហេតុការណ៍ណាមួយ ឬស្ថានភាពណាមួយដែលអាចបណ្តាលឱ្យមានការទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌ អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវរក្សាទុកព័ត៌មានជាភស្តុតាងនិងជូនដំណឹងដល់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនានា។

៣. នៅពេលបានដឹងឬទទួលដំណឹងពាក់ព័ន្ធនឹងព័ត៌មានក្នុងកំណត់ត្រាអេឡិចត្រូនិកដែលអាចបង្កឱ្យមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌ ក្រសួងប្រៃសណីយ៍និង

ទូរគមនាគមន៍ ឬក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ អាចបញ្ជាឱ្យអន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក៖

ក. ដកព័ត៌មានចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន។

ខ. ផ្អាកឬឈប់ផ្តល់សេវាដល់បុគ្គលនោះ។ ឬ

គ. ផ្អាកឬឈប់ផ្តល់សេវាពាក់ព័ន្ធនឹងកំណត់ត្រាអេឡិចត្រូនិក។

៤. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មអេឡិចត្រូនិកមិនត្រូវទទួលខុសត្រូវផ្នែករដ្ឋប្បវេណី តាមកិច្ចសន្យាឬក្រៅកិច្ចសន្យា ឬកំណត់ដោយច្បាប់ ចំពោះការអនុវត្តដោយសុទ្ធចិត្តតាមបញ្ជារបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ឬក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

៥. បុគ្គលដែលជូនដំណឹងអំពីសកម្មភាពខុសច្បាប់ទៅដល់អន្តរការីឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយដឹងថាការជូនដំណឹងនោះខុសពីការពិតឬមានលក្ខណៈបោកបញ្ឆោត ត្រូវទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌពីអំពើនោះ។

**មាត្រា២៦ .- ការផ្តល់លិខិតអនុញ្ញាតឬអាជ្ញាបណ្ណ**

១. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវស្នើសុំការអនុញ្ញាតឬអាជ្ញាបណ្ណពីក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍។

២. ក្រសួងពាណិជ្ជកម្មផ្តល់លិខិតអនុញ្ញាតឬអាជ្ញាបណ្ណរួមមាន៖

ក. លិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់រូបវន្តបុគ្គល។

ខ. អាជ្ញាបណ្ណឱ្យប្រតិបត្តិការផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់នីតិបុគ្គល។

៣. ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ផ្តល់វិញ្ញាបនបត្រសេវាអនឡាញ។

៤. ការលើកលែង ការកំណត់ប្រភេទអាជ្ញាបណ្ណ បែបបទ និងនីតិវិធីនៃការផ្តល់ការអនុញ្ញាតឬអាជ្ញាបណ្ណ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៧ .- ក្រមសីលធម៌វិជ្ជាជីវៈនិងបទប្បញ្ញត្តិសម្រាប់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

១. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈ និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍។

២. ក្រមសីលធម៌វិជ្ជាជីវៈ ដែលបានលើកឡើងក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើត្រូវកំណត់និងរៀបរៀងឡើងដោយក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍ដោយសហការជាមួយក្រសួង ស្ថាប័ននិងភាគីពាក់ព័ន្ធ។

**មាត្រា២៨ .- កាតព្វកិច្ចពន្ធ ការលើកទឹកចិត្ត និងការអនុគ្រោះ**

អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវស្ថិតនៅក្រោមនីតិរបបនៃរបបសារពើពន្ធជាធរមាន និងទទួលបានការលើកទឹកចិត្តនិងការអនុគ្រោះនានា ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៦
## កិច្ចការពារអ្នកប្រើប្រាស់

**មាត្រា២៩ .- ព័ត៌មានអប្បបរមាក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

១. បុគ្គលដែលប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកដើម្បីលក់ទំនិញឬសេវាទៅឱ្យអ្នកប្រើប្រាស់ត្រូវផ្ដល់ព័ត៌មានត្រឹមត្រូវ ច្បាស់លាស់ និងងាយយល់បាន ហើយត្រូវមានព័ត៌មានយ៉ាងតិចដូចខាងក្រោម៖

ក. ឈ្មោះឬនាមករណ៍ស្របច្បាប់របស់បុគ្គល អាសយដ្ឋានអាជីវកម្មដែលបានចុះបញ្ជី និងមធ្យោបាយអេឡិចត្រូនិកសម្រាប់ទំនាក់ទំនងឬលេខទូរសព្ទ។

ខ. ទម្រង់ទំនាក់ទំនងដែលរហ័ស ងាយស្រួល និងមានប្រសិទ្ធភាពរវាងអ្នកប្រើប្រាស់ជាមួយអ្នកលក់។

គ. ខចែង លក្ខខណ្ឌ និងសោហ៊ុយរបស់ទំនិញឬសេវានានាដែលពាក់ព័ន្ធនឹងប្រតិបត្តិការពាណិជ្ជកម្ម ជាពិសេស ខចែង លក្ខខណ្ឌ និងមធ្យោបាយទូទាត់ប្រាក់ និងព័ត៌មានលម្អិតពាក់ព័ន្ធនឹងការដកឬលុបចោលការបញ្ជាទិញ ការបញ្ឈប់ ការប្រគល់ និងការប្ដូរទំនិញ និងការសងប្រាក់មកវិញ។ និង

ឃ. ទំនិញនិងសេវាជាក់ស្ដែងដែលដាក់លក់។

២. ព័ត៌មានដែលមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើ ចាំបាច់ត្រូវមានលក្ខណៈគ្រប់គ្រាន់ ដើម្បីឱ្យអ្នកប្រើប្រាស់អាចធ្វើការសម្រេចចិត្តលើប្រតិបត្តិការពាណិជ្ជកម្មនិងរក្សាទុកជាព័ត៌មាន។

៣. បញ្ញត្តិនៃមាត្រានេះមិនយកមកអនុវត្តចំពោះវិស័យមូលបត្រនិងធានារ៉ាប់រងឡើយ។

**មាត្រា៣០ .- ទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំ**

បុគ្គលណាក៏ដោយ ទោះបីជាមានទីតាំងអាជីវកម្មក្នុងឬក្រៅព្រះរាជាណាចក្រកម្ពុជាដែលផ្ញើទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំទៅកាន់អ្នកប្រើប្រាស់ដែលស្ថិតនៅក្នុងឬក្រៅព្រះរាជាណាចក្រកម្ពុជា តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ឬតាមរយៈអន្តរការី ឬអ្នកផ្ដល់សេវាទូរគមនាគមន៍ ត្រូវផ្ដល់ជម្រើសច្បាស់លាស់និងងាយស្រួលសម្រាប់ឱ្យអ្នកប្រើប្រាស់អាចធ្វើការបដិសេធមិនទទួលយកទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំនោះ។

**មាត្រា៣១ .- ការបង្កើតប្រព័ន្ធអេឡិចត្រូនិកក្លែងបន្លំនិងកូដព្យាបាទ**

១. បុគ្គលទាំងឡាយមិនត្រូវបង្កើតប្រព័ន្ធអេឡិចត្រូនិក ក្នុងគោលបំណងក្លែងបន្លំឬបង្កការភាន់ច្រឡំ ដើម្បីទាញយកផលប្រយោជន៍ ឬក្នុងគោលបំណងទាក់ទាញឱ្យមានការប្រើប្រាស់ឬធ្វើប្រតិបត្តិការ ហើយនាំឱ្យមានព្យសនកម្មដល់បុគ្គលដែលប្រើប្រាស់នោះឬតតិយជនឡើយ។

២. បុគ្គលទាំងឡាយមិនត្រូវបង្កើត ផ្ដល់ បង្កលទ្ធភាព ចែកចាយ ឬបញ្ជូននូវលេខកូដចម្លងមេរោគ ក្នុងគោលបំណងទុច្ចរិត តាមមធ្យោបាយអេឡិចត្រូនិក ទៅក្នុងឧបករណ៍ឬប្រព័ន្ធអេឡិចត្រូនិករបស់បុគ្គលផ្សេងទៀតឡើយ។

**មាត្រា៣២ ._ ការការពារទិន្នន័យ**

១. បុគ្គលដែលរក្សាព័ត៌មានជាលក្ខណៈឯកជនក្រោមទម្រង់អេឡិចត្រូនិក ត្រូវប្រើគ្រប់មធ្យោបាយដើម្បីធានាថា ព័ត៌មាននោះត្រូវបានការពារប្រកបដោយសុវត្ថិភាពគ្រប់កាលៈទេសៈសមហេតុផល ដើម្បីជៀសវាង ការបាត់បង់ ការចូល ការប្រើប្រាស់ ការកែប្រែ ការបែកធ្លាយ ឬការលាតត្រដាងព័ត៌មានទាំងនោះ លើកលែងតែមានការអនុញ្ញាតពីម្ចាស់នៃព័ត៌មាននោះឬពីភាគីផ្សេងទៀតដែលអនុញ្ញាតដោយច្បាប់។

២. បុគ្គលទាំងឡាយមិនត្រូវជ្រៀតជ្រែកក្នុងប្រព័ន្ធអេឡិចត្រូនិក ចូលប្រើប្រាស់ ទាញយក ថតចម្លង ស្រង់យក ធ្វើឱ្យបែកធ្លាយ លុបបំបាត់ ឬកែប្រែទិន្នន័យ ដែលស្ថិតក្រោមការរក្សាទុករបស់បុគ្គលផ្សេងទៀត ដោយទុច្ចរិត ឬគ្មានការអនុញ្ញាតឡើយ។

**មាត្រា៣៣ ._ ការអនុវត្តបទប្បញ្ញត្តិទាក់ទងនឹងកិច្ចការពារអ្នកប្រើប្រាស់**

បុគ្គលដែលប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកក្នុងសកម្មភាពពាណិជ្ជកម្មជាមួយអ្នកប្រើប្រាស់ក៏ត្រូវអនុវត្តតាមបទប្បញ្ញត្តិនានាទាក់ទងនឹងកិច្ចការពារអ្នកប្រើប្រាស់ផងដែរ។

## ជំពូកទី៧
## សកម្មភាពនិងប្រតិបត្តិការរបស់រដ្ឋតាមប្រព័ន្ធអេឡិចត្រូនិក

**មាត្រា៣៤ ._ ការទទួលស្គាល់ទំនាក់ទំនងអេឡិចត្រូនិកដោយស្ថាប័នរដ្ឋ**

១. ក្រសួងឬស្ថាប័នរដ្ឋនានាអាចប្រើប្រាស់ទម្រង់អេឡិចត្រូនិកសម្រាប់សកម្មភាពនិងប្រតិបត្តិការ ដូចខាងក្រោម៖

ក. ការទទួលចុះបញ្ជីឯកសារ ឬការបំពេញលក្ខខណ្ឌតម្រូវ សម្រាប់បង្កើតឬរក្សាទុកឯកសារ។

ខ. ការចេញអាជ្ញាបណ្ណឬលិខិតអនុញ្ញាត។

គ. ការកំណត់មធ្យោបាយនិងរបៀបក្នុងការទូទាត់ប្រាក់។ ឬ

ឃ. សកម្មភាពផ្សេងទៀតដែលកំណត់ដោយក្រសួង ឬស្ថាប័នរដ្ឋ។

២. នៅពេលដែល ក្រសួង ឬស្ថាប័នរដ្ឋសម្រេចប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកសម្រាប់សកម្មភាព ឬប្រតិបត្តិការណាមួយ ដូចមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើ ក្រសួងឬស្ថាប័ននោះអាចបញ្ជាក់៖

ក. របៀបនិងទម្រង់ដែលព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកត្រូវទទួលចុះបញ្ជី បង្កើត រក្សាទុក ឬបោះផ្សាយ។

ខ. ប្រភេទនៃហត្ថលេខាដែលតម្រូវឱ្យធ្វើនៅពេលដែលមានការតម្រូវឱ្យចុះហត្ថលេខាក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះ។

គ. របៀបនិងទម្រង់ដែលហត្ថលេខានោះត្រូវភ្ជាប់ក្នុងទំនាក់ទំនងអេឡិចត្រូនិក។

ឃ. ដំណើរការគ្រប់គ្រងនិងនីតិវិធីដែលសមស្របដើម្បីធានាសុក្រឹតភាព សុវត្ថិភាព និងការរក្សាការសម្ងាត់នៃទំនាក់ទំនងអេឡិចត្រូនិក ឬការទូទាត់ប្រាក់ និង

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ង. លក្ខខណ្ឌកំណត់ផ្សេងទៀតដែលផ្តល់តម្លៃសមមូលរវាងឯកសារ ឬការទូទាត់ក្នុងទម្រង់អេឡិចត្រូនិក ជាមួយនឹងឯកសារ ឬការទូទាត់ក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ។

## ជំពូកទី៨

## ភស្តុតាងអេឡិចត្រូនិក

**មាត្រា៣៥ .-** ការទទួលយកជាទូទៅនូវភស្តុតាងអេឡិចត្រូនិក

គ្មានបទប្បញ្ញត្តិនៃវិធានស្តីពីភស្តុតាងណាមួយដែលយកមកអនុវត្ត ដើម្បីបដិសេធក្នុងការទទួលយកជាទូទៅនូវកំណត់ត្រាអេឡិចត្រូនិកធ្វើជាភស្តុតាង ដោយហេតុផលគ្រាន់តែសម្អាងលើមូលដ្ឋានថា វាជាកំណត់ត្រាអេឡិចត្រូនិកនោះឡើយ ទោះបីជាភស្តុតាងនោះមិនស្ថិតក្នុងទម្រង់ដើមក៏ដោយ។

**មាត្រា៣៦ .-** សុក្រឹតភាពនៃប្រព័ន្ធអេឡិចត្រូនិក

១. នៅក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ សុពលភាពនៃភស្តុតាងអេឡិចត្រូនិកអាចត្រូវបានបញ្ជាក់តាមរយៈសុក្រឹតភាពនៃប្រព័ន្ធអេឡិចត្រូនិក ដែលបានកត់ត្រាឬរក្សាទុកនូវទិន្នន័យណាមួយ។

២. លើកលែងតែមានភស្តុតាងផ្ទុយ ប្រព័ន្ធអេឡិចត្រូនិកដែលបានប្រើប្រាស់សម្រាប់កត់ត្រាឬរក្សាទុកកំណត់ត្រាអេឡិចត្រូនិក ត្រូវបានសន្មតថាមានសុក្រឹតភាព ក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ តាមលក្ខខណ្ឌណាមួយដូចខាងក្រោម៖

ក. ក្នុងករណីមានភស្តុតាងគាំទ្រដល់អង្គហេតុណាមួយដែលបញ្ជាក់ថាប្រព័ន្ធអេឡិចត្រូនិកឬឧបករណ៍ស្រដៀងគ្នាផ្សេងទៀត បានដំណើរការជាប្រក្រតីនៅពេលដែលកំណត់ត្រាអេឡិចត្រូនិកនោះត្រូវបានកត់ត្រាឬរក្សាទុកឬនៅពេលដែលយកទៅធ្វើជាភស្តុតាង ឬក្នុងករណីដែលប្រព័ន្ធអេឡិចត្រូនិក ឬឧបករណ៍ ស្រដៀងគ្នាផ្សេងទៀតនោះមិនបានដំណើរការជាប្រក្រតី ឬឈប់ដំណើរការទាំងស្រុង ប៉ុន្តែមិនធ្វើឱ្យប៉ះពាល់ដល់សុក្រឹតភាពនៃកំណត់ត្រាអេឡិចត្រូនិក ហើយគ្មានមូលហេតុ សមស្របណាផ្សេងយកមកជំទាស់សុក្រឹតភាពនៃកំណត់ត្រានោះ។

ខ. ក្នុងករណីមានភស្តុតាងអាចបង្ហាញបានថា កំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រាឬរក្សាទុក ដោយភាគីដែលមានផលប្រយោជន៍ផ្ទុយគ្នាទៅនឹងភាគីម្ខាងទៀតដែលប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកនោះជាភស្តុតាងក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់។ ឬ

គ. នៅពេលដែលមានភស្តុតាងអាចបង្ហាញបានថា កំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រាឬរក្សាទុកជាប្រក្រតីក្នុងគោលបំណងអាជីវកម្មធម្មតាដោយបុគ្គលដែលមិនមែនជាភាគីក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ ហើយបុគ្គលនោះមិនបានកត់ត្រាឬរក្សាទុកនូវកំណត់ត្រាអេឡិចត្រូនិកក្រោមការគ្រប់គ្រងរបស់ភាគីដែលប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកនោះជាភស្តុតាងក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់។

ROYAUME DU CAMBODGE · SECRÉTARIAT ROYAL · MINISTÈRE DU PALAIS ROYAL

**មាត្រា៣៧ .. សុក្រឹតភាពនៃព័ត៌មាន**

១. លើកលែងតែមានភស្តុតាងផ្ទុយពីនេះ កំណត់ត្រាអេឡិចត្រូនិកដែលបានកត់ត្រាឬរក្សាទុកនៅក្នុងប្រព័ន្ធអេឡិចត្រូនិកត្រូវបានសន្មតថាមានសុក្រឹតភាពនៅក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ ប្រសិនបើកំណត់ត្រាអេឡិចត្រូនិកនោះ៖

ក. នៅពេញលេញនិងគ្មានការកែប្រែក្រៅពីការធ្វើបដិលេខបន្ថែមណាមួយ ឬការផ្លាស់ប្តូរដែលមិនសំខាន់ណាមួយដែលកើតឡើងនៅក្នុងដំណើរការជាប្រក្រតីនៃទំនាក់ទំនងការរក្សាទុកឬការបង្ហាញ។

ខ. ត្រូវបានបញ្ជាក់ឬចុះហត្ថលេខានៅក្នុងទម្រង់អេឡិចត្រូនិក តាមរយៈមធ្យោបាយដែលផ្តល់ឱ្យដោយអ្នកផ្តល់នីតិវិធីសុវត្ថិភាពដែលមានអាជ្ញាបណ្ណត្រឹមត្រូវ។

គ. មានសុក្រឹតភាពនិងមានខ្លឹមសារដែលត្រូវបានបញ្ជាក់ដោយក្រសួងឬស្ថាប័នមានសមត្ថកិច្ច។

ឃ. ត្រូវបានកត់ត្រាទុកនៅក្នុងឧបករណ៍រក្សាទុកឬតាមមធ្យោបាយអេឡិចត្រូនិកផ្សេងទៀតដែលមិនអនុញ្ញាតឱ្យមានការកែប្រែទៅលើកំណត់ត្រាអេឡិចត្រូនិក។

ង. ត្រូវបានត្រួតពិនិត្យនិងបញ្ជាក់ពីសុក្រឹតភាព ដោយអ្នកជំនាញដែលត្រូវបានតែងតាំងដោយតុលាការ។

ច. នៅពេលដែលមានភស្តុតាងគាំទ្រដល់អង្គហេតុណាមួយ ដែលបញ្ជាក់ថាប្រព័ន្ធអេឡិចត្រូនិកឬឧបករណ៍ស្រដៀងគ្នាផ្សេងទៀតបានដំណើរការជាប្រក្រតីនៅគ្រប់រយៈពេលសំខាន់ៗ ឬក្នុងករណីដែលប្រព័ន្ធអេឡិចត្រូនិកឬឧបករណ៍ស្រដៀងគ្នាផ្សេងទៀតនោះមិនបានដំណើរការជាប្រក្រតីឬឈប់ដំណើរការទាំងស្រុង តែសុក្រឹតភាពនៃកំណត់ត្រាមិនរងការប៉ះពាល់ដោយសារស្ថានភាពទាំងនោះទេ ហើយគ្មានមូលហេតុសមស្របណាផ្សេងទៀតដែលចោទជាមន្ទិលសង្ស័យលើសុក្រឹតភាពនៃកំណត់ត្រានោះឡើយ។ ឬ

ឆ. នៅពេលដែលមានភស្តុតាងអាចបង្ហាញបានថាកំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រាឬរក្សាទុកដោយភាគីដែលចូលរួមនៅក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់នោះ ហើយដែលភាគីមានទំនាស់ផលប្រយោជន៍ផ្ទុយគ្នាទៅនឹងភាគីម្ខាងទៀត ដែលមានបំណងប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកនោះ។

២. នៅពេលដែលមានភស្តុតាងអាចបង្ហាញបានថាកំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រាឬរក្សាទុកតាមធម្មតានិងក្នុងគោលបំណងអាជីវកម្មធម្មតា ដោយបុគ្គលដែលមិនមែនជាភាគីនៅក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ ហើយបុគ្គលនោះមិនបានកត់ត្រាឬរក្សាទុកនូវកំណត់ត្រាអេឡិចត្រូនិក ក្រោមការគ្រប់គ្រងរបស់ភាគីដែលមានបំណងប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកនោះ។

៣. នៅពេលដែលរបាយការណ៍ត្រូវបានកត់ត្រាទុកនៅក្នុងកំណត់ត្រាអេឡិចត្រូនិក ដែលត្រូវបានបង្កើតឡើងដោយប្រព័ន្ធអេឡិចត្រូនិក មិនត្រូវបានចាត់ទុកថាជាពាក្យចចាមអារ៉ាមទេនោះ របាយការណ៍ទាំងនោះអាចទទួលយកបាន ប្រសិនបើលក្ខខណ្ឌដូចដែលមានចែងនៅក្នុងបញ្ញត្តិនៃកថាខណ្ឌទី២ ទាក់ទងនឹងកំណត់ត្រាអេឡិចត្រូនិកនោះត្រូវបានបំពេញ។

**មាត្រា៣៨ .- ឯកសារដែលបានបោះពុម្ពចេញ**

ឯកសារដែលបានបោះពុម្ពចេញត្រឹមត្រូវស្របនឹងខ្លឹមសារដើមចេញពីកំណត់ត្រាអេឡិចត្រូនិក អាចយកមកប្រើប្រាស់ជាភស្តុតាងបានក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់។

**មាត្រា៣៩ .- បន្ទុកក្នុងការបង្ហាញអំពីយថាភូតភាពនៃភស្តុតាងអេឡិចត្រូនិក**

១. បុគ្គលដែលស្នើសុំបង្ហាញកំណត់ត្រាអេឡិចត្រូនិកក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ណាមួយ បុគ្គលនោះត្រូវទទួលបន្ទុកបង្ហាញពីយថាភូតភាពនៃកំណត់ត្រាអេឡិចត្រូនិកដោយមានភស្តុតាងគាំទ្រដល់កំណត់ត្រាដែលបានបង្ហាញ។

២. ក្នុងករណីមានបទប្បញ្ញត្តិណាមួយការពារបុគ្គលងាយរងគ្រោះដែលរាប់បញ្ចូលទាំងអ្នកប្រើប្រាស់និងកុមារ ហើយដែលមានកំណត់អំពីបន្ទុកនៃការបង្ហាញភស្តុតាងដែលផ្តល់ប្រយោជន៍ដល់បុគ្គលទាំងនោះច្រើនជាងច្បាប់នេះ បទប្បញ្ញត្តិនោះត្រូវមានអាទិភាពជាងមាត្រានេះ។

**មាត្រា៤០ .- បទដ្ឋាននៃការកត់ត្រាឬការរក្សាទុកកំណត់ត្រាអេឡិចត្រូនិក**

ដើម្បីកំណត់បានថាកំណត់ត្រាអេឡិចត្រូនិកត្រូវទទួលយកឬមិនទទួលយកក្នុងបទប្បញ្ញត្តិផ្សេងទៀត ការបង្ហាញភស្តុតាងអាចត្រូវធ្វើឡើងដោយផ្អែកលើបទដ្ឋាន នីតិវិធី ការប្រើឬការអនុវត្តនៃការកត់ត្រាឬរក្សាទុកកំណត់ត្រាអេឡិចត្រូនិក ដោយត្រូវពិនិត្យពិចារណាអំពីប្រភេទអាជីវកម្ម ចរិតលក្ខណៈ និងគោលបំណងនៃកំណត់ត្រាអេឡិចត្រូនិកនោះ។

**មាត្រា៤១ .- ការចេញលិខិតបញ្ជាក់យថាភូតភាព**

១. ក្នុងករណីដែលបុគ្គលណាមួយមានបំណងចង់បង្ហាញយថាភូតភាពនៃកំណត់ត្រាអេឡិចត្រូនិកមួយដើម្បីធ្វើជាភស្តុតាង បុគ្គលនោះអាចស្នើសុំភស្តុតាងនោះពីអ្នកជំនាញពាក់ព័ន្ធនឹងយថាភូតភាពនៃកំណត់ត្រាអេឡិចត្រូនិកនោះក្រោមទម្រង់ជាលិខិតបញ្ជាក់។

២. លិខិតបញ្ជាក់យថាភូតភាពដូចមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើត្រូវចេញដោយៈ

- ក. ក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬបុគ្គលដែលទទួលខុសត្រូវពាក់ព័ន្ធនឹងប្រតិបត្តិការ ឬការគ្រប់គ្រងអ្នកបង្កើតនីតិវិធីសុវត្ថិភាពជាក់លាក់ណាមួយ ឬអ្នកបង្កើតនីតិវិធីសុវត្ថិភាពដែលទទួលស្គាល់ដោយតុលាការ។ ឬ
- ខ. អ្នកជំនាញដែលតែងតាំងឬដែលទទួលស្គាល់ដោយតុលាការ។

៣. បុគ្គលដែលមានសមត្ថកិច្ចក្នុងការចេញលិខិតបញ្ជាក់យថាភូតភាព ដូចមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី២ខាងលើ មិនត្រូវក្លែងឬចេញលិខិតបញ្ជាក់យថាភូតភាពនៃកំណត់ត្រាឬភស្តុតាងអេឡិចត្រូនិកដែលមានលក្ខណៈក្លែងបន្លំឬមិនមែនជាការពិតនោះឡើយ។

**មាត្រា៤២ .- នីតិវិធីផ្សេងទៀតក្នុងការបង្កើតភស្តុតាងអេឡិចត្រូនិក**

បន្ថែមលើមធ្យោបាយបង្ហាញភស្តុតាងដូចមានចែងក្នុងច្បាប់នេះ ភស្តុតាងអេឡិចត្រូនិក អាចត្រូវបានបង្កើតឡើង តាមបច្ចេកទេសនិងនីតិវិធីផ្សេងទៀតដូចជា ការបញ្ជាក់ដោយសារការី ឬស្ថាប័នមានសមត្ថកិច្ច កំណត់ត្រាក្នុងមធ្យោបាយអេឡិចត្រូនិកដែលមិនអនុញ្ញាតឱ្យមានការកែប្រែបាន និងលទ្ធផលកោសល្យវិច័យលើប្រព័ន្ធអេឡិចត្រូនិកតាមការរកឃើញរបស់យុត្តាធិការតុលាការ។

**មាត្រា៤៣ .- ការបំពានលើកូដនីយកម្ម**

បុគ្គលទាំងឡាយមិនត្រូវដាក់កូដក្នុងទំនាក់ទំនងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលជាភស្តុតាងអាចនាំទៅដល់ការចោទប្រកាន់ ឬការដាក់កូដលើទិន្នន័យ ឬភស្តុតាងក្នុងប្រព័ន្ធអេឡិចត្រូនិកដែលទាក់ទិននឹងបទល្មើសឡើយ។

**មាត្រា៤៤ .- ការទទួលយកកំណត់ត្រាអេឡិចត្រូនិកពីបរទេស**

ភស្តុតាងអេឡិចត្រូនិកដែលបញ្ជាក់ដោយក្រសួងឬស្ថាប័នមានសមត្ថកិច្ចនៃបណ្តារដ្ឋបរទេស ត្រូវបានទទួលយកជាភស្តុតាង ប្រសិនបើប្រព័ន្ធអេឡិចត្រូនិកដែលកត់ត្រាឬរក្សាទុកកំណត់ត្រាអេឡិចត្រូនិកនោះមានសុក្រឹតភាពស្របតាមបទដ្ឋាន ដូចមានចែងក្នុងជំពូកទី៨នៃច្បាប់នេះ។

**មាត្រា៤៥ .- ការទទួលយកព័ត៌មានអេឡិចត្រូនិកមកពីបរទេស**

ដើម្បីកំណត់ថាព័ត៌មានក្នុងទម្រង់អេឡិចត្រូនិកមួយអាចទទួលយកឬមិនអាចទទួលយកបាន ឬអាចទទួលយកបានត្រឹមកម្រិតណាមួយនោះ មិនត្រូវគិតពីទីតាំងដែលព័ត៌មាននោះត្រូវបានបង្កើតឡើងឬត្រូវបានប្រើប្រាស់ ឬទីតាំងអាជីវកម្មដែលបានបង្កើតឡើងនៅបរទេសនោះឡើយ ឱ្យតែកំណត់ត្រាអេឡិចត្រូនិកនោះអាចចូលនិងទាញយកមកប្រើបាននៅក្នុងដែនសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៩

## ការទូទាត់និង/ឬការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក

**មាត្រា៤៦ .- ប្រតិបត្តិការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក**

១. បុគ្គលណាដែលធ្វើប្រតិបត្តិការប្រព័ន្ធទូទាត់ ផ្តល់សេវាទូទាត់ ចេញផ្សាយឧបករណ៍ទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ឬផ្តល់មធ្យោបាយទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ឬធ្វើប្រតិបត្តិការណាដែលត្រូវបានចាត់ទុកថាជាការផ្តល់ការទូទាត់សងប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកដល់សាធារណជនត្រូវស្នើសុំការអនុញ្ញាតឬអាជ្ញាបណ្ណជាមុនពីធនាគារជាតិនៃកម្ពុជា។

២. ធនាគារជាតិនៃកម្ពុជាជាស្ថាប័នមានសមត្ថកិច្ចក្នុងការរៀបចំបទប្បញ្ញត្តិទាក់ទងនឹងការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។

**មាត្រា៤៧ .. ការទទួលខុសត្រូវរបស់បុគ្គលផ្តល់សេវាទូទាត់**

១. បុគ្គលផ្តល់សេវាទូទាត់មិនត្រូវផ្តល់ជូនអតិថិជននូវឧបករណ៍ទូទាត់ ដែលអតិថិជនមិនបានស្នើសុំនោះទេ លើកលែងតែករណីដែលបណ្ណទូទាត់នោះជាបណ្ណទូទាត់ហួសរយៈពេលប្រើប្រាស់ ឬដល់ពេលត្រូវផ្លាស់ប្តូរ។

២. មុនពេលធ្វើប្រតិបត្តិការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក បុគ្គលផ្តល់សេវាត្រូវបញ្ជាក់ឱ្យបានច្បាស់ពីអត្តសញ្ញាណរបស់អតិថិជននិងផ្ទៀងផ្ទាត់ឡើងវិញនូវភាពត្រឹមត្រូវនៃការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។ បុគ្គលផ្តល់សេវាទូទាត់ត្រូវទទួលខុសត្រូវលើករណីដូចខាងក្រោម៖

ក. ប្រតិបត្តិការកើតឡើងដោយគ្មានការអនុញ្ញាតពីអតិថិជន។

ខ. ប្រតិបត្តិការកើតឡើងបន្ទាប់ពីដឹងថាមានការបន្លំ បាត់បង់ ឬចោរកម្មនៃឧបករណ៍ផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។

គ. ប្រតិបត្តិការកើតឡើងបន្ទាប់ពីមានការជូនដំណឹងពីអតិថិជនដូចមានចែងក្នុងមាត្រា៤៨ខាងក្រោម។

ឃ. ការខកខានមិនបានប្រតិបត្តិតាមបញ្ជារបស់អតិថិជនឬការប្រតិបត្តិខុសពីបញ្ជារបស់អតិថិជន។ ឬ

ង. ភាពមិនប្រក្រតីនៃប្រព័ន្ធបច្ចេកទេស កំហុសក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកទេស ឬភាពខ្វះខាតនៃឧបករណ៍ផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។

៣. បុគ្គលផ្តល់សេវាទូទាត់អាចរួចផុតពីការទទួលខុសត្រូវបានតែក្នុងករណីប្រធានស័ក្តិ ឬជាកំហុសរបស់អតិថិជនផ្ទាល់ប៉ុណ្ណោះ។

៤. ក្នុងករណីដែលបុគ្គលផ្តល់សេវាទូទាត់ត្រូវទទួលខុសត្រូវ បុគ្គលផ្តល់សេវាទូទាត់ត្រូវសងថ្លៃខូចខាតជូនអតិថិជនក្នុងរយៈពេលមិនឱ្យលើសពី៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងពីអតិថិជនដូចមានចែងក្នុងមាត្រា៤៨នៃច្បាប់នេះ នូវតម្រៃប្រតិបត្តិការដែលបានខាតបង់សោហ៊ុយ និងការពិន័យក្នុងការបង់ការប្រាក់យឺតយ៉ាវដែលកើតចេញពីប្រតិបត្តិការនេះ ដោយ មិនទាន់គិតបញ្ចូលការសងថ្លៃខូចខាតដទៃទៀតដែលអាចកើតឡើងចំពោះអតិថិជន។

៥. បុគ្គលទាំងឡាយមិនត្រូវចេញផ្សាយបណ្ណទូទាត់ ឬកែប្រែបណ្ណទូទាត់ទៅជាទម្រង់ណាមួយដែលខុសពីទម្រង់ដើម ដោយគ្មានការអនុញ្ញាតក្នុងគោលបំណងទុច្ចរិត ឆបោក ឬក្លែងបន្លំដែលនាំឱ្យមានព្យសនកម្មដល់បុគ្គលមួយផ្សេងទៀតឡើយ។

**មាត្រា៤៨ .. ការទទួលខុសត្រូវរបស់អតិថិជន**

១. អតិថិជនត្រូវជូនដំណឹងដល់បុគ្គលផ្តល់សេវាទូទាត់ អំពីប្រតិបត្តិការដែលកើតឡើងដោយគ្មានការអនុញ្ញាត កំហុសឆ្គង ឬភាពមិនត្រឹមត្រូវផ្សេងទៀតនៅក្នុងគណនីរបស់ខ្លួន។

២. អតិថិជនត្រូវជូនដំណឹងដល់បុគ្គលផ្តល់សេវាទូទាត់ឬគ្រឹះស្ថានដែលទទួលបានការអនុញ្ញាតពីបុគ្គលផ្តល់សេវាទូទាត់អំពីករណីបាត់បង់ឬអំពើចោរកម្មលើឧបករណ៍/មធ្យោបាយផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ឬការលួចយកទិន្នន័យសម្រាប់ប្រើប្រាស់ជាមួយឧបករណ៍ទូទាត់។ ការជូនដំណឹងនេះអាចធ្វើឡើងជាលាយលក្ខណ៍អក្សរឬតាមមធ្យោបាយអេឡិចត្រូនិកណាមួយដែលទទួលយកដោយបុគ្គលផ្តល់សេវាទូទាត់ ហើយត្រូវជូនដំណឹងជាបន្ទាន់តាមលទ្ធភាពដែលអាចធ្វើទៅបានឬមិនឱ្យលើសរយៈពេល២(ពីរ)ថ្ងៃ បន្ទាប់ពីបានដឹងថាមានករណីចោរកម្មឬបាត់បង់ឧបករណ៍ទូទាត់កើតឡើង។

៣. ក្នុងករណីមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាការបាត់បង់ឬការខូចខាតក្នុងករណីខាងលើជាកំហុសរបស់អតិថិជន បុគ្គលផ្តល់សេវាទូទាត់មានសិទ្ធិទាមទារឱ្យអតិថិជនទទួលខុសត្រូវទាំងស្រុងចំពោះការបាត់បង់ឬការខូចខាតនោះ។

៤. ក្នុងករណីមិនមានភស្តុតាងបញ្ជាក់អំពីកំហុសរបស់អតិថិជនទេ បុគ្គលផ្តល់សេវាទូទាត់ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការបាត់បង់ឬការខូចខាតនោះ ដោយឥតលក្ខខណ្ឌ។

## ជំពូកទី១០
## សមត្ថកិច្ច ការប្តឹងតវ៉ា និងនីតិវិធីនៃការដាក់ពិន័យ

### មាត្រា៤៩ .- សមត្ថកិច្ច

ការព្រមានជាលាយលក្ខណ៍អក្សរ ការបញ្ឈប់សកម្មភាពឬប្រតិបត្តិការអាជីវកម្ម ការព្យួរ ការដកហូត ឬការលុបចោលលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ និងការដាក់ពិន័យ ជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍។

ក្នុងករណីដែលបុគ្គលមិនអនុវត្តតាមវិធានការខាងលើ ក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍ អាចធ្វើបណ្តឹងទៅតុលាការមានសមត្ថកិច្ច។

### មាត្រា៥០ .- នីតិវិធីនៃការប្តឹងតវ៉ា

១. បុគ្គលដែលមិនសុខចិត្តនឹងការព្រមានជាលាយលក្ខណ៍អក្សរ ការបញ្ឈប់សកម្មភាពឬប្រតិបត្តិការអាជីវកម្ម ការព្យួរ ការដកហូត ឬការលុបចោលលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ និងការដាក់ពិន័យរបស់ក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍ មានសិទ្ធិប្តឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍។

២. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍ត្រូវសម្រេចក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ។

៣. បុគ្គលណាមួយដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍ មានសិទ្ធិប្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជាបានក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបានសេចក្តីជូនដំណឹងនៃសេចក្តីសម្រេចនោះ។

**មាត្រា៥១ .- នីតិវិធីនៃការផាកពិន័យ**

នីតិវិធីនៃការផាកពិន័យ ការបង់ប្រាក់ផាកពិន័យ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យ និងការចាត់ចែងប្រាក់ចំណូលដែលបានពីការផាកពិន័យ ដូចមានចែងនៅក្នុងបទប្បញ្ញត្តិច្បាប់នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

## ជំពូកទី១១
## ទោសប្បញ្ញត្តិ

**មាត្រា៥២ .- ទណ្ឌកម្ម**

ទណ្ឌកម្មនៅក្នុងច្បាប់នេះរួមមាន ការព្រមានជាលាយលក្ខណ៍អក្សរ ការបញ្ឈប់សកម្មភាព ឬប្រតិបត្តិការអាជីវកម្ម ការព្យួរ ការដកហូត ឬការលុបចោលលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ ការផាកពិន័យ ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។

**មាត្រា៥៣ .- អំពើល្មើសលើការលួចប្រើប្រាស់អត្តសញ្ញាណ**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែទៅ៣(បី)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី ១ 000 000(មួយលាន)រៀលទៅ៦ 000 000(ប្រាំមួយលាន)រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃមាត្រា២២។

**មាត្រា៥៤ .- អំពើល្មើសលើការមិនរាយការណ៍អំពីព័ត៌មានឬហេតុការណ៍**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី១០០ ០០០(មួយសែន)រៀលទៅ២ ០០០ ០០០(ពីរលាន)រៀល ចំពោះអំពើរបស់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី១និងកថាខណ្ឌទី២នៃមាត្រា២៥។

**មាត្រា៥៥ .- អំពើផ្តល់ពត៌មានមិនពិត**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី១០០ ០០០(មួយសែន)រៀលទៅ២ ០០០ ០០០(ពីរលាន)រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើដូចមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី៥នៃមាត្រា២៥។

**មាត្រា៥៦ .- ការធ្វើប្រតិបត្តិការដោយគ្មានការអនុញ្ញាត**

ត្រូវបញ្ឈប់សកម្មភាពឬប្រតិបត្តិការអាជីវកម្មនិងត្រូវទទួលការផាកពិន័យជាប្រាក់មិនលើសពី១០ ០០០ ០០០(ដប់លាន)រៀល ចំពោះបុគ្គលទាំងឡាយណាដែលប្រព្រឹត្តផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី១នៃមាត្រា២៦។

ក្នុងករណីធ្លាប់ទទួលរងនូវវិធានការដូចមានចែងក្នុងកថាខណ្ឌទី១ជាស្ថាពររួចហើយ ហើយបានប្រព្រឹត្តបទល្មើសដដែលនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀលពី៦ ០០០ ០០០(ប្រាំមួយលាន)រៀល។

**មាត្រា៥៧ ._ អំពើល្មើសលើការមិនអនុវត្តតាមបទប្បញ្ញត្តិស្តីពីព័ត៌មានអប្បបរមាក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី១និងកថាខណ្ឌទី២នៃមាត្រា២៩។

ក្នុងករណីទទួលរងនូវការព្រមានជាលាយលក្ខណ៍អក្សរម្តងរួចហើយ នៅតែបន្តប្រព្រឹត្តល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវព្យួរឬដកហូតអាជ្ញាបណ្ណឬលិខិតអនុញ្ញាតជាបុគ្គលផ្តល់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

**មាត្រា៥៨ ._ អំពើល្មើសលើការផ្ញើទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំ**

ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃមាត្រា៣០។

ក្នុងករណីទទួលរងនូវការព្រមានជាលាយលក្ខណ៍អក្សរម្តងរួចហើយ នៅតែបន្តប្រព្រឹត្តល្មើស ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវព្យួរឬដកហូតអាជ្ញាបណ្ណឬលិខិតអនុញ្ញាតជាអន្តរការីឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឬបិទមិនឱ្យដំណើរការនូវប្រព័ន្ធផ្សព្វផ្សាយឬមធ្យោបាយអេឡិចត្រូនិករបស់អ្នកផ្ញើ។

**មាត្រា៥៩ ._ អំពើល្មើសលើការក្លែងប្រព័ន្ធអេឡិចត្រូនិកនិងកូដព្យាបាទ**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែទៅ៣(បី)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី ១ ០០០ ០០០(មួយលាន)រៀលទៅ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃមាត្រា៣១។

**មាត្រា៦០ ._ អំពើល្មើសលើការមិនអនុវត្តកាតព្វកិច្ចការពារទិន្នន័យ**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ២(ពីរ)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀលទៅ៤ ០០០ ០០០(បួនលាន)រៀល ចំពោះបុគ្គលដែលរក្សាព័ត៌មានជាលក្ខណៈឯកជនក្រោមទម្រង់អេឡិចត្រូនិក ដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី១នៃមាត្រា៣២។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ២(ពីរ)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀលទៅ៤ ០០០ ០០០(បួនលាន)រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី២នៃមាត្រា៣២។

**មាត្រា៦១ ._ អំពើល្មើសលើការបំពានលើការចេញលិខិតបញ្ជាក់យថាភូតភាព**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី១០០ ០០០(មួយរយពាន់)រៀលទៅ២ ០០០ ០០០(ពីរលាន)រៀល ចំពោះបុគ្គលទាំងឡាយដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី៣នៃមាត្រា៤១។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា៦២ .- អំពើល្មើសលើការបំពានលើភូជនីយកម្ម**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀលទៅ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះបុគ្គលទាំងឡាយដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃមាត្រា៤៣។

**មាត្រា៦៣ .- អំពើល្មើសលើការធ្វើប្រតិបត្តិការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី១ ០០០ ០០០(មួយលាន)រៀលទៅ១០ ០០០ ០០០(ដប់លាន)រៀល ចំពោះបុគ្គលទាំងឡាយដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី១នៃមាត្រា៤៦។

**មាត្រា៦៤ .- អំពើល្មើសលើការក្លែងបន្លំឧបករណ៍ទូទាត់សងប្រាក់ជាអេឡិចត្រូនិក**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀលទៅ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះបុគ្គលទាំងឡាយដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី៥នៃមាត្រា៤៧។

**មាត្រា៦៥ .- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល**

១. នីតិបុគ្គលអាចត្រូវប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា៥៣ដល់មាត្រា៥៥ កថាខណ្ឌទី២នៃមាត្រា៥៦និងមាត្រា៥៩ដល់មាត្រា៦៤នៃច្បាប់នេះ។

២. នីតិបុគ្គលត្រូវពិន័យជាប្រាក់ទ្វេដង ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចតទៅនេះ៖

- ក. ការរំលាយតាមបែបបទកំណត់ដោយមាត្រា១៧០(ការរំលាយនិងការជម្រះបញ្ជីនៃនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។
- ខ. ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា១៧១(ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ)នៃក្រមព្រហ្មទណ្ឌ។
- គ. ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយឬច្រើន តាមបែបបទកំណត់ដោយមាត្រា១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព)នៃក្រមព្រហ្មទណ្ឌ។
- ឃ. ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា១៨០(ការបិទផ្សាយសេចក្តីសម្រេច)នៃក្រមព្រហ្មទណ្ឌ។
- ង. ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ សារព័ត៌មានអេឡិចត្រូនិក ឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា១៨១(ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ជាអាទិ៍)នៃក្រមព្រហ្មទណ្ឌ។

## ជំពូកទី១២
## អវសានប្បញ្ញត្តិ

**មាត្រា៦៦** .- ការទុកជានិរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៦៧** .- ការអនុវត្តច្បាប់នេះ

ក្រោយពីចូលជាធរមាន ច្បាប់នេះត្រូវផ្សព្វផ្សាយរយៈពេល៦(ប្រាំមួយ)ខែ ទើបអនុវត្ត។

ថ្ងៃ សៅរ៍ ៦កើត ខែ កត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ២០១៩

នស/រកម.១១១៩.០១៦

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

## ឧបសម្ព័ន្ធ
## និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើនៅក្នុងច្បាប់នេះត្រូវបានកំណត់និយមន័យដូចតទៅ៖

**១. ការចូលប្រើប្រាស់/អាក់សេស(Access)** សំដៅដល់ការចូលទៅប្រើកម្មវិធីកុំព្យូទ័រ ប្រព័ន្ធកុំព្យូទ័រ ប្រព័ន្ធឬបណ្តាញអេឡិចត្រូនិក ដើម្បីទាក់ទង បញ្ជូន រក្សាទុក ឬទាញយកនូវទិន្នន័យ ព័ត៌មានឬឯកសារផ្សេងៗទៀតក្នុងប្រព័ន្ធអេឡិចត្រូនិកតាមគ្រប់មធ្យោបាយ។

**២. អ្នកទទួល(Addressee)** សំដៅដល់បុគ្គលដែលទទួលទំនាក់ទំនងអេឡិចត្រូនិក ស្របតាមឆន្ទៈរបស់អ្នកផ្ញើ លើកលែងតែអន្តរការីក្នុងការប្រាស្រ័យទាក់ទងតាមប្រព័ន្ធអេឡិចត្រូនិក។

**៣. ប្រព័ន្ធស្វ័យប្រវត្តិ(Automated System)** សំដៅដល់កម្មវិធីកុំព្យូទ័រ ប្រព័ន្ធកុំព្យូទ័រ ប្រព័ន្ធ ឬបណ្តាញអេឡិចត្រូនិក ឬមធ្យោបាយអេឡិចត្រូនិកផ្សេងទៀតដែលត្រូវបានប្រើប្រាស់សម្រាប់ជូនដំណឹងឬឆ្លើយតបដោយស្វ័យប្រវត្តិដោយគ្មានអន្តរាគមន៍ពីរូបវន្តបុគ្គលណាមួយ។

**៤. បណ្ណ/កាតទូទាត់(Card)** សំដៅដល់បណ្ណ/កាតធនាគារ បណ្ណឥណទាន/ឥណពន្ធ ស្មាតកាត (Smart Card) ឬបណ្ណ/កាតទូទាត់ ទោះបីក្នុងទម្រង់អេឡិចត្រូនិកដែលផ្ទុកតម្លៃ ហើយមានមុខងារសម្រាប់ទូទាត់។

**៥. កម្មវិធីចម្លងមេរោគ(Contaminant)** សំដៅដល់កម្មវិធីអេឡិចត្រូនិកដែលត្រូវបានបង្កើតឡើងដើម្បី៖

(ក) កែប្រែ បំផ្លាញ កត់ត្រា បញ្ជូនទិន្នន័យឬកម្មវិធីនៅក្នុងប្រព័ន្ធអេឡិចត្រូនិក ឬ

(ខ) ជ្រៀតជ្រែកតាមគ្រប់មធ្យោបាយនូវដំណើរការប្រក្រតីរបស់ប្រព័ន្ធឬបណ្តាញអេឡិចត្រូនិក។

**៦. ម្ចាស់បណ្ណ/កាតទូទាត់(Cardholder)** សំដៅដល់បុគ្គលដែលមានឈ្មោះចារឹកនៅលើបណ្ណ/កាត និងជាបុគ្គលដែលទទួលប្រយោជន៍ពីបណ្ណ/កាតទូទាត់នោះ។

**៧. ទំនាក់ទំនង(Communication)** សំដៅដល់អំណះអំណាង សេចក្តីថ្លែងការណ៍ ការទាមទារ សេចក្តីជូនដំណឹង សំណូមពរ សំណើ ឬស្នើការ ដែលគូភាគីត្រូវធ្វើឬសម្រេចចិត្តធ្វើពាក់ព័ន្ធនឹងការបង្កើតឬការអនុវត្តកិច្ចសន្យា។

**៨. បណ្ណ/កាតទូទាត់ក្លែងក្លាយ(Counterfeit card)** សំដៅដល់បណ្ណ/កាតទូទាត់ទាំងឡាយណាដែលត្រូវបានបង្កើតឡើងដោយការបង្ហាញឬការពិពណ៌នាដែលត្រូវបានប្រឌិតឡើង កែប្រែក្លែងបន្លំ ឬបណ្ណ/កាតទូទាត់ដែលមានសមាសធាតុណាមួយនៃបណ្ណ/កាតទូទាត់នោះមានលក្ខណៈខុសច្បាប់។

**៩. ទិន្នន័យ(Data)** សំដៅដល់បណ្តុំលេខ អក្សរ និមិត្តសញ្ញា សារ រូបភាព សំឡេង វីដេអូ ព័ត៌មាន ឬកម្មវិធីអេឡិចត្រូនិក ដែលត្រូវបានរៀបចំក្នុងទម្រង់សមស្របសម្រាប់ប្រើប្រាស់ក្នុងមូលដ្ឋានទិន្នន័យឬប្រព័ន្ធអេឡិចត្រូនិក។

១០. **អេឡិចត្រូនិក(Electronic)** សំដៅដល់អ្វីដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យាដែលមានចរន្តអគ្គិសនី ឌីជីថល ម៉ាញេទិច អុបទិក ជីវមាត្រ អេឡិចត្រូគីមី វ៉ាយអឺឡេស (wireless) អេឡិចត្រូម៉ាញេទិក ឬបច្ចេកវិទ្យាដែលមានមុខងារប្រហាក់ប្រហែលផ្សេងទៀត។

១១. **អាសយដ្ឋានអេឡិចត្រូនិក(Electronic Address)** សំដៅដល់លេខឬអាសយដ្ឋានប្រើប្រាស់សម្រាប់ផ្ញើឬទទួលការជូនដំណឹង ឯកសារ ព័ត៌មាន ឬទំនាក់ទំនងតាមមធ្យោបាយអេឡិចត្រូនិក។

១២. **យថាភូតភាព(Authenticity)** សំដៅដល់ភាពត្រឹមត្រូវនិងអាចជឿទុកចិត្តបាននៃទំនាក់ទំនងអេឡិចត្រូនិក។

១៣. **ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក(Electronic Commerce)** សំដៅដល់សកម្មភាពទិញលក់ ជួល ផ្លាស់ប្តូរទំនិញឬសេវា ដោយរាប់បញ្ចូលទាំងសកម្មភាពពាណិជ្ជកម្មនិងរដ្ឋប្បវេណី ព្រមទាំងសកម្មភាពនិងប្រតិបត្តិការនានារបស់រដ្ឋ តាមប្រព័ន្ធអេឡិចត្រូនិក។

១៤. **ឧបករណ៍ទូទាត់អេឡិចត្រូនិក(Electronic Payment Instrument)** សំដៅដល់បណ្ណ/កាតទូទាត់ ឬឧបករណ៍ទូទាត់ទាំងឡាយណាដែលមានទម្រង់ជាអេឡិចត្រូនិក ហើយមានមុខងារសម្រាប់ទូទាត់សងប្រាក់។

១៥. **ទំនាក់ទំនងអេឡិចត្រូនិក(Electronic Communication)** សំដៅដល់ព័ត៌មានដែលត្រូវបានទាក់ទង ដំណើរការ កត់ត្រាទុក បង្ហាញឡើង បង្កើតឡើង រក្សាទុក ទទួលបាន ឬបញ្ជូនតាមមធ្យោបាយអេឡិចត្រូនិក។

១៦. **ឧបករណ៍អេឡិចត្រូនិក(Electronic device)** សំដៅដល់ឧបករណ៍ទាំងឡាយណាដែលបង្កើតឡើងដើម្បីគ្រប់គ្រង បញ្ជា និងប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិក។

១៧. **ភស្តុតាងអេឡិចត្រូនិក(Electronic evidence)** សំដៅដល់ព័ត៌មាន ទិន្នន័យ ឬឯកសារនានាដែលបានបង្កើតឡើង រក្សាទុក ផ្ញើចេញ ឬទទួលក្នុងទម្រង់ឬទំនាក់ទំនងអេឡិចត្រូនិកសម្រាប់ជាសំអាងទាក់ទងនឹងអង្គហេតុណាមួយក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ ហើយព័ត៌មាន ទិន្នន័យ ឬឯកសារនោះមានយថាភូតភាពស្របតាមច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

១៨. **ទម្រង់អេឡិចត្រូនិក(Electronic form)** សំដៅដល់ទម្រង់នៃព័ត៌មាន ទិន្នន័យ ឬឯកសារដែលបង្កើត បញ្ជូន ទទួលបាន ឬរក្សាទុកក្នុងប្រព័ន្ធអេឡិចត្រូនិក។

១៩. **ការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក(Electronic fund transfer)** សំដៅដល់ប្រតិបត្តិការទាំងឡាយណាដែលធ្វើឡើងតាមរយៈបញ្ជាផ្ទេរប្រាក់អេឡិចត្រូនិក ឬតាមឧបករណ៍អេឡិចត្រូនិកចល័ត ឬតាមឧបករណ៍អេឡិចត្រូនិកដែលមានមុខងារស្រដៀងគ្នា ដើម្បីបញ្ជាឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុធ្វើការចុះឥណពន្ធឬឥណទានក្នុងគណនី។

២០. កំណត់ត្រាអេឡិចត្រូនិក(Electronic record) សំដៅដល់កំណត់ត្រាដែលត្រូវបានបង្កើតឡើង ទាក់ទង ទទួល រក្សាទុក ឬដំណើរការក្នុងប្រព័ន្ធអេឡិចត្រូនិក ឬសម្រាប់បញ្ជូនពីប្រព័ន្ធអេឡិចត្រូនិកមួយទៅប្រព័ន្ធអេឡិចត្រូនិកមួយទៀត។

២១. បុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក(Electronic-Commerce service provider) សំដៅដល់បុគ្គលដែលប្រើប្រាស់មធ្យោបាយអេឡិចត្រូនិកដើម្បីផ្គត់ផ្គង់ទំនិញនិង/ឬសេវា លើកលែងគ្រឹះស្ថានធានារ៉ាប់រង។

២២. ហត្ថលេខាអេឡិចត្រូនិក(Electronic Signature) សំដៅដល់រាល់ហត្ថលេខាដែលត្រូវបានបង្កើតឡើងតាមមធ្យោបាយអេឡិចត្រូនិកសម្រាប់ប្រើប្រាស់កំណត់អត្តសញ្ញាណរបស់ហត្ថលេខីដែលរួមមាន ហត្ថលេខាឌីជីថល ហត្ថលេខាជីវមាត្រ និងហត្ថលេខាដទៃទៀត។

២៣. ប្រព័ន្ធអេឡិចត្រូនិក(Electronic system) សំដៅដល់ឧបករណ៍អេឡិចត្រូនិកឬបណ្តុំឧបករណ៍តភ្ជាប់គ្នាឬទាក់ទងគ្នា តាមរយៈកម្មវិធីអេឡិចត្រូនិក ដែលអាចធ្វើឱ្យដំណើរការជាស្វ័យប្រវត្តិនៃទិន្នន័យ ព័ត៌មាន ឬឯកសារ រួមបញ្ចូលទាំងឧបករណ៍អេឡិចត្រូនិកសម្រាប់រក្សាទុកទិន្នន័យ ព័ត៌មាន ឬឯកសារនោះ។

២៤. ប្រព័ន្ធព័ត៌មាន(Information system) សំដៅដល់ប្រព័ន្ធសម្រាប់បង្កើត ផ្ញើ ទទួល រក្សាទុក ឬដំណើរការកំណត់ត្រាអេឡិចត្រូនិក។

២៥. អន្តរការី(Intermediary) សំដៅដល់បុគ្គលដែលផ្តល់សេវា ផ្ញើ ទទួល បញ្ជូន ឬរក្សាទុកជាបណ្តោះអាសន្នឬជាអចិន្ត្រៃយ៍នូវទំនាក់ទំនងអេឡិចត្រូនិកនោះ ឬផ្តល់សេវាផ្សេងទៀតដែលពាក់ព័ន្ធនឹងទំនាក់ទំនងអេឡិចត្រូនិក រួមបញ្ចូលនូវបុគ្គលដូចខាងក្រោម៖

១. បុគ្គលដែលតំណាងឱ្យអ្នកផ្ញើ អ្នកទទួល អ្នកបញ្ជូន ឬអ្នករក្សាទុក

២. បុគ្គលផ្តល់សេវាទូរគមនាគមន៍

៣. បុគ្គលផ្តល់សេវាបណ្តាញនានា

៤. បុគ្គលផ្តល់សេវាអ៊ិនធឺណិត

៥. បុគ្គលផ្តល់មធ្យោបាយស្វែងរកទិន្នន័យណាមួយតាមប្រព័ន្ធអេឡិចត្រូនិក

៦. បុគ្គលផ្តល់សេវាទូទាត់តាមអនឡាញ

៧. បុគ្គលផ្តល់សេវាដេញថ្លៃតាមអនឡាញ

៨. បុគ្គលផ្តល់សេវាទីផ្សារអនឡាញនិងសេវាពាណិជ្ជកម្មតាមបណ្តាញអ៊ិនធឺណិត។

២៦. បុគ្គលចេញបណ្ណ/កាតទូទាត់(Issuer) សំដៅដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬបុគ្គលណាមួយដែលបានចេញបណ្ណ/កាតទូទាត់ ដែលបានទទួលការអនុញ្ញាត។

**២៧. កូដព្យាបាទ(Malicious code)** សំដៅដល់កម្មវិធីឬតួនាទីលាក់មុខនៃកម្មវិធីដែលចម្លងមេរោគដល់ទិន្នន័យ ព័ត៌មាន ឬឯកសារ ដោយមានឬគ្មានបន្សល់ទុកស្លាកស្នាមសម្គាល់នៃមេរោគនោះក្នុងឯកសារអេឡិចត្រូនិកដែលបានឆ្លងមេរោគ ហើយមេរោគនោះអាចចម្លងបន្តក្នុងប្រព័ន្ធដោយឯកឯងឬដោយមានអន្តរាគមន៍ពីមនុស្ស។

**២៨. អ្នកផ្ញើ(Originator)** សំដៅដល់ភាគីឬអ្នកតំណាងដែលបានផ្តើមប្រតិបត្តិការបង្កើត រក្សាទុក ឬបញ្ជូនទិន្នន័យតាមមធ្យោបាយអេឡិចត្រូនិក ដោយមិនរាប់បញ្ចូលអន្តរការី។

**២៩. បុគ្គលផ្តល់សេវាទូទាត់(Payment Service Provider)** សំដៅដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬបុគ្គលដទៃទៀតដែលបានទទួលការអនុញ្ញាតឬអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ឱ្យធ្វើប្រតិបត្តិការប្រព័ន្ធទូទាត់ ចេញផ្សាយឧបករណ៍ទូទាត់អេឡិចត្រូនិកឬមធ្យោបាយទូទាត់ ជាអេឡិចត្រូនិក ឬធ្វើប្រតិបត្តិការណាដែលត្រូវបានចាត់ទុកថាជាការផ្តល់ការទូទាត់សងប្រាក់ ជាអេឡិចត្រូនិកដល់សាធារណជន។

**៣០. ទីតាំងអាជីវកម្ម(Place of business)** សំដៅដល់៖

ក. ទីតាំងដែលអ្នកផ្ញើឬអ្នកទទួលបានចង្អុលបង្ហាញ លើកលែងតែភាគីណាមួយបានបង្ហាញថាអ្នកអះអាងនោះ ពុំមានទីតាំងអាជីវកម្មនៅទីនោះឡើយ។

ខ. ប្រសិនបើភាគីណាមួយមិនបានចង្អុលបង្ហាញទីកន្លែងអាជីវកម្មជាក់លាក់ណាមួយ ហើយភាគីនោះមានទីតាំងអាជីវកម្មច្រើនជាងមួយកន្លែង ទីតាំងអាជីវកម្មត្រូវកំណត់ថាជាទីកន្លែងដែលមានទំនាក់ទំនងជិតស្និទ្ធជាងគេទៅនឹងកិច្ចសន្យាដែលពាក់ព័ន្ធ ដោយត្រូវពិចារណាផងដែរអំពីកាលៈទេសៈដែលបានដឹងឬពិនិត្យដោយភាគីនៅពេលណាមួយមុនឬក្នុងពេលចុះកិច្ចសន្យា។

គ. សម្រាប់រូបវន្តបុគ្គលដែលពុំមានទីតាំងអាជីវកម្មទេនោះ ទីតាំងអាជីវកម្មសំដៅដល់ទីលំនៅអចិន្ត្រៃយ៍របស់បុគ្គលនោះ។

មិនត្រូវចាត់ទុកថាជាទីតាំងអាជីវកម្មរបស់ភាគីដោយគ្រាន់តែជា៖

- ទីតាំងដែលសម្ភារៈឬឧបករណ៍បច្ចេកវិទ្យានៃប្រព័ន្ធព័ត៌មានត្រូវបានប្រើ
- អាសយដ្ឋានអេឡិចត្រូនិកឬឈ្មោះដែនកម្មសិទ្ធិ(Domain Name) ដែលភ្ជាប់ជាមួយនឹងទីតាំងរបស់ភាគី។

**៣១. កំណត់ត្រា(Record)** សំដៅដល់ព័ត៌មាន ទិន្នន័យ ឬឯកសារដែលត្រូវបានកត់ត្រាចូលរក្សាទុក ឬបញ្ចូលទៅក្នុងទម្រង់រូបី ឬដែលត្រូវបានរក្សាទុកក្នុងទម្រង់អេឡិចត្រូនិក ជាត្រាសស្នាម ឬទម្រង់ប្រភេទផ្សេងទៀត ហើយដែលអាចទាញយកកំណត់ត្រានោះវិញបានក្នុងទម្រង់ជាក់លាក់ដែលអាចមើលបាន។

៣២. **បុគ្គលផ្តល់សេវា( service provider)** សំដៅដល់

(ក) បុគ្គលដែលផ្តល់សេវាព័ត៌មាននិងសេវាទំនាក់ទំនង រួមមាន ការផ្ញើ ការទទួល ការរក្សាទុក ឬដំណើរការទំនាក់ទំនងអេឡិចត្រូនិក ឬការផ្តល់សេវាតាមប្រព័ន្ធអេឡិចត្រូនិកផ្សេងទៀត។

(ខ) បុគ្គលដែលជាម្ចាស់ បុគ្គលកាន់កាប់ បុគ្គលដំណើរការ បុគ្គលគ្រប់គ្រង ឬបុគ្គលត្រួតពិនិត្យបណ្តាញស្វិចសាធារណៈ(Public Switched Network) ឬបុគ្គលដែលផ្តល់សេវាទូរគមនាគមន៍។ ឬ

(គ) បុគ្គលផ្សេងទៀតដែលប្រតិបត្តិឬរក្សាទុកទិន្នន័យបម្រើឱ្យសេវាទំនាក់ទំនងអេឡិចត្រូនិកនោះ ឬអ្នកប្រើប្រាស់សេវា។

៣៣. **បុគ្គលផ្តល់នីតិវិធីសុវត្ថិភាព( Security procedure provider)** សំដៅដល់បុគ្គលបង្កើត ឬផ្តល់នីតិវិធីសុវត្ថិភាព។

៣៤. **នីតិវិធីសុវត្ថិភាព(Security Procedure)** សំដៅដល់នីតិវិធីដែលកំណត់ដោយច្បាប់ ឬកិច្ចសន្យា ឬការសម្រេចដោយភាគីណាមួយ ហើយដែលត្រូវបានប្រើក្នុងគោលបំណង៖

(ក) ផ្ទៀងផ្ទាត់ថាហត្ថលេខា ទំនាក់ទំនង ឬប្រតិបត្តិការក្នុងប្រព័ន្ធអេឡិចត្រូនិក ពិតជារបស់បុគ្គលនោះ។

(ខ) រកឱ្យឃើញកំហុសឆ្គងឬការកែប្រែនៅក្នុងទំនាក់ទំនងឬក្នុងកន្លែងរក្សាទុកកំណត់ត្រាអេឡិចត្រូនិក ចាប់តាំងពីពេលជាក់ណាមួយ។

នីតិវិធីសុវត្ថិភាពខាងលើអាចតម្រូវឱ្យប្រើរូបមន្តអាល់ហ្គោរីត(algorithms)ឬកូដ ពាក្យឬលេខសម្រាប់ សម្គាល់អត្តសញ្ញាណ កូដនីយកម្ម សំណួរសម្ងាត់ ឬការទទួលស្គាល់នីតិវិធីណាមួយ ឬក៏ឧបករណ៍សុវត្ថិភាពស្រដៀងគ្នាផ្សេងទៀត។

៣៥. **ព័ត៌មានឬកំណត់ត្រាជាលាយលក្ខណ៍អក្សរ(writing/written)** សំដៅដល់ព័ត៌មានឬកំណត់ត្រាផ្សេងៗទៀតដែលត្រូវបានសរសេរ ចារឹក ឬបោះពុម្ពនៅលើក្រដាសឬសម្ភារៈ ផ្សេងៗទៀត។

៣៦. **អ៊ីមែលឬសារអេឡិចត្រូនិក(E-mail or Electronic Message)** សំដៅដល់សារឬព័ត៌មានដែលត្រូវបានបង្កើតឡើង ឬបញ្ជូន ឬទទួលបានពីប្រព័ន្ធអេឡិចត្រូនិក រួមទាំងឯកសារភ្ជាប់ក្នុងអត្ថបទ រូបភាព សំឡេង វីដេអូ និងកំណត់ត្រាអេឡិចត្រូនិកណាមួយផ្សេងទៀតដែលអាចបញ្ជូនជាមួយសារបាន។

៣៧. **សន្តតិកម្ម(Will)** សំដៅដល់ការផ្ទេរនូវសិទ្ធិនិងករណីកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ឬច្រើននាក់តាមឆន្ទៈឬតាមច្បាប់។

៣៨. **ស្វីការ**(Acceptance) សំដៅដល់ការសំដែងឆន្ទៈដែលបុគ្គលម្នាក់បានបញ្ចេញការយល់ព្រមរបស់ខ្លួនចំពោះសំណើដែលបុគ្គលដទៃបានស្នើមកខ្លួនដើម្បីបង្កើតកិច្ចសន្យា។

# អនុក្រឹត្យ

# ស្តីពី

# ហត្ថលេខាឌីជីថល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ២៤៦ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ហត្ថលេខាឌីជីថល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា២៦ មាត្រា២៧ មាត្រា២៨ និងមាត្រា២៩ និងបំពេញបន្ថែមមាត្រា២៩ ស្ទួន នៃអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

# សម្រេច

# ជំពូកទី១

# បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងគ្រប់គ្រងនិងជំរុញការប្រើប្រាស់ហត្ថលេខាឌីជីថលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាពខ្ពស់។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីៈ

- គោលការណ៍នៃហត្ថលេខាឌីជីថលនិងស្ថាប័នមានសមត្ថកិច្ច
- ការផ្តល់ ការកែប្រែ ការព្យួរ ការបញ្ឈប់ និងការដកហូតអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល
- វិញ្ញាបនបត្រហត្ថលេខាឌីជីថល
- កាតព្វកិច្ចរបស់វិញ្ញាតធរហត្ថលេខាឌីជីថល
- កាតព្វកិច្ចរបស់កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រតិបត្តិការ ដែលពាក់ព័ន្ធនឹងហត្ថលេខាឌីជីថលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ .-**

ពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះមានន័យដូចខាងក្រោមៈ

**កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល** សំដៅដល់បុគ្គលដែលទទួលបានវិញ្ញាបនបត្រហត្ថលេខាឌីជីថលពីវិញ្ញាតធរហត្ថលេខាឌីជីថល។

**គន្លឹះបង្កើតហត្ថលេខាឌីជីថល** សំដៅដល់កូដនៅក្នុងប្រព័ន្ធកុំព្យូទ័រដែលត្រូវបានប្រើប្រាស់សម្រាប់បង្កើតហត្ថលេខាឌីជីថល។

**គន្លឹះផ្ទៀងផ្ទាត់ហត្ថលេខាឌីជីថល** សំដៅដល់កូដនៅក្នុងប្រព័ន្ធកុំព្យូទ័រដែលត្រូវបានប្រើប្រាស់សម្រាប់ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃហត្ថលេខាឌីជីថល។

**ទិន្នន័យ** សំដៅដល់អត្ថបទ រូបភាព សំឡេង វីដេអូ ឬសញ្ញាណផ្សេងៗទៀតដែលត្រូវបានបង្កើត ប្រើប្រាស់ និងរក្សាទុកនៅក្នុងប្រព័ន្ធកុំព្យូទ័រ។

**ប្រព័ន្ធកុំព្យូទ័រ** សំដៅដល់រាល់ឧបករណ៍អេឡិកត្រូនិកទាំងឡាយ ទោះស្ថិតនៅដាច់ដោយឡែកតែឯង ឬជាបណ្តុំនៃឧបករណ៍អេឡិកត្រូនិកដែលតភ្ជាប់គ្នា ឬឧបករណ៍ពាក់ព័ន្ធដែលដំណើរការប្រព្រឹត្តកម្មស្វ័យប្រវត្តិនៃទិន្នន័យ ក្នុងនោះរាប់ទាំងឧបករណ៍គ្រប់ប្រភេទដែលមានសមត្ថភាពធ្វើប្រព្រឹត្តកម្មទិន្នន័យ ដោយរាប់បញ្ចូលតែមិនកំណត់ត្រឹម កុំព្យូទ័រ កុំព្យូទ័របន្ទះ និងទូរស័ព្ទ។

**លិខិតលាយលក្ខណ៍អក្សរ** សំដៅដល់លិខិតដែលមានទម្រង់ជាក្រដាសដែលមានឬតម្រូវឱ្យមាន ហត្ថលេខាឬស្នាមម្រាមដៃ, ហត្ថលេខាឬស្នាមម្រាមដៃ និងឈ្មោះ, ហត្ថលេខាឬស្នាមម្រាមដៃ និងត្រា, ឈ្មោះនិងត្រា, ឬហត្ថលេខាឬស្នាមម្រាមដៃ ឈ្មោះ និងត្រា។

**វិញ្ញាបនបត្រហត្ថលេខាឌីជីថល** សំដៅដល់កំណត់ត្រាក្នុងប្រព័ន្ធកុំព្យូទ័រមួយដែលចេញដោយវិញ្ញាតធរហត្ថលេខាឌីជីថល សម្រាប់បញ្ជាក់អត្តសញ្ញាណរបស់កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល ដែលជាម្ចាស់កម្មសិទ្ធិនៃគន្លឹះផ្ទៀងផ្ទាត់ហត្ថលេខាឌីជីថល។

**វិញ្ញាតធរហត្ថលេខាឌីជីថល** សំដៅដល់នីតិបុគ្គលដែលធ្វើវិញ្ញាតកម្មហត្ថលេខាឌីជីថល។

**វិញ្ញាតកម្មហត្ថលេខាឌីជីថល** សំដៅដល់ការចេញវិញ្ញាបនបត្រហត្ថលេខាឌីជីថល។

**វិធានរួមស្តីពីវិញ្ញាតកម្មហត្ថលេខាឌីជីថល** សំដៅដល់វិធាននិងនីតិវិធីពាក់ព័ន្ធនឹងវិញ្ញាតកម្មហត្ថលេខាឌីជីថលរបស់វិញ្ញាតធរហត្ថលេខាឌីជីថល ដើម្បីធានាសុវត្ថិភាពនិងប្រសិទ្ធភាពនៃវិញ្ញាតកម្មហត្ថលេខាឌីជីថលនិងការប្រើប្រាស់ហត្ថលេខាឌីជីថលស្របទៅនឹងបទប្បញ្ញត្តិពាក់ព័ន្ធនឹងស្តង់ដានិងគោលការណ៍បច្ចេកទេស ដែលបានកំណត់ដោយ **ក.ប.ទ.**។

**សារអេឡិកត្រូនិក** សំដៅដល់ព័ត៌មានដែលត្រូវបានបង្កើតឡើង បញ្ជូន ទទួល ឬរក្សាទុកក្នុងទម្រង់ជាអេឡិក-ត្រូនិកនៅក្នុងប្រព័ន្ធកុំព្យូទ័រ។

**ហត្ថលេខាឌីជីថល** សំដៅដល់ទិន្នន័យដែលភ្ជាប់នឹងសារអេឡិកត្រូនិក ដើម្បីបញ្ជាក់អត្តសញ្ញាណនៃហត្ថលេខីឌីជីថលនិងផ្ទៀងផ្ទាត់ស្ថានភាពដើមនៃសារអេឡិកត្រូនិក ដែលហត្ថលេខីឌីជីថលបានចុះហត្ថលេខា។

**ហេដ្ឋារចនាសម្ព័ន្ធគន្លឹះសាធារណៈ** សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធមួយដែលមានយន្តការនិងគ្រឿងសម្ភារៈបរិក្ខារបច្ចេកទេស បុគ្គលិក គោលនយោបាយ និងនីតិវិធីក្នុងការធានានូវសន្តិសុខនិងសុវត្ថិភាពសម្រាប់ការគ្រប់គ្រងនិងការប្រើប្រាស់ហត្ថលេខាឌីជីថល។

**អាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល** សំដៅដល់អាជ្ញាបណ្ណដែលចេញដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដើម្បីផ្តល់នីតិសម្បទាឱ្យនីតិបុគ្គលណាមួយជាវិញ្ញាតធរហត្ថលេខាឌីជីថល។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

### មាត្រា៥ .-

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (**ក.ប.ទ.**) ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងលើហត្ថលេខាឌីជីថល និងផ្តល់វិញ្ញាបនបត្រហត្ថលេខាឌីជីថលដល់ក្រសួង ស្ថាប័ន និងអាជ្ញាធរថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (**អ.ប.គ.ព.**) ជាសេនាធិការរបស់ **ក.ប.ទ.** ក្នុងការគ្រប់គ្រង ការផ្តល់ ការត្រួតពិនិត្យ និងការតាមដានការអនុវត្តអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល ស្របតាមអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

### មាត្រា៦ .-

**ក.ប.ទ.** ត្រូវកំណត់ស្តង់ដានិងគោលការណ៍បច្ចេកទេសដើម្បីលើកកម្ពស់សុវត្ថិភាពនិងប្រសិទ្ធភាពនៃការគ្រប់គ្រងនិងការប្រើប្រាស់ហត្ថលេខាឌីជីថល ជាអាទិ៍៖

ក- ស្តង់ដានិងនិម្មាបនកម្មហេដ្ឋារចនាសម្ព័ន្ធគន្លឹះសាធារណៈ

ខ- គោលការណ៍ណែនាំអំពីការស្ថាបនានិងការដំឡើងហេដ្ឋារចនាសម្ព័ន្ធគន្លឹះសាធារណៈ និងការប្រើប្រាស់ហត្ថលេខាឌីជីថល។

**មាត្រា៧ .-**

**អ.ប.គ.ព.** ត្រូវបង្កើតនិងរក្សាបញ្ជីអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល ដោយចុះបញ្ជាក់នូវព័ត៌មានជាក់លាក់មួយចំនួន ជាអាទិ៍ អត្តសញ្ញាណនៃវិញ្ញាតធរហត្ថលេខាឌីជីថល កាលបរិច្ឆេទនៃអាជ្ញាបណ្ណ លក្ខខណ្ឌបច្ចេកទេសនៃហត្ថលេខាឌីជីថល និងការទទួលបានសិទ្ធិធ្វើអាជីវកម្ម ព្រមទាំងបញ្ជីឧបសម្ព័ន្ធ។

**មាត្រា៨ .-**

**អ.ប.គ.ព.** ត្រូវផ្សាយជាសាធារណៈនូវឈ្មោះវិញ្ញាតធរហត្ថលេខាឌីជីថលទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងឈ្មោះវិញ្ញាតធរហត្ថលេខាឌីជីថលបរទេសដែលត្រូវបានទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៣
## គោលការណ៍នៃហត្ថលេខាឌីជីថល

**មាត្រា៩ .-**

ដើម្បីចាត់ទុកជាហត្ថលេខាឌីជីថលត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

ក- បញ្ជាក់អត្តសញ្ញាណរបស់ហត្ថលេខីឌីជីថលដោយត្រឹមត្រូវនិងជាក់លាក់

ខ- បញ្ជាក់អំពីស្ថានភាពដើមនៃសារអេឡិចត្រូនិក

គ- បញ្ជាក់អំពីពេលវេលានិងកាលបរិច្ឆេទនៃការចុះហត្ថលេខាឌីជីថល

ឃ- ចំណុចផ្សេងទៀតដែលកំណត់ដោយ **ក.ប.ឌ.**។

**មាត្រា១០ .-**

សារអេឡិចត្រូនិកដែលមានភ្ជាប់ហត្ថលេខាឌីជីថលបញ្ជាក់ដោយវិញ្ញាតធរហត្ថលេខាឌីជីថល មានតម្លៃគតិយុត្តស្មើនឹងលិខិតលាយលក្ខណ៍អក្សរ។

**មាត្រា១១ .-**

រាល់ប្រតិបត្តិការហិរញ្ញវត្ថុតាមប្រព័ន្ធអនឡាញទាំងអស់ ត្រូវប្រើប្រាស់ហត្ថលេខាឌីជីថលស្របតាមអនុក្រឹត្យនេះ លើកលែងមានការកំណត់ផ្សេងដោយប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងធនាគារជាតិនៃកម្ពុជា។

**មាត្រា១២ .-**

ត្រូវបានហាមឃាត់ដាច់ខាតចំពោះការផ្សព្វផ្សាយគន្លឹះបង្កើតហត្ថលេខាឌីជីថលរបស់អ្នកដទៃ។

ត្រូវបានហាមឃាត់ចំពោះការរក្សាទុកឬការប្រើប្រាស់នូវគន្លឹះបង្កើតហត្ថលេខាឌីជីថលរបស់អ្នកដទៃ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីកម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល។

**មាត្រា១៣ .-**

វិញ្ញាបនបត្រហត្ថលេខាឌីជីថលដែលចេញដោយវិញ្ញាតធរហត្ថលេខាឌីជីថលបរទេស ត្រូវបានទទួលស្គាល់ស្របតាមលក្ខខណ្ឌនៃអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ក្នុងករណីដូចខាងក្រោម៖

ក- តាមការយល់ព្រមរបស់ **ក.ប.ឌ.** ឬ

ខ- តាមកិច្ចព្រមព្រៀងអន្តរជាតិទទួលស្គាល់គ្នាទៅវិញទៅមកជាមួយព្រះរាជាណាចក្រកម្ពុជា។

# ជំពូកទី៤
# អាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល
## ផ្នែកទី១
## ការផ្តល់អាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល

**មាត្រា១៤ ._**

គ្មានបុគ្គលណាអាចតាំងខ្លួនជាវិញ្ញាតធរហត្ថលេខាឌីជីថលបានទេ លុះត្រាតែបុគ្គលនោះបានទទួលអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថលពី **អ.ប.គ.ព.** ក្រោយពីទទួលបានការឯកភាពពីរដ្ឋមន្ត្រី **ក.ប.ទ.** ស្របតាមការកំណត់ក្នុងអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**មាត្រា១៥ ._**

បុគ្គលដែលមានបំណងស្នើសុំអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល ត្រូវមានជំនាញបច្ចេកទេស ធនធានហិរញ្ញវត្ថុ ប្រាក់តម្កល់ធានាអាជីវកម្ម គ្រឿងសម្ភារៈបរិក្ខារបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងគុណវុឌ្ឍិផ្សេងទៀតស្របតាមការកំណត់ដោយប្រកាសរបស់ **ក.ប.ទ.**។

**មាត្រា១៦ ._**

អាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថលមានរយៈពេល ១០ (ដប់) ឆ្នាំ គិតចាប់ពីថ្ងៃចេញអាជ្ញាបណ្ណ។

រយៈពេលនេះអាចត្រូវបានបន្តសាជាថ្មីតាមការសម្រេចរបស់ **អ.ប.គ.ព.** ក្រោយពីទទួលបានការឯកភាពពីរដ្ឋមន្ត្រី **ក.ប.ទ.**។

**មាត្រា១៧ ._**

បុគ្គលដែលមានបំណងស្នើសុំអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល ត្រូវដាក់ពាក្យស្នើសុំមក **អ.ប.គ.ព.**។

លក្ខខណ្ឌនិងនីតិវិធីនៃការស្នើសុំនិងការស្នើសុំបន្តអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថលត្រូវកំណត់ដោយប្រកាសរបស់ **ក.ប.ទ.**។

## ផ្នែកទី២
## ការផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ឬការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការបញ្ឈប់វិញ្ញាតកម្មហត្ថលេខាឌីជីថល

**មាត្រា១៨ ._**

ការផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការបញ្ឈប់វិញ្ញាតកម្មហត្ថលេខាឌីជីថល ត្រូវគោរពតាមការកំណត់ក្នុងអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**មាត្រា១៩ ._**

ក្នុងករណីវិញ្ញាតធរហត្ថលេខាឌីជីថល មានបំណងចង់បញ្ឈប់វិញ្ញាតកម្មហត្ថលេខាឌីជីថល បុគ្គលនោះត្រូវ៖

ក- ជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ **អ.ប.គ.ព.** យ៉ាងតិច ០៣ (បី) ខែ មុនថ្ងៃបញ្ឈប់ ដោយបញ្ជាក់អំពីមូលហេតុនៃការបញ្ឈប់ និងចុះហត្ថលេខាដោយវិញ្ញាតធរហត្ថលេខាឌីជីថល

ខ- ជូនដំណឹងជាមុនដល់អ្នកប្រើប្រាស់សេវារបស់ខ្លួនយ៉ាងតិច ០៣ (បី) ខែ មុនថ្ងៃបញ្ឈប់

គ- ផ្ទេរវិញ្ញាបនបត្រហត្ថលេខាឌីជីថល និងកំណត់ត្រាវិញ្ញាបនបត្រហត្ថលេខាឌីជីថលទាំងអស់ដែលបានចេញទៅវិញ្ញាតធរហត្ថលេខាឌីជីថលផ្សេងមួយទៀត។

**ក.ប.ឆ.** ត្រូវកំណត់អំពីនីតិវិធីនៃការជូនដំណឹងអំពីការបញ្ឈប់វិញ្ញាតកម្មហត្ថលេខាឌីជីថល។

**មាត្រា២០.-**

ការផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការបញ្ឈប់វិញ្ញាតកម្មហត្ថលេខាឌីជីថលត្រូវមានការយល់ព្រមជាមុនពី **អ.ប.គ.ព.** ស្របតាមការកំណត់របស់ **ក.ប.ឆ.** ។

លក្ខខណ្ឌនិងនីតិវិធីនៃការផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការបញ្ឈប់វិញ្ញាតកម្មហត្ថលេខាឌីជីថលត្រូវកំណត់ដោយប្រកាសរបស់ **ក.ប.ឆ.**។

## ផ្នែកទី៣
## ការដកហូតអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល

**មាត្រា២១.-**

អាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថលត្រូវបានដកហូតក្នុងករណីណាមួយដូចខាងក្រោម៖

ក- វិញ្ញាតធរហត្ថលេខាឌីជីថលត្រូវបានផ្តន្ទាទោសព្រហ្មទណ្ឌ

ខ- វិញ្ញាតធរហត្ថលេខាឌីជីថលត្រូវបានជម្រះបញ្ជីឬរំលាយក្រុមហ៊ុន

គ- វិញ្ញាតធរហត្ថលេខាឌីជីថលបានក្លែងបន្លំវិញ្ញាបនបត្រហត្ថលេខាឌីជីថល

ឃ- សកម្មភាពរបស់វិញ្ញាតធរហត្ថលេខាឌីជីថលគំរាមដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខ ឬការពារជាតិ

ង- ការផ្តល់ព័ត៌មានឬឯកសារក្លែងដោយវិញ្ញាតធរហត្ថលេខាឌីជីថលដល់ **អ.ប.គ.ព.**

ច- ការផ្ទេរកិច្ចសន្យា សន្តតិកម្ម ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការបញ្ឈប់វិញ្ញាតកម្មហត្ថលេខាឌីជីថលដោយពុំគោរពតាមលក្ខខណ្ឌនិងនីតិវិធីដូចមានចែងក្នុងអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត

ឆ- ករណីផ្សេងទៀតដែលកំណត់ដោយ **ក.ប.ឆ.**។

សេចក្តីសម្រេចស្តីពីការដកហូតអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថលត្រូវផ្សាយជាសាធារណៈ។

នីតិវិធីនៃការដកហូតអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថលត្រូវកំណត់ដោយប្រកាសរបស់ **ក.ប.ឆ.**។

**មាត្រា២២.-**

ក្នុងករណីអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថលត្រូវបានដកហូត វិញ្ញាតធរហត្ថលេខាឌីជីថលត្រូវជូនដំណឹងដល់កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល និងត្រូវផ្ទេរវិញ្ញាបនបត្រហត្ថលេខាឌីជីថលទៅវិញ្ញាតធរហត្ថលេខាឌីជីថលផ្សេងទៀត ស្របតាមការកំណត់ដោយប្រកាសរបស់ **ក.ប.ឆ.**។

**ក.ប.ឆ.** ត្រូវកំណត់អំពីលក្ខខណ្ឌនិងនីតិវិធីក្នុងការផ្ទេរវិញ្ញាបនបត្រហត្ថលេខាឌីជីថល ក្នុងករណីអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថលត្រូវបានដកហូត។

## ផ្នែកទី៤
## កម្រៃអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល

**មាត្រា២៣ .–**

អ្នកស្នើសុំអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល ឬវិញ្ញាតធរហត្ថលេខាឌីជីថល ត្រូវបង់កម្រៃនៃការស្នើសុំកម្រៃអាជ្ញាបណ្ណ កម្រៃនៃការស្នើសុំបន្ត កម្រៃនៃការផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ឬការរំលាយក្រុមហ៊ុនបញ្ចូលគ្នាពាក់ព័ន្ធនឹងអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល និងកម្រៃផ្សេងទៀត ស្របតាមការកំណត់ដោយប្រកាសរួមរវាង **អ.ប.ទ.** និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៥
## វិញ្ញាបនបត្រហត្ថលេខាឌីជីថល

**មាត្រា២៤ .–**

វិញ្ញាតធរហត្ថលេខាឌីជីថលត្រូវរៀបចំវិធានរួមស្តីពីវិញ្ញាតកម្មហត្ថលេខាឌីជីថល ស្របតាមស្តង់ដានិងគោល-ការណ៍បច្ចេកទេសស្តីពីហត្ថលេខាឌីជីថល ដែលកំណត់ដោយប្រកាសរបស់ **អ.ប.ទ.**។

**មាត្រា២៥ .–**

វិញ្ញាតធរហត្ថលេខាឌីជីថលត្រូវផ្តល់វិញ្ញាបនបត្រហត្ថលេខាឌីជីថលដល់បុគ្គលស្នើសុំ បន្ទាប់ពីបានបំពេញតាមលក្ខខណ្ឌ ដែលត្រូវបានកំណត់ដោយអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

វិញ្ញាតធរហត្ថលេខាឌីជីថលអាចផ្អាក ឬបញ្ឈប់ការប្រើប្រាស់វិញ្ញាបនបត្រហត្ថលេខាឌីជីថល ស្របតាមការកំណត់ក្នុងអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**អ.ប.ទ.** ត្រូវកំណត់អំពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការផ្អាក និងការបញ្ឈប់ការប្រើប្រាស់វិញ្ញាបនបត្រហត្ថលេខាឌីជីថល។

**មាត្រា២៦ .–**

វិញ្ញាបនបត្រហត្ថលេខាឌីជីថលត្រូវកំណត់និទ្ទេសដូចខាងក្រោម៖

ក- អត្តសញ្ញាណរបស់កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល

ខ- គន្លឹះផ្ទៀងផ្ទាត់ហត្ថលេខាឌីជីថលរបស់កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល

គ- ការពិពណ៌នាអំពីវិធីដែលប្រើប្រាស់ដើម្បីចុះហត្ថលេខាឌីជីថលលើវិញ្ញាបនបត្រហត្ថលេខាឌីជីថល

ឃ- លេខសម្គាល់វិញ្ញាបនបត្រហត្ថលេខាឌីជីថល

ង- រយៈពេលសុពលភាពនៃវិញ្ញាបនបត្រហត្ថលេខាឌីជីថល

ច- អត្តសញ្ញាណរបស់វិញ្ញាតធរហត្ថលេខាឌីជីថល

ឆ- វិសាលភាពនិងគោលបំណងនៃការប្រើប្រាស់វិញ្ញាបនបត្រហត្ថលេខាឌីជីថល

ជ- និទ្ទេសផ្សេងទៀតដែលកំណត់ដោយ **អ.ប.ទ.**។

## ជំពូកទី៦
## ភារកិច្ចរបស់វិញ្ញាតធរហត្ថលេខាឌីជីថលនិងកម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល

**មាត្រា២៧ ._**

វិញ្ញាតធរហត្ថលេខាឌីជីថលមានកាតព្វកិច្ចដូចខាងក្រោម៖

ក- ការពារនិងរក្សាសន្តិសុខសុវត្ថិភាពពាក់ព័ន្ធនឹងការចេញវិញ្ញាបនបត្រហត្ថលេខាឌីជីថល និងការប្រើប្រាស់ហត្ថលេខាឌីជីថលស្របតាមការកំណត់របស់ **ក.ប.ទ.** និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត

ខ- មិនត្រូវរក្សាទុកគន្លឹះបង្កើតហត្ថលេខាឌីជីថលរបស់កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល លើកលែងតែមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរ

គ- មិនត្រូវប្រើប្រាស់ឬផ្សព្វផ្សាយគន្លឹះបង្កើតហត្ថលេខាឌីជីថលរបស់កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល

ឃ- រក្សាការសម្ងាត់ព័ត៌មានឯកជនរបស់កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល

ង- រក្សាទុកគន្លឹះបង្កើតហត្ថលេខាឌីជីថលដោយសម្ងាត់និងមានសុវត្ថិភាព

ច- រក្សាទុកនិងគ្រប់គ្រងកំណត់ត្រានៃការចេញវិញ្ញាបនបត្រហត្ថលេខាឌីជីថលប្រកបដោយសុវត្ថិភាពក្នុងរយៈពេល ១០ ឆ្នាំ បន្ទាប់ពីផុតសុពលភាពនៃវិញ្ញាបនបត្រហត្ថលេខាឌីជីថល

ឆ- រាយការណ៍ភ្លាមទៅ **អ.ប.គ.ព.** ក្នុងករណីមានការអោក់អួលនៃប្រព័ន្ធដំណើរការទិន្នន័យ ឬឧបករណ៍វិធីសាស្ត្រ និងប្រព័ន្ធវិញ្ញាតកម្ម ក្នុងរយៈពេល ២៤ (ម្ភៃបួន) ម៉ោង

ជ- ផ្តល់ជូនកម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល នូវឧបករណ៍ ឬមធ្យោបាយដែលអនុញ្ញាតឱ្យជូនដំណឹងអំពីការលួច ការបាត់បង់ ឬការលាតត្រដាងនូវគន្លឹះបង្កើតហត្ថលេខាឌីជីថល

ឈ- ផ្តល់របាយការណ៍ហិរញ្ញវត្ថុ និងព័ត៌មានមិនមែនហិរញ្ញវត្ថុជាប្រចាំ ឬតាមការស្នើសុំរបស់ **អ.ប.គ.ព.**

ញ- កាតព្វកិច្ចទាំងឡាយដែលត្រូវបានកំណត់ដោយអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**មាត្រា២៨ ._**

កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថលមានកាតព្វកិច្ចដូចខាងក្រោម៖

ក- រក្សាទុកគន្លឹះបង្កើតហត្ថលេខាឌីជីថលដោយសម្ងាត់និងមានសុវត្ថិភាព

ខ- ជូនដំណឹងទៅវិញ្ញាតធរហត្ថលេខាឌីជីថលជាបន្ទាន់និងទៅអ្នកទទួលទិន្នន័យដែលត្រូវបានផ្ញើនៅពេលដែលគន្លឹះបង្កើតហត្ថលេខាឌីជីថល ត្រូវបានលួច បាត់បង់ ឬលាតត្រដាង

គ- កាតព្វកិច្ចទាំងឡាយដែលត្រូវបានកំណត់ដោយអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

## ជំពូកទី៧
## ការដោះស្រាយវិវាទ

**មាត្រា២៩ ._**

ក្រៅពីករណីបទល្មើសព្រហ្មទណ្ឌ គ្រប់វិវាទដែលពាក់ព័ន្ធនឹងវិញ្ញាតធរហត្ថលេខាឌីជីថល ជាអាទិ៍ វិវាទរវាងវិញ្ញាតធរហត្ថលេខាឌីជីថលនិងវិញ្ញាតធរហត្ថលេខាឌីជីថល និងរវាងវិញ្ញាតធរហត្ថលេខាឌីជីថលនិងកម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល ភាគីវិវាទអាចដាក់សំណុំរឿងទៅ **ក.ប.ទ.** ដើម្បីធ្វើការផ្សះផ្សា។

លក្ខខណ្ឌនិងនីតិវិធីនៃការផ្សះផ្សាត្រូវកំណត់ដោយប្រកាសរបស់ **ក.ប.ទ.**។ កម្រៃសេវាសម្រាប់ដោះស្រាយវិវាទត្រូវកំណត់ដោយប្រកាសរួមរវាង **ក.ប.ទ.** និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៨
## ទោសប្បញ្ញត្តិ

**មាត្រា៣០ .-**

ក្រោយពេលផ្តល់អាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល ប្រសិនបើពិនិត្យឃើញថាវិញ្ញាតធរហត្ថលេខាឌីជីថល មិនអនុវត្តតាមលក្ខខណ្ឌណាមួយនៃអាជ្ញាបណ្ណ ឬលក្ខខណ្ឌណាមួយដែលកំណត់ដោយអនុក្រឹត្យនេះ ឬបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត **គ.ប.ឌ.** អាចចាត់វិធានការជាអាទិ៍ ដូចខាងក្រោម៖

ក- ដឹកនាំកែតម្រង់វិញ្ញាតធរហត្ថលេខាឌីជីថលឱ្យអនុវត្តតាមលក្ខខណ្ឌនិងលក្ខខណ្ឌបន្ថែម

ខ- ដាក់កំហិតលើអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល

គ- ព្យួរអាជ្ញាបណ្ណរហូតដល់វិញ្ញាតធរហត្ថលេខាឌីជីថលគោរពពេញលេញតាមលក្ខខណ្ឌ ឬលក្ខខណ្ឌបន្ថែម។

ក្នុងករណីវិញ្ញាតធរហត្ថលេខាឌីជីថលមិនអនុវត្តតាមវិធានការ ដែលបានដាក់ចេញដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ ឬបានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ឬបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត **គ.ប.ឌ.** អាចចាត់វិធានការជាអាទិ៍ ដូចខាងក្រោម៖

ក- ព្យួរបណ្តោះអាសន្ន ឬបញ្ឈប់ការងាររបស់អគ្គនាយក នាយកប្រតិបត្តិ សមាជិកគណៈគ្រប់គ្រង ឬបុគ្គលិកជាន់ខ្ពស់របស់វិញ្ញាតធរហត្ថលេខាឌីជីថល

ខ- ជ្រើសរើសនិងផ្តល់អំណាចដល់បុគ្គលដែលមានសមត្ថកិច្ចសមស្រប ដើម្បីពិនិត្យមើលសកម្មភាពអាជីវកម្ម ឬសកម្មភាពពាក់ព័ន្ធផ្សេងទៀតរបស់វិញ្ញាតធរហត្ថលេខាឌីជីថល។ បុគ្គលនោះត្រូវធ្វើរបាយការណ៍ជូន **គ.ប.ឌ.** តាមលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យាជាមួយ **គ.ប.ឌ.**

គ- ដាក់កំហិត ឬបញ្ឈប់សកម្មភាពជាក់លាក់ ឬទូទៅរបស់វិញ្ញាតធរហត្ថលេខាឌីជីថល ទោះបីជាសកម្មភាពទាំងនោះបានធ្វើឡើងស្រប ឬមិនស្របតាមលក្ខខណ្ឌនៃអាជ្ញាបណ្ណក៏ដោយ។

**គ.ប.ឌ.** អាចចាត់វិធានការដូចមានចែងក្នុងកថាខណ្ឌទី១ ឬកថាខណ្ឌទី២ លុះត្រាតែបានជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនដល់វិញ្ញាតធរហត្ថលេខាឌីជីថល អំពីមូលហេតុនៃការចាត់វិធានការនេះនិងផ្តល់ឱកាសឱ្យវិញ្ញាតធរហត្ថលេខាឌីជីថលពន្យល់។

**មាត្រា៣១ .-**

ត្រូវពិន័យអន្តរការណ៍ ចំពោះការធ្វើប្រតិបត្តិការដូចមានចែងក្នុងមាត្រា១៤ នៃអនុក្រឹត្យនេះ ដោយគ្មានអាជ្ញាបណ្ណពី **គ.ប.ឌ.** ដូចខាងក្រោម៖

- រូបវន្តបុគ្គល៖ ចំនួនទឹកប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅ ១៥ ០០០ ០០០ (ដប់ប្រាំលាន) រៀល។
- នីតិបុគ្គល៖ ចំនួនទឹកប្រាក់ពី ៥០ ០០០ ០០០ (ហាសិបលាន) រៀល ទៅ ១៥០ ០០០ ០០០ (មួយរយហាសិបលាន) រៀល។

**មាត្រា៣២ .-**

រាល់ការរក្សាទុកឬការប្រើប្រាស់នូវគន្លឹះបង្កើតហត្ថលេខាឌីជីថលរបស់អ្នកដទៃ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីកម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- រូបវន្តបុគ្គល៖ ចំនួនទឹកប្រាក់ពី ៣ ០០០ ០០០ (បីលាន) រៀល ទៅ ៩ ០០០ ០០០ (ប្រាំបួនលាន)រៀល។
- នីតិបុគ្គល៖ ចំនួនទឹកប្រាក់ពី ២៥ ០០០ ០០០ (ម្ភៃប្រាំលាន) រៀល ទៅ ៧៥ ០០០ ០០០ (ចិតសិបប្រាំលាន) រៀល។

**មាត្រា៣៣ .-**

ការផ្សព្វផ្សាយនូវគន្លឹះបង្កើតហត្ថលេខាឌីជីថល ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- រូបវន្តបុគ្គល៖ ចំនួនទឹកប្រាក់ពី ៣ ០០០ ០០០ (បីលាន) រៀល ទៅ ៩ ០០០ ០០០ (ប្រាំបួនលាន)រៀល។
- នីតិបុគ្គល៖ ចំនួនទឹកប្រាក់ពី ២៥ ០០០ ០០០ (ម្ភៃប្រាំលាន) រៀល ទៅ ៧៥ ០០០ ០០០ (ចិតសិបប្រាំលាន) រៀល។

**មាត្រា៣៤ .-**

វិញ្ញាតធរហត្ថលេខាឌីជីថលដែលបានផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ឬការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ដោយពុំមានការយល់ព្រមជាមុនពី **អ.គ.ប.ព.** ស្របតាមការកំណត់របស់ **ក.ប.ឌ.** ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ២០ ០០០ ០០០ (ម្ភៃលាន) រៀល ទៅ ៦០ ០០០ ០០០ (ហុកសិបលាន) រៀល។

**មាត្រា៣៥ .-**

រាល់វិញ្ញាតធរហត្ថលេខាឌីជីថលដែលមិនអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងមាត្រា២៧ ចំណុច (ឈ) នៃអនុក្រឹត្យនេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ៣០ ០០០ ០០០ (សាមសិបលាន) រៀល។

**មាត្រា៣៦ .-**

រាល់ការរារាំង មិនសហការ ឬការបង្កជាឧបសគ្គដល់ការចុះត្រួតពិនិត្យការអនុវត្តអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល របស់មន្ត្រីដែលបានចាត់តាំងដោយ **ក.ប.ឌ.** ឬស្ថាប័នមានសមត្ថកិច្ចត្រូវពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- រូបវន្តបុគ្គល៖ ចំនួនទឹកប្រាក់ពី ៣ ០០០ ០០០ (បីលាន) រៀល ទៅ ៩ ០០០ ០០០ (ប្រាំបួនលាន)រៀល។
- នីតិបុគ្គល៖ ចំនួនទឹកប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀលទៅ៣០ ០០០ ០០០ (សាមសិបលាន) រៀល។

**មាត្រា៣៧ .-**

រាល់វិញ្ញាតធរហត្ថលេខាឌីជីថលដែលមិនចេញវិញ្ញាបនបត្រហត្ថលេខាឌីជីថល ឬយឺតយ៉ាវក្នុងការចេញវិញ្ញាបនបត្រហត្ថលេខាឌីជីថល ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ៣ ០០០ ០០០ (បីលាន) រៀល ទៅ ៩ ០០០ ០០០ (ប្រាំបួនលាន) រៀល។

**មាត្រា៣៨ .-**

ការដាក់ពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់ **ក.ប.ឌ.**។

**មាត្រា៣៩ .-**

បុគ្គលដែលបានប្រព្រឹត្តបទល្មើសដូចដែលមានចែងក្នុងមាត្រា៣១ មាត្រា៣២ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ និងមាត្រា៣៧ នៃអនុក្រឹត្យនេះ ត្រូវបង់ប្រាក់ពិន័យអន្តរការណ៍ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេចពិន័យ។

ក្នុងករណីជនល្មើសមិនបានបង់ប្រាក់ពិន័យអន្តរការណ៍តាមការកំណត់ដូចកថាខណ្ឌទី១ ខាងលើ **ក.ប.ឌ.** ត្រូវរៀបចំសំណុំឯកសារបញ្ជូនទៅអយ្យការអមសាលាដំបូង។

ទម្រង់បែបបទនៃការពិន័យនិងការគ្រប់គ្រងប្រាក់ ដែលបានមកពីការពិន័យត្រូវកំណត់ដោយប្រកាសរួមរវាង **ក.ប.ឌ.** និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា៤០ .—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤១ .—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១២កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**ត្រាំ អ៊ីវតឹក**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឯកសារជំនួយស្មារតី៖

# ការវាយតំលៃភាពត្រៀមខ្លួន
# រួចរាល់សំរាប់ពាណិជ្ជកម្មឆ្លងកាត់
# ព្រំដែនដោយមិនបាច់ប្រើ
# ក្រដាសស្នាម៖ ប្រទេសកម្ពុជា

## IV. ភាពត្រៀមខ្លួនរួចរាល់ផ្នែកច្បាប់សំរាប់ពាណិជ្ជកម្មឆ្លងកាត់ព្រំដែនដោយមិនបាច់ប្រើក្រដាសស្នាម: ចំណុចគំហើញគន្លឹះ

ចំណុចគំហើញគន្លឹះស្តីពីភាពត្រៀមខ្លួនរួចរាល់ផ្នែកច្បាប់របស់កម្ពុជា សំរាប់ពាណិជ្ជកម្មឆ្លងកាត់ព្រំដែនដោយមិនបាច់ប្រើក្រដាសស្នាម ត្រូវបានសង្ខេបនៅខាងក្រោម។ ចំណុចគំហើញ ត្រូវបានបង្ហាញតាមរយៈតារាងបញ្ជីវាយតំលៃភាពត្រៀមខ្លួនរួចរាល់ផ្នែកច្បាប់ ដែលអនុម័តឱ្យប្រើដោយក្រុមអន្តររដ្ឋាភិបាលបណ្តោះអាសន្នដឹកនាំការសម្រួលពាណិជ្ជកម្មឆ្លងកាត់ព្រំដែនដោយមិនបាច់ប្រើក្រដាសស្នាម នៅក្នុងកិច្ចប្រជុំលើកទី5 របស់ខ្លួន។ តារាងបញ្ជីវាយតំលៃដែលបានបំពេញ ដែលមានព័ត៌មាននិងការពន្យល់លម្អិតថែមទៀត មាននៅក្នុងឧបសម្ព័ន្ធទី V។

គេអាចកត់សម្គាល់ថាកម្ពុជាមានវិធានគតិយុត្តិតិចតួចណាស់ដែលពាក់ព័ន្ធនឹងពាណិជ្ជកម្មឆ្លងកាត់ព្រំដែនដោយមិនបាច់ប្រើក្រដាសស្នាម។ ករណីលើកលែងរួមមាន មាត្រាមួយចំនួនរបស់អនុសញ្ញាអន្តរជាតិខ្លះ ដែលកម្ពុជាគឺជាភាគីមួយ, ជាពិសេស តាមរយៈអង្គការពាណិជ្ជកម្មពិភពលោក (WTO) និង អង្គការគយពិភពលោក (WCO) និងតាមរយៈគំនិតផ្តួចផ្តើមប្រព័ន្ធបញ្ជរតែមួយអាស៊ាន (ASW)។ កម្ពុជាក៏មានវិធានច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុកស្តួចស្តើងផងដែរទាក់ទិននឹងប្រតិបត្តិការអេឡិចត្រូនិក។ បទបញ្ញត្តិសំខាន់បំផុតដែលមានជាធរមាន នៅពេលនេះ គឺអនុក្រឹត្យស្តីពីហត្ថលេខាឌីជីថល (2017)។ បន្ថែមលើអនុក្រឹត្យនេះ ច្បាប់ស្តីពីគយ (2007), ប្រកាសមួយចំនួន និងវិធានផ្សេងទៀតត្រូវបានចេញ, ដែលដោះស្រាយទិដ្ឋភាពពាណិជ្ជកម្មអេឡិចត្រូនិកក្នុងស្រុក និង ប្រតិបត្តិការប្រព័ន្ធអេឡិចត្រូនិកគយ។

ទោះជាយ៉ាងណាក្តី កម្ពុជាបាននិងកំពុងមានសកម្មភាពជាងមួយទសវត្សរ៍មកហើយ ក្នុងការតាក់តែងច្បាប់ជាតិរបស់ខ្លួនស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលបានឈានដល់ការអនុម័តច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករបស់កម្ពុជានាពេលថ្មីៗនេះ។ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា ត្រូវបានអនុម័តដោយរដ្ឋសភានៅថ្ងៃទី 8 ខែ តុលា ឆ្នាំ 2019 យល់ព្រមដោយព្រឹទ្ធសភាកម្ពុជានៅថ្ងៃទី 18 ខែ តុលា ឆ្នាំ 2019 ត្រូវបានឡាយព្រហស្តលេខាទៅជាច្បាប់ដោយព្រះមហាក្សត្រកម្ពុជានៅថ្ងៃទី 2 ខែ វិច្ឆិកា ឆ្នាំ 2019។ ច្បាប់នេះនឹងចូលជាធរមានក្នុងរយៈពេលប្រាំមួយខែ ក្រោយពេល "ផ្សព្វផ្សាយ"។ ក្នុងរបាយការណ៍នេះ យើងពិនិត្យមើលសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (ដែលនៅក្នុងឯកសារនេះ ហៅថាសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក 2019), វាជាសេចក្តីព្រាងច្បាប់ចុងក្រោយនៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា ដែលត្រូវបានផ្តល់ជូនអង្គការ UN-ESCAP ដោយក្រសួងពាណិជ្ជកម្ម រួមជាមួយច្បាប់ក្នុងស្រុកពាក់ព័ន្ធផ្សេងទៀត។

ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា គឺជាច្បាប់ជឿនលឿនទំនើបមួយ ដែលត្រូវបានគេសង្ឃឹមថានឹងបង្កើតបរិស្ថានគតិយុត្តពេញលេញថ្មីមួយសំរាប់ប្រតិបត្តិការអេឡិចត្រូនិក និង ពាណិជ្ជកម្មមិនបាច់ប្រើក្រដាសស្នាមនៅកម្ពុជា។ កម្ពុជាក៏កំពុងសម្រេចបានវឌ្ឍនភាពច្រើនផងដែរក្នុងការអនុវត្តដំបូងនៃប្រព័ន្ធបញ្ជរតែមួយជាតិ (NSW) របស់ខ្លួន និងការសាងសង់ប្រព័ន្ធជាតិទូទាត់តាមអេឡិចត្រូនិក។ វឌ្ឍនាការដ៏សំខាន់ៗទាំងនេះ ជាអាទិ៍ នឹងបង្កើតលក្ខខ័ណ្ឌអំណោយផលសំរាប់ពាណិជ្ជកម្មអន្តរជាតិ និង ការឈានទៅកាន់ប្រតិបត្តិការនិង នីតិវិធីពាណិជ្ជកម្មមិនបាច់ប្រើក្រដាសស្នាមនៅកម្ពុជា ។

### A. ប្រតិបត្តិការអេឡិចត្រូនិក និងច្បាប់ស្តីពីហត្ថលេខាអេឡិចត្រូនិក

#### ប្រតិបត្តិការអេឡិចត្រូនិក

ប្រព័ន្ធគតិយុត្តសំរាប់ប្រតិបត្តិការនិងហត្ថលេខាអេឡិចត្រូនិកនៅកម្ពុជា បច្ចុប្បន្ននេះ កំពុងស្ថិតក្រោមការកសាង ។ របបគតិយុត្តថ្មីថ្មោងនេះ នឹងត្រូវបានជំរុញប្រកបដោយនិន្តរភាពយ៉ាងច្រើន ជាមួយការចូលជាធរមាននៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា, 6ខែក្រោយពេលអនុម័តនៅថ្ងៃទី 2 ខែ វិច្ឆិកា ឆ្នាំ 2019 ។

បច្ចុប្បន្ន, អនុក្រឹត្យស្តីពីហត្ថលេខាឌីជីថល (2017)[12] នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (ក.ប.ទ.) គឺជាបទបញ្ញត្តិដ៏សំខាន់បំផុតដែលពាក់ព័ន្ធនឹងទំនាក់ទំនងអេឡិចត្រូនិកនៅកម្ពុជា។ ប៉ុន្តែ ច្បាប់នេះមានវិសាលភាពមានកម្រិត។ ទោះជាយ៉ាងណាក៏ដោយ អនុក្រឹត្យនេះដែលបច្ចុប្បន្នត្រូវអនុវត្តចំពោះរាល់ប្រតិបត្តិការដែលទាក់ទិននឹងហត្ថលេខាឌីជីថលនៅកម្ពុជា [13] ទទួលស្គាល់សមមូលមុខងារនៃទំនាក់ទំនងអេឡិចត្រូនិកជាមួយហត្ថលេខាឌីជីថល ដែលមានការបញ្ជាក់ ទៅនឹងឯកសារជាក្រដាសស្នាម។[14]

សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (សេចក្តីព្រាងចុះថ្ងៃទី 3 ខែ មេសា ឆ្នាំ 2019) (ដែលនៅក្នុងឯកសាររបាយការណ៍ខាងក្រោមនេះ ហៅថាសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក 2019) គឺជាមូលដ្ឋាន, សំរាប់ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជាដែលមិនទាន់អនុម័ត, ផ្តល់ចំណុចលម្អិតច្រើនជាង ពាក់ព័ន្ធនឹងច្បាប់ស្តីពីប្រតិបត្តិការ និង ហត្ថលេខាអេឡិចត្រូនិក។ នៅក្នុងសេចក្តីព្រាងច្បាប់នេះ សមមូលមុខងារនៃកំណត់ត្រា/ឯកសារអេឡិចត្រូនិក និងហត្ថលេខាឌីជីថល ទៅនឹងកំណត់ត្រា/ឯកសារជាក្រដាសស្នាម និង ហត្ថលេខាជាលាយលក្ខណ៍អក្សរ ត្រូវបានទទួលស្គាល់យ៉ាងច្បាស់ និងយ៉ាងជាច់ណាត់។[15]

ប៉ុន្តែ ភាពមិនស៊ីសង្វាក់គ្នាមួយចំនួនពាក់ព័ន្ធនឹងសមមូលមុខងារ ឃើញមាននៅក្នុងបទប្បញ្ញត្តិផ្សេងទៀត។ ជាពិសេស, សមមូលមុខងារ នៃ កំណត់ត្រាអេឡិចត្រូនិក (ឧ. ក្នុងទម្រង់នៃប្រតិវេទន៍គយអេឡិចត្រូនិក) មិនត្រូវបានទទួលស្គាល់ច្បាស់លាស់ដោយច្បាប់ស្តីពីគយ (2007) និងបទប្បញ្ញត្តិគយពាក់ព័ន្ធទេ។[16] លើសពីនោះទៀត, បទប្បញ្ញត្តិគយកម្ពុជា បន្ថយអានុភាពនៃហត្ថលេខាឌីជីថលឬអេឡិចត្រូនិក និង ប្រើជំនួសវិញនូវប្រព័ន្ធបញ្ជាក់ និង ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណផ្សេងៈ គឺអ្នកប្រើប្រាស់ដែលបានចុះបញ្ជី (ដូចជា, ឈ្មោះអ្នកប្រើប្រាស់/លេខសម្ងាត់)។ ជាលទ្ធផល, បទប្បញ្ញត្តិនិងការអនុវត្តបច្ចុប្បន្ននៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករ ហាក់បីដូចជាកាត់បន្ថយសមមូលមុខងារនៃហត្ថលេខាឌីជីថល ឬ ហត្ថលេខាអេឡិចត្រូនិក។ វាហាក់ដូចជាមិនប្រាកដ, ថាតើនៅដំណាក់កាលនេះ ហត្ថលេខាឌីជីថល (ឬ ហត្ថលេខាអេឡិចត្រូនិក) ដំណើរការកំរិតប៉ុណ្ណានៅក្នុងបរិស្ថានប្រព័ន្ធបញ្ជរតែមួយជាតិ (NSW) កម្ពុជា។[17]

អនុក្រឹត្យស្តីពីហត្ថលេខាឌីជីថល (2017) ចែងពីប្រព័ន្ធមួយនៃវិញ្ញាបនបត្រឌីជីថល និងហត្ថលេខាឌីជីថលដែលត្រូវបានប្រើដើម្បីបញ្ជាក់និងធានាឱ្យបាននូវទំនុកចិត្តលើការប្រើកំណត់ត្រាអេឡិចត្រូនិក។ អនុក្រឹត្យ និយាយយោងដល់ការបង្កើតប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធសាធារណៈសំខាន់ៗ (PKI) មួយសំរាប់គោលបំណងនេះ។[18] តាមអនុក្រឹត្យនេះ, វិញ្ញាតធរ/សមត្ថកិច្ចបញ្ជាក់វិញ្ញាបនបត្រ (CAs) នឹងត្រូវបានអនុវិញ្ញាតឱ្យចេញវិញ្ញាបនបត្របញ្ជាក់ហត្ថលេខាឌីជីថលជូនអ្នកជាវ ដែលប្រើសំរាប់ហត្ថលេខាឌីជីថលនៅកម្ពុជា។[19] ក្នុងករណីដែលកម្ពុជាពឹងផ្អែកទាំងស្រុងលើប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធសាធារណៈសំខាន់ៗ (PKI) មួយ ដែលគ្រប់គ្រងដោយរដ្ឋាភិបាលសំរាប់

[12] អនុក្រឹត្យស្តីពីហត្ថលេខាឌីជីថល (លេខ 246 ចុះថ្ងៃទី 29 ខែ ធ្នូ ឆ្នាំ 2017)

[13] មាត្រា 3, អនុក្រឹត្យស្តីពីហត្ថលេខាឌីជីថល (2017)

[14] មាត្រា 10, អនុក្រឹត្យស្តីពីហត្ថលេខាឌីជីថល (2017)

[15] មាត្រា 5 និង 6, សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡេចត្រូនិក (2019) ទទួលស្គាល់សមមូលមុខងារនៃទំនាក់ទំនងអេឡេចត្រូនិក និងកំណត់ត្រាអេឡេចត្រូនិក តាមលំដាប់រៀង, មាត្រា 7 ទទួលស្គាល់ដូចគ្នាចំពោះហត្ថលេខាអេឡេចត្រូនិក។ បទប្បញ្ញត្តិទាំងនេះ យកលំនាំតាមមាត្រា 5, 6 និង 7 នៃច្បាប់គម្រូស្តីពីពាណិជ្ជកម្មអេឡេចត្រូនិកនៃ UNCITRAL (1996)។

[16] សូមមើលមាត្រា 51, ច្បាប់ស្តីពីគយ (2007), សូមមើលផងដែរនូវប្រកាសលេខ 1447 (26 ធ្នូ 2007), ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ស្តីពីបទប្បញ្ញត្តិនិងនីតិវិធីស្តីពីប្រតិវេទន៍គយ, និង សេចក្តីណែនាំ លេខ 1308 អគ្គនាយកដ្ឋានគយ និងរដ្ឋាករ (24 វិច្ឆិកា 2009) ពីនីតិវិធីលំអិត និងភារកិច្ចទទួលខុសត្រូវ ក្នុងកិច្ចដំណើរការប្រតិវេទន៍គយ (ឯកសាររដ្ឋបាលតែមួយ) តាមមធ្យោបាយអេឡេចត្រូនិក។

[17] អគ្គនាយកដ្ឋានគយ និងរដ្ឋាករ បានបញ្ជាក់ថាខ្លួនទទួលស្គាល់សារៈសំខាន់នៃហត្ថលេខាឌីជីថល/អេឡេចត្រូនិក ហើយចំពោះតែប្រតិវេទន៍គយអេឡិកត្រូនិកដែលដាក់ជូនតាមប្រព័ន្ធ ASYCUDA ប៉ុណ្ណោះ (ពោលគឺ ឯកសាររដ្ឋបាលតែមួយ) ដែលហត្ថលេខាប្រភេទនេះមិនកំពុងត្រូវបានគេប្រើ។

[18] មាត្រា 5, អនុក្រឹត្យស្តីពីហត្ថលេខាឌីជីថល (2017)

[19] ឯកសារដដែល។ ប៉ុន្តែ បច្ចុប្បន្ន ពុំមានវិញ្ញាតធរ/សមត្ថកិច្ចបញ្ជាក់វិញ្ញាបនបត្រ (CAs) នៅកម្ពុជាទេ។

ការចេញវិញ្ញាបនបត្រនិងហត្ថលេខាឌីជីថល, ប្រការនេះអាចប៉ះពាល់ដល់អព្យាក្រឹតភាពបច្ចេកវិទ្យា។

### ការរក្សាទុកទិន្នន័យ និង ការរក្សាទុកឯកសារអេឡិចត្រូនិក (ឯកសារ-កាលប្បវត្តិ អេឡិចត្រូនិក)

ការរក្សាទុកទិន្នន័យ ត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពីគយ (2007) ដែលចែងថាពាណិជ្ជករ និងស្ថាប័នរដ្ឋាភិបាលត្រូវតែរក្សាឯកសារ បញ្ជីកំណត់ត្រានិងព័ត៌មានផ្សេងទៀតឱ្យបានត្រឹមត្រូវ, រាប់បញ្ចូលទាំងព័ត៌មានជាប្រភេទអេឡិចត្រូនិក ដែលពាក់ព័ន្ធនឹងការនាំចេញ ឬ នាំចូលនោះ។[20] សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (2019) ក៏កំណត់ផងដែរនូវល័ក្ខខ័ណ្ឌតម្រូវមួយចំនួនទាក់ទិននឹងការរក្សាទុកទិន្នន័យ – ជាពិសេស, ព័ត៌មានដែលភ្ជាប់ជាទម្រង់ទំនាក់ទំនងអេឡិចត្រូនិក គួរត្រូវអាចចូលយកប្រើប្រាស់ជាការបាន នៅពេលអនាគត ។[21] គប្បីកត់សម្គាល់ថា កម្ពុជាបច្ចុប្បន្នកំពុងតាក់តែងច្បាប់មួយ ស្តីពីអភិបាលកិច្ចទិន្នន័យ ដែលនឹងរៀបបទ ប្បញ្ញត្តិ អំពីមជ្ឈមណ្ឌលទិន្នន័យនៅកម្ពុជា ក៏ដូចជា ល័ក្ខខ័ណ្ឌ និងរយៈពេល សំរាប់ការរក្សាទុកទិន្នន័យ។[22]

### ភស្តុតាងអេឡិចត្រូនិក

បច្ចុប្បន្ននេះ, ពុំមានច្បាប់ជាតិនៅកម្ពុជាដែលអនុញ្ញាតយ៉ាងច្បាស់លាស់នូវភាពអាចទទួលយកបាន នៃភស្តុតាងអេឡិចត្រូនិកនៅក្នុងតុលាការកម្ពុជា ឬ ក្នុងចំណាត់ការរដ្ឋបាល/និយ័តកម្មទេ។ ប៉ុន្តែ ការអនុវត្តរបស់តុលាការ គឺទទួលយកភស្តុតាងអេឡិចត្រូនិក តាមវិធីដូចគ្នានិងយោងតាមវិធានដូចគ្នា ដែលអនុវត្តលើប្រភេទឯកសារភស្តុតាងផ្សេងទៀត - យោងតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឬ ច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ។ នៅក្នុងចំណាត់ការព្រហ្មទណ្ឌ ភស្តុតាងអេឡិចត្រូនិកអាចទទួលយកបាន "ដោយភាពស្រដៀងគ្នា" ទៅនឹងមាត្រា 317 នៃច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ។

ក្រមព្រហ្មទណ្ឌ ទទួលស្គាល់បទល្មើសមួយចំនួនពាក់ព័ន្ធនឹងការជ្រៀតជ្រែកចូលទូរគមនាគមន៍ ដូចជាការលួចចូលប្រព័ន្ធ (cyber-hacking) ដែលមិនអាចបង្ហាញភស្តុតាងណាបាន ក្រៅតែពីការដាក់បង្ហាញភស្តុតាងជាប្រភេទអេឡិចត្រូនិកនោះ។ កម្ពុជាក៏កំពុងតាក់តែងច្បាប់មួយផងដែរស្តីពីប្រឆាំងបទឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ិនធឺណិត (Cybercrime law) ដែលនឹងផ្តល់បទប្បញ្ញត្តិបំពេញបន្ថែមទៀត ស្តីពីការទទួលយកភស្តុតាងអេឡិចត្រូនិក។

សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (2019) មានមួយជំពូកពេញដែលចែងពីភស្តុតាងអេឡិចត្រូនិក ដែលនៅក្នុងនោះគឺ គោលការណ៍នៃការមិនរើសអើងត្រូវបានអនុវត្តចំពោះកំណត់ត្រាអេឡិចត្រូនិកទាក់ទិននឹងភាពអាចទទួលយកបាននៃភស្តុតាង។[23] វិធីបញ្ជាក់កំណត់ត្រាអេឡិចត្រូនិកក៏ត្រូវបានកំណត់ផងដែរ។ គួរឱ្យកត់សម្គាល់ថា, សេចក្តីព្រាងច្បាប់ឆ្នាំ 2019 នេះទទួលស្គាល់*ការទាមទារឯកសារជាភស្តុតាងអេឡិចត្រូនិកដោយតុលាការ*។[24] គេក៏ឃើញមានផងដែរនូវបទប្បញ្ញត្តិដែលមានលក្ខណៈវិវត្ត នៅក្នុងជំពូកដែលពាក់ព័ន្ធនឹងការទទួលស្គាល់ភស្តុតាងអេឡិចត្រូនិកបរទេស។[25]

## B. ប្រព័ន្ធពាណិជ្ជកម្មមិនបាច់ប្រើក្រដាសស្នាម និងប្រព័ន្ធបញ្ជរតែមួយ

### ប្រព័ន្ធបញ្ជរតែមួយ/ប្រព័ន្ធពាណិជ្ជកម្មមិនបាច់ប្រើក្រដាសស្នាម

ក្នុងឆ្នាំ 2015 កម្ពុជាបានចេញអនុក្រឹត្យមួយ (ដែលចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី) ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ (NSWSC)

[20] មាត្រា 51, ច្បាប់ស្តីពីគយ (2007)

[21] មាត្រា 10, សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡេចត្រូនិក (2019)

[22] យោងតាមក្រសួងពាណិជ្ជកម្ម និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (ក.ប.ទ.)

[23] ជំពូកទី 8, សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡេចត្រូនិក (2019)។ មាត្រា 31 ដោយឡែក កំណត់ការទទួលយកជាទូទៅនៃភស្តុតាងអេឡិកត្រូនិក។ មាត្រា 31 យកលំនាំតាមមាត្រា 9 (1)(ក) នៃច្បាប់គម្រូស្តីពីពាណិជ្ជកម្មអេឡេចត្រូនិកនៃ UNCITRAL។

[24] មាត្រា 38, សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡេចត្រូនិក (2019)

[25] មាត្រា 39 និង 40, សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡេចត្រូនិក (2019)។ មាត្រា 40 ដោយឡែកគឺផ្អែកលើគម្រូ UNCITRAL។

កម្ពុជា។ អនុក្រឹត្យនេះ ត្រូវបានអមជាមួយ ដោយប្រកាសអនុវត្តមួយចំនួន រួមទាំងការបង្កើតក្រុមពិគ្រោះយោបល់ផ្នែកច្បាប់ និង គោលនយោបាយនៃគម្រោងបញ្ជរតែមួយជាតិ (ពោលគឺ ក្រុមការងារផ្នែកច្បាប់) និង ក្រុមអនុវត្តគម្រោងបញ្ជរតែមួយជាតិ(ពោលគឺក្រុមការងារបច្ចេកទេស)។[26]

## សុវត្ថិភាពព័ត៌មាន

បច្ចុប្បន្ននេះ, កម្ពុជាមិនមានប្រព័ន្ធសុវត្ថិភាពព័ត៌មានដំណើរការពេញលេញមួយទេ ទោះបីជាប្រព័ន្ធបែបនេះត្រូវបានគ្រោង និង កំពុងត្រូវបានអនុវត្តក្តី។ អនុក្រឹត្យស្តីពីហត្ថលេខាឌីជីថល (2017) ចែងពីការបង្កើតប្រព័ន្ធវិញ្ញាបនបត្រនិងហត្ថលេខាឌីជីថលមួយ ដែលគាំទ្រដោយ PKI (ហេដ្ឋារចនាសម្ព័ន្ធសាធារណៈសំខាន់ៗ) ដើម្បីផ្តល់សុវត្ថិភាពព័ត៌មានដល់អ្នកប្រើប្រាស់ពាណិជ្ជកម្មមិនបាច់ប្រើក្រដាសស្នាម។ ស្ថាបត្យកម្មនេះ ត្រូវបានពង្រឹង និងនឹងត្រូវបានពង្រឹងបន្ថែមទៀត ដោយបណ្តាបទល្មើសអ៊ីនធឺណិតមួយចំនួន។ ប៉ុន្តែ ស្តង់ដារសុវត្ថិភាពព័ត៌មានគឺជាគម្លាតចម្បងមួយ នៅក្នុងក្របខ័ណ្ឌគតិយុត្តព័ត៌មានវិទ្យានិងសារគមនាគមន៍ (ICT) ជាតិកម្ពុជាបច្ចុប្បន្ន។

តាមសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (2019), ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា ត្រូវបានរំពឹងថានឹងជួយពង្រឹងយ៉ាងច្រើននូវកម្រិតសុវត្ថិភាពព័ត៌មាននៅក្នុងប្រទេស។ សេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងបទល្មើស/បទឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិត ក៏នឹងមានអានុភាពដូចគ្នាដែរ ក្រោយពេលអនុម័ត ។

មាត្រា 28 នៃសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (2019) ផ្តល់នូវការការពារទិន្នន័យមួយកម្រិត, រួមទាំងការយោងដល់វិធានការសុវត្ថិភាពព័ត៌មាន និងការហាមឃាត់ការប្រើប្រាស់ព័ត៌មានឯកជនដោយគ្មានការយល់ព្រម។

សេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងបទល្មើស/បទឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិត កំពុងត្រូវបានរៀបចំ ដែលត្រូវបានគេនិយាយថាផ្អែកលើអនុសញ្ញាប៊ុយដាប៉េស្ត។

សេចក្តីព្រាងច្បាប់នេះ កំណត់បទល្មើសជាច្រើន រួមមានចារកម្មទិន្នន័យ, ការស្ទាក់ចាប់ដោយខុសច្បាប់ (illegal interception), ការជ្រៀតជ្រែកទិន្នន័យ, ការផ្ទេរទិន្នន័យដោយគ្មានការអនុញ្ញាត, ការជ្រៀតជ្រែកប្រព័ន្ធ និងការបំពានលើការប្រើប្រាស់ឧបករណ៍ រួមមានកម្មវិធីកុំព្យូទ័រ ឬចូលប្រើប្រាស់កូដ (access codes) ដើម្បីគោលបំណងឧក្រិដ្ឋ។ ជំពូកទី 10 នៃសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (2019) ដែលត្រូវបានតាក់តែងដោយក្រសួងយុត្តិធម៌ កំណត់បន្ថែមទៀតនូវបទឧក្រិដ្ឋតាមប្រព័ន្ធអ៊ីនធឺណិត និងទោសបញ្ញត្តិពាក់ព័ន្ធ។[27]

## កិច្ចព្រមព្រៀងកម្រិតសេវា (SLA) និង អនុស្សរណៈនៃការយោគយល់ (MOUs)

បច្ចុប្បន្ន ពុំមានកិច្ចព្រមព្រៀងកម្រិតសេវា (SLAs) ក្នុងចំណោមសាមីក្រសួង/ស្ថាប័នដែលពាក់ព័ន្ធប្រព័ន្ធបញ្ជរតែមួយជាតិ (NSW) សំរាប់ការចែករំលែកទិន្នន័យ ឬការដោះដូរទិន្នន័យគ្នាទេ។ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (ក.ប.ទ.) បានបញ្ជាក់ថាការព្រមព្រៀងចែករំលែកទិន្នន័យនឹងមានចែងនៅក្នុងច្បាប់ស្តីពីអភិបាលកិច្ចទិន្នន័យ។

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (ក.ប.ទ.) មានកិច្ចព្រមព្រៀងកម្រិតសេវា (SLAs) ជាមួយអ្នកផ្តល់សេវាបណ្តាញទាំងបី។ អ្នកផ្តល់សេវាបណ្តាញទាំងបី ក៏ដូចជាអ្នកផ្តល់សេវាស្រដៀងគ្នាដ៏ទៃទៀតដែរនៅកម្ពុជា មានកាតព្វកិច្ចត្រូវគោរពតាមខសន្យា, ល័ក្ខខ័ណ្ឌ, និងស្តង់ដារនៃកិច្ចព្រមព្រៀងកម្រិតសេវា (SLA), ដូច្នេះ អាចត្រូវទទួលខុសត្រូវលើការរំលោភខសន្យានៃកិច្ចសន្យាទាំងនោះ។ គួកត់សម្គាល់ថា អ្នកផ្តល់សេវាបណ្តាញ ក៏ដូចជាប្រតិបត្តិករសេវាពាណិជ្ជកម្មមិនបាច់ប្រើក្រដាសស្នាម អាចត្រូវទទួលខុសត្រូវមិនត្រឹមតែតាមកិច្ចសន្យាប៉ុណ្ណោះ

---

[26] នៅថ្ងៃទី 17 ខែ សីហា ឆ្នាំ 2015 ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញប្រកាសលេខ 958 ដែលបង្កើត "ក្រុមពិគ្រោះយោបល់ផ្នែកច្បាប់ និងគោលនយោបាយនៃគម្រោងបញ្ជរតែមួយជាតិ" និង ប្រកាសលេខ 959 ដែលបង្កើត "ក្រុមអនុវត្តគម្រោងបញ្ជរតែមួយជាតិ"។

[27] ជំពូកទី 10 នៃសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡេចត្រូនិក (2019) កំណត់បទល្មើសបន្ថែម មានជាអាទិ៍ ការលួចចូលប្រព័ន្ធ អំពើលួចអត្តសញ្ញាណ ការបោកបញ្ឆោត ការបន្លំ និងការរំលោភ (ការប្រើបំពាន) ឯកជនភាព។

ទេ ប៉ុន្តែថែមទាំងការទទួលខុសត្រូវតាមច្បាប់ជា "អន្តរការី" ឬ "អ្នកផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក" អនុលោមតាមជំពូកទី 5 នៃសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (2019) ទៀតផង (សំរាប់ការពិភាក្សាបន្ថែម សូមមើលការទទួលខុសត្រូវរបស់ភាគី *ជាអាទិ៍*)។

## C. និច្ចភាពឆ្លងកាត់ព្រំដែន

### កិច្ចព្រមព្រៀងឧបតោភាគីឬប្រចាំតំបន់ដែលមានស្រាប់

កម្ពុជា ក្នុងឋានៈជាសមាជិកអាស៊ានមួយ និងជាសមាជិកប្រទេសមហាអនុតំបន់មេគង្គ (GMS) កំពុងចូលរួមយ៉ាងសកម្មនៅក្នុងគំនិតផ្តួចផ្តើមពាណិជ្ជកម្មឆ្លងកាត់ព្រំដែនដោយមិនបាច់ប្រើក្រដាសស្នាមមួយចំនួនៈ

- កម្ពុជាកំពុងចូលរួមក្នុងប្រព័ន្ធបញ្ជរតែមួយអាស៊ាន (ASW) និងគំនិតផ្តួចផ្តើមពាណិជ្ជកម្មឆ្លងកាត់ព្រំដែនដោយមិនបាច់ប្រើក្រដាសស្នាម និង គំនិតផ្តួចផ្តើមដោះដូរទិន្នន័យពាណិជ្ជកម្មផ្សេងៗនៃប្រព័ន្ធបញ្ជរតែមួយអាស៊ាន (ASW) ស្របតាមផែនទីបង្ហាញផ្លូវប្រព័ន្ធបញ្ជរតែមួយអាស៊ាន (ASW) និងឯកសារផ្សេងៗទៀត។
- បច្ចុប្បន្ន កម្ពុជាទទួលបានប្រយោជន៍ពីការអនុគ្រោះនៃប្រទេសអភិវឌ្ឍទាប (LDC) ក្នុងការចូលទីផ្សារសហភាពអឺរ៉ុបក្រោមកម្មវិធីអ្វីៗទាំងអស់លើកលែងតែអាវុធ (EBA)។ ពាណិជ្ជករកម្ពុជា បានប្រើប្រព័ន្ធ REX សំរាប់ការចុះបញ្ជី GSP អនឡាញនៃសហភាពអឺរ៉ុប សំរាប់ការនាំចេញរបស់ពួកគេ។
- កម្ពុជាបានចុះហត្ថលេខាកិច្ចព្រមព្រៀងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកអាស៊ាន និង គម្រោងសហការកសាងសមត្ថភាពសំរាប់ប្រទេសកម្ពុជា សាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងមីយ៉ាន់ម៉ា ត្រូវបានគ្រោង។
- កម្ពុជា តាមរយៈអាស៊ាន ក៏បានចូលរួមផងដែរក្នុងការចរចារកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយថ្នាក់តំបន់ (RCEP) ដែលនៅក្នុងនោះ ផ្នែកទាំងឡាយនៃជំពូកស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៃកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយថ្នាក់តំបន់ (RCEP) ត្រូវបានឯកភាព ។
- ក្នុងឋានៈជាសមាជិកមួយនៃមហាអនុតំបន់មេគង្គ (GMS) កម្ពុជាបានចុះហត្ថលេខាក្នុងឆ្នាំ 2001 លើកិច្ចព្រមព្រៀងស្តីពីការសម្រួលការដឹកជញ្ជូនឆ្លងព្រំដែន (CBTA)។ បណ្តាប្រទេសមហាអនុតំបន់មេគង្គ (GMS) បានឯកភាពគ្នាលើការប្រើលិខិតអនុញ្ញាតដឹកជញ្ជូនតាមផ្លូវគោកអនុតំបន់ និងប្រតិបត្តិការសាកល្បងនៃប្រព័ន្ធឆ្លងកាត់គយ និងអនុញ្ញាតគយបណ្តោះអាសន្ន (Customs Transit and Temporary Admission System) និងប្រព័ន្ធលិខិតអនុញ្ញាតផ្លូវគោកមហាអនុតំបន់មេគង្គ (GMS) រួមមានកិច្ចព្រមព្រៀងស្តីពី "ច្រកលឿន" នៃការសម្រួលការដឹកជញ្ជូនឆ្លងព្រំដែន (CBTA) នៅចំណុចត្រួតពិនិត្យព្រំដែន ច្រករបៀងកើត-លិច (East-West Corridor) នៃមហាអនុតំបន់មេគង្គ (GMS)។ ចាប់ពីខែមិថុនា ឆ្នាំ 2018 អនុស្សរណៈនៃការយោគយល់ (MOU) មួយស្តីពីការអនុវត្ត "ការប្រមូលផលឆាប់ៗ (early harvest)" នៃកិច្ចព្រមព្រៀងស្តីពីការសម្រួលការដឹកជញ្ជូនឆ្លងព្រំដែន (CBTA) ត្រូវបានចុះហត្ថលេខាដែលអនុញ្ញាតឱ្យចាប់ផ្តើម ប្រើលិខិតអនុញ្ញាតការដឹកជញ្ជូនផ្លូវគោកមហាអនុតំបន់មេគង្គ (GMS) និងការទទួលយកឯកសារជាបណ្តោះអាសន្នសំរាប់យានយន្តពាណិជ្ជកម្ម។

### ស្តង់ដារ/គោលការណ៍ណែនាំអន្តរជាតិ

កម្ពុជា គឺជាភាគីឬហត្ថលេខីនៃសន្ធិសញ្ញាអន្តរជាតិមួយចំនួន ដែលរាប់បញ្ចូល ឬ អនុញ្ញាតឱ្យប្រើ ឯកសារនិងទំនាក់ទំនងអេឡិចត្រូនិក។ សន្ធិសញ្ញាអន្តរជាតិសំខាន់ៗពាក់ព័ន្ធដែលកម្ពុជាគឺជាភាគីឬហត្ថលេខីមួយ រួមមានៈ

- អង្គការពាណិជ្ជកម្មពិភពលោក (WTO) និង កិច្ចព្រមព្រៀងសម្រួលពាណិជ្ជកម្ម (TFA) នៃអង្គការនេះ,
- អនុសញ្ញាក្យូតូកែសម្រួលស្តីពីសុខដុមនីយកម្ម និងការសម្រួលការអនុវត្តផ្នែកគយ (RKC)

- កិច្ចព្រមព្រៀងស្តីពីអនាម័យ និងភូតគាមអនាម័យនៃអង្គការពាណិជ្ជកម្មពិភពលោក (WTO)
- កិច្ចព្រមព្រៀងស្តីពីការកំណត់តំលៃគយនៃអង្គការពាណិជ្ជកម្មពិភពលោក (WTO)

កម្ពុជាបានយោងដល់គំរូអន្តរជាតិក្នុងការតាក់តែងច្បាប់ជាតិរបស់ខ្លួនស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក យកលំនាំតាមច្បាប់គំរូស្តីពីពាណិជ្ជកម្មអេឡិចត្រូនិករបស់គណៈកម្មការអង្គការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ (UNCITRAL, 1996) និង អនុសញ្ញាសហប្រជាជាតិស្តីពីការប្រើទំនាក់ទំនងអេឡិចត្រូនិក នៅក្នុងកិច្ចសន្យាអន្តរជាតិ (2005)។

កម្ពុជាកំពុងស្ថិតក្នុងកិច្ចដំណើរការនៃការអនុវត្តតាមអនុលោមអនុសញ្ញាតក្យូតូកែសម្រួល(RKC)។ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ កំពុងប្រើគំរូទិន្នន័យនៃអង្គការគយពិភពលោក (WCO) ទម្រង់គំរូសហប្រជាជាតិ (UNLK) ពាក់ព័ន្ធនឹងប្រព័ន្ធ ASYCUDA World និងការអភិវឌ្ឍប្រព័ន្ធបញ្ជរតែមួយជាតិ (NSW) ។

ដោយសារតួនាទីរបស់ខ្លួននៅក្នុង គំនិតផ្តួចផ្តើមដឹកជញ្ជូន និងឆ្លងកាត់ព្រំដែនតំបន់អាស៊ាន និង មហាអនុតំបន់មេគង្គ (GMS) កម្ពុជាគប្បីពិចារណាយ៉ាងមធ្យ័តផងដែរអំពីការចូលរួមក្នុងអនុសញ្ញាខាងក្រោម៖

- អនុសញ្ញាអង្គការគយពិភពលោក (WCO) ស្តីពីការគ្រប់គ្រងព្រំដែនប្រកបដោយសុខុមនីយកម្ម[28]
- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីកិច្ចសន្យាសំរាប់ការដឹកទំនិញអន្តរជាតិទាំងមូលឬមួយផ្នែកតាមផ្លូវសមុទ្រ - វិធានក្រុងរ៉ូធ័រដាម (Rotterdam Rules)[29]
- អនុសញ្ញាស្តីពីការដឹកជញ្ជូនអន្តរជាតិតាមកប៉ាល់នូវទំនិញក្រោមគម្របនៃ TIR Carnets (Convention on International Shipping of Goods under Cover of TIR Carnets), (សូមជ្រាបថាកម្មវិធី e-TIR ទើបតែត្រូវបានសម្ពោធនាពេលថ្មីៗនេះ)[30]
- អនុសញ្ញាស្តីពីកិច្ចសន្យាសំរាប់ដឹកជញ្ជូនទំនិញតាមផ្លូវគោក (Convention on the Contract for the Shipping of Goods by Road (CMR Convention)) [31] និងពិធីសារបន្ថែមមួយចំពោះអនុសញ្ញានេះ ដែលត្រូវបានអនុម័តក្នុងឆ្នាំ 2008 ដែលចែងពីការប្រើប្រាស់ឯកសាទំនិញប្រភេទអេឡិចត្រូនិកបញ្ជាក់ពីការទទួលទំនិញ (CMR electronic consignment notes)[32]
- អនុសញ្ញាស្តីពីការដឹកអន្តរជាតិតាមផ្លូវដែក (Convention on the International Carriage by Rail (COTIF)) ដែលបានដាក់ឱ្យប្រើប្រាស់នូវឯកសារអេឡិចត្រូនិកបញ្ជាក់ពីការទទួលទំនិញសំរាប់ដឹកជញ្ជូនតាមផ្លូវដែក (CIM Electronic consignment notes)[33]

[28] មាននៅលើ: http://tfig.unece.org/contents/Harmonized-frontier-controls-convention.htm ហើយអត្ថបទមាននៅទីនេះ: http://www.unece.org/fileadmin/DAM/trans/conventn/ECE-TRANS-55r2e.pdf

[29] មាននៅលើ: https://uncitral.un.org/en/texts/transportgoods/conventions/rotterdam_rules ហើយអត្ថបទមាននៅទីនេះ: https://uncitral.un.org/sites/uncitral.un.org/files/media-documents/uncitral/en/rotterdam-rules-e.pdf

[30] មាននៅលើ: http://tfig.unece.org/contents/TIR-convention.htm ហើយអត្ថបទនេះមាននៅក្នុងផ្នែកទីពីរនៃសៀវភៅណែនាំ TIR: http://www.unece.org/fileadmin/DAM/tir/handbook/english/newtirhand/TIR-6Rev11e.pdf

[31] អនុសញ្ញា CMR មាននៅលើ: https://treaties.un.org/doc/Treaties/1961/07/19610702%2001-56%20AM/Ch_XI_B_11.pdf.

[32] ពិធីសារនេះមាននៅលើ: https://treaties.un.org/doc/Treaties/2008/03/20080303%2006-53%20PM/CTC-xi-B-11b.pdf ហើយសេចក្តីអធិប្បាយអំពីគម្រោង "e-CMR" មាននៅទីនេះ: http://www.eu-gate.eu/system/files/ppmo_attachments/UNCEFACT%20eCMR%20project_DTLF_30AUG2017_v3.pdf

[33] ព័ត៌មានស្តីពី COTIF មាននៅលើ: https://www.cit-rail.org/en/rail-transport-law/cotif/ និងនៅទីនេះ: http://otif.org/en/ អង្គការ ESCAP ក៏បានផ្តល់សេចក្តីពន្យល់ឆ្នាំ 2015 ដ៏ល្អអំពី COTIF និងកំណត់សម្គាល់អំពីទំនិញ:

## D. ចំណុចពិចារណាផ្សេងទៀត

### បញ្ហាទទួលខុសត្រូវ

ជំពូកទី 5 នៃសេចក្ដីព្រាងច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (2019) ដាក់បញ្ចូលបទប្បញ្ញត្តិថ្មីពាក់ព័ន្ធនឹងការទទួលខុសត្រូវតាមច្បាប់របស់ "អន្តរការី" និង "អ្នកផ្ដល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក" – ដែលរាប់បញ្ចូលអ្នកផ្ដល់សេវាបណ្ដាញ និង ប្រតិបត្តិករពាណិជ្ជកម្មមិនបាច់ប្រើក្រដាសស្នាម។[34] ជំពូកទី 5 កំណត់មូលដ្ឋានសំរាប់បង្កើតការទទួលខុសត្រូវនៃបណ្ដាភាគីទាំងនោះ ទោះបីជាមានការលើកលែងយ៉ាងទូលាយពីការទទួលខុសត្រូវខ្លះផងដែរ។[35] បទប្បញ្ញត្តិថ្មីទាំងនេះអាចនាំទៅដល់ស្ថានភាពមួយ ដែលនៅក្នុងនោះ ស្ថាប័នរាជរដ្ឋាភិបាលកម្ពុជា អាចត្រូវទទួលខុសត្រូវ លើការបាត់បង់ឬការខូចខាតទិន្នន័យ, ការយឺតយ៉ាវ ឬ ការប្រើបំពានប្រព័ន្ធកុំព្យូទ័រ ឬ សេវាបណ្ដាញ រួមទាំងការពាក់ព័ន្ធនឹងប្រតិបត្តិការប្រព័ន្ធបញ្ជរតែមួយជាតិ (NSW) នាពេលអនាគត។ មូលដ្ឋានមួយទៀតសំរាប់ការទទួលខុសត្រូវរបស់ភាគីទាំងនោះ គឺការរំលោភបទដ្ឋានសុវត្ថិភាពព័ត៌មាន, ក្រមសីលធម៌ ឬ បទប្បញ្ញត្តិផ្សេទៀតដែលនាំទៅដល់ទោសបញ្ញត្តិផ្សេងៗ។[36] លើសពីនេះ ជំពូកទី 9 នៃសេចក្ដីព្រាងច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (2019) ផ្ដល់នូវវិធានថ្មីស្ដីពីការទទួលខុសត្រូវរបស់អ្នកផ្ដល់សេវាទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក នៅក្នុងបរិបទប្រតិបត្តិការមួយចំនួន។[37]

អនុក្រឹត្យស្ដីពីហត្ថលេខាឌីជីថល (2017) ចែងពីការបង្កើតប្រព័ន្ធសុវត្ថិភាព PKI និង ប្រព័ន្ធវិញ្ញាតកម្ម (authentication) ពាក់ព័ន្ធនឹងការប្រើហត្ថលេខាឌីជីថល ។ ប៉ុន្តែ នៅមានតម្រូវការបទប្បញ្ញត្តិពីរាជរដ្ឋាភិបាលបន្ថែមទៀតនៃការកំណត់មុខងារ អំណាច និង ភារកិច្ចរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (ក.ប.ទ.) ដែលជាស្ថាប័នគ្រប់គ្រងរបស់រាជរដ្ឋាភិបាល/វិញ្ញាតធរហត្ថលេខាឌីជីថលឫស (Root CA), ក៏ដូចជាវិញ្ញាតធរដែលត្រូវបានផ្ដល់អាជ្ញាប័ណ្ណឱ្យនាពេលអនាគត (future licensed CA) ។ នៅពេលមានបទប្បញ្ញត្តិទាំងនេះ ភាគីទាំងនោះទំនងជានឹងត្រូវមានការទទួលខុសត្រូវ។

### ការពិចារណាអំពីការដោះស្រាយវិវាទ

ច្បាប់ស្ដីពីមជ្ឈត្តិការផ្នែកពាណិជ្ជកម្មកម្ពុជា (Commercial Arbitration law of Cambodia) ត្រូវបានអនុម័តក្នុងឆ្នាំ 2006។ មជ្ឈត្តវិនិច្ឆ័យក្នុងស្រុក ត្រូវបានបង្ខំឱ្យយោងទៅច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលគឺជាបញ្ញត្តិច្បាប់មួយនៃច្បាប់គំរូ UNCITRAL ស្ដីពីមជ្ឈត្តការអន្តរជាតិផ្នែកពាណិជ្ជកម្ម។ មជ្ឈត្តវិនិច្ឆ័យបរទេស ត្រូវបានទទួលស្គាល់ និងបង្ខំឱ្យអនុវត្តអនុលោមតាមអនុសញ្ញាញូវយ៉កដែលកម្ពុជាគឺជាភាគីមួយ ថ្វីបើគេមិនដឹងអំពីករណីនៃការអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេសនៅកម្ពុជាក្ដី។ យ៉ាងណាក៏ដោយ ភាពល្បីល្បាញនៃមជ្ឈត្តិការពាណិជ្ជកម្មអន្តរជាតិនេះ គួរបំពេញចិត្តដល់ដៃគូពាណិជ្ជកម្មអន្តរជាតិដែលជួបប្រទះវិវាទពាណិជ្ជកម្មមិនបាច់ប្រើក្រដាសស្នាមនាពេលអនាគតនៅកម្ពុជា។

ប៉ុន្តែ គេហាក់បីដូចជាឃើញមានគម្លាតគតិយុត្តមួយចំនួនពាក់ព័ន្ធនឹងជម្រើសសាលាជំនុំជម្រះក្ដី និងជម្រើសច្បាប់សំរាប់កិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិនៅកម្ពុជា។ ជាពិសេស វិធាននៃភាពទំនាស់ច្បាប់ (specific conflict of laws rules) ដែលគ្រប់គ្រងកិច្ចសន្យាអន្តរជាតិ ហាក់បីដូចជាមិនមានចែងនៅក្នុងក្រមរដ្ឋប្បវេណី (2011) និងក្រមនីតិវិធីរដ្ឋប្បវេណី (2006)។ មានការកត់សម្គាល់ថា

https://www.unescap.org/sites/default/files/CIT%20-%20Common%20consignment%20note.pdf

[34] សូមមើលឧបសម្ព័ន្ធ (ដែលត្រូវបានដាក់បញ្ចូលក្នុងមាត្រា 4) នៃសេចក្ដីព្រាងច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡេចត្រូនិក (2019) ដែលកំណត់និយមន័យភាគីទាំងនេះ។

[35] មាត្រា 23(3), សេចក្ដីព្រាងច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡេចត្រូនិក (2019) សំរាប់ជាមូលដ្ឋាននៃការទទួលខុសត្រូវ, មាត្រា 23(1) និង (2) សេចក្ដីព្រាងច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡេចត្រូនិក (2019) កំណត់ការលើកលែងពីការទទួលខុសត្រូវ។

[36] មាត្រា 25 ចែងបន្ថែមទៀតនូវមូលដ្ឋាននៃការទទួលខុសត្រូវៈ ការរំលោភបទដ្ឋានសុវត្ថិភាពព័ត៌មាន ក្រមសីលធម៌ ឬបទប្បញ្ញត្តិផ្សេទៀតដែលបានអនុម័ត ដែលអាចនាំទៅដល់ទោសបញ្ញត្តិក្រោមក្នុងមាត្រា 54 ។

[37] ជំពូកទី 9: ការទូទាត់តាមអេឡេចត្រូនិក និង/ឬការផ្ទេរប្រាក់តាមអេឡេចត្រូនិក, សេចក្ដីព្រាងច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡេចត្រូនិក (2019), សូមមើល ដោយឡែក មាត្រា 42។

មានសេចក្តីព្រាងច្បាប់មួយស្តីពីកិច្ចសន្យាពាណិជ្ជកម្ម ដែលស្ថិតនៅក្រោមការពិនិត្យដោយរដ្ឋសភា។ ប៉ុន្តែ គេមិនដឹងទេនៅពេលនេះថាតើច្បាប់នេះមានដាក់បញ្ចូលទំនាស់វិធានច្បាប់ឬទេ។

## កម្មសិទ្ធិបញ្ញា និងកម្មសិទ្ធិលើប្រព័ន្ធមូលដ្ឋានទិន្នន័យ

កម្ពុជាបាននិងកំពុងអភិវឌ្ឍរបបច្បាប់ស្តីពីកម្មសិទ្ធិបញ្ញារបស់ខ្លួនក្នុងលក្ខណៈសកម្មជាងមុន ក្នុងអំឡុងពេល ដប់ប្រាំពីរឆ្នាំ កន្លងមកនេះ។ កម្ពុជាបានអនុម័តច្បាប់ស្តីពីកម្មសិទ្ធិបញ្ញាធំៗមួយចំនួន រួមមានច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និង ការប្រកួតប្រជែងមិនស្មោះត្រង់ (2002), ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ (2003), ច្បាប់ប៉ាតង់ (2003) និងច្បាប់ស្តីពីបទដ្ឋាន (2007)។ កម្ពុជាកំពុងពិចារណាអនុម័តច្បាប់ស្តីពីការសម្ងាត់ពាណិជ្ជកម្ម និង ច្បាប់ស្តីពីការការពាររចនាបថសៀគ្វីចម្រុះ (Protection of IC Layout Design)។ កម្ពុជាគឺជាសមាជិកមួយនៃអង្គការ WIPO និង អង្គការ WTO ហើយបច្ចុប្បន្ននេះ កំពុងធានាឱ្យបាននូវការគោរពតាមកិច្ចព្រមព្រៀង WTO TRIPS Agreement។ រហូតទាល់តែកម្ពុជាអាចសម្រេចអនុវត្តបានទាំងស្រុងនូវកាតព្វកិច្ច TRIPS (មុនថ្ងៃទី 1 ខែ កក្កដា ឆ្នាំ 2021), បើមិនដូច្នេះទេ នឹងបន្ត មានភាពមិនប្រាកដប្រជាជុំវិញការការពារស្នាដៃអ្នកនិពន្ធបរទេស រួមទាំងសូហ្វែរ (software) បរទេស។[38] កម្មសិទ្ធិលើទិន្នន័យ និងព័ត៌មាន ក៏នៅមិនទាន់បានកំណត់ច្បាស់លាស់ដែរនៅពេលនេះ។ ប៉ុន្តែ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (ក.ប.ទ.) បានផ្តល់ការធានាថាបញ្ហានៃកម្មសិទ្ធិលើទិន្នន័យ រួមទាំងកម្មសិទ្ធិលើប្រព័ន្ធមូលដ្ឋានទិន្នន័យ នឹងត្រូវបានដាក់បញ្ចូលក្នុងច្បាប់ស្តីពីអភិបាលកិច្ចទិន្នន័យ ដែលបច្ចុប្បន្នស្ថិតក្នុងទម្រង់ជាសេចក្តីព្រាង។

## ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក

បច្ចុប្បន្ន កម្ពុជាកំពុងដាក់ឱ្យដំណើរការប្រព័ន្ធជាតិទូទាត់អេឡិចត្រូនិក ដែលទិដ្ឋភាពរបស់វានឹងតភ្ជាប់ជាមួយប្រព័ន្ធបញ្ជរតែមួយជាតិកម្ពុជា និងប្រព័ន្ធទូទាត់តាមប្រព័ន្ធអេឡិចត្រូនិកនៃពាណិជ្ជកម្មមិនបាច់ប្រើក្រដាសស្នាម។ ចំណុចសំខាន់ៗនៃប្រព័ន្ធជាតិទូទាត់អេឡិចត្រូនិកនេះ រួមមាន: Central Shared Switch (CSS System) គម្រោង KOIKA (RTGS) និង គម្រោងបាគងរបស់ធនាគារជាតិនៃកម្ពុជា។

សមាសភាគគតិយុត្តនៃប្រព័ន្ធជាតិទូទាត់អេឡិចត្រូនិក ក៏កំពុងលេចរូបរាងដែរ។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសសំខាន់ពីរ 1) បញ្ញត្តិនៃសេវាទូទាត់តាមរយៈគណនីប្រតិបត្តិការទូទាត់ (ឧទាហរណ៍ ប្រព័ន្ធផ្ទេរឥណពន្ធ និង ប្រព័ន្ធទូទាត់តាមអេឡិចត្រូនិក) ជាសកម្មភាពត្រូវមានអាជ្ញាប័ណ្ណ ដែលតម្រូវឱ្យសុំការយល់ព្រមជាមុនពីធនាគារជាតិ.[39] និង 2) អនុញ្ញាតឱ្យអ្នកដំណើរការភាគីទីពីបំពេញមុខងារជំនួសឱ្យធនាគារ ក្នុងការផ្តល់សេវាអន្តរការីទូទាត់អេឡិចត្រូនិក។[40] អនុក្រឹត្យស្តីពីហត្ថលេខាឌីជីថល (2017) ក៏មានលក្ខណៈពាក់ព័ន្ធផងដែរ ពីព្រោះវាតម្រូវឱ្យប្រើហត្ថលេខាឌីជីថលសំរាប់ប្រតិបត្តិការហិរញ្ញវត្ថុអនឡាញទាំងអស់ លើកលែងតែមានវិធានការកំណត់ផ្ទុយពីនេះ។[41]

សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (2019) មានសារៈសំខាន់ណាស់នៅពេលនេះ។ គប្បីរំឭកថា អនុលោមតាមជំពូកទី 5 "អន្តរការី" អាចត្រូវរងការទទួលខុសត្រូវតាមច្បាប់ក្នុងកាលៈទេសៈមួយចំនួន។ "អន្តរការី" រួមមាន "អ្នកផ្តល់សេវាទូទាត់អនឡាញ"។ ជាក់ច្បាស់ជាងនេះទៀតគឺ ជំពូកទី 9 នៃសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក(2019) ចែងពីវិធានថ្មីស្តីពីការទទួលខុសត្រូវរបស់អ្នកផ្តល់សេវាទូទាត់តាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា។[42]

## ច្បាប់ស្តីពីការប្រកួតប្រជែង

នៅពេលនេះ កម្ពុជាមិនមានច្បាប់ស្តីពីការប្រកួតប្រជែងទេ។ សេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែងនេះ ត្រូវបានរាយការណ៍ថាបានដាក់ជូនគណៈរដ្ឋមន្ត្រី និងក្រុមប្រឹក្សា

[38] កម្ពុជាក៏គប្បីពិចារណាឲ្យមធ្យ័តផងដែរអំពីការចូលរួមអនុសញ្ញាក្រុងប៊ែនស្តីពីការការពារស្នាដៃអក្សរសិល្ប៍ និងស្នាដៃសិល្បៈ។

[39] ប្រកាសស្តីពីការគ្រប់គ្រងអ្នកផ្តល់សេវាទូទាត់ (2017)

[40] ប្រកាសស្តីពីអ្នកដំណើរការតតិយភាគី (2010)

[41] មាត្រា 11, អនុក្រឹត្យស្តីពីហត្ថលេខាឌីជីថល (2017)

[42] ជំពូកទី 9: ការទូទាត់តាមអេឡេចត្រូនិក និង/ឬការផ្ទេរប្រាក់តាមអេឡេចត្រូនិក, សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡេចត្រូនិក (2019)

អ្នកច្បាប់។ សេចក្ដីព្រាងច្បាប់ស្ដីពីការប្រកួតប្រជែង នៅពេលត្រូវអនុម័ត គប្បីត្រូវអនុវត្តចំពោះអ្នកផ្ដល់សេវាពាណិជ្ជកម្មមិនបាច់ប្រើក្រដាសស្នាម ទោះបីជាអ្នកផ្ដល់សេវាទាំងនេះគឺជាក្រុមហ៊ុនឯកជន ឬជាសហគ្រាសរដ្ឋក្ដី។ អ្នកផ្ដល់សេវាពាណិជ្ជកម្មមិនបាច់ប្រើក្រដាសស្នាម ទំនងជានឹងរួមមាន ជាអាទិ៍ ធនាគារ អ្នកផ្ដល់សេវាបណ្ដាញ (រួមទាំង ISPs) ក្រុមហ៊ុនទូរគមនាគមន៍ វិញ្ញាតធរ/សមត្ថកិច្ចបញ្ជាក់វិញ្ញាបនបត្រ និង ក្រុមហ៊ុនព័ត៌មានវិទ្យា និងសារគមនាគមន៍ (ICT) ។

# ឯកសារជំនួយស្មារតី៖

Cambodia's Fintech 2021

# Cambodia's Digital Economy

## AN OVERVIEW

Cambodia has a unique foundation for building its digital economy, with a young demography and high internet penetration.

> **One of the youngest demographics in the region**
> A population of approximately 16 million, with a median age of 25 years.

> **Rapidly growing financial services sector**
> With 2.65 million debit cards in 2019, a figure that has doubled in 5 years with sufficient growth to come

> **High mobile connection**
> Cambodia has one of the highest mobile penetration rates in the world, with 20.8 million mobile connections, or 124% of the population.

> **High smartphone penetration**
> 10.7 million smart phones are connected to the internet. Data rates are one of the cheapest in the region at US$1 per 10GB. 4G and 3G coverage is 80% and 85% of the population, respectively.

> **Internet usage is highly social**
> By mid 2020, there are 10.8 million Facebook users.

> **Opportunity in MSME segment**
> Cambodia has approximately 500,000 micro, small and medium enterprises (MSMEs), of which 95% are informal unregistered businesses. Only a small number of businesses practice appropriate bookkeeping: micro (0.02%), small (3.89%), medium (24.11%).

| | | | |
|---|---|---|---|
| **10.8m**<br>NUMBER OF FACEBOOK USERS IN CAMBODIA<br>(65% OF THE POPULATION) | **2.65m**<br>NUMBER OF DEBIT CARDS<br>(DOUBLE THE AMOUNT OF 5 YEARS AGO) | **124%**<br>MOBILE PENETRATION<br>(20.8M MOBILE CONNECTION) | **80%**<br>4G COVERAGE OF THE POPULATION<br>(3G COVERAGE IS 85%) |
| **16.6m**<br>CAMBODIA'S POPULATION<br>(53% BELOW 25 YEARS OLD) | **7.1%**<br>GDP GROWTH RATE IN 2019<br>($26.9B GDP & $1,623 GDP PER CAPITA IN 2019) | **21**<br>NUMBER OF PAYMENT SERVICE INSTITUTIONS<br>(27,974 AGENTS & 15,037 MERCHANTS) | **5.22m**<br>E-WALLET ACCOUNTS (BY YEAR END 2019)<br>(64% GROWTH IN ONE YEAR) |
| **>17**<br>NUMBER OF CO-WORKING SPACES<br>(WITH OVER 500 DESKS) | **>6**<br>NUMBER OF VENTURE CAPITAL FIRMS<br>(LOCALLY-BASED FUNDS FOR TECH INVESTMENT) | **>300**<br>NUMBER OF ACTIVE TECH STARTUPS | **>30**<br>NUMBER OF STARTUP INVESTMENTS<br>(PUBLICLY DISCLOSED WITH INSTITUTIONAL CAPITAL) |

Sources:
Startup Kingdom: Cambodia's Vibrant Tech Startup Ecosystem, Mekong Strategic Partners and Raintree 2018, Accelerating Financial Inclusion in South-East Asia with Digital Finance, ADB, 2017
Harnessing Technology for More Inclusive and Sustainable Finance in Asia and the Pacific, ADB 2018, Telecommunication Regulator of Cambodia (TRC)

# Tech Startup Landscape by Category

OVER 300 ACTIVE TECHNOLOGY STARTUPS, OPERATING AT VARIOUS STAGES OF MATURITY, WITH FINTECH BEING THE MOST ACTIVE CATEGORY

### Fintech

Digital payments, Saas for financial institutions, digital banking & access to finance.

**Eg:** Morakot | Banhji | Pi Pay | BongLoy | SmartLoy

**MATURITY** Adopted & growing market — **ACTIVE #** >50

### Digital Media & Advertising

Digitial content delivery/ streaming, advertising & gaming, news media.

**Eg:** Direxplay | Khmerload | Sabay | Soyo

**MATURITY** Adopted & growing market — **ACTIVE #** >40

### E-commerce & Logistics

E-commerce, social selling, inventory management systems & delivery services.

**Eg:** Joonaak | Nham24 | LaRue | Little Fashion

**MATURITY** Market demand validated, scaling & refining market fit — **ACTIVE #** >30

### Digital Marketplaces

Digitial classifieds & booking platforms.

**Eg:** BookMeBus | BongPheak | Khmer24 | Realestate.com.kh | Last2ticket

**MATURITY** Adopted & growing market — **ACTIVE #** >20

### Development Services

Web development & applications outsourcing for domestic & international clients.

**Eg:** Codingate | Web essentials | Biz Solutions | Pathmazing | BiKay

**MATURITY** Maturing & facing competition — **ACTIVE #** >30

### Transportation

Local Taxi, Tuk Tuk applications operating before Grab/Uber.

**Eg:** PassApp | WeGo | Exnet

**MATURITY** Widely adopted with growing market base — **ACTIVE #** >10

### Internet-of-things & Hardware

Hardware manufacturing, IOT solutions & smart device software.

**Eg:** Koompi | Demine Robotics | ArrowDot | Angkot E&C

**MATURITY** Early product & early adoption — **ACTIVE #** >5

### Edtech

E-learning, university management systems, student information services.

**Eg:** Sala Enrollment | Edemy

**MATURITY** Early product & early adoption — **ACTIVE #** >5

### Healthtech

Healthcare information, management systems & services.

**Eg:** Healthogo | Sokhakrom

**MATURITY** Early product & early adoption — **ACTIVE #** >5

### Agriculture-tech

Platforms for agricultural information & innovative farming practices

**Eg:** Agribuddy

**MATURITY** Early product & early adoption — **ACTIVE #** <5

Source: Startup Kingdom: Cambodia's Vibrant Tech Startup Ecosystem, Mekong Strategic Partners and Raintree 2018

# Selected Roles of Fintechs in the Ecosystem

FINTECH PLAYERS COLLABORATE TO BUILD THE CUSTOMER VALUE PROPOSITION (CONVENIENCE, SAFETY, ACCESS, COSTS)

### Payment Providers/Mobile Wallets

- Connect merchants and consumers for digital payment.
- Provide money transfer, bill payment.
- Provide other value-added services.

### Payment Infrastructure Provider

- Provide payment gateway to facilitate transactions from Cambodia and abroad.
- Provide API connector: connect banks to networks.
- Provide card issuing API: allow developers to issue cards within their applications to their end users.

### Regulators & Supervisors

- Ensures consumer protection across every aspect of the value chain.
- Supervise financial institutions and Service Providers for regulatory requirements.
- Maintain integrity and confidence of the Financial Sector.




### Mobile Banking Applications

- Provide a 24/7 alternative, cashless, service channel.
- Better understanding of customer needs through mobile analytics.
- Improved security and communications with push and in-app notifications
- Inter-connectivity of financial institutional partner distribution networks.

### Financing, Credit Scoring and Insurance

- Assist with assessing customer creditworthiness.
- Facilitate digital loans.
- De-risk a loan for the lender, through data analytics.
- Provide digital insurance.

### Accounting and Bank Systems

- Provide core banking system.
- Provide solutions on accounting, financial report, invoice, inventory management.

TREND 01

# Digital channels are crucial to banks' growth & competitiveness

BANKS WITH A HIGHER DEGREE OF LOCAL IT AUTONOMY ARE LEADING THE WAY IN PROVIDING CONTEMPORARY DIGITAL BANKING EXPERIENCES TO MEET CUSTOMER'S EXPECTATIONS

| | |
|---|---|
| **SELECTED INCUMBENT FINANCIAL INSTITUTIONS** | ABA MOBILE, PPCBank, PRINCE BANK, HKL, PRASAC, Amret Mobile, J Trust Royal Bank, ACLEDA Unity ToanChet |
| **PRODUCT CAPABILITIES** | **Banking services:** funds transfers within and between different banks, withdraw funds from an ATM without card, QR code/mobile payments, bill payments, open and manage bank accounts, online loan application & repayments, manage cards. ATM/branch locator, exchange rate calculator, loan and interest rate calculator, trade CSX stocks, and lifestyle promotions. |
| **INDUSTRY INSIGHTS** | > **A need for local IT autonomy and capability:** **Local-owned banks** and **foreign-owned banks** with a higher degree of local IT autonomy tend **to be more agile and faster** in bringing new digital product offerings to the market, compared with foreign-owned banks where decisions are made by their regional office's or parent bank's IT.<br>> **Adapting to market trends:** The rise of new fintech startups (mobile wallets/payment) in Cambodia has **pushed existing banks to increase investment** into digital banking offerings, to make the payments experience more seamless.<br>> **More than 20 banking and financial institutions** provided mobile banking services to their customers as of 2018.<br>> Efficiency of operations from a well executed digital strategy is likely to **improve scale and profitability for banks**<br>> ABA Bank has reaped the benefits of investing early in digital channels with 550k mobile banking users and more than 4,000 micro merchants in 2019. The number of money transfer transactions surged by 30% and the volume almost doubled. |

Note: Selected players for illustrative purposes only. Source: NBC's Supervision Report 2018

## Mobile Banking Registered Users (Thousands)




Source: NBC, ABA and ACLEDA Annual Report 2019

TREND 04

# Increased Acceptance of Digital Payments

THE **COVID-19 PANDEMIC** AND THE CONVENIENCE OF E-COMMERCE & CONTACTLESS, HAS ACCELERATED THE ACCEPTANCE OF DIGITAL PAYMENT BETWEEN MERCHANTS AND CONSUMERS

## Payment account numbers and PSI transaction volumes are accelerating

- The number of payment accounts with PSIs in the Kingdom reached **1.8M (11% of the population)** in 2019.
- There are **21** PSIs operating with **27,974 payment and settlement agents** and **15,037 merchant locations**. Total balance of the e-wallet of PSI is $58M and the balance of trust accounts is $68M.
- Payment transaction via payment accounts of PSI surged to **US$8 billion**.
- **Adoption is likely to accelerate in the post-COVID environment as ease and convenience of digital payments is suited to the socially distanced world.**

## Cambodian consumer payment attitude

- According to **Visa Consumer Payment Attitudes**, convenience and security are among the top reasons accelerating digital payment growth in Cambodia.
- Scenarios in which electronic payments are likely to be used: **79 percent** expecting to see them used in supermarkets, **61 percent** in large shopping malls, and **49 percent** in chain and convenience stores.
- **24 percent** of those surveyed interested in mobile payments, while roughly one third are interested in contactless payments.
- 42 percent of all Visa transactions in Cambodia were contactless.

## China & India Lead in e-Wallet Penetration, but Southeast Asia is at a Tipping Point

PORTION OF ADULT POPULATION (18 & OLDER) USING e-WALLETS IN 2019 (%)




Sources: Statista; World Bank; BCG analysis.
Note: Nascent = penetration less than 5%; Adopters = penetration between 5% and 10%; Tipping point = penetration between 10% and 20%; Mature = penetration greater than 20%.




